# ការបោះឆ្នោត បឋម

## ថ្ងៃអង្គារ ទី 2 ខែមិថុនា ឆ្នាំ 2026

**មគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតផ្លូវការ**

### កុំបង្អង់យូរ បោះឆ្នោតថ្ងៃនេះ!

សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកមកវិញភ្លាមៗនៅពេលដែលអ្នកទទួលបានវា។

រយៈពេលបោះឆ្នោតមុនតាមប្រៃសណីយ៍នឹងចាប់ផ្តើមនៅថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026។

ការិយាល័យបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹកដល់ម៉ោង 8:00 យប់ នៅថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026 ដែលជាថ្ងៃបោះឆ្នោត!

### California ព័ត៌មានដែលទុកចិត្ត

អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់នៅក្នុងរដ្ឋ California នឹងទទួលបានសន្លឹកឆ្នោតតាមប្រៃសណីយ៍។

សន្លឹកឆ្នោតត្រូវបានផ្ញើតាមប្រៃសណីយ៍នៅថ្ងៃទី 4 ខែឧសភា ឬមុននោះ។

សន្លឹកឆ្នោតអាចត្រូវបានបោះឆ្នោត និងប្រគល់ជូនវិញភ្លាមៗ នៅពេលដែលពួកវាត្រូវបានទទួល។

ប្រអប់ទម្លាក់សន្លឹកឆ្នោតបើកនៅថ្ងៃទី 5 ខែឧសភា។

ជម្រើសការបោះឆ្នោតដោយផ្ទាល់នឹងអាចរកបាននៅគ្រប់ខោនធី។



ងាយស្រួលប្រើលើទូរសព្ទស្មេនខ្ញុំ

### វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ

ខ្ញុំ Shirley N. Weber លេខាធិការ នៃរដ្ឋ California សូម បញ្ជាក់ថា ព័ត៌មានដែលមាននៅក្នុងនេះនឹងត្រូវបានដាក់ជូនអ្នកបោះឆ្នោតនៃរដ្ឋ California នៅក្នុងការបោះឆ្នោតបឋមដែលនឹងប្រព្រឹត្តទៅនៅទូទាំង រដ្ឋ នៅថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026 ហើយថាការណែនាំនេះត្រូវបាន រៀបចំ យ៉ាងត្រឹមត្រូវតាមច្បាប់។ សូមធ្វើជាសាក្សីនៃដៃរបស់ខ្ញុំ និងត្រាដ៏អស្ចារ្យរបស់រដ្ឋនៅ Sacramento រដ្ឋ California នៅ ថ្ងៃទី 9 ខែមីនា ឆ្នាំ 2026 នេះ។

Shirley N. Weber, Ph.D.
រដ្ឋលេខាធិការ

## កម្រងសិទ្ធិនៃ

# អ្នកបោះឆ្នោត

## អ្នកមានសិទ្ធិដូចខាងក្រោម៖

1. **សិទ្ធិបោះឆ្នោត ប្រសិនបើអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ។** អ្នកមានសិទ្ធិបោះឆ្នោតប្រសិនបើអ្នក៖
   - ជាពលរដ្ឋអាមេរិកាំងដែលរស់នៅរដ្ឋ California
   - យ៉ាងហោចណាស់មានអាយុ 18 ឆ្នាំ
   - បានចុះឈ្មោះនៅកន្លែងដែលអ្នកកំពុងរស់នៅបច្ចុប្បន្ន
   - បច្ចុប្បន្ននេះមិនជាប់ក្នុងពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសបទឧក្រិដ្ឋ និង
   - បច្ចុប្បន្ននេះ តុលាការមិនបានរកឃើញថា អ្នកអស់មត្ថភាពផ្លូវចិត្ត ក្នុងការបោះឆ្នោតនោះទេ

2. **សិទ្ធិក្នុងការបោះឆ្នោត បើសិនអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះរួចហើយ ទោះបីជាឈ្មោះរបស់អ្នកមិនមាននៅក្នុងបញ្ជីក៏ដោយ។** អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរាប់បញ្ចូល បើសិនមន្ត្រីបោះឆ្នោតកំណត់ថាអ្នកមានលក្ខណៈសម្បត្តិ ដើម្បីបោះឆ្នោត។

3. **សិទ្ធិក្នុងការបោះឆ្នោត បើសិនអ្នកនៅតែស្ថិតនៅក្នុងជួររង់ចាំនៅពេលដែលការិយាល័យបោះ ឆ្នោតត្រូវបិទ។**

4. **សិទ្ធិក្នុងការបោះសន្លឹកឆ្នោតសម្ងាត់** ដោយគ្មាននរណាំរំខានអ្នក ឬប្រាប់អ្នកពីរបៀបបោះឆ្នោត។

5. **សិទ្ធិទទួលបានសន្លឹកឆ្នោតថ្មី បើសិនអ្នកបានធ្វើខុស** បើសិនអ្នកមិនទាន់បានបោះឆ្នោតទេ។ អ្នកអាច៖

   **ស្នើសុំមន្ត្រីបោះឆ្នោតនៅកន្លែងបោះឆ្នោត** រកសន្លឹកឆ្នោតថ្មី

   **ប្តូរសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក** រកសន្លឹកឆ្នោតថ្មីមួយនៅការិយាល័យបោះឆ្នោត ឬនៅការិយាល័យបោះឆ្នោតរបស់អ្នក ឬ

   **បោះឆ្នោតដោយការប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។**

6. **សិទ្ធិទទួលបានជំនួយក្នុងការបោះសន្លឹកឆ្នោតរបស់អ្នក** ពីនរណាម្នាក់ដែលអ្នកជ្រើសរើស លើកលែងតែពីនិយោជក ឬ តំណាងសហជីពរបស់អ្នកតែប៉ុណ្ណោះ។

7. **សិទ្ធិដាក់សន្លឹកឆ្នោតបោះ-តាម-សំបុត្ររបស់អ្នក ដែលបានបំពេញរួចរាល់នៅកន្លែងបោះឆ្នោតណាមួយ** នៅក្នុងរដ្ឋ California។

8. **សិទ្ធិទទួលបានឯកសារបោះឆ្នោតជាភាសាមួយក្រៅពីភាសាអង់គ្លេស** បើសិនមានអ្នកបោះឆ្នោតគ្រប់គ្រាន់នៅក្នុង មណ្ឌលបោះឆ្នោតរបស់អ្នកនិយាយភាសានោះ។

9. **សិទ្ធិ ក្នុងការ សួរសំនួរ ទៅ មន្ត្រីបោះឆ្នោត អំពី នីតិវិធី បោះឆ្នោត** និងមើល ពីដំណើរការបោះឆ្នោត។ បើសិនបុគ្គលដែលអ្នកសួរមិនអាចឆ្លើយតបនឹងសំនួររបស់អ្នកបាន នោះពួកគេត្រូវតែបញ្ជូនអ្នកទៅកាន់បុគ្គលដែលអាចឆ្លើយបាន ដើម្បីឆ្លើយសំនួររបស់អ្នក។ ប្រសិនបើអ្នកបង្កការរំខាន ពួកគេអាចឈប់ឆ្លើយនឹងអ្នក។

10. **សិទ្ធិ រាយការណ៍ អំពី សកម្មភាព បោះឆ្នោតខុសច្បាប់ ឬក្លែងបន្លំ** ទៅ មន្ត្រីបោះឆ្នោត ឬការិយាល័យ រដ្ឋលេខាធិការ។

    - នៅលើគេហទំព័រ **www.sos.ca.gov**
    - តាមទូរសព្ទលេខ **(888) 345-4917**
    - តាមអ៊ីមែល **elections@sos.ca.gov**

**បើសិនអ្នកជឿថា អ្នកត្រូវបានគេបដិសេធចំពោះសិទ្ធិណាមួយទាំងអស់នេះ** សូមហៅទូរសព្ទទៅលេខសម្ងាត់របស់ការិយាល័យរដ្ឋលេខាធិការ ដោយឥតគិតថ្លៃបណ្តាញទូរសព្ទទាន់ហេតុការណ៍អ្នកបោះឆ្នោតតាមលេខ **(888) 345-4917**។

# តារាងមាតិកា

ទំព័រ

**សេចក្តីថ្លែងការណ៍របស់បេក្ខជន** **10**

**ព័ត៌មានអ្នកបោះឆ្នោត**


កម្រងសិទ្ធិអ្នកបោះឆ្នោត....................................................2
អ្នករួមចំណែកកំពូលៗ....................................................3
ធនធានគេហទំព័ររបស់លេខាធិការរដ្ឋ....................................................3
តាមដានសន្លឹកឆ្នោតរបស់អ្នក....................................................3
សារពីរដ្ឋលេខាធិការ....................................................4
កុំបង្អង់យូរ បោះឆ្នោតថ្ងៃនេះ!....................................................5
ចំនួនថ្ងៃកាន់តែច្រើន វិធីកាន់តែច្រើនដើម្បីបោះ
ឆ្នោតជាមួយ VCA....................................................5
ការពិតរហ័ស....................................................6
ការបោះឆ្នោតនៅរដ្ឋ California....................................................7
ព័ត៌មានអំពីសេចក្តីថ្លែងការណ៍របស់បេក្ខជន....................................................8
អ្នកបោះឆ្នោតតាមរដ្ឋបាលរថយន្ត California....................................................57
ព័ត៌មានឯកជនភាពនៃការចុះឈ្មោះបោះឆ្នោត....................................................57
សេចក្តីជូនដំណឹងអំពីការបោះឆ្នោត....................................................58
សេចក្តីជូនដំណឹងអំពីអំពើពុករលួយនៃដំណើរការបោះឆ្នោត....................................................59
លក្ខខណ្ឌតម្រូវនៃអត្តសញ្ញាណអ្នកបោះឆ្នោត និងការចុះឈ្មោះ
នៅរដ្ឋ California....................................................60
ការបោះឆ្នោតតាមប្រៃសណីយ៍ដែលអាចចូលប្រើបានពីចម្ងាយ....................................................61
ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព....................................................62
កាលបរិច្ឆេទដែលត្រូវចងចាំ....................................................63


# អ្នកចូលរួមចំណែកកំពូលៗចំពោះ បេក្ខជនរដ្ឋ

នៅពេលដែលគណៈកម្មាធិការ(បុគ្គល ឬក្រុមមនុស្សដែលទទួល ឬចំណាយប្រាក់សម្រាប់គោលបំណងដែលជះឥទ្ធិពលដល់អ្នកបោះឆ្នោតឱ្យគាំទ្រ ឬប្រឆាំងនឹងបេក្ខជន) រៃអង្គាសប្រាក់យ៉ាងហោចណាស់ $1 លាន គណៈកម្មាធិការនោះត្រូវតែរាយការណ៍ពីអ្នករួមចំណែកកំពូលទាំង 10 របស់ខ្លួន ទៅគណៈគណៈកម្មការការអនុវត្តនយោបាយដោយយុត្តិធម៌រដ្ឋ California (FPPC)។ គណៈកម្មការត្រូវតែធ្វើបច្ចុប្បន្នភាពបញ្ជីនៅពេលមានការផ្លាស់ប្តូរណាមួយ។

បញ្ជីទាំងនេះអាចរកបាននៅលើគេហទំព័រ FPPC តាមរយៈ៖
*fppc.ca.gov/transparency/top-contributors.html*

ដើម្បីស្រាវជ្រាវអំពីការចូលរួមចំណែកក្នុងយុទ្ធនាការឃោសនាបោះឆ្នោតសម្រាប់បេក្ខជន ឬវិធានការបោះឆ្នោត សូមចូលទៅកាន់ គេហទំព័ររបស់រដ្ឋលេខាធិការតាមរយៈ *powersearch.sos.ca.gov*។

កំពូលទាំង 10

# ចូលមើលគេហទំព័ររបស់រដ្ឋលេខាធិការ ដើម្បី៖

- មើលមគ្គុទ្ទេសក៍អ្នកបោះឆ្នោតនេះជាភាសាផ្សេងទៀតនៅ *voterguide.sos.ca.gov*
- ដើម្បីស្នើសុំមគ្គុទ្ទេសក៍នេះជាសំឡេង និងអក្សរធំៗ ឬជាភាសាអង់គ្លេស ចិន ហិណ្ឌូ ជប៉ុន ខ្មែរ កូរ៉េ អេស្ប៉ាញ តាហ្គាឡុក ថៃ និងវៀតណាមដោយមិនគិតថ្លៃ សូមចូលទៅកាន់ *vote.ca.gov*
- ស្វែងរកប្រអប់ទម្លាក់សន្លឹកឆ្នោត កន្លែងបោះឆ្នោត ឬមជ្ឈមណ្ឌលបោះឆ្នោតដែលនៅជិតអ្នកបំផុតនៅ *caearlyvoting.sos.ca.gov*
- ស្វែងរកការិយាល័យបោះឆ្នោត ឬមជ្ឈមណ្ឌលបោះឆ្នោតរបស់អ្នកនៅថ្ងៃបោះឆ្នោតនៅ *sos.ca.gov/elections/polling-place* ឬ *voterstatus.sos.ca.gov*
- សូមពិនិត្យមើលស្ថានភាពចុះឈ្មោះ និងព័ត៌មានចុះឈ្មោះរបស់អ្នកនៅ *voterstatus.sos.ca.gov*
- ទស្សនាលទ្ធផលបោះឆ្នោតផ្ទាល់បន្ទាប់ពីការិយាល័យបោះឆ្នោតបិទនៅថ្ងៃបោះឆ្នោតនៅ *electionresults.sos.ca.gov*

# តាមដានសន្លឹកឆ្នោតរបស់អ្នក

អ្នកបោះឆ្នោតទាំងអស់អាចទទួលបានព័ត៌មានថ្មីៗសំខាន់ៗលើសន្លឹកឆ្នោតរបស់ពួកគេតាមរយៈឧបករណ៍តាមដានផ្លូវការរបស់រដ្ឋ California សន្លឹ "តើសន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?" (Where's My Ballot?)។ ការចុះឈ្មោះចំណាយពេលតិចជាងបីនាទី!

តើសន្លឹកឆ្នោតរបស់ខ្ញុំ នៅទីណា?

អ្នកអាចជ្រើសរើសទទួលការជូនដំណឹងអំពីស្ថានភាពសន្លឹកឆ្នោតរបស់អ្នកតាមរយៈសារជាអក្សរ (SMS) អ៊ីមែល ឬការហៅជាសំឡេង រួមទាំងការជូនដំណឹង ប្រសិនបើមានបញ្ហាណាមួយជាមួយសន្លឹកឆ្នោតរបស់អ្នក និងការណែនាំអំពីរបៀបកែតម្រូវវា ដើម្បីធានាថា សន្លឹកឆ្នោតរបស់អ្នកត្រូវបានរាប់។

កុំឲ្យឱកាសតាមដានសន្លឹកឆ្នោតរបស់អ្នកគ្រប់ជំហាននេះកន្លងផុតទៅឲ្យសោះ! សូមចូលទៅកាន់ *wheresmyballot.sos.ca.gov* ដើម្បីស្វែងយល់បន្ថែម។

# សារពីរដ្ឋលេខាធិការ

ជូនចំពោះអ្នកបោះឆ្នោតនៅរដ្ឋ California

សូមអរគុណសម្រាប់ការចំណាយពេលវេលាដើម្បីស្វែងយល់អំពីបេក្ខជនដែលនឹងលេចឡើងនៅលើសន្លឹកឆ្នោតនៃការបោះឆ្នោតបឋម ខែមិថុនា ឆ្នាំ 2026។ មគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតនេះ ត្រូវបានរចនាឡើងដើម្បីផ្តល់ជូនអ្នកនូវព័ត៌មានសំខាន់ៗ និងមិនលម្អៀងដើម្បីជួយអ្នកធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់នៅពេលបោះឆ្នោត។

រដ្ឋ California មានមោទនភាពក្នុងការផ្តល់ជូនអ្នកបោះឆ្នោតនូវការបោះឆ្នោតដែលមានសុវត្ថិភាព អាចចូលដំណើរការបាន និងមានតម្លាភាព។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះសកម្មម្នាក់ៗនឹងទទួលបានសន្លឹកឆ្នោតតាមប្រៃសណីយ៍ ដែលអនុញ្ញាតឱ្យពួកគេបោះឆ្នោតដោយសុវត្ថិភាព និងងាយស្រួល។ អ្នកអាចប្រគល់សន្លឹកឆ្នោតរបស់អ្នកនៅប្រអប់ទម្លាក់សន្លឹកឆ្នោតផ្លូវការ ដោយបោះឆ្នោតដោយផ្ទាល់នៅទីតាំងបោះឆ្នោត ឬដោយប្រគល់វាមកវិញតាមរយៈសេវាប្រៃសណីយ៍សហរដ្ឋអាមេរិក។ ឱកាសបោះឆ្នោតបានមុនមាននៅក្នុងសហគមន៍ជាច្រើន ហើយថ្ងៃបោះឆ្នោតនៅតែជាជម្រើសមួយសម្រាប់អ្នកដែលចង់បោះឆ្នោតដោយផ្ទាល់។

សន្លឹកឆ្នោតរបស់អ្នកគឺជាសម្លេងរបស់អ្នក។ ការចូលរួមក្នុងការបោះឆ្នោតជួយកំណត់អនាគតនៃសហគមន៍ រដ្ឋ និងប្រទេសជាតិរបស់យើង។ ការិយាល័យនៃរដ្ឋលេខាធិការធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីរៀបចំការបោះឆ្នោតប្រចាំខោនធី ដើម្បីធានាថា ប្រជាជន California គ្រប់រូបដែលមានសិទ្ធិមានឱកាសចុះឈ្មោះ បោះឆ្នោត និងឱ្យសន្លឹកឆ្នោតរបស់ពួកគេត្រូវបានរាប់ត្រឹមត្រូវ និងមានសុវត្ថិភាព។

មគ្គុទ្ទេសក៍នេះមានព័ត៌មានអំពីបេក្ខជនទូទាំងរដ្ឋ និងធនធានបោះឆ្នោតដែលមានសម្រាប់អ្នក។ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យពិនិត្យមើលវាដោយប្រុងប្រយ័ត្ន ហើយស្វែងរកព័ត៌មានបោះឆ្នោតដែលគួរឱ្យទុកចិត្តបន្ថែម ដោយចូលទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការនៅ *voterstatus.sos.ca.gov* ឬដោយទាក់ទងការិយាល័យបោះឆ្នោតខោនធីរបស់អ្នក។

ចំណុចខ្លាំងរបស់រដ្ឋ California បានមកពីការចូលរួមរបស់អ្នកបោះឆ្នោតរបស់ខ្លួន។ នៅពេលអ្នកបោះឆ្នោត អ្នកជួយធានាថា លទ្ធិប្រជាធិបតេយ្យរបស់យើងឆ្លុះបញ្ចាំងពីសំឡេង និងតម្លៃនៃរដ្ឋចម្រុះរបស់យើង។

សូមអរគុណសម្រាប់ការធ្វើជាអ្នកបោះឆ្នោតដែលចូលរួមយ៉ាងសកម្ម និងមានព័ត៌មានគ្រប់គ្រាន់។

# កុំបង្អង់យូរ បោះឆ្នោតថ្ងៃនេះ!

អ្នកបោះឆ្នោតរដ្ឋ California ទាំងអស់នឹងទទួលបានសន្លឹកឆ្នោតតាមប្រៃសណីយ៍ រួមជាមួយនឹងស្រោមសំបុត្រប្រៃសណីយ៍បង់ប្រាក់ជាមុនសម្រាប់ការបោះឆ្នោតបឋមថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026។ មន្ត្រីរៀបចំការបោះឆ្នោតប្រចាំខោនធីនឹងចាប់ផ្តើមផ្ញើសន្លឹកឆ្នោតមិនឱ្យលើសពីថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 ឡើយ។

ធ្វើឱ្យគេឮសំឡេងរបស់អ្នកបានមុន។ កុំពន្យារពេលអី បោះឆ្នោតភ្លាមៗ។ អ្នកអាចបោះឆ្នោតសន្លឹកឆ្នោតរបស់អ្នកបានភ្លាមនៅពេលដែលអ្នកទទួលបានវានៅក្នុង សំបុត្រ។

លទ្ធិប្រជាធិបតេយ្យពឹងផ្អែកលើអ្នកហើយ! សូមអនុវត្តតាមជំហានងាយៗទាំងប្រាំនេះ ដើម្បីអនុវត្តសិទ្ធិបោះឆ្នោតរបស់អ្នក៖

**បំពេញវា។**

គូសយកជម្រើសរបស់អ្នកនៅលើសន្លឹកឆ្នោតរបស់អ្នក។

**បិទស្រោមសំបុត្រ។**

ដាក់សន្លឹកឆ្នោតរបស់អ្នកនៅក្នុងស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតដែលអ្នកបានទទួលពីការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក។

**ចុះហត្ថលេខាលើវា។**

ចុះហត្ថលេខានៅខាងក្រៅស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតរបស់អ្នក។

ត្រូវប្រាកដថា ហត្ថលេខារបស់អ្នកត្រូវគ្នានឹងហត្ថលេខានៅលើប័ណ្ណបើកបរ/អត្តសញ្ញាណប័ណ្ណរដ្ឋ CA របស់អ្នក ឬហត្ថលេខាដែលអ្នកបានផ្តល់នៅពេលចុះឈ្មោះបោះឆ្នោត។ ការិយាល័យបោះឆ្នោតខោនធីរបស់អ្នកនឹងប្រៀបធៀបហត្ថលេខានោះ មុនពេលពួកគេរាប់សន្លឹកឆ្នោតរបស់អ្នក។

**ផ្ញើវាត្រឡប់មកវិញ។**

<u>តាមប្រអប់ទម្លាក់សន្លឹកឆ្នោត</u>—ទម្លាក់សន្លឹកឆ្នោតដែលបានបំពេញរបស់អ្នកទៅក្នុងស្រោមសំបុត្រ ប្រគល់មកវិញនៅប្រអប់ទម្លាក់សន្លឹកឆ្នោតផ្លូវការដែលមានសុវត្ថិភាពនៅក្នុងខោនធីរបស់អ្នកនៅពេលណាក៏បានរវាងថ្ងៃទី 5 ខែឧសភារហូតដល់ការបិទការិយាល័យបោះឆ្នោតនៅថ្ងៃទី 2 ខែមិថុនា។

<u>ដោយទៅផ្ទាល់</u>—សូមទម្លាក់សន្លឹកឆ្នោតដែលបានបំពេញរបស់អ្នកទៅក្នុងស្រោមសំបុត្រប្រគល់មកវិញនៅប្រអប់ទម្លាក់ដែលមានសុវត្ថិភាព ការិយាល័យបោះឆ្នោត មជ្ឈមណ្ឌលបោះឆ្នោត ឬការិយាល័យរៀបចំការបោះឆ្នោតខោនធី មុនម៉ោង 8:00 យប់ នៅថ្ងៃទី 2 ខែមិថុនា។ ទីតាំងបោះឆ្នោតនឹងមាននៅគ្រប់ខោនធីទាំងអស់មុនថ្ងៃបោះឆ្នោត។ ទីតាំងបោះឆ្នោតផ្តល់ជូនការចុះឈ្មោះអ្នកបោះឆ្នោត សន្លឹកឆ្នោតជំនួស ម៉ាស៊ីនបោះឆ្នោតដែលអាចចូលប្រើបាន និងជំនួយផ្នែកភាសា។

<u>តាមប្រៃសណីយ៍</u>—សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមប្រៃសណីយ៍មកវិញភ្លាមនៅពេលអ្នកទទួលបានវា។ សន្លឹកឆ្នោតដែលបានផ្ញើតាមប្រៃសណីយ៍ត្រូវតែមានបោះត្រាប្រៃសណីយ៍នៅថ្ងៃបោះឆ្នោត ឬមុនថ្ងៃបោះឆ្នោត ហើយត្រូវទទួលបានមិនឱ្យលើសពី 7 ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។ ដើម្បីធានាថា សន្លឹកឆ្នោតរបស់អ្នកត្រូវបានបោះត្រាប្រៃសណីយ៍មុនថ្ងៃបោះឆ្នោត ត្រូវប្រាកដថា ផ្ញើវាតាមប្រៃសណីយ៍យ៉ាងហោចណាស់ប្រាំថ្ងៃមុនថ្ងៃបោះឆ្នោត គឺថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026។ ប្រសិនបើផ្ញើសំបុត្រនៅថ្ងៃបោះឆ្នោត សូមទទួលបានត្រាប្រៃសណីយ៍ដែលបោះត្រាដោយដៃពីបុគ្គលិកប្រៃសណីយ៍នៅក្នុងការិយាល័យប្រៃសណីយ៍សហរដ្ឋអាមេរិក។

**តាមដានវា។**

ចុះឈ្មោះនៅ *wheresmyballot.sos.ca.gov* ដើម្បីទទួលបានព័ត៌មានថ្មីៗអំពីស្ថានភាពសន្លឹកឆ្នោតរបស់អ្នកតាមរយៈសារជាអក្សរ (SMS) អ៊ីមែល ឬសារសំឡេង។ កុំឲ្យខកខានឱកាសតាមដានសន្លឹកឆ្នោតរបស់អ្នកគ្រប់ជំហាននេះឲ្យសោះ!

# ចំនួនថ្ងៃកាន់តែច្រើន វិធីកាន់តែច្រើនដើម្បីបោះឆ្នោត

CALIFORNIA VOTER'S CHOICE ACT

### ជាមួយច្បាប់ជម្រើសរបស់អ្នកបោះឆ្នោតរដ្ឋ California

មជ្ឈមណ្ឌលបោះឆ្នោតបើកសម្រាប់ការបោះឆ្នោតដោយផ្ទាល់រហូតដល់ 10 ថ្ងៃ មុនថ្ងៃបោះឆ្នោតនៅក្នុងខោនធីនានានៃច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត។ ប្រសិនបើអ្នករស់នៅក្នុងខោនធីណាមួយខាងក្រោម អ្នកអាចបោះឆ្នោតដោយផ្ទាល់នៅ មជ្ឈមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធីរបស់អ្នក។

- Alameda
- Amador
- Butte
- Calaveras
- El Dorado
- Fresno
- Humboldt
- Imperial
- Kings
- Los Angeles
- Madera
- Marin
- Mariposa
- Merced
- Napa
- Nevada
- Orange
- Placer
- Riverside
- Sacramento
- San Benito
- San Diego
- San Mateo
- Santa Clara
- Santa Cruz
- Sonoma
- Stanislaus
- Tuolumne
- Ventura
- Yolo

ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់ *vca.sos.ca.gov*។

# ព័ត៌មានពិតរហ័សសម្រាប់ការបោះឆ្នោតបឋម ថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026

**តើខ្ញុំត្រូវចុះឈ្មោះបោះឆ្នោតដោយរបៀបណា?**

ចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នកតាមអ៊ីនធឺណិតនៅ *registertovote.ca.gov*។ ប្រសិនបើអ្នកចង់បំពេញទម្រង់បែបបទជាក់ស្តែង ពាក្យសុំចុះឈ្មោះបោះឆ្នោតអាចរកបាននៅការិយាល័យប្រៃសណីយ៍ ការិយាល័យបោះឆ្នោតខោនធី និងបណ្ណាល័យ។

**ចុះបើខ្ញុំខកខានថ្ងៃផុតកំណត់ការចុះឈ្មោះបោះឆ្នោត?**

ប្រសិនបើអ្នកខកខានថ្ងៃផុតកំណត់សម្រាប់ការចុះឈ្មោះបោះឆ្នោត អ្នកនៅតែអាចទៅកាន់ការិយាល័យបោះឆ្នោតប្រចាំខោនធី មជ្ឈមណ្ឌលបោះឆ្នោត ឬការិយាល័យបោះឆ្នោតរបស់អ្នកនៅថ្ងៃបោះឆ្នោត ឬមុនថ្ងៃបោះឆ្នោត ដើម្បីបំពេញការចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌ (ជារឿយៗត្រូវបានគេហៅថា "ការចុះឈ្មោះបោះឆ្នោតនៅថ្ងៃតែមួយ")។ សូមទាក់ទងការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម ឬចូលទៅកាន់ *vote.ca.gov*។

**ចុះបើខ្ញុំត្រូវពិនិត្យមើលស្ថានភាពការចុះឈ្មោះបោះឆ្នោតរបស់ខ្ញុំ?**

ដើម្បីពិនិត្យមើលស្ថានភាពចុះឈ្មោះបោះឆ្នោតរបស់អ្នក អ្នកអាចប្រើឧបករណ៍ "ស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំ" *(My Voter Status)* នៅ *voterstatus.sos.ca.gov*។

**តើខ្ញុំនឹងទទួលបានសន្លឹកឆ្នោតរបស់ខ្ញុំនៅពេលណា?**

អ្នកបោះឆ្នោតដែលបានចុះឈ្មោះសកម្មទាំងអស់នឹងទទួលបានសន្លឹកឆ្នោតតាមប្រៃសណីយ៍សម្រាប់ការបោះឆ្នោតបឋមថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026។ ថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026 គឺជាថ្ងៃចុងក្រោយសម្រាប់ខោនធីនានាដើម្បីចាប់ផ្តើមផ្ញើសន្លឹកឆ្នោតតាមប្រៃសណីយ៍។

**តើខ្ញុំនឹងទទួលបានមគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតផ្លូវការរបស់រដ្ឋនៅពេលណា?**

អ្នកបោះឆ្នោតដែលបានចុះឈ្មោះនឹងទទួលបានមគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតផ្លូវការរបស់រដ្ឋរបស់ពួកគេ ពីរបីសប្តាហ៍មុនថ្ងៃបោះឆ្នោត។ វាក៏នឹងអាចរកបានតាមអនឡាញនៅ *voterguide.sos.ca.gov* ផងដែរ ។

**ចុះបើខ្ញុំត្រូវការសន្លឹកឆ្នោតជំនួស?**

ប្រសិនបើអ្នកមិនបានទទួលសន្លឹកឆ្នោតរបស់អ្នកតាមប្រៃសណីយ៍ ឬសន្លឹកឆ្នោតដើមរបស់អ្នកបានបាត់ ឬខូចខាត អ្នកអាចដាក់ពាក្យសុំសន្លឹកឆ្នោតជំនួសបាន។ ពាក្យសុំសន្លឹកឆ្នោតជំនួសអាចរកបាននៅ *https://elections.cdn.sos.ca.gov/vote-by-mail/pdf/replacement-application.pdf*។

អ្នកក៏អាចស្នើសុំសន្លឹកឆ្នោតជំនួសពីការិយាល័យបោះឆ្នោតនៅក្នុងខោនធីរបស់អ្នកតាមទូរសព្ទ អ៊ីមែល ទូរសារ ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។

**តើខ្ញុំអាចប្រគល់សន្លឹកឆ្នោតរបស់ខ្ញុំត្រឡប់ទៅវិញដោយរបៀបណា?**

អ្នកអាចប្រគល់សន្លឹកឆ្នោតរបស់អ្នកមកវិញតាមរយៈ៖

- **តាមប្រអប់ទម្លាក់សន្លឹកឆ្នោត៖** អ្នកអាចយកសន្លឹកឆ្នោតរបស់អ្នកទៅការិយាល័យបោះឆ្នោត ឬទីតាំងទម្លាក់សន្លឹកឆ្នោតណាមួយនៅក្នុងរដ្ឋ California ត្រឹមម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត។
- **ដោយទៅផ្ទាល់៖** ទីតាំងបោះឆ្នោតត្រូវបានបង្កើតឡើងដោយមន្ត្រីរៀបចំការបោះឆ្នោតប្រចាំខោនធី ហើយបើកពីម៉ោង **7:00 ព្រឹក ដល់ 8:00 យប់ នៅថ្ងៃបោះឆ្នោត ថ្ងៃអង្គារ ទី 2 ខែមិថុនា ឆ្នាំ 2026**។ ដើម្បីស្វែងរកទីតាំងដើម្បីបោះឆ្នោតឱ្យបានមុនថ្ងៃបោះឆ្នោត សូមចូលទៅកាន់ *caearlyvoting.sos.ca.gov*។
- **តាមប្រៃសណីយ៍** ប្រគល់សន្លឹកឆ្នោតរបស់អ្នកតាមប្រៃសណីយ៍ត្រឡប់មកវិញភ្លាមនៅពេលអ្នកទទួលបានវា។ សន្លឹកឆ្នោតដែលបានផ្ញើតាមប្រៃសណីយ៍ត្រូវតែបោះត្រាប្រៃសណីយ៍នៅថ្ងៃបោះឆ្នោត ឬមុនថ្ងៃបោះឆ្នោត ហើយត្រូវទទួលបានមិនឱ្យលើសពី 7 ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។ ដើម្បីធានាថា សន្លឹកឆ្នោតរបស់អ្នកត្រូវបានបោះត្រាប្រៃសណីយ៍មុនថ្ងៃបោះឆ្នោត ត្រូវប្រាកដថា ផ្ញើវាតាមប្រៃសណីយ៍យ៉ាងហោចណាស់ប្រាំថ្ងៃមុនថ្ងៃបោះឆ្នោត គឺថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026។ ប្រសិនបើផ្ញើសំបុត្រនៅថ្ងៃបោះឆ្នោត សូមទទួលបានត្រាប្រៃសណីយ៍ដែលបោះត្រាដោយដៃពីបុគ្គលិកប្រៃសណីយ៍នៅក្នុងការិយាល័យប្រៃសណីយ៍សហរដ្ឋអាមេរិក។

**តើខ្ញុំអាចស្វែងរកប្រអប់ទម្លាក់សន្លឹកឆ្នោត កន្លែងបោះឆ្នោត ឬមជ្ឈមណ្ឌលបោះឆ្នោតដែលនៅជិតបំផុតរបស់ខ្ញុំដោយរបៀបណា?**

- សូមចូលទៅកាន់ *caearlyvoting.sos.ca.gov* ដើម្បីស្វែងរកប្រអប់ទម្លាក់សន្លឹកឆ្នោត កន្លែងបោះឆ្នោត ឬទីតាំងមជ្ឈមណ្ឌលបោះឆ្នោតដែលនៅជិតអ្នកបំផុត។
- ទាក់ទងការិយាល័យបោះឆ្នោតខោនធីរបស់អ្នក។

**តើខ្ញុំអាចតាមដានសន្លឹកឆ្នោតរបស់ខ្ញុំតាមរបៀបណាដើម្បីដឹងថាតើវាត្រូវបានទទួល និងរាប់រួចរាល់ហើយឬនៅ? (Where's My Ballot?)**

អ្នកបោះឆ្នោតអាចទទួលបានការជូនដំណឹង អំពីស្ថានភាពនៃសន្លឹកឆ្នោតដែលបាន ប្រគល់មកវិញរបស់ពួកគេ ដោយការចុះឈ្មោះសម្រាប់ឧបករណ៍ "*តើសន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា?*" ។

ចុះឈ្មោះនៅ *wheresmyballot.sos.ca.gov* ដើម្បីទទួលបានព័ត៌មានថ្មីៗដោយស្វ័យប្រវត្តិតាមរយៈសារជាអក្សរ (SMS) អ៊ីមែល ឬការហៅជាសំឡេង។

អ្នកក៏អាចចូលទៅកាន់ *voterstatus.sos.ca.gov* ដើម្បីស្វែងយល់ថាតើសន្លឹកឆ្នោតរបស់អ្នកត្រូវបានរាប់ឬអត់។

**ថ្ងៃផុតកំណត់សំខាន់ៗ៖**

| | |
|---|---|
| ថ្ងៃចុងក្រោយសម្រាប់ខោនធីនានាដើម្បីចាប់ផ្តើមសន្លឹកឆ្នោតតាមប្រៃសណីយ៍ | ថ្ងៃទី 4 ខែឧសភា |
| ថ្ងៃចុងក្រោយសម្រាប់ចុះឈ្មោះបោះឆ្នោត | ថ្ងៃទី 18 ខែឧសភា |
| ការចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌ | ថ្ងៃទី 19 ខែឧសភា ដល់ថ្ងៃទី 2 ខែមិថុនា |
| សន្លឹកឆ្នោតទាំងអស់ត្រូវតែប្រគល់ត្រឡប់មកវិញ* | ថ្ងៃទី 2 ខែមិថុនា |

*សន្លឹកឆ្នោតទាំងអស់ដែលបានផ្ញើត្រឡប់តាមប្រៃសណីយ៍ត្រូវតែមានត្រាប្រៃសណីយ៍នៅចំ ឬ នៅមុនថ្ងៃទី 2 ខែមិថុនា ហើយត្រូវទទួលដោយការិយាល័យរៀបចំការបោះឆ្នោតប្រចាំខោនធីមិនឱ្យលើសពីថ្ងៃទី 9 ខែមិថុនា។

# ការបោះឆ្នោតក្នុងរដ្ឋ California

ច្បាប់បោះឆ្នោតបឋមបើកចំហរសម្រាប់បេក្ខជនកំពូលពីរនាក់តម្រូវថា បេក្ខជនទាំងអស់សម្រាប់តំណែងក្នុងការិយាល័យតែងតាំងដោយអ្នកបោះឆ្នោតត្រូវបានធ្វើបញ្ជីឈ្មោះនៅលើសន្លឹកឆ្នោតតែមួយ។ កាលពីមុនត្រូវបានស្គាល់ថាជាការិយាល័យបក្សព័ន្ធ ការិយាល័យតែងតាំងដោយអ្នកបោះឆ្នោតរួមមានការិយាល័យច្បាប់រដ្ឋ ការិយាល័យសភាសហរដ្ឋអាមេរិក និងការិយាល័យរដ្ឋធម្មនុញ្ញរបស់រដ្ឋ។

ទាំងនៅក្នុងការបោះឆ្នោតបឋមបើកចំហរ និងការបោះឆ្នោតសកល អ្នកអាចបោះឆ្នោតជ្រើសរើសបេក្ខជនណាមួយ ដោយមិនគិតពីចំណូលចិត្តគណបក្សដែលអ្នកបានបង្ហាញនៅលើទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នក។ នៅក្នុងការបោះឆ្នោតបឋម បេក្ខជនពីររូបដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេ - មិនគិតពីចំណូលចិត្តគណបក្ស - នឹងបន្តទៅប្រកួតក្នុងការបោះឆ្នោតសាកល។ ប្រសិនបើបេក្ខជនទទួលបានសន្លឹកឆ្នោតភាគច្រើន (យ៉ាងតិច 50 ភាគរយ + 1) ការបោះឆ្នោតសាកលនៅតែត្រូវធ្វើឡើង។

ប្រព័ន្ធបឋមបើកចំហររបស់រដ្ឋ California មិនអនុវត្តចំពោះបេក្ខជនឈរឈ្មោះជា ប្រធានាធិបតីសហរដ្ឋអាមេរិក គណៈកម្មាធិការកណ្តាលខោនធី ឬការិយាល័យមូលដ្ឋានទេ។

បេក្ខជនដែលគេសរសេរបញ្ចូលឈ្មោះលើសន្លឹកឆ្នោតសម្រាប់ការិយាល័យដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោតនៅតែអាចឈរឈ្មោះនៅក្នុងការបោះឆ្នោតបឋម។ ទោះជាយ៉ាងណាក៏ដោយ បេក្ខជនដែលគេសរសេរបញ្ចូលឈ្មោះក្នុងសន្លឹកឆ្នោតអាចបន្តទៅការបោះឆ្នោតសាកលបានតែក្នុងករណីដែលបេក្ខជននោះ គឺជាបេក្ខជនមួយក្នុងចំណោមបេក្ខជនពីររូប ដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេក្នុងការបោះឆ្នោតបឋមនោះ។ លើសពីនេះទៀត មិនមានដំណើរការតែងតាំងឯករាជ្យសម្រាប់ការបោះឆ្នោតសកលឡើយ។

ច្បាប់រដ្ឋ Californiaតម្រូវឱ្យមានព័ត៌មានដូចខាងក្រោមដែលត្រូវតែបោះពុម្ពនៅក្នុងមគ្គុទ្ទេសក៍នេះ។

# ការិយាល័យដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោត

គណបក្សនយោបាយមិនមានសិទ្ធិដាក់បេក្ខជនឱ្យឈរឈ្មោះជាផ្លូវការសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបឋមឡើយ។ បេក្ខជនដែលត្រូវបានតែងតាំងសម្រាប់ការិយាល័យ ដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបឋម គឺជាអ្នកដែលត្រូវបានឈរឈ្មោះរបស់ពលរដ្ឋ ហើយមិនមែនជាបេក្ខជនឈរឈ្មោះផ្លូវការគណបក្សណាមួយនៅក្នុងការបោះឆ្នោតសាកលនោះទេ។ បេក្ខជនសម្រាប់ការតែងតាំងទៅការិយាល័យដែលត្រូវតែងតាំង ដោយអ្នកបោះឆ្នោតត្រូវមានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់របស់ខ្លួន ឬមិនមានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានបង្ហាញនៅលើសន្លឹកឆ្នោត ប៉ុន្តែការកំណត់ចំណូលចិត្តគណបក្សត្រូវតែជ្រើសរើសដោយបេក្ខជន ហើយត្រូវបានបង្ហាញសម្រាប់តែជាព័ត៌មាននៃអ្នកបោះឆ្នោតតែប៉ុណ្ណោះ។ វាមិនមានន័យថាបេក្ខជននោះត្រូវបានឈរឈ្មោះ ឬគាំទ្រដោយគណបក្សដែលបានកំណត់ទេ ឬថាមានទំនាក់ទំនងរវាងគណបក្ស និងបេក្ខជន ហើយគ្មានបេក្ខជនណា ដែលត្រូវបានឈរឈ្មោះដោយអ្នកបោះឆ្នោតត្រូវបានចាត់ទុកថាជាបេក្ខជនដែលត្រូវបានតែងតាំងជាផ្លូវការរបស់គណបក្សនយោបាយណាមួយឡើយ។ នៅក្នុងមគ្គុទេសក៍ព័ត៌មានអ្នកបោះឆ្នោតក្នុងខោនធី គណបក្សអាចចុះបញ្ជីបេក្ខជនសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោត ដែលបានទទួលការយល់ព្រមជាផ្លូវការពីគណបក្ស។

អ្នកបោះឆ្នោតណាមួយអាចបោះឆ្នោតជ្រើសរើសបេក្ខជនណាមួយ សម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោត ប្រសិនបើពួកគេបំពេញតាមលក្ខណសម្បត្តិផ្សេងទៀតដែលតម្រូវដើម្បីបោះឆ្នោតសម្រាប់ការិយាល័យនោះ។ អ្នកទទួលសំឡេងឆ្នោតច្រើនជាងគេពីររូបក្នុងការបោះឆ្នោតបឋម បន្តទៅការបោះឆ្នោតសាកលសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោត ថ្វីបើបេក្ខជនទាំងពីរបានបញ្ជាក់ពីចំណូលចិត្តគណបក្សដូចគ្នាក៏ដោយ។ គ្មានគណបក្សណាមានសិទ្ធិឱ្យបេក្ខជនដែលកំណត់ចំណូលចិត្តគណបក្សរបស់ខ្លួន បន្តទៅការបោះឆ្នោតសាកលបានទេ លើកលែងតែបេក្ខជននោះគឺជាបេក្ខជនមួយក្នុងចំណោមពីររូបដែលទទួលបានសន្លឹកឆ្នោតច្រើនជាងគេ នៅក្នុងការបោះឆ្នោតបឋម។

# ការិយាល័យគ្មានបក្សព័ន្ធ

គណបក្សនយោបាយមិនមានសិទ្ធិតែងតាំងបេក្ខជនសម្រាប់ការិយាល័យគ្មានបក្សព័ន្ធ នៅក្នុងការបោះឆ្នោតបឋមទេ ហើយបេក្ខជននៅឯការបោះឆ្នោតបឋមមិនមែនជាបេក្ខជនជាផ្លូវការ សម្រាប់គណបក្សណាមួយសម្រាប់ការិយាល័យជាក់លាក់នៅការបោះឆ្នោតសកលទេ។ បេក្ខជនសម្រាប់ការតែងតាំងឱ្យទៅការិយាល័យគ្មានបក្សព័ន្ធអាចនឹងមិនកំណត់ចំណូលចិត្តគណបក្សរបស់ខ្លួន ឬមិនមានចំណូលចិត្តគណបក្ស នៅលើសន្លឹកឆ្នោត។ បេក្ខជនពីររូបដែលទទួលសម្លេងឆ្នោតច្រើនជាងគេក្នុងការបោះឆ្នោតបឋម នឹងបន្តទៅការបោះឆ្នោតសកល សម្រាប់ការិយាល័យគ្មានបក្សព័ន្ធ។

# ព័ត៌មានអំពីសេចក្ដីថ្លែងការណ៍របស់បេក្ខជន

មគ្គុទ្ទេសក៍អ្នកបោះឆ្នោតនេះរួមបញ្ចូលនូវសេចក្ដីថ្លែងការណ៍របស់បេក្ខជនពីបេក្ខជនការិយាល័យរដ្ឋធម្មនុញ្ញទូទាំងរដ្ឋ ដែលចាប់ផ្ដើមនៅ ទំព័រ 10 នៃមគ្គុទ្ទេសក៍នេះ។

# ការិយាល័យរដ្ឋធម្មនុញ្ញទូទាំងរដ្ឋ

ច្បាប់រដ្ឋ California រួមបញ្ចូលនូវដែនកំណត់នៃការចំណាយស្ម័គ្រចិត្តសម្រាប់បេក្ខជន ដែលកំពុងឈរឈ្មោះសម្រាប់ការិយាល័យរដ្ឋដែលជ្រើសរើសរក្សាការចំណាយលើយុទ្ធនាការរបស់ពួកគេ នៅក្រោមចំនួនជាប្រាក់ដុល្លារជាក់លាក់។ បេក្ខជនការិយាល័យរដ្ឋធម្មនុញ្ញទូទាំងរដ្ឋ ដែលទទួលយកដែនកំណត់ការចំណាយ អាចទិញកន្លែងសម្រាប់សេចក្ដីថ្លែងការណ៍របស់បេក្ខជន (រហូតដល់ 250 ពាក្យ) នៅក្នុងមគ្គុទ្ទេសក៍អ្នកបោះឆ្នោតនេះ។

ដែនកំណត់ការចំណាយដោយស្ម័គ្រចិត្តសម្រាប់ការិយាល័យដូចខាងក្រោមសម្រាប់ការបោះឆ្នោតបឋមថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026 គឺ៖
• អភិបាលរដ្ឋ—$11,767,000 • អភិបាលរង រដ្ឋលេខាធិការ អ្នកត្រួតពិនិត្យ រតនាគារិក អគ្គមេធាវី ស្នងការធានារ៉ាប់រង និងស្នងការការអប់រំសាធារណៈ—$7,844,000 • សមាជិកក្រុមប្រឹក្សាភិបាលសមភាព—$1,961,000

ក្នុងបញ្ជីបេក្ខជនខាងក្រោម សញ្ញាផ្កាយ (*) ជ្រើសតាំងបេក្ខជនការិយាល័យរដ្ឋធម្មនុញ្ញទូទាំងរដ្ឋ ដែលបានទទួលដែនកំណត់ការចំណាយលើយុទ្ធនាការស្ម័គ្រចិត្តរបស់រដ្ឋ California ហើយដូច្នេះមានជម្រើសក្នុងការទិញកន្លែងសម្រាប់សេចក្ដីថ្លែងការណ៍របស់បេក្ខជន ក្នុងសៀវភៅមគ្គុទេសក៍អ្នកបោះឆ្នោតនេះ។ បេក្ខជនដែលមានសិទ្ធិមួយចំនួន ដែលបានទទួលយកដែនកំណត់ការចំណាយ ជ្រើសរើសមិនទិញកន្លែងសម្រាប់សេចក្ដីថ្លែងការណ៍របស់បេក្ខជន។ បេក្ខជនដែលមិនបានទទួលយកដែនកំណត់ការចំណាយមិនត្រូវបានអនុញ្ញាតឱ្យដាក់បញ្ជូនសេចក្ដីថ្លែងការណ៍ទេ។

សម្រាប់បញ្ជីបេក្ខជនដែលត្រូវបានបញ្ជាក់ចុងក្រោយ ដែលបានដល់ពេលកំណត់ បន្ទាប់ពីសៀវភៅមគ្គុទេសក៍នេះត្រូវបានបោះពុម្ពផ្សាយ សូមចូលទៅកាន់ *vote.ca.gov*។

**អភិបាល**

| | |
|---|---|
| Akinyemi Agbede* | ប្រជាធិបតេយ្យ |
| Mohammad Arif* | ប្រជាធិបតេយ្យ |
| James Athans Jr.* | សាធារណរដ្ឋ |
| Larry Azevedo | ប្រជាធិបតេយ្យ |
| Naomi Bar-Lev* | គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ |
| Xavier Becerra | ប្រជាធិបតេយ្យ |
| Chad Bianco* | សាធារណរដ្ឋ |
| Carolina Buhler* | ប្រជាធិបតេយ្យ |
| Joseph Cabrera* | គ្មានចំណូលចិត្តគណបក្ស |
| Elaine Culotti* | គ្មានចំណូលចិត្តគណបក្ស |
| Patricia De Luca Basualdo* | សាធារណរដ្ឋ |
| Louis A. DeBarraicua | ប្រជាធិបតេយ្យ |
| LivingForGod AndCountry DeMott* | គ្មានចំណូលចិត្តគណបក្ស |
| Randeep S. Dhillon* | សាធារណរដ្ឋ |
| Sophia Edum-A-Sam | ប្រជាធិបតេយ្យ |
| Serge Fiankan* | គ្មានចំណូលចិត្តគណបក្ស |
| Lukasz Adam Filinski | គ្មានចំណូលចិត្តគណបក្ស |
| Max Fomin* | គ្មានចំណូលចិត្តគណបក្ស |
| Derek Grasty* | ប្រជាធិបតេយ្យ |
| Don J. Grundmann* | គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ |
| Jon Henderson* | គ្មានចំណូលចិត្តគណបក្ស |
| Lewis Herms* | គ្មានចំណូលចិត្តគណបក្ស |
| Rafael M. Hernandez* | សាធារណរដ្ឋ |
| Steve Hilton | សាធារណរដ្ឋ |
| Joel Jacob | ប្រជាធិបតេយ្យ |
| Dawit E. Kellel | គ្មានចំណូលចិត្តគណបក្ស |
| Gary Howard Kidgell* | ប្រជាធិបតេយ្យ |
| Anne Komarovsk* | គ្មានចំណូលចិត្តគណបក្ស |
| Alicia Olivia Lapp* | សាធារណរដ្ឋ |
| Matthew Chase Levy* | ប្រជាធិបតេយ្យ |
| Duane Terrence Loynes Jr.* | គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ |
| Matt Mahan | ប្រជាធិបតេយ្យ |
| Amanda Martin* | គ្មានចំណូលចិត្តគណបក្ស |
| Brent Maupin* | គ្មានចំណូលចិត្តគណបក្ស |
| Daniel Mercuri* | គ្មានចំណូលចិត្តគណបក្ស |
| Leo Naranjo IV* | សាធារណរដ្ឋ |
| Tim Nelson | សាធារណរដ្ឋ |
| Barack D. Obama Shaw* | ប្រជាធិបតេយ្យ |
| Mauro Alberto Orozco | គ្មានចំណូលចិត្តគណបក្ស |
| Thunder Parley | ប្រជាធិបតេយ្យ |
| Katie Porter* | ប្រជាធិបតេយ្យ |
| Raji Rab* | ប្រជាធិបតេយ្យ |
| Satish Rao* | ប្រជាធិបតេយ្យ |
| Ramsey Robinson* | សន្តិភាពនិងសេរីភាព |
| Reza Safarnejad* | គ្មានចំណូលចិត្តគណបក្ស |
| Sam Sandak | គ្មានចំណូលចិត្តគណបក្ស |
| Christine R. Sarmiento* | គ្មានចំណូលចិត្តគណបក្ស |
| Frederic C. Schultz* | គ្មានចំណូលចិត្តគណបក្ស |
| Scott P Shields* | ប្រជាធិបតេយ្យ |
| Gretha Solórzano* | សាធារណរដ្ឋ |
| Tom Steyer | ប្រជាធិបតេយ្យ |
| Eric Swalwell | ប្រជាធិបតេយ្យ |
| Ebony Taylor | សាធារណរដ្ឋ |
| Tony K. Thurmond* | ប្រជាធិបតេយ្យ |
| Margaret Trowe* | គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ |
| Antonio Villaraigosa | ប្រជាធិបតេយ្យ |
| Tom Woodard | សេរីនិយម |
| Betty T. Yee* | ប្រជាធិបតេយ្យ |
| Nancy D. Young* | គ្មានចំណូលចិត្តគណបក្ស |
| Leo Samuel Zacky* | សាធារណរដ្ឋ |
| Erin “Zez” Zezulak* | ប្រជាធិបតេយ្យ |
| David Zickefoose | សាធារណរដ្ឋ |

**អភិបាលរង**

| | |
|---|---|
| Rakesh Christian | សាធារណរដ្ឋ |
| David Collenberg | សាធារណរដ្ឋ |
| Sean Collinson | គ្មានចំណូលចិត្តគណបក្ស |
| David Fennell* | សាធារណរដ្ឋ |
| Josh Fryday* | ប្រជាធិបតេយ្យ |
| Janelle Kellman* | ប្រជាធិបតេយ្យ |

**អភិបាលរងបន្ត**

| | |
|---|---|
| Jason Lopez* | ប្រជាធិបតេយ្យ |
| Ebie Lynch* | សាធារណរដ្ឋ |
| Fiona Ma* | ប្រជាធិបតេយ្យ |
| Oliver Ma* | ប្រជាធិបតេយ្យ |
| Tim Myers* | ប្រជាធិបតេយ្យ |
| Gloria Romero* | សាធារណរដ្ឋ |
| Skip Shelton | សាធារណរដ្ឋ |
| Abdur Rahman Sikder* | ប្រជាធិបតេយ្យ |
| Alice Stek* | សន្តិភាពនិងសេរីភាព |
| Michael Tubbs* | ប្រជាធិបតេយ្យ |

**រដ្ឋលេខាធិការ**

| | |
|---|---|
| Gary N. Blenner* | បៃតង |
| Michael Feinstein* | បៃតង |
| Donald P. (Don) Wagner* | សាធារណរដ្ឋ |
| Shirley N. Weber* | ប្រជាធិបតេយ្យ |

**អ្នកត្រួតពិនិត្យ**

| | |
|---|---|
| Meghann Adams* | សន្តិភាពនិងសេរីភាព |
| Malia M. Cohen* | ប្រជាធិបតេយ្យ |
| Herb W Morgan* | សាធារណរដ្ឋ |

**អ្នកចាត់ចែងធនធានហិរញ្ញវត្ថុ**

| | |
|---|---|
| Anna M. Caballero* | ប្រជាធិបតេយ្យ |
| Jennifer Hawks* | សាធារណរដ្ឋ |
| Eleni Kounalakis* | ប្រជាធិបតេយ្យ |
| David Serpa* | សាធារណរដ្ឋ |
| Glenn Turner* | បៃតង |
| Tony Vazquez* | ប្រជាធិបតេយ្យ |

**អគ្គមេធាវី**

| | |
|---|---|
| Rob Bonta | ប្រជាធិបតេយ្យ |
| Michael E. Gates* | សាធារណរដ្ឋ |
| Marjorie Mikels* | បៃតង |

**ស្នងការធានារ៉ាប់រង**

| | |
|---|---|
| Eric Thor Aarnio* | សាធារណរដ្ឋ |
| Ben Allen* | ប្រជាធិបតេយ្យ |
| Steven Craig Bradford* | ប្រជាធិបតេយ្យ |
| Merritt Farren* | សាធារណរដ្ឋ |
| Robert P Howell* | សាធារណរដ្ឋ |
| Jane Kim* | ប្រជាធិបតេយ្យ |
| Stacy A. Korsgaden* | សាធារណរដ្ឋ |
| Sean Lee* | សាធារណរដ្ឋ |
| Eduardo “Lalo” Vargas* | សន្តិភាពនិងសេរីភាព |
| Patrick Wolff* | ប្រជាធិបតេយ្យ |

**ក្រុមប្រឹក្សាភិបាលសមភាព មណ្ឌល 1**

| | |
|---|---|
| Dusty Beach* | សាធារណរដ្ឋ |
| Nelson Esparza* | ប្រជាធិបតេយ្យ |
| Shannon Grove* | សាធារណរដ្ឋ |
| Nader F Shahatit* | សាធារណរដ្ឋ |
| Donald E. Williamson* | ប្រជាធិបតេយ្យ |

**ក្រុមប្រឹក្សាភិបាលសមភាព មណ្ឌល 2**

| | |
|---|---|
| Sally J. Lieber* | ប្រជាធិបតេយ្យ |
| J Brett Marymee* | សាធារណរដ្ឋ |
| Mark McComas | សាធារណរដ្ឋ |
| John Pimentel* | ប្រជាធិបតេយ្យ |
| Bill Shireman* | សាធារណរដ្ឋ |
| John W. Zaruka | សាធារណរដ្ឋ |

**ក្រុមប្រឹក្សាភិបាលសមភាព មណ្ឌល 3**

| | |
|---|---|
| Carlo Basail | សាធារណរដ្ឋ |
| Rudy Bermudez | ប្រជាធិបតេយ្យ |
| Mike Gipson* | ប្រជាធិបតេយ្យ |
| Stephan Hohil | សាធារណរដ្ឋ |
| Zhijing Liu | ប្រជាធិបតេយ្យ |
| Marie Manvel | គ្មានចំណូលចិត្តគណបក្ស |
| Rey Portela* | សាធារណរដ្ឋ |
| Baru Alejandro Sanchez* | ប្រជាធិបតេយ្យ |
| Samuel P. Sukaton | ប្រជាធិបតេយ្យ |
| Yvonne Yiu* | ប្រជាធិបតេយ្យ |

**ក្រុមប្រឹក្សាភិបាលសមភាព មណ្ឌល 4**

| | |
|---|---|
| Martín Arias* | ប្រជាធិបតេយ្យ |
| Denis Bilodeau* | សាធារណរដ្ឋ |
| Gardner C. Osborne* | សេរីនិយម |
| Cody Petterson* | ប្រជាធិបតេយ្យ |
| Tom Umberg* | ប្រជាធិបតេយ្យ |

**អគ្គនាយកផ្នែកអប់រំសាធារណៈ**

| | |
|---|---|
| Richard Barrera* | គ្មានគណបក្ស |
| Wendy Castaneda Leal | គ្មានគណបក្ស |
| Nichelle M. Henderson* | គ្មានគណបក្ស |
| Frank Lara* | គ្មានគណបក្ស |
| Ainye Long* | គ្មានគណបក្ស |
| Gus Mattammal* | គ្មានគណបក្ស |
| Al Muratsuchi* | គ្មានគណបក្ស |
| Josh Newman* | គ្មានគណបក្ស |
| Anthony Rendon* | គ្មានគណបក្ស |
| Sonja Shaw* | គ្មានគណបក្ស |

សម្រាប់គោលបំណងនៃសៀវភៅមគ្គុទេសក៍នេះ បេក្ខជនដែលបានរាយបញ្ជីថា “គ្មានចំណូលចិត្តគណបក្ស” បានជ្រើសរើសជម្រើសនោះ ឬមិនបានធ្វើការជ្រើសរើសណាមួយ នៅពេលចុះឈ្មោះបោះឆ្នោត។ បេក្ខជនដែលបានរាយបញ្ជីថា “គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់” បានបង្ហាញពីចំណូលចិត្តសម្រាប់គណបក្សមួយដែលមិនទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់ពេលបច្ចុប្បន្ននៅក្នុងរដ្ឋ California នៅពេលចុះឈ្មោះបោះឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាល

- ក្នុងនាមជាមន្ត្រីនាយកប្រតិបត្តិរបស់រដ្ឋ ត្រួតពិនិត្យលើនាយកដ្ឋាន និងភ្នាក់ងាររដ្ឋភាគច្រើន និងតែងតាំងចៅក្រម។
- ដាក់ស្នើច្បាប់ថ្មី អនុម័ត ឬហាមឃាត់ច្បាប់ និងដាក់បញ្ជូនថវិកាប្រចាំឆ្នាំរបស់រដ្ឋទៅអង្គនីតិបញ្ញត្តិ។
- ជំរុញ និងដឹកនាំធនធានរបស់រដ្ឋក្នុងគ្រាអាសន្ន។



### Katie Porter | ប្រជាធិបតេយ្យ

ខ្ញុំបានចំណាយពេលពេញមួយអាជីពរបស់ខ្ញុំដើម្បីឲ្យអ្នកដែលកាន់អំណាចទទួលខុសត្រូវនៅពេលដែលពួកគេកុហក ឬបំពានច្បាប់។ ក្នុងនាមជាអភិបាលរដ្ឋ ខ្ញុំនឹងប្រឈមមុខតទល់ជាមួយលោក Donald Trump និងអ្នកណាដែលព្យាយាមធ្វើបាបគ្រួសាររដ្ឋ California។ ក្នុងនាមជាសមាជិកសភា ខ្ញុំបានប្រឈមមុខនឹងCEOមហាសេដ្ឋី និងមន្ត្រីនានារបស់ Trump ដែលគ្មានសមត្ថភាព ដោយការប្រើក្តារខៀន ដើម្បីបង្ហាញពីការពិត និងលាតត្រដាងអំពើពុករលួយ និងការបោកប្រាស់។ ខ្ញុំបានស្រោចស្រង់មកវិញរាប់ពាន់លានសម្រាប់ម្ចាស់គេហដ្ឋាននៅរដ្ឋ California នៅពេលដែលធនាគារធំៗបានកេងប្រវ័ញ្ចពួកគេ, បានបង្ខំឱ្យក្រុមហ៊ុនឱសថបញ្ឈប់ការយកប្រាក់លើសពីអ្នកបង់ពន្ធ ហើយបានធ្វើឱ្យរដ្ឋបាល Trump ផ្តល់ការធ្វើតេស្តរក COVID ដោយឥតគិតថ្លៃសម្រាប់អ្នករាល់គ្នា។ មិនដូចអ្នកប្រជាធិបតេយ្យផ្សេងទៀតទេ ខ្ញុំបដិសេធការបរិច្ចាគពីសាជីវកម្ម និងអ្នកបញ្ចុះបញ្ចូល។ ផលប្រយោជន៍ពិសេសទាំងនោះ និងគណៈកម្មាធិការសកម្មភាពនយោបាយ PAC មានអំណាចខ្លាំងពេកនៅក្នុង Sacramento ហើយកំពុងធ្វើឱ្យរដ្ឋ California មិនមានលទ្ធភាពសម្រាប់ពួកយើងដែលនៅសល់។ ខ្ញុំមិនអាចត្រូវបានគេទិញទេ ដូច្នេះអ្នកអាចពឹងផ្អែកលើខ្ញុំដើម្បីកាត់បន្ថយថ្លៃចំណាយរបស់អ្នក ធានាគុណភាពការថែទាំសុខភាព និងការពារបរិស្ថាន។ ក្នុងនាមខ្ញុំជាម្តាយទោលដែលមានកូនបីនាក់ ខ្ញុំផ្ទាល់រុញរទេះដាក់ម្ហូប ចាក់សាំងរថយន្តខ្នាតតូច និងបង់វិក្កយបត្រចំណាយប្រចាំខែ។ ខ្ញុំបានមើលការចំណាយដូចជាថ្លៃទឹកភ្លើង និងធានារ៉ាប់រងកើនឡើង ហើយប្រាក់ដុល្លារមិនគ្រប់គ្រាន់ ដូចទៅនឹងប្រជាជន California ជាច្រើន។ ក្នុងនាមជាអភិបាលរដ្ឋ ខ្ញុំនឹងកាត់បន្ថយថ្លៃចំណាយសម្រាប់គ្រួសារ ហើយដំឡើងប្រាក់ខែកម្មករ។ នេះជាមធ្យោបាយ៖ ខ្ញុំនឹងលុបបំបាត់ពន្ធលើប្រាក់ចំណូលសម្រាប់ប្រជាជន California ដែលរកបានតិចជាង $100,000, សាងសង់លំនៅឋានដែលកម្មករអាចមានលទ្ធភាព បញ្ឈប់ការគិតថ្លៃសិក្សានៅសាកលវិទ្យាល័យសាធារណៈរបស់យើង និងធ្វើឱ្យការថែទាំកុមារឥតគិតថ្លៃសម្រាប់ប្រជាជន California ទាំងអស់។ ស្វែងយល់បន្ថែមនៅ *KatiePorter.com* ។

1700 Tribute Rd., Suite 201, Sacramento, CA 95815 | ទូរស័ព្ទ: (909) 457-7850
អ៊ីមែល: info@katieporter.com | Facebook: @KatiePorterCA | X: @KatiePorterCA



### Betty T. Yee | ប្រជាធិបតេយ្យ

យើងមិនអាចដោះស្រាយវិបត្តិលទ្ធភាពទិញបាន ដោយគ្មានអភិបាលដែលអាចដោះស្រាយថវិការដ្ឋបាននោះទេ។ បញ្ហាថវិកាដែលកំពុងបន្តកំពុងធ្វើឱ្យប៉ះពាល់ដល់ការវិនិយោគនៅក្នុងសាលារៀន ការថែទាំសុខភាព លំនៅឋាន ការថែទាំកុមារ មនុស្សចាស់ និងបរិស្ថានរបស់យើង។ ខ្ញុំជាបេក្ខជនតែម្នាក់គត់ដែលបានបម្រើការជានាយកថវិការដ្ឋ ដែលជាសមាជិកជាប់ឆ្នោតនៃក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ និងជាអ្នកត្រួតពិនិត្យរដ្ឋ។ ខ្ញុំបានដឹកនាំប្រឆាំងនឹងសាជីវកម្ម និងអ្នកមានស្តុកស្តម ដោយធ្វើឱ្យប្រាកដថាពួកគេបានបង់ពន្ធត្រឹមត្រូវរបស់ពួកគេ។ ខ្ញុំបានរកឃើញការចំណាយខុសចំនួន $7.3 ពាន់លានដុល្លារ។ ខ្ញុំមិនដែលខ្ចីប្រាក់ពីខាងក្រោមកបង់វិក្កយបត្ររដ្ឋទេ។ ខ្ញុំបានការពារមូលនិធិចូលនិវត្តន៍សម្រាប់បុគ្គលិកសាលារៀន។ នេះគឺជាអ្វីដែលប្រជាជន California ដែលខិតខំធ្វើការរំពឹងទុក ហើយសមនឹងទទួលបាន អ្នកដឹកនាំដែលមានបទពិសោធន៍ដែលធ្វើការដើម្បីពួកគេ។ ជារៀងរាល់ថ្ងៃ គ្រួសារត្រូវជ្រើសយកជម្រើសសេដ្ឋកិច្ចយ៉ាងលំបាកអំពីថាតើវិក្កយបត្រអ្វីដែលត្រូវបង់ និងអ្វីដែលត្រូវចៀសវាង។ ខ្ញុំឃើញចំណុចនេះ នៅពេលដែលខ្ញុំជួយគ្រួសារស្វែងរកតម្រូវការការថែទាំមនុស្សចាស់ និងការថែទាំកុមារ។ យើងមិនអាចអនុញ្ញាតឱ្យគ្រួសារធ្លាក់ចុះទៅកាន់តែឆ្ងាយទៀតទេ។ ហើយយើងមិនត្រូវដាក់បន្ទុកលើអ្នកជំនាន់បន្ទាប់ ដោយការចំណាយដែលនឹងកាត់បន្ថយសមត្ថភាពរបស់ពួកគេដើម្បីជោគជ័យ និងរីកចម្រើននោះទេ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចវិនិយោគលើប្រជាជនរបស់យើង ធ្វើឲ្យសេដ្ឋកិច្ចរបស់យើងរីកចម្រើនដោយបង្កើតការងារដែលមាន ប្រាក់ខែល្អនៅគ្រប់ជ្រុងនៃរដ្ឋ ។ ចូលរួមជាមួយ Progressive Democrats of America, Asian Americans and Pacific Islanders Victory Fund, National Women's Political Caucus of California, California Women's List, Democratic Activists for Women Now, និងមន្ត្រីជាប់ឆ្នោតក្នុងតំបន់ក្នុងការគាំទ្រភាពជាអ្នកដឹកនាំដែលមានបទពិសោធន៍ និងទំនួលខុសត្រូវដើម្បីធ្វើឱ្យរដ្ឋ California សមហេតុផលសម្រាប់មនុស្សគ្រប់គ្នា។ ខ្ញុំសូមស្នើសុំសន្លឹកឆ្នោតពីអ្នកដោយសេចក្តីគោរព។

16633 Ventura Blvd., Suite 1008, Encino, CA 91436 | ទូរស័ព្ទ: (818) 884-1818
អ៊ីមែល: info@bettyyee.com | Facebook: facebook.com/BettyYeeforCA | Instagram: instagram.com/bettyyeeforcalifornia

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាល



**Anne Komarovsk** | គ្មានចំណូលចិត្តគណបក្ស

ជម្រាបសួរអ្នកបោះឆ្នោត៖ *Please-Help-Make-CaliforniA-Great-Again-Thank-You-NPP26.com HowTheWestWasOne.org*

9663 Santa Monica Blvd., Beverly Hills, CA 90210 | ទូរស័ព្ទ: (202) 844-0026
អ៊ីមែល: NPP26@Aol.com | NPP26.com | Facebook: FaceBook.com/AnneKomarovsk

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



### Gary Howard Kidgell | ប្រជាធិបតេយ្យ

អ្នកសាងសង់កេរ្តិ៍ដំណែលដែលផ្តល់នូវដំណោះស្រាយដែលអាចរកបានសម្រាប់ប្រជាជន California ប្រចាំថ្ងៃ

Santa Clara, CA | ទូរស័ព្ទ: (415) 471-6699
អ៊ីមែល: ghkcalifornia@gmail.com | @Kidgell4CA2026 | KidgellforCalifornia.com



### Tony K. Thurmond | ប្រជាធិបតេយ្យ

កើតមកពីម្តាយជនអន្តោប្រវេសន៍ពីប្រទេសប៉ាណាម៉ា, លោក Tony Thurmond និងបងប្រុសរបស់គាត់ត្រូវបានចិញ្ចឹមដោយបងប្អូនជីដូនមួយដែលពួកគេមិនធ្លាប់បានជួបបន្ទាប់ពីម្តាយរបស់ពួកគេបានស្លាប់នៅពេលលោក Tony មានអាយុត្រឹមតែ 6 ឆ្នាំ។ ធំឡើងក្នុងភាពក្រីក្រ គ្រួសាររបស់ Tony ពឹងផ្អែកលើជំនួយសាធារណៈ និងសាលារដ្ឋដ៏ល្អ ដើម្បីងើបចេញពីភាពលំបាក បទពិសោធន៍ដែលជំរុញទឹកចិត្តឱ្យមានការលះបង់ពេញមួយជីវិតរបស់គាត់ដើម្បីសមធម៌ និងឱកាសសម្រាប់ប្រជាជន California ទាំងអស់។ នៅទីបំផុតគាត់បានក្លាយជាបុគ្គលិកសង្គម សមាជិកក្រុមប្រឹក្សាក្រុង សមាជិកក្រុមប្រឹក្សាសាលា សមាជិកសភា ហើយចុងក្រោយជា អគ្គនាយកនៃប្រព័ន្ធសាលារដ្ឋ $150 ពាន់លានដុល្លាររបស់រដ្ឋ California។ ក្នុងនាមជាអគ្គនាយករដ្ឋ, Tony បានឧបត្ថម្ភច្បាប់មួយ ដើម្បីទប់ស្កាត់ ICE ចេញពីសាលារៀននៅ California។ គាត់បានជួយបង្កើតសាលាមត្តេយ្យជាសកលសម្រាប់ក្មេងអាយុ 4 ឆ្នាំ និងអាហារជាសកលសម្រាប់កុមារដែលស្រេកឃ្លាន។ Thurmond បានជួយផ្តល់ថវិការាប់ពាន់លាន ដើម្បីធ្វើឱ្យសាលារៀនមានសុវត្ថិភាពជាងមុន ដោយការលុបបំបាត់សារធាតុ អាបស្តូស និងជាតិពុលផ្សេងទៀត។ លោក Tony យល់ថា ប្រព័ន្ធនយោបាយរបស់យើងបានបែកបាក់។ ពីការកើនឡើងថ្លៃអាហារ និងទំនិញ រហូតដល់រដ្ឋាភិបាលសហព័ន្ធ វាយប្រហារសេរីភាពប្រជាពលរដ្ឋរបស់យើង រដ្ឋរបស់យើងកំពុងស្ថិតនៅក្នុងវិបត្តិ។ ទន្ទឹមនឹងនោះ មហាសេដ្ឋីក៏កាន់តែមានទៅ មានទៅ។ នោះហើយជាមូលហេតុដែលគាត់ប្រយុទ្ធដើម្បីយកពន្ធលើមហាសេដ្ឋី, ការថែទាំសុខភាពសម្រាប់ទាំងអស់គ្នា, ការលុបបំបាត់ ICE, លំនៅឋានថ្មីចំនួន 2 លានខ្នង, ទីបំផុតការផ្តល់មូលនិធិយ៉ាងពេញលេញដល់សាលារៀនសាធារណៈរបស់យើង, ការថែទាំផ្នែករំលូតកូនដែលស្របច្បាប់និងអាចប្រើប្រាស់បាន, ការដកយកអាវុធសង្គ្រាមចេញពីផ្លូវរបស់យើង និងការការពារលទ្ធិប្រជាធិបតេយ្យ។ យើងត្រូវការមេដឹកនាំម្នាក់ដែលនឹងតតាំងជាមួយមហាសេដ្ឋី រហូតដល់រដ្ឋាភិបាលសហព័ន្ធ និងប្រយុទ្ធដើម្បីប្រជាជន California ឋានៈកម្មកររៀងរាល់ថ្ងៃ។ យើងត្រូវការ Tony Thurmond ។ នៅថ្ងៃទី 2 ខែមិថុនា សូមបោះឆ្នោតជូនលោក Tony Thurmond ជាអភិបាល។ សូមចូលទៅកាន់ *tonythurmond.com*។

312 Clay St. #300, Oakland, CA 94607 | អ៊ីមែល: tony@tonythurmond.com
X: x.com/TonyThurmond | Facebook: www.facebook.com/tonythurmond

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



### Margaret Trowe | គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

Margaret Trowe ដែលជាសមាជិកនៃគណបក្សសង្គមនិយមកម្មករ អស់រយៈពេលប្រាំទសវត្សរ៍ គឺជាអ្នកថែទាំបោសសម្អាតសណ្ឋាគារ និងជាសមាជិកនៃសហជីព UNITE-HERE ។ បានរៀបចំសាមគ្គីភាព ចូលរួមកូដកម្មរបស់សណ្ឋាគារ សាលារៀន បុគ្គលិកមន្ទីរពេទ្យ។ អំពាវនាវឲ្យមានការតស៊ូគាំទ្រដោយសហជីពដើម្បីលើកលែងទោស ដល់កម្មករដែលគ្មានឯកសារដើម្បីកសាងឯកភាពឋានៈកម្មករ។ អ្នកតស៊ូយូរអង្វែងប្រឆាំងនឹងការរើសអើងពូជសាសន៍ សម្រាប់សិទ្ធិនារី និងប្រឆាំងនឹងសង្គ្រាមរបស់រដ្ឋាភិបាលទីក្រុងវ៉ាស៊ីនតោន ពីប្រទេសវៀតណាម រហូតដល់ប្រទេសវេណេស៊ុយអេឡា។ ការពារសិទ្ធិរបស់អ៊ីស្រាអែលក្នុងការរស់រាន និងការពារខ្លួន។ ប្រឆាំងនឹងការកើនឡើងនៃការស្អប់ជនជាតិយូដា។ អ្នកគាំទ្របដិវត្តន៍ប្រទេសគុយបាដែលបាននាំប្រជាជនធ្វើការមកកាន់អំណាច។ និយាយថា “សហរដ្ឋអាមេរិក កុំពាក់ព័ន្ធប្រទេសគុយបា!” បញ្ចប់ការបិទខ្ទប់សេដ្ឋកិច្ចសហរដ្ឋអាមេរិកលើគុយបា! ការពារសេរីភាពនៃការនិយាយ ការកាត់ក្ដីត្រឹមត្រូវ ការការពាររដ្ឋធម្មនុញ្ញផ្សេងទៀត។ យុទ្ធនាការសម្រាប់តម្រូវការឱ្យកម្មករកាន់អំណាចនយោបាយ - ដែលជាដំណោះស្រាយតែមួយគត់សម្រាប់វិបត្តិសេដ្ឋកិច្ច នយោបាយ និងសីលធម៌របស់មូលធននិយមពិភពលោកនិងវិធីតែមួយគត់ដើម្បីបញ្ឈប់អ្នកគ្រប់គ្រងមូលធននិយមពីការដើរទៅរកសង្គ្រាមលោកលើកទី III ។

675 Hegenberger Rd., Suite 250, Oakland, CA 94621 | ទូរស័ព្ទ: (510) 686-1351
អ៊ីមែល: SocialistWorkers2026campaign@gmail.com | www.themilitant.com



### Erin “Zez” Zezulak | ប្រជាធិបតេយ្យ

ជម្រាបសួរប្រជាជន California, ខ្ញុំគឺ Erin *Zez* Zezulak, RN, IBCLC, MPH, គិលានុបដ្ឋាយិកា, អ្នកអប់រំ, ម្ចាស់អាជីវកម្មខ្នាតតូច, អ្នកប្រឹក្សា, និងជាម្ដាយ។ ខ្ញុំបានកើត ធំធាត់ និងទទួលការអប់រំនៅរដ្ឋ California។ ម្ដាយរបស់ខ្ញុំដែលជាអ្នកប្រជាធិបតេយ្យជាគ្រូបង្រៀននៅសាលា និងឪពុករបស់ខ្ញុំដែលអ្នកជីវវិទូសត្វព្រៃ, អ្នកសាធារណរដ្ឋ, អ្នកប្រមាញ់ដ៏ប៉ិនប្រសប់បានផ្ដល់ឱ្យបងប្អូនស្រីរបស់ខ្ញុំ និងខ្ញុំនូវទស្សនវិស័យចម្រុះនៃរដ្ឋ California។ ទៅតាមសត្វដែលឪពុកខ្ញុំបានសិក្សា ខ្ញុំធ្លាប់បានរស់នៅក្នុងឧទ្យានរដ្ឋ និងឧទ្យានជាតិដ៏ស្រស់ស្អាតជាច្រើនក្នុងរដ្ឋ California ក៏ដូចជាជាមួយជីដូនជីតារបស់ខ្ញុំនៅតំបន់ Los Angeles និង ឈូងសមុទ្រ San Francisco ។ *ខ្ញុំស្គាល់រដ្ឋ California ។* ការធ្វើការជាមួយអ្នកជំងឺ និងក្រុមគ្រួសារនៅក្នុងប្រព័ន្ធវេជ្ជសាស្ត្ររដ្ឋ California អស់រយៈពេលជិត 30 ឆ្នាំបានជួយខ្ញុំក្នុងការធ្វើផែនការសម្រាប់ប្រព័ន្ធថែទាំសុខភាពដែលរួបរួម និងមានសមធម៌សម្រាប់មនុស្សទាំងអស់ដែលរស់នៅក្នុងរដ្ឋ California។ សមធម៌សម្រាប់ប្រជាជន California ទាំងអស់ ពង្រីកដល់ការអប់រំ សុវត្ថិភាព និងការការពារ។ យើងទាំងអស់គ្នាត្រូវតែទទួលបានការការពារពីការរើសអើង និងការអនុវត្តដែលមិនស្របតាមរដ្ឋធម្មនុញ្ញ។ ICE នឹងមិនត្រូវបានអនុញ្ញាតនៅក្នុងរដ្ឋ California ដោយប្រើយុទ្ធសាស្ត្របច្ចុប្បន្នរបស់ខ្លួនឡើយ។ ការធ្វើការជាមួយជីតារបស់ខ្ញុំ ដែលជាអ្នកម៉ៅការសំណង់ បានជួយខ្ញុំឱ្យឃើញពីរបៀបពង្រីកទីក្រុងរបស់យើងឱ្យបានច្រើនបំផុត ដែលធ្វើឱ្យមានលំនៅឋានតម្លៃសមរម្យសម្រាប់ទាំងអស់គ្នា។ ការរស់នៅក្នុងសហគមន៍កសិកម្មបានបំផុសគំនិតផែនការគ្រប់គ្រងទឹករបស់ខ្ញុំដើម្បីលុបបំបាត់វដ្តរាំងស្ងួត/ទឹកជំនន់ដែលជះឥទ្ធិពលដល់កសិកម្ម សេដ្ឋកិច្ច និងសហគមន៍របស់រដ្ឋ California។ ក្នុងនាមជាអ្នកបើកយន្តហោះកំពុងទទួលការបណ្ដុះបណ្ដាល ខ្ញុំបានរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការប្រយុទ្ធប្រឆាំងនឹងភ្លើងឆេះព្រៃពីលើអាកាស និងសម្រាប់ការរកឃើញភ្លើងទាន់ពេល ដើម្បីកាត់បន្ថយការបំផ្លិចបំផ្លាញភ្លើងឆេះព្រៃ។ *ខ្ញុំស្គាល់រដ្ឋ California ។ ខ្ញុំនឹងខិតខំកសាងរដ្ឋ California ឱ្យកាន់តែប្រសើរឡើងសម្រាប់ទាំងអស់គ្នាក្នុងនាមជាអភិបាលបន្ទាប់របស់អ្នក។ សូមអរគុណចំពោះការបោះឆ្នោតរបស់អ្នក។*

P.O. Box 4518, Davis, CA 95617 | ទូរស័ព្ទ: (530) 304-8737
អ៊ីមែល: erinzezulak@gmail.com | Facebook | Instagram

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្ដីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្ដល់ជូនសេចក្ដីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្ដីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្ដីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាល



### Duane Terrence Loynes Jr. | គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

វេទិកាគណបក្សសាមគ្គីអាមេរិកសង្កត់ធ្ងន់លើតម្រូវការដើម្បីលើកតម្កើងសេចក្តីថ្លៃថ្នូររបស់មនុស្សតាំងពីការចាប់កំណើតរហូតដល់ការស្លាប់ដោយធម្មជាតិ ដែលរួមមានទារកមិនទាន់កើត ម្តាយមានផ្ទៃពោះស្ថិតក្នុងវិបត្តិ ជនអន្តោប្រវេសន៍ អ្នកមានឯកសារឬគ្មានឯកសារ កុមារដែលប្រឈមនឹងការឃ្លាតពីម្តាយឬឪពុក ជនចាស់ជរា ឬឈឺដែលប្រឈមនឹងការដាក់សម្ពាធឱ្យបញ្ចប់ជីវិតខ្លួនឯង កម្មករដែលជួបការលំបាកក្នុងការចិញ្ចឹមគ្រួសារ ឬទិញផ្ទះ ជនអនាថាដែលគ្មានទីជម្រក និងត្រូវបានកាត់ផ្តាច់ពីគ្រួសារ។ ប្រសិនបើអ្នកយល់ស្របជាមួយនឹងតម្រូវការដើម្បីរក្សាសេចក្តីថ្លៃថ្នូរនេះជាមួយនឹងគោលនយោបាយដើម្បីផលប្រយោជន៍រួម សូមធ្វើការសម្រេចចិត្តថ្ងៃនេះដើម្បីចុះឈ្មោះជាមួយគណបក្សសាមគ្គីអាមេរិកដោយធ្វើតាមការណែនាំនៅទីនេះ *https://ca.solidarity-party.org/learn_more/register-to-vote/*



### Matthew Chase Levy | ប្រជាធិបតេយ្យ

Matthew Chase Levy គឺជាសហគ្រិនដែលមានមូលដ្ឋាននៅរដ្ឋ California ដែលជាអ្នកវិទ្យាសាស្ត្រត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងកំពុងឈរឈ្មោះសម្រាប់តំណែងអភិបាលក្នុងនាមជាអ្នកខាងក្រៅនយោបាយ ។ គាត់គឺជាស្ថាបនិកនៃ NobleAI ដែលជាវេទិកា AI ផ្អែកលើវិទ្យាសាស្ត្រដែលបង្កើនល្បឿននៃការរកឃើញ និងការច្នៃប្រឌិតក្នុងផ្នែកគីមីវិទ្យា វត្ថុធាតុដើម និងថាមពល ព្រមទាំង AE Blue Capital ដែលជាក្រុមហ៊ុនបណ្តាក់ទុនដែលគាំទ្រការលាយបញ្ចូលគ្នា និងបច្ចេកវិទ្យាថាមពលស្អាតកម្រិតខ្ពស់ផ្សេងទៀតដែលមានសារៈសំខាន់ក្នុងការដោះស្រាយការកើនឡើងថ្លៃចំណាយលើថាមពល បញ្ហាភាពជឿជាក់លើបណ្តាញអគ្គិសនី និងគោលដៅកាត់បន្ថយកាបូនឌីអុកស៊ីតរយៈពេលវែង។ បទពិសោធន៍របស់គាត់ជាមួយនឹងការខិតខំទាំងនេះនឹងជំរុញដំណោះស្រាយជាក់ស្តែងនៃបញ្ហាសង្គម ពង្រីកការងារ និងរក្សាតួនាទីដ៏លេចធ្លោរបស់រដ្ឋ California ក្នុងនាមជាអ្នកដឹកនាំពិភពលោកក្នុងការប្រើប្រាស់វិទ្យាសាស្ត្រ ដើម្បីជាប្រយោជន៍ដល់ប្រជាជន California ទាំងអស់។ Levy ទទួលបានបរិញ្ញាបត្រពី UCLA និងសញ្ញាបត្រអនុបណ្ឌិត និង បណ្ឌិតផ្នែករូបវិទ្យាពីសាកលវិទ្យាល័យ Rice។ កំឡុងពេលសិក្សាថ្នាក់បណ្ឌិតរបស់គាត់ គាត់បានធ្វើការស្រាវជ្រាវនៅមន្ទីរពិសោធន៍ជាតិ Lawrence Livermore ស្តីពីសន្តិសុខយុទ្ធសាស្ត្ររបស់សហរដ្ឋអាមេរិក។ នេះបាននាំឱ្យគាត់ក្លាយជារូបវិទូជនជាតិអាមេរិកដំបូងគេដែលបានទទួលពានរង្វាន់អាហារូបករណ៍ Isaac Newton អន្តរជាតិ ដោយ Royal Society នៅសាកលវិទ្យាល័យ Oxford ។ បទពិសោធន៍អន្តរជាតិដំបូងនៅទីក្រុងតូក្យូ—មុន និងអំឡុងពេល ឆ្នាំ UCLA របស់គាត់—រួមផ្សំជាមួយការងាររបស់គាត់នៅចក្រភពអង់គ្លេស ផ្តល់ឱ្យគាត់នូវទស្សនវិស័យពិសេសមួយលើការច្នៃប្រឌិតជាសកល និងបញ្ហាប្រឈមដែលគ្រួសាររដ្ឋ California កំពុងជួបប្រទះ។ លេវីជានិស្សិតអាហារូបករណ៍នៅមហាវិទ្យាល័យ Wolfson, Oxford; អ្នកទទួលគ្រប់គ្រងនៃវិទ្យាស្ថានវ៉ាស៊ីនតោន; និងបម្រើការនៅក្នុងគណៈកម្មាធិការហិរញ្ញវត្ថុសម្រាប់អភិបាលក្រុង Oakland និងអតីតសមាជិកសភាលោកស្រី Barbara Lee។ Levy រស់នៅក្នុង Oakland ជាមួយប្រពន្ធរបស់គាត់ Debbie Senesky ជា សាស្ត្រាចារ្យនៅ Stanford និងកូនស្រីអាយុ 12 ឆ្នាំ។ *www.Matthewchaselevy.com*

P.O. Box 4679, Oakland, CA, 94505 | ទូរស័ព្ទ: (510) 269-7469
អ៊ីមែល: matthew@matthewchaselevy.com | Instagram: matthewchaselevy | X: matthewclevy

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



### Akinyemi Agbede | ប្រជាធិបតេយ្យ

ការពង្រឹងអនាគតរបស់រដ្ឋកាលីហ្វ័រញ៉ា ចូលមើលគេហទំព័ររបស់ខ្ញុំនៅ *www.thenextgovernorofcalifornia2026.net*

545 S. San Pedro Street, Los Angeles, CA 90013 | ទូរស័ព្ទ: (213) 509-7673
អ៊ីមែល: yemibode@hotmail.com | www.thenextgovernorofcalifornia2026.net

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាល



### Joseph Cabrera | គ្មានចំណូលចិត្តគណបក្ស

រដ្ឋ California ត្រូវបានបង្កើតឡើងតាមការសន្យាមួយ៖ តាមរយៈការខិតខំប្រឹងប្រែង និងការច្នៃប្រឌិត ប្រជាពលរដ្ឋគ្រប់រូបអាចកសាងជីវិតដ៏រុងរឿងមួយ។ សព្វថ្ងៃនេះ ការសន្យានោះកំពុងរលុបទៅក្រោមការបិទក្រឡាចត្រង្គនៃក្រុមបក្សព័ន្ធ និងថវិកាផ្នែកដឹកជញ្ជូនចំនួន $31 ពាន់លាន ដែលបន្សល់នូវផ្លូវថ្នល់របស់យើងដែលខូច។ ខ្ញុំកំពុងប្រជែងតំណែងជាអភិបាលដើម្បីផ្តល់ "ការជួសជុលឯករាជ្យ" ដែលរដ្ឋរបស់យើងត្រូវការយ៉ាងខ្លាំង។ អ្នកនយោបាយ Sacramento កំពុងស្នើសុំពន្ធថ្មី ប៉ុន្តែថវិកាផ្ទាល់ខ្លួនរបស់ពួកគេ —តារាងទី 11— បង្ហាញថាពួកគេកំពុងអង្គុយនៅលើ $ 30.1 ពាន់លានជាប្រាក់មូលបត្របំណុលដែលបានអនុម័តដោយអ្នកបោះឆ្នោត ដែលមិនត្រូវបានចំណាយ ។ យើងមានទឹកប្រាក់ជិត $500 លាន សម្រាប់ការកាត់បន្ថយចរាចរណ៍ ដែលត្រូវបានទុកនៅស្ងៀមតាំងពីឆ្នាំ 2006 មកម្ល៉េះ។ ក្នុងនាមជាម្ចាស់អាជីវកម្ម ខ្ញុំដឹងថាអ្នកមិនសុំកាតក្រេឌីតថ្មីទេ នៅពេលដែលអ្នកមិនទាន់បានប្រើកាតនៅក្នុងហោប៉ៅរបស់អ្នកនៅឡើយនោះ។ យើងត្រូវតែប្រឈមមុខនឹងវិបត្តិមនុស្សធម៌របស់យើងផងដែរ។ ភាពគ្មានផ្ទះសម្បែង លទ្ធផលនៅសាលាធ្លាក់ចុះ និងវិបត្តិសុខភាពផ្លូវចិត្តរបស់យើង គឺជារោគសញ្ញាទាំងអស់នៃការិយាធិបតេយ្យដែលបរាជ័យដដែល។ យូរណាស់មកហើយ ដែលយើងបានប្រើពន្ធនាគារជាកន្លែងទុកដាក់អ្នកជំងឺផ្លូវចិត្ត ខណៈពេលដែលយើងអនុញ្ញាតឱ្យផ្លូវថ្នល់របស់យើងក្លាយជាទីបោះជំរំ។ ខ្ញុំនឹងបង្វែរធនធានចេញពីការបំប៉ោង ទៅជាការព្យាបាល សហគមន៍ ដែលផ្តោតលើការត្រឡប់មកសភាពដើមវិញជំនួសឱ្យវដ្តនៃការចេញចូលពន្ធនាគារ។ ជាចុងក្រោយ យើងត្រូវស្តារ និងកែប្រែច្បាប់ឧត្តមសិក្សា Donahoe ឡើងវិញ។ ខ្ញុំនឹងប្រគល់សាកលវិទ្យាល័យសាធារណៈរបស់យើងទៅជាគំរូដែលអាចចូលប្រើប្រាស់បានដោយផ្អែកលើគុណសម្បត្តិ ដែលធ្លាប់បានធ្វើឱ្យរដ្ឋ California ក្លាយជាអ្នកគួរឱ្យច្រណែនរបស់ពិភពលោក។ តាមរយៈការធ្វើសវនកម្ម "គម្រោងខ្មោច" និងបង្វែរទិសដៅការសន្សំការប្រាក់ យើងអាចផ្តល់មូលនិធិដល់សាលារៀន និងគ្លីនិករបស់យើងដោយមិនចាំបាច់ដំឡើងពន្ធរបស់អ្នក។ ខ្ញុំជាអ្នកបង្រួបបង្រួមឯករាជ្យមកពី Inland Empire មិនមែនជាអ្នកនយោបាយអាជីពទេ។ ខ្ញុំសុំការបោះឆ្នោតរបស់អ្នកដោយក្តីគោរពដើម្បីជួសជុលរដ្ឋ California។

1941 California Ave., P.O. Box 77217, Corona, CA 92887 | ទូរស័ព្ទ: (909) 757-4615



### Elaine Culotti | គ្មានចំណូលចិត្តគណបក្ស

ប្រជាជន California ធុញទ្រាន់នឹងនយោបាយ។ ពួកគេចង់បានដំណោះស្រាយ។ ខ្ញុំកំពុងឈរឈ្មោះជាអភិបាលដើម្បីបង្រួបបង្រួមរដ្ឋ California នៅជុំវិញលទ្ធផលជាក់ស្តែង និងស្តារឡើងវិញនូវក្តីសុបិន្តរដ្ឋ California ។ ខ្ញុំជឿជាក់លើការសន្យាដ៏សាមញ្ញមួយ៖ ប្រសិនបើអ្នកចង់បានការងារនៅរដ្ឋ California អ្នកគួរតែអាចស្វែងរកការងារនៅទីនេះ។ រដ្ឋរបស់យើងត្រូវបានកសាងឡើងដោយសហគ្រិន អាជីវកម្មខ្នាតតូច កសិករ អ្នកច្នៃប្រឌិត និងកម្មករដែលមានឆន្ទៈក្នុងការទទួលយកហានិភ័យ និងខិតខំធ្វើការ។ តួនាទីរបស់រដ្ឋាភិបាលគឺដើម្បីបង្កើតលក្ខខណ្ឌសម្រាប់ឱកាស មិនមែនឈរពាំងផ្លូវនោះទេ។ ចាប់តាំងពីឆ្នាំ 1991 ខ្ញុំបានបង្កើតអាជីវកម្ម និងបង្កើតការងារនៅរដ្ឋ California។ ខ្ញុំបានធ្វើដំណើរឆ្លងកាត់រដ្ឋរបស់យើង ជួបប្រជុំជាមួយចៅហ្វាយក្រុង និងអ្នកដឹកនាំក្នុងមូលដ្ឋានពីគណបក្សទាំងពីរ។ ពួកគេទាំងអស់គ្នាចង់បានមូលដ្ឋានគ្រឹះដូចគ្នា៖ ផ្លូវមានសុវត្ថិភាព សាលារៀនរឹងមាំ សេដ្ឋកិច្ចក្នុងស្រុកដែលរីកចម្រើន និងការទទួលខុសត្រូវចំពោះប្រាក់របស់អ្នកជាប់ពន្ធ។ រដ្ឋ California គួរតែជារដ្ឋនៃអនាគត មិនមែនជារដ្ឋមួយដែលគ្រួសារ និងនិយោជកមានអារម្មណ៍ថា ត្រូវបង្ខំចិត្តចាកចេញទេ។ ចំណូលពន្ធមិនមែនជាគំរូអាជីវកម្មទេ។ ការរីកចម្រើន ការច្នៃប្រឌិត និងការបង្កើតការងារទើបជាគំរូអាជីវកម្ម។ អាទិភាពរបស់ខ្ញុំគឺច្បាស់លាស់។ ការអភិវឌ្ឍន៍សេដ្ឋកិច្ចដែលសម្រួលបទប្បញ្ញត្តិ គាំទ្រអាជីវកម្មខ្នាតតូច ពង្រឹងការបណ្តុះបណ្តាលកម្លាំងពលកម្ម និងពង្រីកឱកាសនៅគ្រប់តំបន់។ សុខភាព និងសុវត្ថិភាពដែលផ្តល់មូលនិធិដល់ការព្យាបាលសុខភាពផ្លូវចិត្តដែលត្រូវបានបញ្ជាក់ ដំណោះស្រាយលំនៅឋានជាក់ស្តែង និងសុវត្ថិភាពសាធារណៈប្រកបដោយការទទួលខុសត្រូវ។ ផ្តល់អំណាចត្រឡប់ទៅប្រជាជនវិញដោយការស្តារការគ្រប់គ្រងក្នុងតំបន់ ការបញ្ចប់អាណត្តិដែលមិនមានមូលនិធិ ការលាតត្រដាងការក្លែងបន្លំ និងការធានានូវតម្លាភាពពេញលេញអំពីរបៀបដែលប្រាក់ពន្ធត្រូវបានចំណាយ។ រួមគ្នា យើងអាចបង្កើតឱកាសឡើងវិញ ហើយឆ្ពោះទៅមុខក្នុងនាមជា តែមួយ California។

2 Civic Center Dr., Unit 4338, San Rafael, CA 94913-5703
អ៊ីមែល: contact@culottiforcalifornia.com | www.culottiforcalifornia.com | Instagram: @elaineculotti

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



### Gretha Solórzano | សាធារណរដ្ឋ

ឈ្មោះរបស់ខ្ញុំគឺ Gretha Solórzano។ ខ្ញុំជាអ្នកវិទ្យាសាស្ត្រដែលបានទទួលការបណ្តុះបណ្តាលពី UC Berkeley ជាវិស្វករនុយក្លេអ៊ែរចូលនិវត្តន៍ និងជាបេក្ខជនសម្រាប់អភិបាលរដ្ឋ California។ ក្នុងនាមជាអ្នកនិយាយផ្លូវកណ្តាលដែលមានហេតុផល ខ្ញុំប្តេជ្ញាចិត្តក្នុងការផ្សារភ្ជាប់ការបែកបាក់នយោបាយ និងបង្រួបបង្រួមប្រជាជន California - អ្នកអភិរក្សនិយម, សេរីនិយម, និងអ្នកឯករាជ្យដូចគ្នា - ជុំវិញដំណោះស្រាយជាក់ស្តែងដែលដំណើរការ។ បេសកកម្មរបស់ខ្ញុំគឺសាមញ្ញ៖ *ធ្វើឱ្យរដ្ឋ California មានតម្លៃសមរម្យ និងមាននិរន្តរភាពឡើងវិញ*។ ខ្ញុំនឹងពង្រឹងសេដ្ឋកិច្ចរបស់យើងតាមរយៈការវិនិយោគជាយុទ្ធសាស្ត្រក្នុងវិស័យថាមពល និងហេដ្ឋារចនាសម្ព័ន្ធទឹកកម្រិតខ្ពស់ រួមទាំងការបង្វែរទឹកប្រាក់ចំនួន *$32.7 ពាន់លានដុល្លារ* ដែលបច្ចុប្បន្នយើងចំណាយលើប្រេងបរទេសឆ្ពោះទៅផលិតកម្មក្នុងស្រុកវិញ ដើម្បីកែលម្អសន្តិសុខថាមពល និងរក្សាការងារនៅទីនេះក្នុងស្រុក។ ខ្ញុំក៏នឹងដោះស្រាយការខ្វះខាតលំនៅឋានរបស់រដ្ឋ California ផងដែរ ហើយខ្ញុំនឹងផ្លាស់ប្តូរការធ្លាក់ចុះនៃប្រព័ន្ធអប់រំរបស់យើង។ ជាមួយនឹងជំនាញបច្ចេកទេសរបស់ខ្ញុំ វិន័យផ្នែកថវិកា និងការដឹកនាំដែលផ្តោតលើលទ្ធផល ខ្ញុំនឹងបង្កើតការងារ កាត់បន្ថយថ្លៃទឹកភ្លើង និងផ្តល់ការរីកចម្រើនរយៈពេលវែងសម្រាប់ប្រជាជន California ទាំងអស់។

ទូរស័ព្ទ: (949) 534-5402 | អ៊ីមែល: CAGovGrethaSolo@outlook.com
X: x.com/GrethaSolorzano | TikTok: TikTok.com/@CA.Gov.Gretha



### Christine R. Sarmiento | គ្មានចំណូលចិត្តគណបក្ស

ខ្ញុំកំពុងប្រជែងតំណែងជាអភិបាលរដ្ឋ California ដើម្បីផ្តល់នូវ*ភាពជា*អ្នកដឹកនាំប្រកបដោយសមត្ថភាព និងការទទួលខុសត្រូវ ផ្តោតលើលទ្ធផល។ ក្នុងនាមជាគិលានុបដ្ឋាយិកា និងជាអ្នកគ្រប់គ្រងប្រតិបត្តិការ ខ្ញុំបានធ្វើការនៅក្នុងបរិយាកាសដែលមាន*សម្ពាធខ្ពស់* ដែលកំហុសមាន*ផលវិបាកពិតប្រាកដ* ហើយ*ទំនួលខុសត្រូវគឺសំខាន់*។ ខ្ញុំក៏ជាម្តាយម្នាក់ដែលបានធ្វើការពេញម៉ោងពេលកំពុងរៀន មហាវិទ្យាល័យ ដូច្នេះខ្ញុំយល់ពីភាពតានតឹង ការលះបង់ និងទំនួលខុសត្រូវ*ដោយផ្ទាល់* ។ បញ្ហាប្រឈមរបស់រដ្ឋ California គឺ*ជាក់ស្តែង* មិនមែនអរូបីទេ។ *តម្លៃសមរម្យ សុវត្ថិភាពសាធារណៈ លទ្ធភាពទទួលបានការថែទាំសុខភាព ការអប់រំ និងភាពអាចទុកចិត្តបាននៃហេដ្ឋារចនាសម្ព័ន្ធ*ប៉ះពាល់ដល់គ្រួសារ*ជារៀងរាល់ថ្ងៃ*។ ប្រព័ន្ធមិនខូចទេ *គឺវាមានជំងឺ*។ ជាមួយនឹងជំហានត្រឹមត្រូវ យើងអាចធ្វើឱ្យវាកាន់តែប្រសើរឡើងជារៀងរាល់ថ្ងៃ ហើយយើងនឹងបានសុខ។ ខ្ញុំសុំឱ្យមានការពិចារណានិងការជឿទុកចិត្តរបស់អ្នកដើម្បីជួយជំរុញ California ឱ្យរីកចម្រើន។

3100 Big Dalton Ave., Ste. 170-336, Baldwin Park, CA 91706 | ទូរស័ព្ទ: (213) 444-6204
អ៊ីមែល: info@christineforgovernor.com | christineforgovernor.com | X: x.com/C_R_Sarmiento

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន
## អភិបាលរដ្ឋ



### Frederic C. Schultz | គ្មានចំណូលចិត្តគណបក្ស

សូមជ្រើសរើសខ្ញុំជាអភិបាលដើម្បីសង្គ្រោះសិទ្ធិ/ជីវិតរបស់យើង។ យើងកំពុងស្ថិតនៅក្នុងភាពអាសន្នៈ ខ្ញុំនឹងប្រកាសស្ថានភាពអាសន្នដើម្បីសង្គ្រោះយើង! ពួកសកម្មប្រយុទ្ធរបស់រដ្ឋាភិបាលសម្លាប់យើងជារៀងរាល់ថ្ងៃ សម្រាប់ "បទឧក្រិដ្ឋ" នៃការស្វែងរកសិទ្ធិជ្រកកោន ការធ្វើឯកសារអំពីការវាយប្រហារ ការបាតុកម្មប្រឆាំង។ California ចាប់ខ្លួន 800,000 នាក់ជារៀងរាល់ឆ្នាំ ដែលភាគច្រើនសម្រាប់ "ឧក្រិដ្ឋកម្ម" ដែលផ្ទុយពីរដ្ឋធម្មនុញ្ញដោយគ្មានជនរងគ្រោះ/ជាការព្រមព្រៀង យកធ្វើទាសករ 200,000 នាក់ជារៀងរាល់ថ្ងៃដោយមិនចាំបាច់ប្រាប់ចៅក្រមថាយើង*តែងតែ*អាចបោះឆ្នោត "មិនមានកំហុស" ។ ការហាមឃាត់/ច្បាប់គ្រប់គ្រង "គ្រឿងញៀន" បណ្ដាលឱ្យមានការខាតបង់ផ្នែកវេជ្ជសាស្ត្រ ឃាតកម្ម ភាពក្រីក្រនៅទូទាំងពិភពលោក ការធ្វើឱ្យមានជនភៀសខ្លួនរាប់លាននាក់ ការធ្វើទារុណកម្មមនុស្សឈឺរហូតដល់ស្លាប់។ ជនជាតិអាមេរិករាប់លាននាក់គ្មានផ្ទះសម្បែង ពាក់កណ្ដាលទុរគត។ យើងនឹងយកពន្ធ 5% ចំពោះទ្រព្យសម្បត្តិលើសពី $10,000,000 និងប្រាក់ចំណូលលើសពី $1,000,000 ដែលផ្ដល់ទិន្នផល $1,100,000,000,000 ប្រចាំឆ្នាំ សូម្បីតែត្រលប់ទៅឆ្នាំមុនៗ។ បង្កកតម្លៃផ្ទះជួល! គ្មានការបង្ខាំងមិនឱ្យចេញចូល ឬការចាក់វ៉ាក់សាំងបង្ខំទេៈ ជំនួសទៅវិញគឺអាហារពិតប្រាកដជាជម្រើស! ខ្ញុំគាំទ្រការជ្រើសរើសសាលារៀន និងប្រឆាំងនឹងការរើសអើងបញ្ច្រាស៖ ឱកាសស្មើគ្នាជំនួសវិញ។ យើងនឹងបង្កើនកងកម្លាំងការពាររដ្ឋ California ពី 900 ទៅ 2,000,000 នាក់ ម្នាក់ក្នុងមួយថ្នាក់រៀន បញ្ឈប់ការសម្លាប់ភាគច្រើន រួមទាំងដោយ ICE ទូទាំងប្រទេស ការពារច្បាប់អាជ្ញាសឹក បិទជំរំទាសករ/ការស្លាប់ លើកលែងទោសទាសករដែលគ្មានកំហុស! យើងនឹងអនុវត្តសិទ្ធិស្វ័យភាពរបស់រាងកាយទៅលើការរំលូតកូន ការសម្លាប់ខ្លួនដោយមានជំនួយ និងអាវុធ។ សិទ្ធិមនុស្សក្នុងការមានលំនៅឋាន (ផ្ទះ $10,000), ប្រាក់ឈ្នួលដែលអាចរស់បាន, ការងារ, ប្រាក់ចំណូល, ការអប់រំខ្ពស់/ជំនាញ, សេវាថែទាំសុខភាព (ទូទាំងប្រទេស), អាហារ (ទូទាំងពិភពលោក), ការថែទាំកុមារ, ការដឹកជញ្ជូនសាធារណៈដោយគ្មានរថភ្លើងល្បឿនលឿនដ៏គ្រោះថ្នាក់។ សេវាទឹកភ្លើង/ប្រេងឥន្ធនៈដោយឥតគិតថ្លៃ ប៉ុន្តែសន្សំបរិស្ថាន។ យើងនឹងហាមឃាត់ថ្នាំបាញ់សម្លាប់សត្វចង្រៃ កសិដ្ឋានរោងចក្រ យានយន្ត "ស្វ័យប្រវត្តិ" ។ គ្មានពន្ធលើការលក់ ឬពន្ធលើប្រាក់ចំណូលក្រោម $100,000! យើងនឹងពង្រឹងសិទ្ធិរបស់យើងចំពោះលទ្ធិប្រជាធិបតេយ្យ៖ ការបោះឆ្នោតស្មើគ្នា និងឱកាសក្នុងការបម្រើ (ការបោះឆ្នោតដែលផ្ដល់ហិរញ្ញប្បទានជាសាធារណៈ)។ សិទ្ធិឯកជនភាព៖ គ្មានការឃ្លាំមើលទ្រង់ទ្រាយធំ កាមេរ៉ាតាមផ្លូវ "Flock" ។ Carina Sanchez អភិបាលរង, Dan Kapelovitz អគ្គមេធាវី។ ដោះលែងប្រជាជន! #*Fred4CA.com*!

ទូរស័ព្ទ: (858) 888-0461 | អ៊ីមែល: Fred4CA.com@gmail.com | Instagram: Instagram.com/Fred4CA | X: X.com/FredericEsq



### Scott P Shields | ប្រជាធិបតេយ្យ

សូមចូលទៅកាន់ *ShieldsForGovernor.com*

12912 Brookhurst Street, Garden Grove, CA 92840 | ទូរស័ព្ទ: (650) 313-0727
អ៊ីមែល: info@votethecandidate.com | thecryptogovernor.com | shieldsforgovernor.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្ដីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្ដល់ជូនសេចក្ដីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្ដីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្ដីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



### Jon Henderson | គ្មានចំណូលចិត្តគណបក្ស

រួបរួមគ្នា យើងឈរ បែកបាក់គ្នា យើងដួលរលំ។ California កាលីហ្វ័រញ៉ា មិនដែលធ្លាប់មានការបែកបាក់គ្នាច្រើនដល់ថ្នាក់នេះនៅក្នុងនយោបាយរបស់យើងទេ ហើយវាធ្វើឱ្យយើងខាតបង់ពេលវេលា លុយកាក់ និងភាពជឿជាក់។ ខ្ញុំឈ្មោះ Jon Henderson ហើយខ្ញុំកំពុងប្រជែងតំណែងជាអភិបាលក្នុងនាមជាអ្នកឯករាជ្យ ពីព្រោះរដ្ឋ California ត្រូវការតុល្យភាព មិនមែនការបន្ទោសទេ។ រដ្ឋរបស់យើងមានភាពចម្រុះពេក ផ្អែកលើតំបន់ ពូជសាសន៍ ប្រាក់ចំណូល អាយុ និងមនោគមវិជ្ជា ក្នុងការដែលត្រូវបានគ្រប់គ្រងសម្រាប់តែមួយផ្នែក។ ខ្ញុំនឹងដឹកនាំសម្រាប់មនុស្សគ្រប់រូបដែលធ្វើការលំបាក ចិញ្ចឹម គ្រួសារ បើកអាជីវកម្ម បម្រើសហគមន៍ ឬគ្រាន់តែចង់បានឱកាស ត្រឹមត្រូវ។ ខ្ញុំជឿលើច្បាប់មាសសម្រាប់រដ្ឋមាស។ ជាផលិតផលដ៏មានមោទនភាពនៃសាលារដ្ឋ California ខ្ញុំបានបង្កើតក្រុមហ៊ុនជាច្រើនពីបាតដៃទទេ។ ខ្ញុំដឹងពីរបៀបកំណត់គោលដៅ វាស់វែងលទ្ធផល និងផ្តល់។ រដ្ឋាភិបាលគួរតែប្រតិបត្តិការតាមស្តង់ដារដែលផ្តល់ការទុកចិត្ត ដោយដាក់ផលប្រយោជន៍សាធារណៈជាមុន។ ខ្ញុំនឹងដាក់ទ្រព្យសម្បត្តិរបស់ខ្ញុំនៅក្នុងប្រាក់សន្សំគ្រប់គ្រងដោយភាគីទីបី ហើយខ្ញុំនឹងជំរុញឱ្យមានប្រាក់សន្សំនេះសម្រាប់អ្នកតាក់តែងច្បាប់នៅរដ្ឋ California។ អំពើពុករលួយនិងទំនាស់ផលប្រយោជន៍បានមានការលំបាកក្នុងការគ្រប់គ្រង។ ប្រសិនបើយើងលុបបំបាត់ការលើកទឹកចិត្តការរកប្រាក់ចំណេញពីការិយាល័យសាធារណៈ យើងអាចកសាងទំនុកចិត្តឡើងវិញតាមជួរគណបក្ស។ សៀវភៅរបស់ខ្ញុំ California 2.0៖ ចក្ខុវិស័យឯករាជ្យសម្រាប់អនាគតដ៏បរិបូរណ៍របស់រដ្ឋ California ផ្តល់នូវផែនការជាមួយនឹងដំណោះស្រាយចំពោះបញ្ហាប្រឈមដ៏ធំបំផុតរបស់យើង ពីលំនៅឋាននិងភ្លើងឆេះព្រៃ ដោយប្រើបច្ចេកវិទ្យាច្នៃប្រឌិតដែលមានស្រាប់។ ខ្ញុំកំពុងប្រជែងតំណែងសម្រាប់ប្រជាជនភាគច្រើននៃរដ្ឋ California នៅកណ្តាល ដែលធុញទ្រាន់នឹងពួកជ្រុលនិយម។ ប្រសិនបើអ្នកជឿថារដ្ឋរបស់យើងសមនឹងទទួលបានការគិតឯករាជ្យ តុល្យភាព និងការទទួលខុសត្រូវ ជាជាងភាពស្មោះត្រង់ជាមួយបក្ស ខ្ញុំពិតជាមានកិត្តិយសក្នុងការទទួលបានការបោះឆ្នោតរបស់អ្នក។

1802 Tice Valley Blvd., Walnut Creek, CA 94595 | ទូរស័ព្ទ: (925) 592-4501
អ៊ីមែល: jhenderson@echo45advisors.com | Instagram: www.instagram.com/jonhendersonca | X: x.com/JonHendersonCA



### Rafael M. Hernandez | សាធារណរដ្ឋ

ចំពោះខ្ញុំ៖ ប្រជាជន California គឺជាអាទិភាពទីមួយ។ គោលដៅរបស់ខ្ញុំគឺ: 1. កាត់បន្ថយថ្លៃចំណាយលើការរស់នៅ។ 2. បង្កើតការងារដែលមានប្រាក់ខែល្អបន្ថែមទៀត។ 3. ដោះស្រាយវិបត្តិគ្មានផ្ទះសម្បែង។ 4. សាងសង់ផ្ទះដែលមានតម្លៃសមរម្យ។

ទូរស័ព្ទ: (805) 732-1350 | អ៊ីមែល: rafagarecords2009@hotmail.com
Instagram: Rafael4CAGovernor6-2-26 | TikTok: rafaelcagov2026

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



**Lewis Herms** | គ្មានចំណូលចិត្តគណបក្ស

ការក្លាយជាអភិបាលគួរតែជាការងារដ៏លំបាក ពីព្រោះប្រជាជន California សមនឹងអ្នកដឹកនាំដែលបម្រើ មិនមែនគ្រប់គ្រងទេ។ ក្នុងនាមជា "*We The People Guy*" ខ្ញុំជឿថា ការទទួលខុសត្រូវនិងសេរីភាពត្រូវតែជំនួសនយោបាយដូចធម្មតា។ អ្នកនយោបាយអាជីពបានមានឱកាសរបស់ពួកគេហើយ; វាដល់ពេលដែលត្រូវស្តារសុភវិនិច្ឆ័យ និងភាពជាអ្នកដឹកនាំដែលធ្វើការសម្រាប់ប្រជាជន California។

803 Camarillo Springs Rd., 1st Floor, Camarillo, CA 93012 | ទូរស័ព្ទ: (805) 774-1660
អ៊ីមែល: info@hermsforcali.com | X: @wowlewi | Facebook: @ScrewBigGovernment



**Max Fomin** | គ្មានចំណូលចិត្តគណបក្ស

នឹងបដិសេធការគិតពន្ធលើចំនួនម៉ែល បំបាត់ភាពគ្មានផ្ទះសម្បែង បំបាត់ភាពគ្មានការងារធ្វើ បង្ក្រាបបទល្មើសអាវុធនុយក្លេអ៊ែរ ផ្តល់លំនៅឋានដល់អ្នកគ្មានទីលំនៅ កាត់ទោសអំពើពុករលួយ បង្កើតប្រាក់ ចូលចិត្ត$ខ្ញុំ ដាក់ទឹកកក។

1221 W. 3rd Street, Unit 438, Los Angeles, CA 90017 | ទូរស័ព្ទ: (424) 944-7511
អ៊ីមែល: max4mkt@gmail.com | Instagram: @newmericans | www.newmericans.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



### Serge Fiankan | គ្មានចំណូលចិត្តគណបក្ស

បេសកកម្មរបស់ខ្ញុំគឺដើម្បីនាំប្រជាជន California មកជុំគ្នា នៅទូទាំងតំបន់ សាវតា និងបន្ទាត់នយោបាយ ដើម្បីកសាងរដ្ឋដែលធ្វើការសម្រាប់ប្រជាជនដែលរស់នៅទីនេះ។ ខ្ញុំកំពុងប្រជែងដើម្បីផ្តល់ការដឹកនាំជាក់ស្តែង បើកចំហ ទទួលខុសត្រូវ ដែលដាក់ដំណោះស្រាយមុនមនោគមវិជ្ជា និងមនុស្សមុននយោបាយ។ នោះមានន័យថាការស្តារឡើងវិញនូវទំនុកចិត្តលើរដ្ឋាភិបាល ប្រព័ន្ធកំណែទម្រង់ដែលលែងបម្រើយើង និងការពង្រឹងសហគមន៍ ពីទីក្រុងជនបទដល់ទីក្រុងធំៗ ដូច្នេះពលរដ្ឋ California គ្រប់រូបមានឱកាស ជីវិតសមរម្យ និងកន្លែងសុវត្ថិភាពដើម្បីហៅថាផ្ទះ។

P.O. Box 2451, Saratoga, CA 95070 | ទូរស័ព្ទ: (408) 898-0901
អ៊ីមែល: info@sf4gov.com | www.sf4gov.com | YouTube: www.youtube.com/@SF4GOV



### Amanda Martin | គ្មានចំណូលចិត្តគណបក្ស

ម្តាយ អ្នកសាងសង់ សហគ្រិនដែលដោះស្រាយបញ្ហារដ្ឋ California!

អ៊ីមែល: info@AmandaForCalifornia.org | Instagram: www.instagram.com/amandaforcalifornia/ | X: x.com/AmandaForCali

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



### Daniel Mercuri | គ្មានចំណូលចិត្តគណបក្ស

ភាពជាអភិបាលរបស់ខ្ញុំនឹង មិនមែន ជាអ្នកដឹកនាំទេ តែជាអ្នកបម្រើប្រជាជន California ទាំងអស់។ ខ្ញុំជាអតីតទាហានជើងទឹកអាមេរិក និងមានដើមកំណើតនៅរដ្ឋ California ប្រដាប់ដោយចំណេះដឹង និងការយល់ពេញលេញអំពីរដ្ឋធម្មនុញ្ញរបស់យើងដើម្បី៖ ស៊ើបអង្កេត ចោទប្រកាន់ កាត់ទោស និង *ដាក់គុក*ការិយាធិបតេយ្យពុករលួយ ការពារកុមារពីជនរំលោភបំពាន និងអ្នកជួញដូរផ្លូវភេទកុមារ រារាំងអ្នកបញ្ចុះបញ្ចូលមនោគមវិជ្ជាតាមសាលា កែលម្អការអប់រំសិស្ស ពង្រឹងសិទ្ធិមាតាបិតា បញ្ចប់ការដាក់ទោសឧក្រិដ្ឋលើជនរងគ្រោះ និងការធ្វើឱ្យជនឧក្រិដ្ឋក្លាយជាជនរងគ្រោះ ផ្ដល់អាទិភាពដល់ពលរដ្ឋស្របច្បាប់មុនអ្នកខុសច្បាប់ ផាកពិន័យលើការលាងលុយកខ្វក់របស់រដ្ឋាភិបាល បញ្ចប់ពន្ធរដ្ឋលើលុយធីប ការចូលនិវត្តន៍ ទ្រព្យសម្បត្តិ និងប្រាក់ចំណូល ខណៈពេលដែលធ្វើឱ្យអាជីវកម្មខ្នាតតូចមានភាពរស់រវើកឡើងវិញ និងរារាំងការគ្រប់គ្រងហួសកម្រិត។ យើងនឹងក្លាយជាឯករាជ្យផ្នែកថាមពល រឹតបន្តឹង CEQA និងផ្ដល់សេរីភាពផ្នែកវេជ្ជសាស្ត្រ។ ឋានៈរបស់ប្រជាជននឹងនៅពីលើរដ្ឋាភិបាលគ្រប់ពេលវេលានៅក្រោមរដ្ឋបាលរបស់ខ្ញុំ។ នេះជាឱកាសតែមួយរបស់អ្នកក្នុងការបង្កើតភាពខុសគ្នាដោយការបោះឆ្នោតនៅខាងក្រៅការជ្រើសរើសអ្នកដឹកនាំដដែលៗ។ ខ្ញុំនឹងមិនធ្វើឱ្យអ្នកបរាជ័យទេ!
*www.danielforcalgovernor.com*

2828 Cochran St. #139, Simi Valley, CA 93065 | ទូរស័ព្ទ: (805) 390-9309
អ៊ីមែល: daniel@danielforcalgovernor.com | X: @daniel4calgov26 | Instagram: daniel4calgovernor



### Naomi Bar-Lev | គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

ប្រព័ន្ធបក្សបានធ្វើឱ្យយើងបរាជ័យយ៉ាងពិតប្រាកដ។ ការរាយការណ៍មិនពេញលេញរបស់ប្រព័ន្ធផ្សព្វផ្សាយ គឺមិនអាចអត់ទោសឱ្យបាន។ ប្រវត្តិរបស់ខ្ញុំរួមមានបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពី UCLA, ឈ្មួញកណ្ដាលអចលនៈទ្រព្យរយៈពេលជាង 20 ឆ្នាំ, បទពិសោធន៍ផ្នែកសំណង់, អនុប្រធាន, ការគ្រប់គ្រងមន្ត្រី និងភ្នាក់ងារប្រាក់កម្ចីរាប់រយនាក់ រហូតដល់អាជីវកម្ម Airbnb ដ៏រឹងមាំ។ ការកែលម្អត្រូវបានធ្វើឡើងចំពោះទ្រព្យសម្បត្តិរបស់ខ្ញុំដើម្បីបង្កើនប្រាក់ចំណូលទ្វេដងនៃអាជីវកម្ម ក៏ជាឆ្នាំដែលការបំផ្លិចបំផ្លាញ និងចារកម្មប្រឆាំងនឹងខ្ញុំបានចាប់ផ្ដើម។ ការរស់រានមានជីវិតពីការវាយប្រហារជាបន្តបន្ទាប់ បានបំភ្លឺខ្ញុំ! ខ្ញុំបានសរសេរសៀវភៅស្ដីពី របបផ្តាច់ការដែលបានគ្របដណ្តប់ អំពើ ពុករលួយដ៏កក្រើករបស់វា ការប្រើប្រាស់ប៉ូលិសរបស់វា តុលាការ បច្ចេកវិទ្យា ក្រុមហ៊ុននិយម (*https://www.linkedin.com/in/naomi-bar-lev-56b894346*)។ ភាពជាដៃគូនៃក្រុមហ៊ុនបច្ចេកវិទ្យាធំៗឥឡូវនេះកំពុងបំពានសិទ្ធិពលរដ្ឋ និងអ្នកប្រើប្រាស់ ព្រមទាំងច្បាប់ប្រឆាំងការជឿទុកចិត្តផងដែរ។ នៅកណ្ដាលគឺជាមជ្ឈមណ្ឌលរួមបញ្ចូលគ្នា មជ្ឈមណ្ឌលព័ត៌មាន និងបច្ចេកវិទ្យាថ្នាក់យោធា—មជ្ឈមណ្ឌលចំនួន 6 នៅទូទាំងរដ្ឋដែលគ្រប់គ្រងដោយ "ប៉ូលីសក្នុងតំបន់" ។ ពួកគេបានភ្ជាប់ឧបករណ៍ទាំងអស់ ចារកម្មអាចធ្វើទៅបានប្រឆាំងនឹងបុគ្គល និងអាជីវកម្ម ដែលបានផ្លាស់ប្តូរតុលាការ។ ខ្ញុំមិនមែនជាមិត្តរបស់អ្នកនយោបាយទេ។ ក្នុងនាមជាអភិបាល មជ្ឈមណ្ឌលរួមបញ្ចូលគ្នានឹងសម្រាប់ការស៊ើបអង្កេតដ៏តឹងរ៉ឹងអំពីការក្លែងបន្លំ ចោរកម្ម និងការខ្ជះខ្ជាយ ដែលជាប្រភពចំណូលដែលមានសុខភាពល្អជាមួយនឹងថវិកាតិច។ ប៉ូលីសនឹងត្រឡប់ទៅសង្កាត់វិញ ប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម ទទួលយករបាយការណ៍ស្មើៗគ្នាក្នុងចំណោមប្រជាពលរដ្ឋ ដោយប្រើមូលដ្ឋានទិន្នន័យដែលស្របតាមរដ្ឋធម្មនុញ្ញ។ ទូរសព្ទ និងឧបករណ៍នឹងត្រូវបានប្រមូលមកវិញ សេវាកម្មពីមុនត្រូវបានបង្វិលសងវិញ ទូរសព្ទប្រព័ន្ធរោទិ៍ វ៉ាយហ្វាយ. . . "ភាពជាដៃគូ" និងកិច្ចព្រមព្រៀងមិនបង្ហាញព័ត៌មាននៅក្នុងរដ្ឋាភិបាលនឹងត្រូវលុបចោល។ ការជ្រើសរើសបុគ្គលិកច្រើនហួសប្រមាណដើម្បីបំពេញមុខតំណែងភ្នាក់ងារអ្នកប្រើប្រាស់និងសិទ្ធិស៊ីវិល មេដឹកនាំក្នុងតំបន់និងរដ្ឋ ត្រូវបានជំនួសដោយមន្ត្រីសាធារណៈ។ គ្មានពន្ធលើការលក់ ប្រាក់ចំណូល ឬអចលនទ្រព្យ។ ការបង់ថ្លៃចតរថយន្ត និងការបង់ថ្លៃអនុញ្ញាតនឹងត្រូវបានលុបចោល។

2244 2nd Ave. #39, San Diego, CA 92101 | ទូរស័ព្ទ: (619) 317-3634 | អ៊ីមែល: lawfulwon@gmail.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្ដីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្ដល់ជូនសេចក្ដីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្ដីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្ដីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ



### Chad Bianco | សាធារណរដ្ឋ

ឈ្មោះខ្ញុំគឺ Chad Bianco។ ខ្ញុំជាប្តី ជាឪពុក និងជាអធិការនៅខោនធី Riverside ។ ខ្ញុំមិនបានងើបឡើងតាមរយៈនយោបាយទេ។ ខ្ញុំបានងើបឡើងតាមរយៈសេវាសាធារណៈ។ ក្នុងនាមជាអធិការ ខ្ញុំដឹកនាំភ្នាក់ងារអនុវត្តច្បាប់ដ៏ធំជាងគេមួយនៅក្នុងរដ្ឋ California។ យើងបានកាត់បន្ថយឧក្រិដ្ឋកម្មហិង្សា ក្រោកឈរឡើងដើម្បីជនរងគ្រោះ និងគាំទ្របុរសនិងស្ត្រីដែលការពារសហគមន៍របស់យើង។ ខ្ញុំបានធ្វើការសម្រេចចិត្តលំបាកៗក្រោមសម្ពាធ ក្នុងស្ថានភាពដែលមានផលវិបាកពិតប្រាកដ។ ភាពជាអ្នកដឹកនាំមិនមែននិយាយអំពីពាក្យស្លោកទេ។ នៅពេលដែលសុភវិនិច្ឆ័យបរាជ័យ មនុស្សធម្មតាទទួលរងផលវិបាក។ California កំពុងស្ថិតនៅចំណុចរបត់ដ៏សំខាន់មួយ។ គ្រួសារជាច្រើនកំពុងតស៊ូលំបាកគ្រាន់តែដើម្បីរស់រាន។ ម្តាយនិងឪពុកធ្វើការច្រើនម៉ោងជាងមុនហើយនៅតែទប់ទល់នឹងចំណាយបាន។ ការងារកំពុងចាកចេញ ជំរុញឱ្យកូនៗរបស់យើងទៅកន្លែងផ្សេងដើម្បីមានឱកាស។ ការទិញផ្ទះមានអារម្មណ៍ថា មិនអាចធ្វើបានទេ។ សាំង ម្ហូបអាហារ និងទឹកភ្លើងមានតម្លៃខ្ពស់ជាងមុនជារៀងរាល់ខែ។ មនុស្សកំពុងតែធ្វើអ្វីគ្រប់យ៉ាងយ៉ាងត្រឹមត្រូវ ហើយនៅតែត្រូវមានគំនាប។ ក្នុងនាមជាអភិបាលរដ្ឋ ខ្ញុំនឹងនាំការទទួលខុសត្រូវ និងសុភវិនិច្ឆ័យ ត្រឡប់ទៅរដ្ឋាភិបាលវិញ។ ខ្ញុំនឹងកាត់បន្ថយការិយាធិបតេយ្យដែលរារាំងគ្រួសារមិនឱ្យមានការកសាងឡើងវិញបន្ទាប់ពីភ្លើងឆេះព្រៃ។ ខ្ញុំនឹងទាមទារលទ្ធផលពិតប្រាកដសម្រាប់រាប់ពាន់លានដែលបានចំណាយលើភាពគ្មានផ្ទះសម្បែង ហើយបញ្ចប់វដ្តនៃការចំណាយដោយគ្មានការទទួលខុសត្រូវ។ យើងប្រហែលជាមិនយល់ស្របលើអ្វីគ្រប់យ៉ាងនោះទេ ប៉ុន្តែយើងទាំងអស់គ្នាចង់បានមូលដ្ឋានដូចគ្នា៖ សង្កាត់ដែលមានសុវត្ថិភាព ឱកាសសម្រាប់កូនៗរបស់យើង និងឱកាសស្មើគ្នាដើម្បីជោគជ័យ។ ក្នុងនាមជាស្វាមី ឪពុក និងជាអធិការ ខ្ញុំដឹងថាទំនួលខុសត្រូវមានន័យយ៉ាងម៉េច។ ខ្ញុំដឹងថាភាពជាអ្នកដឹកនាំគឺជាអ្វី។ ខ្ញុំធ្លាប់បានឃើញអ្វីដែលល្អបំផុត និងអ្វីដែលអាក្រក់បំផុត ហើយខ្ញុំដឹងថាយើងអាចធ្វើបានល្អជាងនេះ។ ខ្ញុំសុំសំឡេងគាំទ្ររបស់អ្នក។

3649 Mission Inn Ave., Floor 2, Riverside, CA 92501 | ទូរស័ព្ទ: (951) 782-7886
Instagram: @sheriffbianco | Facebook: Sheriff Chad Bianco



### Derek Grasty | ប្រជាធិបតេយ្យ

ខ្ញុំមកពីសហគមន៍វណ្ណៈកម្មករ។ ខ្ញុំជឿថាមនុស្សគ្រប់រូបគួរតែមានគុណភាពជីវិតល្អ។ នោះមានន័យថាលំនៅឋានតម្លៃសមរម្យ សហគមន៍ដែលមានសុវត្ថិភាព និងការអប់រំប្រកបដោយគុណភាព។ បទពិសោធន៍ជីវិតរបស់ខ្ញុំបានបង្រៀនខ្ញុំថា អ្វីក៏ដោយគឺអាចទៅរួច។ ការងាររបស់ខ្ញុំនៅទូទាំងរដ្ឋ California ជាគ្រូបង្រៀន នាយកសាលា និងអ្នកបម្រើសាធារណៈដែលគាំទ្រសហគមន៍ចម្រុះ បានរៀបចំខ្ញុំដើម្បីដោះស្រាយបញ្ហាទូទាំងរដ្ឋ។ រួមគ្នា យើងនឹងទប់ស្កាត់អ្នកចាប់ជំរិត (ICE) ចេញពីផ្លូវរបស់យើង ធ្វើឱ្យផ្ទះមានតម្លៃសមរម្យសម្រាប់គ្រួសារធ្វើការ អ្នកសង្គ្រោះបឋម គ្រូបង្រៀន អ្នកពន្លត់អគ្គីភ័យ និងគិលានុបដ្ឋាយិកា។ ការអប់រំនឹងត្រូវបានគាំទ្រជាមួយមត្តេយ្យសិក្សា អ្នកឯកទេសខាងការអាន និងអ្នកប្រឹក្សាសុខភាពផ្លូវចិត្ត ដើម្បីជួយសិស្សរបស់យើងឱ្យជោគជ័យ។ ចូរយើងធ្វើអោយរដ្ឋ California ជារដ្ឋមាសពិតប្រាកដ។ *www.GrastyforGovernor.com*

2231 Will Wool Road, San Jose, CA 95112
អ៊ីមែល: GrastyforGovernor@gmail.com | www.GrastyforGovernor.com | Facebook: Grasty for Governor

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរដ្ឋ

***ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួនរបស់ពួកគេ ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។***

*គ្មានរូបថតបានដាក់ជូនមកទេ*

### Don J. Grundmann | គ្មានចំណូលចិត្តគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

Kirk ត្រូវបានសម្លាប់ដោយគ្រាប់បែកប្រហោងក្នុងដែលអ៊ីស្រាអែលបានប្រើ។ រដ្ឋាភិបាលដឹង។ YouTube—ហេតុអ្វីបានជា Kirk ត្រូវស្លាប់ (Why Kirk had to die)។ អ៊ីស្រាអែលបានសម្លាប់នាវិក សេរីភាព ។ “សិស្សសិល្បៈ” របស់អ៊ីស្រាអែលបានភ្ជាប់ខ្សែភ្លើងនៅអគារភ្លោះ Twin Towers សម្រាប់ថ្ងៃទី 9/11។ ការបំផ្លិចបំផ្លាញដែលត្រូវបានគ្រប់គ្រង។ យន្តហោះមិនបានបំផ្លាញអគារភ្លោះទេ។ អ៊ីស្រាអែលបានធ្វើ។ 3,000 នាក់ត្រូវបានសម្លាប់ដើម្បីបង្កើត “កំពង់ផែគុជ” ថ្មីដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃសង្គ្រាមប្រយុទ្ធសម្រាប់អ៊ីស្រាអែល។ “ជនជាតិអ៊ីស្រាអែលដែលរាំអបអរសាទរ” (ភ្នាក់ងារ Mossad) បង្ហាញពីចំណេះដឹងនៃការវាយប្រហារ។ រដ្ឋាភិបាលដឹង។ អ៊ីស្រាអែល (សត្រូវដ៏ធំបំផុតរបស់យើង) មិនមែនអ៊ីរ៉ង់ នឹងដាក់វ៉ាលីនុយក្លេអ៊ែរអាមេរិកតាមរយៈ “ជម្រើស Samson” ដែលជាការវាយប្រហារទង់ជាតិក្លែងក្លាយដើម្បីស្ដីបន្ទោសលើអ៊ីរ៉ង់/រុស្ស៊ី និងបញ្ចប់ប្រជាជាតិរបស់យើងជាអចិន្ត្រៃយ៍។ អ៊ីស្រាអែល ដែលជាភេរវករពិតប្រាកដ បានបង្កើតនិងផ្តល់មូលនិធិដល់ក្រុមហាម៉ាស តាមរយៈប្រទេសកាតា។ ឧក្រិដ្ឋកម្មសង្គ្រាមរាប់មិនអស់ដោយសារ Israel/Netanyahu ។ គ្មានការឧបត្ថម្ភថវិកាបន្ថែមទៀតសម្រាប់អ៊ីស្រាអែលទេ។ ពួកគេហៅជនជាតិប៉ាឡេស្ទីន និង គ្រិស្តបរិស័ទ និង អាមេរិកថា “អាម៉ាលេក” ដែលជាសត្រូវរបស់ពួកគេជារៀងរហូត។ យើងជា “goyim” (អន់ជាងសត្វមនុស្ស/សត្វគោ) ដែលពួកគេនឹងយកធ្វើជាទាសករ។ យើងជាមនុស្សឆោតល្ងង់។ អ៊ីស្រាអែលគ្រប់គ្រងសាធារណរដ្ឋដែលត្រូវបានដណ្ដើមយករបស់យើង។ Talmud —ព្រះគម្ពីររបស់ពួកគេ— និយាយថាព្រះគ្រីស្ទដែលកំពុងពុះកញ្ជ្រោលនៅក្នុងប្រទេសអ៊ីស្រាអែលបានអនុញ្ញាត / រៀបចំផែនការ / ជំរុញការវាយប្រហាររបស់ហាម៉ាស (ពួកគេបានសម្លាប់ប្រជាជនរបស់ពួកគេ) ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃអំពើប្រល័យពូជសាសន៍និងលួចរាប់ពាន់លានដុល្លារពីសិទ្ធិប្រេង / ឧស្ម័ននៅហ្គាហ្សា។ Christian Zionism = ថ្នាំពុលព្រលឹង។ “តម្លៃ ជូឌីអូ-គ្រីស្ទាន” របស់ Talmudic មិនមានទេ។ . . . *DestroyTheZOG.org* ។ គណបក្សរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដែលជាសាខារបស់រដ្ឋ គណបក្សជាតិនិយមគ្រីស្ទាន។ *CNParty.org*. កំពុងបង្កើតឡើង។ 28*Fight-the-Power.org*. *CPofCA.org*. *StopNumber24.org*. ធ្វើជាតូបនីយកម្ម FED បោះពុម្ពដោយឥតការប្រាក់ រូបិយបណ្ណសហរដ្ឋអាមេរិក។ សាលាច្បាប់សេរីភាព $30 ម៉ឺន។ *BlackGenocide.org*. Planned Parenthood បានសម្លាប់ជនជាតិស្បែកខ្មៅចំនួន 20 លាននាក់ = “ជំនឿថាជនស្បែកសខ្ពង់ខ្ពស់ជាងជាតិដទៃ” ពិតប្រាកដ។ *HenryMakow.com*. *NationalStraightPrideCoalition.org*. *Gtvflyers.com*

2010 El Camino Real #351, CA | ទូរសព្ទ: (510) 895-6789 | ទូរស័ព្ទ: STOPtheIRS@hotmail.com



### Ramsey Robinson | សន្តិភាពនិងសេរីភាព

*ខ្ញុំកំពុងតស៊ូដើម្បីរដ្ឋ California ដើម្បីប្រជាជន មិនមែនមហាសេដ្ឋីទេ។* មហាសេដ្ឋី 194 នាក់នៅរដ្ឋ California ស្តុកទុកទ្រព្យសម្បត្តិច្រើនជាងយើង 27 លាននាក់។ នោះមិនមែនជាឧបទ្ទវហេតុទេ—វាជាប្រព័ន្ធដែលលួចបន្លំ។ យើងធ្វើឱ្យរដ្ឋ California ក្លាយជាអ្នកមាន ប៉ុន្តែមិនមានលទ្ធភាពសម្រាប់ថ្លៃផ្ទះ ឱសថ ឬសាលារៀនសមរម្យសម្រាប់កូនៗរបស់យើងទេ ដោយសារមហាសេដ្ឋីដកយកទ្រព្យសម្បត្តិដែលយើងបង្កើត។ យុទ្ធនាការសង្គមនិយមរបស់យើងទាមទារឱ្យមានលំនៅឋានដែលមានការធានាការបង់ត្រឹម 20% នៃប្រាក់ចំណូល ការថែទាំសុខភាពដោយឥតគិតថ្លៃ ការថែទាំកុមារដោយឥតគិតថ្លៃ និងការងារសហជីពយ៉ាងហោចណាស់ $30 ក្នុងមួយម៉ោងជាមួយនឹងប្រាក់សោធននិវត្តន៍សមរម្យដែលមានការធានា។ បញ្ឈប់ការនិរទេស លុបបំបាត់ ICE! ខ្ញុំប្រយុទ្ធដើម្បីសង្គមនិយម—ជាប្រព័ន្ធមួយដែលពួកយើងកម្មករមានអំណាចនយោបាយ និងសេដ្ឋកិច្ចដើម្បីបំពេញតម្រូវការរបស់យើង។ យើងរួមគ្នាបញ្ចប់ការគ្រប់គ្រងរបស់មហាសេដ្ឋីម្ដង និងសម្រាប់ទាំងអស់គ្នា។ បោះឆ្នោតសង្គមនិយម! បោះឆ្នោត *leftunityslate.org*។ ចុះឈ្មោះគណបក្សសន្តិភាព និងសេរីភាព។

ទូរស័ព្ទ: (510) 560-3514 | អ៊ីមែល:: info@ramsey4gov.com | Instagram: @ramsey4gov | TikTok: @ramsey4gov

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## អភិបាលរដ្ឋ



### Satish Rao | ប្រជាធិបតេយ្យ

ប្រកបដោយសមត្ថភាព ប្រសិទ្ធិភាព និងមនុស្សធម៌។ នោះគឺជាការសាកល្បង។ គោលនយោបាយទាំងអស់ជួយអ្នកខ្លះ និងបំផ្លាញអ្នកដទៃ ដូច្នេះការពិភាក្សាគឺចាំបាច់ និងពិបាក។ ជាញឹកញាប់ កុលសម្ព័ន្ធ អំណាច និងការលើកទឹកចិត្តតិចតួច ជាអ្នកសម្រេចលទ្ធផល។ ការអប់រំធ្វើអោយវាមានភាពងាយស្រួល។ California បានធ្វើឱ្យបរាជ័យសិស្សដែលងាយរងគ្រោះក្នុងកិច្ចការមូលដ្ឋានមួយៈ ការរៀនអាន។ ទន្ទឹមនឹងនេះ កន្លែងដែលយើងត្រូវបានបង្រៀនឱ្យបំភ្លេចចោលគឺធ្វើបានប្រសើរជាងមុន។ អ្នកមានទេពកោសល្យដ៏អស្ចារ្យ? ពាក្យត្រូវបានបង្កើតឡើងដោយអក្សរ—ជាមូលដ្ឋានគ្រឹះ មិនមែនវេទមន្តទេ។ គណិតវិទ្យាមិនមែនជាឧក្រិដ្ឋកម្មបង្កដោយការស្អប់ទេ។ ប៉ុន្តែនៅក្នុងរដ្ឋ California មូលដ្ឋានគ្រឹះត្រូវបានចាត់ទុកដូចជាមនុស្សអាក្រក់ និងភាពស្មុគស្មាញដូចជាគុណធម៌៖ សៀវភៅរូបវិទ្យាមួយពាន់ទំព័រ ដែលត្រូវបានអនុម័តដោយរដ្ឋ ដែលល្អសម្រាប់ការគាំទ្រខ្លាំង និងកម្រិតចំណេញអ្នកបោះពុម្ព ប៉ុន្តែសំខាន់មិនត្រូវបានអាន។ អ្នកដែលបានមើលខុសត្រូវការបរាជ័យ នៅតែគ្រប់គ្រងស្ថាប័ន។ នោះមិនមែនជាការឃុបឃិតទេ។ វាជាការិយាធិបតេយ្យ។ នៅក្នុងសាកលវិទ្យាល័យ អំណាចប្រមូលផ្តុំនៅក្នុងរដ្ឋបាល ហើយថវិកាដើរតាមអំណាច។ នៅ University of California, Berkeley ជាកន្លែងដែលខ្ញុំធ្វើការ ប្រាក់ខែបុគ្គលិកមិនមែនផ្នែកសិក្សាតែមួយមុខគឺមានតម្លៃ 30,000 សម្រាប់សិស្សម្នាក់។ នោះគឺមុនពេលដែលអ្នកបង់ប្រាក់ឱ្យគ្រូតែមួយ, សាស្ត្រាចារ្យ, TA, អ្នកបង្រៀនក្រៅម៉ោង, អ្នកអាន, ជំនួយការមន្ទីរពិសោធន៍, ឬអ្នកស្រាវជ្រាវ។ ហើយវាមិនឈប់នៅប៉ុណ្ណោះទេ។ នៅរដ្ឋ California មានច្បាប់សម្រាប់បញ្ហាគ្រប់យ៉ាង ហើយជាញឹកញាប់ វាបរាជ័យក្នុងការដោះស្រាយ ខណៈពេលបង្កើតបញ្ហាថ្មីៗ។ អភិបាល Newsom ព្យាយាម— តែងតែរក្សាភាពស្ងប់ស្ងាត់ និងប្រុងប្រយ័ត្ន។ យ៉ាងណាក៏ដោយ គាត់គ្រប់គ្រងក្នុងប្រព័ន្ធមិនស្មោះត្រង់ដែលផ្តល់រង្វាន់ដល់ផលប្រយោជន៍ដែលខ្លាំងជាងគេ និងការសន្យាដ៏ហ៊ឺហាដែលពួកគេលក់។ California សម្បូរទៅដោយមនុស្ស ទីកន្លែង និងតួនាទី។ ចូរចាកចេញពីផ្លូវផ្ទាល់ខ្លួនរបស់យើង: ធ្វើអ្វីដែលដំណើរការ បញ្ឈប់អ្វីដែលមិនដំណើរការ និងប្រព្រឹត្តចំពោះមនុស្សដោយភាពសមរម្យ។

អ៊ីមែល: satish4guv@gmail.com | www.satish4guv.org | www.rao4guv.org



### Raji Rab | ប្រជាធិបតេយ្យ

California ប្រឈមមុខនឹងចំណាយលើសចំណូល 20 ពាន់លានដុល្លារ ដែលជាវិបត្តិលទ្ធភាពទិញ។ ដំណោះស្រាយគឺចំណូលបន្ថែម ការអភិវឌ្ឍន៍អាយុកាលអវកាស មិនមែនត្រឡប់ក្រោយទៅមូលដ្ឋានវិញទេ។ ខ្ញុំជាបេក្ខជនតែមួយគត់ដែលមានគម្រោង Now Plan ដែលនាំមកនូវការវិនិយោគសកលរាប់ពាន់លាន ថវិកាមានតុល្យភាព ចំណូលលើសសម្រាប់គ្រប់នាយកដ្ឋាន ផលិតថ្នាំដែលមានតម្លៃទាប និងផ្ទះពហុគ្រួសារ បន្ធូរបន្ថយបទបញ្ជា ពន្ធទាប ការថែទាំសុខភាពជាសកល ការងារ 1.5 លានក្នុងឆ្នាំដំបូង។ ខ្ញុំជាអាកាសយានិក អ្នកអប់រំ សហគ្រិន ធ្លាប់ជាម្ចាស់ក្រុមហ៊ុនអាកាសចរណ៍ដែលប្រតិបត្តិការ បានណែនាំនិស្សិត បានបម្រើសិទ្ធិស៊ីវិល គាំទ្រការលើកលែងទោសអន្តោប្រវេសន៍។ *www.rajirabforgovovernor.com*

22736 Vanowen St., Suite 105 Gov Sec, West Hills, CA 91307
អ៊ីមែល: info@rajirabforgovernor.com | TikTok: @rajirabforgovernor | Instagram: @rajirabforgovernor

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## អភិបាល



## Randeep S. Dhillon | សាធារណរដ្ឋ

ខ្ញុំជា Dr. Randeep S Dhillon ជាសេដ្ឋកិច្ចវិទូ និងអ្នកជំនាញផ្នែកហិរញ្ញវត្ថុ កំពុងប្រជែងតំណែងជាអភិបាលរដ្ឋ California ដើម្បីផ្តល់នូវភាពជាអ្នកដឹកនាំជាក់ស្តែង ដែលផ្តោតលើតម្លៃសមរម្យ សុវត្ថិភាពសាធារណៈ និងសន្តិសុខសេដ្ឋកិច្ចរយៈពេលវែង។ បញ្ហាប្រឈមរបស់រដ្ឋ California ប៉ះពាល់ដល់គ្រប់សហគមន៍ទាំងអស់។ គ្រួសារប្រឈមមុខនឹងថ្លៃចំណាយការរស់នៅខ្ពស់ កសិករត្រូវការទឹកដែលអាចទុកចិត្តបាន អាជីវកម្មខ្នាតតូចប្រឈមនឹងចំណាយកើនឡើង ហើយសង្កាត់ចង់បានសុវត្ថិភាពឡើងវិញ។ បញ្ហាប្រឈមទាំងនេះទាមទារឱ្យមានដំណោះស្រាយប្រកបដោយតុល្យភាព សន្សំសំចៃ ដែលដឹកនាំដោយព័ត៌មានពិត និងការទទួលខុសត្រូវ។ ប្រវត្តិអាជីពរបស់ខ្ញុំរួមមានសេដ្ឋកិច្ច ហិរញ្ញវត្ថុ ការច្នៃប្រឌិតផ្នែកថែទាំសុខភាព និងប្រតិបត្តិការទ្រង់ទ្រាយធំ។ ខ្ញុំជឿថារដ្ឋាភិបាលត្រូវតែទទួលខុសត្រូវផ្នែកសារពើពន្ធ តម្លាភាព និងផ្តោតលើលទ្ធផល។ ស្ថិរភាពហិរញ្ញវត្ថុពង្រឹងគ្រួសារ គាំទ្រសហគមន៍ និងស្តារទំនុកចិត្តលើស្ថាប័ន។ ក្នុងនាមជាអភិបាល ខ្ញុំនឹងការពារកសិកម្មនៅរដ្ឋ California ដោយការធានាបាននូវទឹកត្រឹមត្រូវ គួរឱ្យទុកចិត្ត និងតម្លៃសមរម្យ រួមទាំងតម្លៃស្របគ្នានៅទូទាំងមណ្ឌលទឹក ដូច្នេះកសិករអាចធ្វើផែនការ វិនិយោគ និងផលិត។ សហគមន៍ជនបទត្រូវតែត្រូវបានចាត់ទុកជាដៃគូនាពេលអនាគតរបស់រដ្ឋ California។ លទ្ធភាពទទួលបានថាមពលមានសារៈសំខាន់ចំពោះគ្រួសារ និងអាជីវកម្មដូចគ្នា។ ខ្ញុំគាំទ្រការផលិតប្រេងឆៅនៅរដ្ឋ California ដែលមានទំនួលខុសត្រូវ រួមជាមួយនឹងការអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ ដើម្បីធ្វើឱ្យមានស្ថិរភាពថ្លៃប្រេងសាំង ការពារការងារ និងកាត់បន្ថយការពឹងផ្អែកលើថាមពលបរទេស។ California ក៏ត្រូវតែនាំមុខគេក្នុងវិស័យបច្ចេកវិទ្យាផងដែរ។ ខ្ញុំនឹងគាំទ្រប្រព័ន្ធប្រតិបត្តិការ កម្មវិធី និងផ្នែករឹងដែលគ្រប់គ្រងដោយរដ្ឋ California ដូច្នេះការច្នៃប្រឌិត ការងារ និងទិន្នន័យនៅតែស្ថិតនៅទីនេះ។ ខ្ញុំនឹងឈរជាមួយអាជីវកម្មខ្នាតតូចដោយកាត់បន្ថយបទប្បញ្ញត្តិ និងពង្រីកលទ្ធភាពទទួលបានដើមទុន ដូច្នេះសហគ្រិនអាចរីកចម្រើន និងជួលបុគ្គលិកបាន។ សុវត្ថិភាពសាធារណៈគឺជាមូលដ្ឋានគ្រឹះ។ ការលួចទំនិញក្នុងហាងនៃចំនួនប៉ុន្មានក៏ដោយ គឺជាបទល្មើស ហើយច្បាប់ត្រូវតែអនុវត្តដោយយុត្តិធម៌។ ខ្ញុំគាំទ្រដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ដំណោះស្រាយចំពោះភាពគ្មានផ្ទះសម្បែងរបស់អតីតយុទ្ធជនតាមរយៈលំនៅឋាន និងការងារ និងសកម្មភាពដ៏រឹងមាំប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់។

1615 South H Street, Bakersfield, CA 93304 | ទូរស័ព្ទ: (661) 374-0005
អ៊ីមែល: Dhillon@Cagov2026.com | Facebook: Facebook.com/Cagov2026 | Instagram: Instagram.com/Cagov2026



## LivingForGod AndCountry DeMott | គ្មានចំណូលចិត្តគណបក្ស

ឈ្មោះផ្លូវការរបស់ខ្ញុំ LivingForGod មានន័យថាការរស់នៅជីវិតមួយដែលឆ្លុះបញ្ចាំងពីអត្តចរិតល្អរបស់ព្រះយេស៊ូវគ្រីស្ទ; វាជាមូលដ្ឋានគ្រឹះរបស់ខ្ញុំ ប្រព័ន្ធប្រតិបត្តិការរបស់ខ្ញុំ និងត្រីវិស័យ។ ក្នុងនាមជាបព្វជិត ខ្ញុំយល់ឃើញថាជោគជ័យណាមួយដែលបានកសាងឡើងលើមូលដ្ឋាននៃការបោកប្រាស់ និងអំពើពុករលួយ គឺដូចជាការសាងសង់ប្រាសាទនៅលើខ្សាច់។ ដូច្នេះ នៅពេលដែលព្យុះបោកបក់ប្រឆាំងនឹងកញ្ចក់ខាងមុខ ខ្ញុំនឹងមិនក្រញែងខ្លួនឡើយ! នៅពេលដែលវាទាក់ទងនឹងប្រភេទនៃភាពចលាចលដែលនាំឱ្យយន្តហោះធ្លាក់ចុះ ខ្ញុំនឹងក្លាយជាអ្នកបើកយន្តហោះដែលដាល់ខ្យល់ឆ្លងកាត់ព្យុះដើម្បីឱ្យអ្នកដំណើរ (អ្នកប្រជាជន) អាចដកដង្ហើមម្តងទៀត។ ក្នុងនាមជាអ្នកជំនួញជោគជ័យ ខ្ញុំបានបង្កើត Big Time Pest Control តាំងពីមូលដ្ឋាន ហើយបន្ទាប់មកបានលក់វា ផ្លាស់ប្តូរពីអ្នកគ្រប់គ្រងថ្នាក់លើ ដើម្បីធ្វើជាបព្វជិត ក្នុងលេណដ្ឋាន លុតជង្គង់ កាន់ដៃគ្នាជាមួយអ្នកដែលត្រូវបានគេបំភ្លេចចោល និងប្រេះឆា។ មរតករបស់ខ្ញុំគឺជាផែនទីនៃថ្មក្រានីតរបស់អាមេរិក ដែលលាតសន្ធឹងពីលោក Samuel Fuller ដែលជាវេជ្ជបណ្ឌិតនៃ Mayflower ទៅដល់បង្គោលបង្វិលរន្ទះរបស់ Ben Franklin ។ ប៉ុន្តែខ្ញុំមិនមើលទៅក្រោយទេ—ខ្ញុំទន្ទឹងរង់ចាំរដ្ឋCalifornia ទាំងអស់ ជាកន្លែងដែលមនុស្សមានអារម្មណ៍ត្រូវគេបោះបង់ចោល និងត្រូវគេក្បត់! ខ្ញុំមានគម្រោងបញ្ឈប់ប្រតិបត្តិការ ICE ខុសច្បាប់។ និងបេះដូងរបស់បព្វជិតម្នាក់ដើម្បីចងចាំថាតើប្រព័ន្ធនេះបម្រើនរណា។ ខ្ញុំ 100% ប្រឆាំងនឹងការបង់ពន្ធលើចំនួនម៉ែលដែលបានបើកបរ។ ដើម្បីធ្វើឱ្យ California អស្ចារ្យម្តងទៀត ការពារប្រជាជន! នៅពេលដែលគណបក្សចាស់កំពុងជជែកគ្នាអំពីកម្តៅថាតើនរណាបានទិញឈើគូស ខណៈពេលដែលភ្លើងឆេះក្នុងធុងសំរាម ខ្ញុំនឹងប្រគល់ម៉ាស៊ីនបាញ់ភ្លើងជូនអ្នក! នោះហើយជាមូលហេតុដែលខ្ញុំជាជម្រើសដ៏ល្អបំផុតសម្រាប់អភិបាលរដ្ឋ California។ • *www.DeMottForGovernor.com*

724 Terrace Dr., Redding, CA 96002 | ទូរស័ព្ទ: (530) 921-1978
អ៊ីមែល: demottforgovernor@gmail.com | X: https://x.com/realdemott | Instagram: https://instagram.com/realdemott

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរង

- ចូលកាន់ដំណែងនិងទទួលភារកិច្ចជាអភិបាល ក្នុងករណីដកហូតតំណែង ការស្លាប់ ការលាលែងពីតំណែង ការដកចេញពីដំណែង ឬអវត្តមានពីរដ្ឋ។
- បម្រើជាប្រធានព្រឹទ្ធសភារដ្ឋ និងមានការបោះឆ្នោតដើម្បីដោះស្រាយការបោះឆ្នោតស្មើ។
- ជាប្រធានគណៈកម្មការអភិវឌ្ឍន៍សេដ្ឋកិច្ច ជាសមាជិកនៃគណៈកម្មការដីធ្លីរបស់រដ្ឋ និងក្រុមប្រឹក្សាការពារមហាសមុទ្រ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធសាកលវិទ្យាល័យរដ្ឋ California ។



### Janelle Kellman | ប្រជាធិបតេយ្យ

លោកស្រី Janelle Kellman គឺជាអ្នកជំនាញខាងហានិភ័យអាកាសធាតុ ជាអ្នកដឹកនាំសហគមន៍ក្នុងមូលដ្ឋាន និងជាមន្ត្រីប្រតិបត្តិមិនស្វែងរកប្រាក់ចំណេញផ្នែកការត្រៀមបង្ការគ្រោះមហន្តរាយដែលផ្តោតលើការដោះស្រាយវិបត្តិចំណាយជីវភាពខ្ពស់ដែលរដ្ឋ California កំពុងប្រឈមមុខ។ ក្នុងនាមជាមេធាវីខាងបរិស្ថានដែលមានជំនាញខាងហានិភ័យអាកាសធាតុ លោកស្រី Janelle បានបង្កើតមជ្ឈមណ្ឌល Center for Sea Rise Solutions ដើម្បីជួយរដ្ឋាភិបាលនិងសហគមន៍មូលដ្ឋានកាត់បន្ថយហានិភ័យសេដ្ឋកិច្ចពីភ្លើងឆេះព្រៃ ទឹកជំនន់ និងអាកាសធាតុអាក្រក់នានា—ជំនួសឱ្យការបញ្ជូនចំណាយដោយសារគ្រោះមហន្តរាយទៅអ្នកជាប់ពន្ធ។ ក្នុងនាមជាអ្នកដឹកនាំសហគមន៍ក្នុងតំបន់ និងជាអភិបាលក្រុង Sausalito លោកស្រី Janelle បានដឹកនាំវិធានការឆ្លើយតបទៅនឹងទឹកជំនន់កំណើននីវ៉ូទឹកសមុទ្រ និងភ្លើងឆេះព្រៃ ដោយធានាបាននូវថវិការាប់លានដុល្លារដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន ដែលនាំឱ្យមានថ្លៃបង់ធានារ៉ាប់រងរបស់ម្ចាស់ផ្ទះទាបជាងមុន។ ជំនួសឱ្យការរង់ចាំអ្នកផ្សេងមកចាត់វិធានការលើបញ្ហាភាពគ្មានផ្ទះសម្បែង ក្នុងនាមជាចៅហ្វាយក្រុង លោកស្រីបានប្រកាសភាពអាសន្នសម្រាប់ការបោះជំរំក្នុងមូលដ្ឋាន និងបានដឹកនាំវិធានការឆ្លើយតបខាងមនុស្សធម៌ ដើម្បីបញ្ជូនប្រជាជនទៅរស់នៅក្នុងលំនៅឋាន។ ចាប់តាំងពីពេលនោះមក ភាពគ្មានផ្ទះសម្បែងក្នុងមូលដ្ឋានបានធ្លាក់ចុះជាងពាក់កណ្តាល។ អភិបាលរងនៃរដ្ឋ California ជួយដឹកនាំគោលនយោបាយអប់រំ បរិស្ថាន និងសេដ្ឋកិច្ចទូទាំងរដ្ឋ។ លោកស្រី Janelle នឹង៖ 1. ប្រើប្រាស់ជំនាញខាងអាកាសធាតុរបស់លោកស្រី ដើម្បីកាត់បន្ថយចំណាយលើការប្រើប្រាស់អគ្គិសនីឱ្យបានពាក់កណ្តាលក្នុងរយៈពេលមួយទសវត្សរ៍ខាងមុខ ដោយការផ្លាស់ប្តូររបៀបផ្តល់ហិរញ្ញប្បទានដល់ការបង្ការអគ្គិភ័យ 2. វិនិយោគលើកម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយ ដើម្បីធ្វើឱ្យទីផ្សារធានារ៉ាប់រងមានស្ថិរភាព និង 3. ពង្រីកការអប់រំវិជ្ជាជីវៈ និងការអប់រំសម្របតាមអាជីព នៅតាមមហាវិទ្យាល័យសហគមន៍របស់យើង ដើម្បីឱ្យនិស្សិតគ្រប់រូបអាចចូលរួមចំណែកដល់ផ្នែកបច្ចេកវិទ្យាអាកាសធាតុ លំនៅឋាន សេវាកម្ម និងជំនាញរបស់រដ្ឋ California។ ដែលនាំឱ្យមានការកាត់បន្ថយការបង់ថ្លៃអគ្គិសនី ការកាត់បន្ថយថ្លៃចំណាយធានារ៉ាប់រងគេហដ្ឋាន និងធ្វើឱ្យអ្នករស់នៅរដ្ឋ California ទាំងអស់អាចចូលរៀនតាមមហាវិទ្យាល័យសហគមន៍ដោយឥតគិតថ្លៃ។ *JanelleKellman.com*

P.O. Box 1688, Sausalito, CA 94965 | អ៊ីមែល: janelle@janellekellman.com
Instagram: https://www.instagram.com/janellekellmanforltg | Facebook: https://facebook.com/janellekellmanforltg



### Michael Tubbs | ប្រជាធិបតេយ្យ

ខ្ញុំកំពុងប្រជែងតំណែងជាអភិបាលរង ដើម្បីធ្វើឱ្យចំណាយរស់នៅរដ្ឋ California កាន់តែសមរម្យជាងមុន និងដើម្បីបញ្ជាក់ថា រដ្ឋាភិបាលអាចសម្រេចលទ្ធផលនានាបាន មិនមែនគ្រាន់តែសន្យាចោលនោះទេ។ ខ្ញុំធំធាត់ឡើងក្នុងភាពក្រីក្រ ចិញ្ចឹមបីបាច់ដោយម្តាយមេម៉ាយម្នាក់។ ក្រុមគ្រួសារនិងសហគមន៍របស់ខ្ញុំបានបង្រៀនខ្ញុំឱ្យស្គាល់នូវភាពធន់និងការបម្រើ ដែលជាគុណតម្លៃដែលបានជួយខ្ញុំឱ្យចូលរៀននៅសាកលវិទ្យាល័យ Stanford និងត្រូវបានជ្រើសរើសជាអភិបាលក្រុង Stockton នៅអាយុ 26 ឆ្នាំ។ ខ្ញុំបានឡើងកាន់តំណែងនៅពេលក្រុង Stockton កំពុងជួបវិបត្តិ ត្រឹមតែប៉ុន្មានឆ្នាំប៉ុណ្ណោះក្រោយពីការក្ស័យធន។ ដោយការសហការជាមួយសហគមន៍របស់យើង ខ្ញុំបានកំណត់ផែនការផ្លូវថ្មីមួយ។ ដោយសារមានការចាប់ដៃគូជាមួយនគរបាល យើងបានកាត់បន្ថយអំពើឃាតកម្មបានចំនួន 40% និងសម្រេចបាននូវការថយចុះយ៉ាងច្រើនបំផុតរបស់រដ្ឋនូវចំនួនករណីបាញ់ប្រហារពាក់ព័ន្ធនឹងមន្ត្រី។ ភាពគ្មានការងារធ្វើបានឈានដល់កម្រិតទាបបំផុតស្ទើរតែមិនធ្លាប់មាន។ ក្រុង Stockton ត្រូវបានគេដាក់ឈ្មោះថាជាក្រុងមានស្ថានភាពហិរញ្ញវត្ថុល្អបំផុតទីពីររបស់រដ្ឋ។ ខ្ញុំបានដាក់ឱ្យដំណើរការកម្មវិធីសាកល្បងលើការធានាប្រាក់ចំណូល ដែលបានជួយប្រជាជនឱ្យចេញពីភាពក្រីក្រ ហើយត្រូវបានយកតម្រាប់តាមដោយក្រុងជាង 150។ រដ្ឋ California កំពុងប្រឈមមុខនឹងបញ្ហាប្រឈមធ្ងន់ធ្ងរនានា ដូចជា ការនិយាយច្រើន តែខ្វះការធ្វើសកម្មភាព។ ក្នុងនាមជាអភិបាលរង ខ្ញុំនឹងផ្តោតការយកចិត្តទុកដាក់ឥតឈប់ឈរលើលទ្ធភាពរ៉ាប់រងចំណាយ៖ ខ្ញុំនឹងតស៊ូដើម្បីបន្ថយចំណាយលើការអប់រំកម្រិតឧត្តមសិក្សា មិនថាជាកម្មវិធីវិជ្ជាជីវៈឬមហាវិទ្យាល័យនោះទេ។ ខ្ញុំនឹងណែនាំគំនិតថ្មីៗ ដើម្បីសាងសង់លំនៅឋានតម្លៃសមរម្យ ដើម្បីឱ្យប្រជាជនរដ្ឋ California អាចស្នាក់នៅក្នុងរដ្ឋដែលយើងស្រឡាញ់បាន។ ហើយខ្ញុំនឹងគាំទ្រដំណោះស្រាយជោគជ័យនានាដូចជា កម្មវិធីធានាប្រាក់ចំណូលដើម្បីបញ្ចប់នូវភាពក្រីក្រ និងទប់ស្កាត់ភាពគ្មានផ្ទះសម្បែង។ ខ្ញុំនឹងប្រើប្រាស់ការិយាល័យនេះដើម្បីជំរុញការទទួលខុសត្រូវ និងពន្លឿនដំណោះស្រាយដែលមានប្រសិទ្ធិភាព។ ខ្ញុំមានកិត្តិយសណាស់ដែលមានការគាំទ្រពី SEIU California, គណបក្សគ្រួសារអ្នកធ្វើការ California, និងថ្នាក់ដឹកនាំទូទាំងរដ្ឋ ដែលជឿថា រដ្ឋ California ត្រូវការថ្នាក់ដឹកនាំដែលដឹងពីរបៀបគ្រប់គ្រង និងអាចសម្រេចកិច្ចការបាន។ ចក្ខុវិស័យរបស់ខ្ញុំគឺសាមញ្ញ៖ រដ្ឋ California ដែលដំណើរការសម្រាប់មនុស្សគ្រប់គ្នា។ *michaeltubbsforca.com*

អ៊ីមែល: info@michaeltubbsforca.com
Instagram: instagram.com/michaeldtubbs | Facebook: facebook.com/stocktontubbs

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរង



**Ebie Lynch** | សាធារណរដ្ឋ

មេធាវី អតីតយុទ្ធជន គិលានុបដ្ឋាយិកា។ California ជាចម្បង! (ស្វែងយល់បន្ថែម)
*www.ebielynchforcalifornia.com*

6261 Hazel Ave. #2943, Orangevale, CA 95662 | ទូរស័ព្ទ: (916) 243-5448
អ៊ីមែល: elynch@ebielynchforcalifornia.com | Facebook: ebielynch4caltgov | Instagram: ebielynch



**Alice Stek** | សន្តិភាព និងសេរីភាព

គ្រូពេទ្យ អ្នកអប់រំ និងអ្នកសង្គមនិយម។ នៅក្នុងការប្រកបអាជីពរយៈពេល 32 ឆ្នាំរបស់ខ្ញុំក្នុងនាមជាអ្នកឯកទេ OBGYN និង HIV នៅក្នុងប្រព័ន្ធសុខាភិបាលដែលកំពុងតែដួលរលំរបស់រដ្ឋ California ខ្ញុំត្រូវបានបញ្ជាក់ជាបន្តបន្ទាប់ថា សង្គមនិយមគឺជាវិធីតែមួយគត់សម្រាប់ព្យាបាលមូលធននិយម។ ចូរយើងកសាងរដ្ឋ California មួយសម្រាប់ប្រជាជន មិនមែនសម្រាប់មហាសេដ្ឋីទេ! សូមបោះឆ្នោតឱ្យអ្នកសង្គមនិយម ហើយគាំទ្រ Left Unity Slate!

333 Washington Blvd. #355, Marina del Rey, CA 90292 | ទូរស័ព្ទ: (323) 487-0931
អ៊ីមែល: alicestek4ca@gmail.com | www.alicestek4ca.com | Instagram: alicestek4ca

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្ដីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្ដល់ជូនសេចក្ដីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្ដីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្ដីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរង



### David Fennell | សាធារណរដ្ឋ

សួស្ដី California! លោក David Fennell កំពុងប្រជែងតំណែងជាអភិបាលរងដើម្បីស្ដារភាពអស្ចារ្យរបស់រដ្ឋនេះឡើងវិញ! រដ្ឋ California តែងតែជានិមិត្តរូបនៃក្ដីស្រមៃរបស់អាមេរិក ប៉ុន្តែក្នុងរយៈពេល 20 ឆ្នាំកន្លងមកនេះ យើងបានឃើញក្ដីស្រមៃនោះរសាត់បាត់ទៅឆ្ងាយ ដោយសារតែអ្នកដឹកនាំដ៏អន់ខ្សោយនៅ Sacramento។ យើងត្រូវការដំណោះស្រាយថ្មីៗ មិនមែនដំណោះស្រាយដដែលបន្ថែមទៀតទេ។ ហេតុអ្វីបានជាយើងមិនអាចសាងសង់គេហដ្ឋានតម្លៃសមរម្យ ចាប់ផ្ដើមអាជីវកម្មថ្មី ឬផ្គត់ផ្គង់គ្រួសាររបស់យើងបាន? ហេតុអ្វីបានជាក្រុមហ៊ុនបច្ចេកវិទ្យាកំពុងចាកចេញទៅរដ្ឋ Texas ភាពយន្តកំពុងត្រូវថតនៅក្រៅប្រទេស ហើយកសិកររបស់យើងកំពុងជួបការលំបាកក្នុងការប្រើប្រាស់ទឹក? ផ្លូវថ្នល់របស់យើងគ្មានសុវត្ថិភាព ហើយព្រៃឈើរបស់យើងកំពុងរងការឆាបឆេះ។ បញ្ហាគឺច្បាស់ណាស់៖ អ្នកដឹកនាំខ្សោយ។ ក្នុងនាមជាអភិបាលរងរបស់អ្នក ខ្ញុំនឹងចាត់វិធានការ។ ខ្ញុំនឹងដឹកនាំការធ្វើសវនកម្មដើម្បីលុបបំបាត់ការខ្ជះខ្ជាយ ការក្លែងបន្លំ និងការរំលោភបំពាននៅ Sacramento ដោយធានាថា ប្រាក់ពន្ធរបស់អ្នកត្រូវបានចាយវាយដោយឈ្លាសវៃ។ ខ្ញុំនឹងធ្វើការជាមួយគណៈកម្មការដីធ្លីរដ្ឋ និងក្រុមប្រឹក្សាផ្សេងៗទៀតដើម្បីធានាថា កសិករទទួលបានទឹកដែលពួកគេត្រូវការ និងដើម្បីគ្រប់គ្រងធនធានរបស់យើង ដោយទប់ស្កាត់និងកសាងឡើងវិញពីភ្លើងឆេះព្រៃ។ ខ្ញុំនឹងតស៊ូដើម្បីការអប់រំមានគុណភាព ដែលត្រៀមលក្ខណៈសិស្សយើងសម្រាប់អនាគតរបស់រដ្ឋ California។ ជាមួយបទពិសោធន៍ខាងអាជីវកម្ម កសិកម្ម និងបច្ចេកវិទ្យា ខ្ញុំត្រៀមខ្លួនរួចជាស្រេចដើម្បីនាំយកវិធីសាស្ត្រពិភពលោកពិតមកកាន់ Sacramento និងដឹកនាំរដ្ឋ California ឱ្យវិលត្រឡប់ទៅភាពរុងរឿងឡើងវិញ។ បោះឆ្នោតគាំទ្រលោក David Fennell ជាអភិបាលរង! ខ្ញុំនឹងមិនធ្វើឱ្យអ្នកខកចិត្តឡើយ! សូមស្វែងយល់បន្ថែមតាម *https://www.fennellforcalifornia.com*

500 Capitol Mall, Suite 2350, Sacramento, CA 95814 | ទូរស័ព្ទ: (916) 305-6361 | អ៊ីមែល: dave@fennellforcalifornia.com
Facebook: https://www.facebook.com/FennellForCalifornia | Instagram: https://www.instagram.com/fennellforcalifornia



### Josh Fryday | ប្រជាធិបតេយ្យ

ខ្ញុំជាអតីតទាហានជើងទឹក ជាអតីតអភិបាលក្រុង និងជាសមាជិកខុទ្ទកាល័យរបស់អភិបាល។ ខ្ញុំជាឪពុកដែលមានកូនបីនាក់រៀននៅសាលារដ្ឋ បានរៀបការជាមួយគ្រូបង្រៀនថ្នាក់ទីពីរនៅសាលារដ្ឋ ហើយមានមោទនភាពដែលខ្លួនជាបេក្ខជនតែម្នាក់គត់ដែលត្រូវបានគាំទ្រដោយសហជីពទាំងពីរដែលតំណាងឱ្យគ្រូបង្រៀននិងអ្នកអប់រំរបស់រដ្ឋ California។ ខ្ញុំកំពុងប្រជែងតំណែងពីព្រោះយើងត្រូវការអ្នកប្រជាធិបតេយ្យជំនាន់ថ្មីដែលម៉ឺងម៉ាត់និងរឹងមាំជាងមុន—ដើម្បីបញ្ឈប់លោក Donald Trump និងសាជីវកម្មដ៏លោភលន់ដែលធ្វើបាបប្រជាជន California។ ក្នុងនាមជាមន្ត្រីJAG នៅក្នុងកងទ័ពជើងទឹក ខ្ញុំបានក្រោកឈរឡើងគាំទ្រនីតិរដ្ឋ ការពារអ្នកជាប់ឃុំ និងបានផ្ដល់សក្ខីកម្មនៅចំពោះមុខសភាប្រឆាំងនឹងការរំលោភសិទ្ធិមនុស្សនៅ Guantanamo Bay។ ក្នុងនាមជាអតីតយុទ្ធជនតែម្នាក់គត់ដែលកំពុងឈរឈ្មោះ ខ្ញុំមានបទពិសោធន៍ក្នុងការដឹកនាំការប្រយុទ្ធរបស់រដ្ឋ California ប្រឆាំងនឹងការប្រើប្រាស់ខុសរបស់លោក Trump នូវឆ្មាំជាតិ និងយោធារបស់យើង ហើយការពារក្រុមគ្រួសារ អ្នកជិតខាង និងលទ្ធិប្រជាធិបតេយ្យរបស់យើងពីកងទ័ព ICE របស់លោក Trump។ នៅគណៈកម្មការឆ្នេរសមុទ្រ និងគណៈកម្មការដីធ្លីរដ្ឋ ខ្ញុំនឹងបញ្ឈប់លោក Trump និងក្រុមហ៊ុន Big Oil ពីការខួងប្រេងថ្មីៗនៅឯនាយសមុទ្រ។ តាមរយៈការបង្កើនទ្វេដងនៃការផលិតថាមពលស្អាតរបស់យើង យើងនឹងកាត់បន្ថយបាននូវការបំពុល និងកាត់បន្ថយថ្លៃចំណាយលើថាមពល ដើម្បីសន្សំប្រាក់របស់អ្នក។ ជាអ្នកកើតនិងធំធាត់នៅរដ្ឋ California គ្រួសាររបស់ខ្ញុំបានផ្លាស់ទីលំនៅចំនួន 17 ដង មុនពេលខ្ញុំបញ្ចប់ការសិក្សានៅវិទ្យាល័យ។ វិបត្តិលំនៅឋាននិងថ្លៃជីវភាពរបស់យើង គឺជារឿងកើតឡើងចំពោះខ្ញុំផ្ទាល់។ ខ្ញុំនឹងទទួលយកការតស៊ូដ៏លំបាកដែលអ្នកនយោបាយអាជីពមិនអាចធ្វើបាន—ដើម្បីការពារលទ្ធិប្រជាធិបតេយ្យរបស់យើង និងធ្វើឱ្យថ្លៃរស់នៅរដ្ឋ California មានភាពសមរម្យជាងមុន សម្រាប់គ្រួសារអ្នកធ្វើការដូចជាខ្ញុំ។ ខ្ញុំមានកិត្តិយសណាស់ក្នុងការទទួលបានការបោះឆ្នោតគាំទ្រពីលោកអ្នក។ សូមស្វែងយល់បន្ថែមអំពីផែនការផ្នែកលំនៅឋាន ថាមពល និងការងាររបស់ខ្ញុំសម្រាប់រដ្ឋ California នៅគេហទំព័រ *www.joshfryday.com*។

ទូរស័ព្ទ: (916) 550-3398 | អ៊ីមែល: Josh@JoshFryday.com
Instagram: @josh_fryday | YouTube: @josh_fryday

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្ដីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្ដល់ជូនសេចក្ដីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្ដីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្ដីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អភិបាលរង



### Tim Myers | ប្រជាធិបតេយ្យ

ខ្ញុំឈ្មោះ Tim Myers ប្រធាននៃ Californians For Climate Change ជាសហស្ថាបនិក និងអតីតសមាជិកនៃក្រុមតន្ត្រីដ៏មានប្រជាប្រិយភាពមួយឈ្មោះ OneRepublic និងជាអ្នកបង្កើតអាល់ប៊ុមលំដាប់មាសនិងផ្លាទីនចំនួន 16។ ខ្ញុំបានសិក្សានៅសាកលវិទ្យាល័យ Harvard ហើយបានចំណាយពេលពេញមួយជីវិតរបស់ខ្ញុំនៅចំណុចប្រសព្វនៃភាពច្នៃប្រឌិត សកម្មនិយម និងសេវាសាធារណៈ។ ក្នុងនាមជាសកម្មជនមួយរូប ខ្ញុំបានដឹកនាំការជួបជុំតវ៉ាប្រឆាំងនឹងលោក Trump និងប្រឆាំងនឹង ICE នៅទូទាំងរដ្ឋ California។ ខ្ញុំធ្លាប់ឈរនៅជួរមុខ ខណៈពេលអ្នកលបបាញ់បានតម្រង់កាំភ្លើង ហើយគ្រាប់កៅស៊ូត្រូវបានបាញ់។ ខ្ញុំប្រថុយជីវិតរបស់ខ្ញុំពីព្រោះខ្ញុំជឿលើយុត្តិធម៌ សមភាព និងអំណាចរបស់មនុស្សដែលងើបឡើងរួមគ្នា។ ខ្ញុំធំឡើងក្នុងភាពក្រីក្រហើយបានបន្តបង្កើត Palladium Records ដោយបង្កើតការងារនិងឱកាសរាប់រយសម្រាប់សិល្បករ និងគ្រួសារអ្នកធ្វើការ។ សព្វថ្ងៃនេះ ខ្ញុំជាស្វាមីនិងជាឪពុករបស់កូនស្រីពីរនាក់ ហើយការតស៊ូរបស់ខ្ញុំគឺជារឿងផ្ទាល់ខ្លួនរបស់ខ្ញុំសុទ្ធសាធ។ ខ្ញុំចង់ឱ្យកូនៗរបស់ខ្ញុំនិងគ្រួសារទាំងអស់នៅរដ្ឋ California ទទួលកេរ្តិ៍ដំណែលជារដ្ឋមួយដែលមានសុវត្ថិភាព មានកម្រិតចំណាយសមរម្យ និងពោរពេញដោយលទ្ធភាព។ ខ្ញុំកំពុងប្រជែងតំណែងលើវេទិកាដែលផ្តល់អាទិភាពដល់មនុស្ស ដែលផ្តោតលើការបង្កើតកម្រិតចំណាយសមរម្យ ការលុបបំបាត់ភាពគ្មានផ្ទះសម្បែង ការនាំយកការងារខាងបច្ចេកវិទ្យាមកវិញ ការបន្ថយចំណាយ ការកាត់បន្ថយឧក្រិដ្ឋកម្ម និងការដំឡើងប្រាក់ឈ្នួល។ ខ្ញុំមានមោទនភាពដែលបានជួយអនុម័តសេចក្តីស្នើច្បាប់លេខ 28 ដើម្បីពង្រីកការអប់រំខាងតន្ត្រីនិងសិល្បៈនៅតាមសាលារៀនរដ្ឋរបស់យើង។ ខ្ញុំមិនបានយកប្រាក់ពី PAC មួយកាក់មួយសេនឡើយ ពីព្រោះការបម្រើសាធារណជនមិនគួរជាការទិញលក់ឡើយ។ អ្នកនយោបាយអាជីពលែងមានអ្វីពាក់ព័ន្ធទៀតហើយ។ អំពើពុករលួយត្រូវតែបញ្ចប់។ សារដ៏ពេញនិយមរបស់ខ្ញុំបានទៅដល់ប្រជាជន California ជាង 16 លាននាក់ដែលត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្លាស់ប្តូរ។ ខ្ញុំនឹងមិនឱបដៃឈរមើលគ្រួសារជាច្រើនទៀតត្រូវបានរុញច្រានចេញនោះឡើយ។ ចូរយើងរួមគ្នាក្រោកឡើងហើយយករដ្ឋ California មកវិញសម្រាប់មនុស្សជំនាន់ក្រោយ និងគ្រួសារអ្នកធ្វើការទូទាំងរដ្ឋ។

Tik Tok: timmyersmusic | Instagram: timmyersofficial



### Fiona Ma | ប្រជាធិបតេយ្យ

រដ្ឋ California ឈរនៅផ្លូវប្រសព្វមួយក្នុងប្រវត្តិសាស្ត្រអាមេរិក។ យើងត្រូវការមេដឹកនាំដែលមានសមត្ថភាពនិងមានភ្នែកមុតច្បាស់ ដែលមានឆន្ទៈក្នុងការក្រោកឈរឡើង និងតស៊ូក្នុងនាមប្រជាជនគ្រប់រូបនៃរដ្ឋ California។ ការការពារតម្លៃនិងប្រជាជនរបស់រដ្ឋ California ជាពិសេសស្ត្រីនិងជនអន្តោប្រវេសន៍ នឹងក្លាយជាអាទិភាពចម្បងរបស់ខ្ញុំ ក្នុងនាមជាអភិបាលរងរបស់អ្នក។ ខ្ញុំជាកូនស្រីរបស់ជនអន្តោប្រវេសន៍ ហើយការភ័យខ្លាចឬការបំភិតបំភ័យមិនត្រូវមាននោះឡើយនៅក្នុងរដ្ឋរបស់យើង។ ខ្ញុំនឹង*ការពារសិទ្ធិសញ្ជាតិពីកំណើត*ពីការវាយប្រហាររបស់លោក Trump ហើយនិង*ឱ្យ ICE ទទួលខុសត្រូវ*ចំពោះអំពើហិង្សាដ៏ហួសហេតុ។ ខ្ញុំបានចំណាយពេលពេញមួយជីវិតរបស់ខ្ញុំក្នុងការបម្រើសាធារណជនដោយក្រោកឈរតំណាងឱ្យស្ត្រីទាំងឡាយ។ ក្នុងនាមជារដ្ឋមន្ត្រីហិរញ្ញវត្ថុរដ្ឋ California ខ្ញុំ*បានផ្តល់មូលនិធិផ្នែកសុខភាពបន្តពូជ ការពន្យារកំណើត និងការពិនិត្យរកជំងឺមហារីក* នៅពេលលោក Trump បានកាត់បន្ថយមូលនិធិ Title X។ ក្នុងនាមជាសមាជិកសភា ខ្ញុំត្រូវបានជ្រើសរើសឱ្យធ្វើជាប្រធានគណៈកម្មាធិការអំពើហិង្សាក្នុងគ្រួសារ ដើម្បី*ការពារជនរងគ្រោះ*។ អភិបាលរងគឺជាអ្នកបម្រើការនៅក្នុងគណៈកម្មការឆ្នេរសមុទ្រ និងក្រុមប្រឹក្សាភិបាលនៃ UC និង CSU។ ខ្ញុំនឹង*ប្រឆាំងនឹងផែនការរបស់លោក Trump ក្នុងការបើកឡើងវិញនៃការខួងយកប្រេងឯនាយសមុទ្រ* ខណៈពេលកំពុងការពារសាកលវិទ្យាល័យ និងការពារសេរីភាពការសិក្សា។ ខ្ញុំនឹងបោះឆ្នោតឱ្យ*បង្កកថ្លៃសិក្សា ដើម្បីឱ្យគ្រួសារវណ្ណៈកណ្តាលអាចមានលទ្ធភាពរៀនមហាវិទ្យាល័យ*។ ម្តាយរបស់ខ្ញុំជាគ្រូបង្រៀននៅសាលារដ្ឋ។ នោះហើយជាមូលហេតុដែលខ្ញុំប្តេជ្ញាផ្តល់ការអប់រំប្រកបដោយគុណភាពដល់សិស្សគ្រប់រូបនៃរដ្ឋ California។ យើងរស់នៅក្នុងគ្រាមួយដែលមិនធ្លាប់កើតមានពីមុនមកឡើយ—ហើយរដ្ឋ California ត្រូវតែកំណត់ផែនការផ្លូវទៅមុខ—អនាគតមួយដែលប្រកាន់យកជំនឿរួមមួយថានឹងទទួលបានរដ្ឋ California ដែលប្រសើរជាងមុនសម្រាប់ទាំងអស់គ្នា។ សូមចូលរួមជាមួយយើង *ក្រុមអ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California, សហព័ន្ធគ្រូបង្រៀនរដ្ឋ California, សហជីពជាតិនៃបុគ្គលិកថែទាំសុខភាព, ជាងសំណង់, ជាងឈើ, លោកស្រីអភិបាលរង Eleni Kounalakis* និងសហជីពជាង 30 នៅក្នុងយុទ្ធនាការរបស់យើងតាម *www.fionama.com*។ ខ្ញុំស្រឡាញ់រដ្ឋ California ហើយខ្ញុំសូមគោរពស្នើសុំឱ្យអ្នកបោះឆ្នោតគាំទ្រខ្ញុំជាអភិបាលរង។

1032 Irving Street, #908, San Francisco, CA 94122
អ៊ីមែល: Fiona@FionaMa.com | www.fionama.com | Facebook: Facebook.com/CA.FionaMa

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## រដ្ឋលេខាធិការ

- ក្នុងនាមជាមន្ត្រីប្រធានរៀបចំការបោះឆ្នោតរបស់រដ្ឋ ត្រួតពិនិត្យការបោះឆ្នោតទូទាំងរដ្ឋ និងផ្តល់លទ្ធភាពដល់សាធារណៈជនឱ្យទទួលបានព័ត៌មានស្តីពីយុទ្ធនាការ និងព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមអ្នកបញ្ចុះបញ្ចូល។
- ថែរក្សាឯកសារអាជីវកម្មមួយចំនួន បញ្ជាក់ភាពត្រឹមត្រូវនៃនិមិត្តសញ្ញា គ្រប់គ្រងការបញ្ជាក់ក្រដាសស្នាមសាធារណៈ និងអនុញ្ញាតឱ្យម្ចាស់បំណុលដែលមានការធានាការពារផលប្រយោជន៍ហិរញ្ញវត្ថុរបស់ពួកគេ។
- ការពារប្រវត្តិសាស្ត្ររបស់រដ្ឋ California តាមរយៈការទទួលបាន ការការពារ និងការចែករំលែករតនសម្បត្តិប្រវត្តិសាស្ត្ររបស់រដ្ឋ។



### Donald P. (Don) Wagner | សាធារណរដ្ឋ

ក្នុងនាមជារដ្ឋលេខាធិការ ខ្ញុំនឹងស្តារទំនុកចិត្តរបស់ប្រជាជននៃរដ្ឋ California លើប្រព័ន្ធបោះឆ្នោតរបស់យើងឡើងវិញ និង*ការពារអ្នកមានសិទ្ធិបោះឆ្នោតគ្រប់រូប*នូវ*សិទ្ធិជាមូលដ្ឋាននៃអាមេរិកដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យរបស់យើង*។ ប្រព័ន្ធបោះឆ្នោតរបស់រដ្ឋ California លែងដំណើរការហើយ។ រដ្ឋចំនួនសាមសិបប្រាំមួយ ព្រមទាំងប្រទេសប្រជាធិបតេយ្យភាគច្រើន តម្រូវឱ្យអ្នកបោះឆ្នោតបង្ហាញអត្តសញ្ញាណរបស់ពួកគេនៅឯមណ្ឌលបោះឆ្នោត។ រដ្ឋ California មិនធ្វើដូច្នោះទេ។ សន្តិសុខក្នុងការបោះឆ្នោតមានភាពទន់ខ្សោយខ្លាំងណាស់ ដែលយ៉ាងហោចណាស់*សុនខមួយក្បាលត្រូវបានចុះឈ្មោះឱ្យបោះឆ្នោត*នៅរដ្ឋ California ហើយសន្លឹកឆ្នោតវាត្រូវបានរាប់ទៀតផង! ខណៈដែលរដ្ឋធំៗផ្សេងទៀតអាចបញ្ចប់ការរាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលនៅយប់បោះឆ្នោត រដ្ឋ California ឯណេះវិញត្រូវចំណាយពេលយ៉ាងលំបាកលំបិនដល់ 30 ថ្ងៃ។ យើងតែងតែជារដ្ឋចុងក្រោយគេនៅក្នុងប្រទេសដែលឈប់រាប់សន្លឹកឆ្នោត ហើយរាយការណ៍ពីលទ្ធផលចុងក្រោយ។ នោះជារឿងដ៏អាម៉ាស់ និងមិនអាចទទួលយកបានឡើយ។ អ្នកសមនឹងទទួលបានប្រព័ន្ធបោះឆ្នោតដ៏ល្អឥតខ្ចោះមួយដែល*មានសុវត្ថិភាព ប្រសិទ្ធិភាព សុក្រឹតភាព និងអាចចូលប្រើប្រាស់បាន*ចំពោះតែអ្នកបោះឆ្នោតដែលមានសិទ្ធិប៉ុណ្ណោះ។ ក្នុងនាមជារដ្ឋលេខាធិការ ខ្ញុំនឹងខិតខំប្រឹងប្រែងបង្កើតនូវកំណែទម្រង់ប្រកបដោយសុភវិនិច្ឆ័យរួមមាន៖ 1) *តម្រូវឱ្យមានអត្តសញ្ញាណប័ណ្ណអ្នកបោះឆ្នោត*នៅកន្លែងបោះឆ្នោត 2) តម្រូវឱ្យសន្លឹកឆ្នោតតាមប្រៃសណីយ៍ត្រូវប្រគល់ជូនវិញនៅថ្ងៃបោះឆ្នោត 3) ហាមឃាត់មិនឱ្យអ្នកស៊ីឈ្នួលឃោសនាបោះឆ្នោតធ្វើ "ការប្រមូលសន្លឹកឆ្នោត" នោះឡើយ។ រដ្ឋលេខាធិការក៏មានតួនាទីក្នុងការជួសជុលបរិយាកាសអាជីវកម្មរបស់រដ្ឋ California ផងដែរ។ ការិយាល័យត្រូវតែធ្វើទំនើបកម្ម និងធ្វើឱ្យមានលក្ខណៈងាយស្រួលសម្រាប់អាជីវកម្ម។ ក្នុងនាមជារដ្ឋលេខាធិការ ខ្ញុំនឹងប្រឆាំងនឹងគោលនយោបាយអាជីវកម្មមិនល្អដែលធ្វើឱ្យការរស់នៅរដ្ឋ California ត្រូវចំណាយខ្ពស់ និងបណ្តេញក្រុមគ្រួសារ មិត្តភក្តិ និងនិយោជករបស់យើងចេញ។ ខ្ញុំមានបទពិសោធន៍ក្នុងការសម្រេចកិច្ចការ។ ខ្ញុំបានបម្រើការជាសមាជិកសភារដ្ឋ California, ជាអភិបាលក្រុង Irvine, ជាអ្នកមើលការខុសត្រូវនៅខោនធី Orange, និងមានអាជីវកម្មផ្ទាល់ខ្លួនផងដែរ។ ខ្ញុំសូមសន្យាការពារសន្លឹកឆ្នោតរបស់អ្នកក្នុងនាមជារដ្ឋលេខាធិការ។ សូមស្វែងយល់បន្ថែមតាម *WagnerforCalifornia.com*។

4100 MacArthur Blvd., Ste. 310, Newport Beach, CA 92660 | ទូរស័ព្ទ: (714) 785-5949
អ៊ីមែល: donwagner@WagnerForCalifornia.com | WagnerForCalifornia.com



### Shirley N. Weber | ប្រជាធិបតេយ្យ

*ខ្ញុំនឹងមិនបោះបង់ចោលការការពារសិទ្ធិបោះឆ្នោតរបស់អ្នកឡើយ។* យើងមិនស្ថិតក្នុងពេលវេលាធម្មតានោះទេ។ យើងត្រូវការមេដឹកនាំដ៏រឹងមាំ ដើម្បីក្រោកឈរឡើងតស៊ូដើម្បីភាពត្រឹមត្រូវនិងយុត្តិធម៌។ ខ្ញុំកើតនៅក្នុងសម័យ Jim Crow ភាគខាងត្បូងក្នុងគ្រួសារកសិករដែលមិនអាចបោះឆ្នោតបាន។ រដ្ឋ California បានបើកចំហរទទួលស្វាគមន៍ពួកយើង ហើយបានក្លាយជាផ្ទះរបស់ខ្ញុំតាំងពីពេលនោះមក។ ឪពុកម្តាយរបស់ខ្ញុំបានបោះឆ្នោតលើកដំបូងនៅទីនេះ ហើយថែមទាំងបានប្រើបន្ទប់ទទួលភ្ញៀវប្រចាំគ្រួសារយើងជាកន្លែងបោះឆ្នោតទៀតផង។ អាមេរិកគឺជាប្រទេសតែមួយគត់ក្នុងលោកដែលក្នុងរយៈពេលមួយជំនាន់ គ្រួសារមួយអាចផ្លាស់ប្តូរពីការត្រូវដកហូតសិទ្ធិបោះឆ្នោតក្នុងសម័យ Jim Crow ទៅជាការរៀបចំការបោះឆ្នោតនៅក្នុងរដ្ឋធំបំផុតប្រចាំប្រទេស។ យើងបានមកដល់ចំណុចយ៉ាងឆ្ងាយ ហើយខ្ញុំបានឃើញវាដោយផ្ទាល់ភ្នែក។ ទោះយ៉ាងណាក៏ដោយ មនុស្សមួយចំនួនចង់ឱ្យវឌ្ឍនភាពនោះដើរថយក្រោយទៅវិញ។ ពួកគេចង់ឱ្យចំនួនម៉ោងបោះឆ្នោតខ្លីជាងមុន ចំនួនថ្ងៃបោះឆ្នោតតិចជាងមុន និងចង់ឱ្យមានការលុបចោលសន្លឹកឆ្នោតតាមប្រៃសណីយ៍។ ពួកគេមួយចំនួនថែមទាំងបានគំរាមកំហែងដល់អាយុជីវិតរបស់មន្ត្រីរៀបចំការបោះឆ្នោត នៅពេលបេក្ខជនដែលពួកគេពេញចិត្តចាញ់ទៀតផង។ នៅរដ្ឋ California ឥរិយាបថនេះនឹងមិនត្រូវបានអត់ឱនឱ្យនោះឡើយ។ ក្នុងនាមជារដ្ឋលេខាធិការ ការបោះឆ្នោតទូទាំងរដ្ឋនិងការបោះឆ្នោតពិសេសចំនួន 28 ត្រូវបានរៀបចំឡើងដោយជោគជ័យ។ នៅពេលសិទ្ធិបោះឆ្នោតរបស់យើងត្រូវបានវាយប្រហារ ខ្ញុំបានតស៊ូដើម្បីពួកយើងរាល់គ្នានៅក្នុងតុលាការ ហើយបានទទួលជ័យជម្នះ។ ខ្ញុំជាអ្នកដឹកនាំប្រកបដោយតម្លាភាព ពីព្រោះការជឿទុកចិត្តគឺជាអ្វីៗគ្រប់យ៉ាង។ ប្រជាជន California គ្រប់រូបដែលមានសិទ្ធិបោះឆ្នោតគួរទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត មិនថាយើងមាននិន្នាការនយោបាយស្របគ្នាឬអត់នោះទេ។ ខ្ញុំនឹងបន្តតស៊ូដើម្បីធានាថា គ្មានអ្វីនៅរារាំងអ្នកមិនឱ្យទៅកាន់ប្រអប់ឆ្នោតនោះទេ។ សូមបោះឆ្នោតជ្រើសរើស បណ្ឌិត. Shirley N. Weber ជារដ្ឋលេខាធិការ។ សូមចូលមើល *www.DrShirleyWeber.com* ដើម្បីស្វែងយល់បន្ថែម។

អ៊ីមែល: info@drshirleyweber.com
Facebook: facebook.com/ShirleyWeber4SOS | X: x.com/drweber4ca

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## រដ្ឋលេខាធិការ



### Michael Feinstein | បៃតង

រដ្ឋ California គឺជាកន្លែងដ៏ស្រស់ស្អាត ដែលសម្បូរទៅដោយភាពចម្រុះនៃមនុស្ស គំនិត និងទស្សនៈផ្សេងៗ។ យើងធ្វើបានល្អបំផុតនៅពេលមនុស្សទាំងអស់ត្រូវបានស្តាប់ឮ និងមានអ្នកតំណាង។ អ្នកគ្រប់គ្នាសមនឹងទទួលបានកៅអីមួយនៅតុលទ្ធិប្រជាធិបតេយ្យរបស់យើង។ ការបោះឆ្នោតឱ្យលោក Michael Feinstein ដែលជាអតីតចៅហ្វាយក្រុង Santa Monica គឺជាការបោះឆ្នោតគាំទ្រ*ច្បាប់ស្តីពីសិទ្ធិប្រជាធិបតេយ្យ*៖ (1) *ការបោះឆ្នោតជម្រើសតាមចំណាត់ថ្នាក់*។ ផ្តល់អំណាចដល់អ្នកបោះឆ្នោតជាមួយនឹងសំឡេងច្រើនជាជាងបេក្ខជនច្រើន ការធ្វើយុទ្ធនាការវិជ្ជមាន និងការកសាងសម្ព័ន្ធភាព។ (2) *លទ្ធិប្រជាធិបតេយ្យពហុបក្ស*។ ជំនួសឱ្យប្រព័ន្ធអ្នកឈ្នះកាន់កាប់ទាំងអស់លក្ខណៈ "រើសយកអ្នកណាអាក្រក់តិចជាង" ដែលមានស្រាប់របស់យើង *សូមអនុវត្តការបោះឆ្នោតតំណាងតាមសមាមាត្រ ដែលអ្នកបោះឆ្នោតដែលមានគំនិតដូចគ្នាទទួលបានការតំណាងតាមសមាមាត្រទៅនឹងចំនួនរបស់ពួកគេ ហើយអ្នកបោះឆ្នោតទាំងអស់អាចជួយជ្រើសរើសបេក្ខជនដែលតំណាងឱ្យទស្សនៈរបស់ពួកគេពិតប្រាកដ*។ ពហុទស្សនវិស័យឈ្នះតំណាងមកពីមណ្ឌលតែមួយ។ *យើងទទួលបានផលចំណេញពីប្រាជ្ញានៃភាពចម្រុះរបស់យើង*។ (3) *កំណែទម្រង់ហិរញ្ញវត្ថុយុទ្ធនាការ*។ បញ្ឈប់ឥទ្ធិពលពុករលួយនៃ Big Money ហើយធានាឲ្យបាននូវការបញ្ចេញព័ត៌មានពេញលេញ។ *កាត់បន្ថយចំណាយលើការឈរឈ្មោះបោះឆ្នោត និងធានាថាអ្នកបោះឆ្នោតទាំងអស់ទទួលបានព័ត៌មានចាំបាច់ ដើម្បីធ្វើការសម្រេចចិត្តប្រកបដោយចំណេះដឹងគ្រប់គ្រាន់*។ ផ្តល់សេចក្តីថ្លែងការណ៍របស់បេក្ខជនដោយឥតគិតថ្លៃនៅក្នុងសេចក្តីណែនាំផ្លូវការសម្រាប់អ្នកបោះឆ្នោត ហើយប្រើប្រាស់បណ្តាញរលកអាកាសសាធារណៈរបស់យើង ដើម្បីជូនដំណឹងដល់អ្នកបោះឆ្នោតអំពីជម្រើសបោះឆ្នោតទាំងអស់។ *ផ្តល់ឱ្យបេក្ខជននូវមូលដ្ឋានទូលំទូលាយពីជំនួយថវិកាដែលស្អាតស្អំ*។ ផ្គូផ្គងថវិកាចំណែករបស់ម្ចាស់ជំនួយតូចៗជាមួយមូលនិធិសាធារណៈ។ ផ្តល់អំណាចដល់ប្រជាពលរដ្ឋដោយប្រើប័ណ្ណទឹកប្រាក់ ប្រជាធិបតេយ្យ ដើម្បីផ្តល់មូលនិធិដល់បេក្ខជន។ *លទ្ធិប្រជាធិបតេយ្យរបស់យើងពិតជាមានតម្លៃ*។ (4) *ភាពសុចរិតនៃការបោះឆ្នោត។ សន្លឹកឆ្នោតទាំងអស់ត្រូវតែរាប់—ហើយសន្លឹកឆ្នោតទាំងអស់ត្រូវតែមានតម្លៃ*។ លើកកម្ពស់តម្លាភាព សុក្រឹតភាព និងភាពគួរឱ្យទុកចិត្តជាមួយនឹងឧបករណ៍បោះឆ្នោតប្រភពបើកចំហគ្រប់គ្រងដោយរដ្ឋ សន្លឹកឆ្នោតជាក្រដាស និងការធ្វើសវនកម្មប្រកបដោយអត្ថន័យ។ (5) *ធានាសិទ្ធិបោះឆ្នោតសម្រាប់ទាំងអស់គ្នា*។ ការចុះឈ្មោះអ្នកបោះឆ្នោតជាសកល។ ពង្រីកលទ្ធភាពប្រើប្រាស់ភាសា។ ធ្វើឱ្យការបោះឆ្នោតកាន់តែងាយស្រួលដោយប្រកាសយកថ្ងៃបោះឆ្នោតជាថ្ងៃឈប់សម្រាករបស់រដ្ឋ។

P.O. Box 5605, Santa Monica, CA 90409 | ទូរស័ព្ទ: (310) 392-8450
អ៊ីមែល: info@feinstein4sos.org | www.feinstein4sos.org | X: www.twitter.com/feinstein4sos



### Gary N. Blenner | បៃតង

ធុញទ្រាន់នឹងរដ្ឋាភិបាលដែលស្តាប់តែផលប្រយោជន៍នាយទុនជាជាងមនុស្សដែលធ្វើការមែនទេ? ចម្លើយគឺត្រូវកែខៃប្រព័ន្ធបោះឆ្នោត និងពង្រីកប្រជាធិបតេយ្យ។ ការតំណាងតាមសមាមាត្រ។ ការបោះឆ្នោតតាមជម្រើសដែលបានចាត់ថ្នាក់។ ការផ្តល់ហិរញ្ញវត្ថុសាធារណៈដល់យុទ្ធនាការ។ បញ្ចប់ភាពជាបុគ្គលសាជីវកម្ម។ សូមបោះឆ្នោតឱ្យ Left Unity Slate នៅថ្ងៃទី 2 ខែមិថុនា! *blenner4sos.org*

4540 American River Drive, Sacramento, CA 95864
អ៊ីម៉ែល: blenner4sos@gmail.com | Facebook: Gary Blenner For California Secretary of State

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អ្នកត្រួតពិនិត្យ

- ក្នុងនាមជាប្រធានមន្ត្រីសារពើពន្ធរបស់រដ្ឋ បម្រើការជាគណនេយ្យករ និងជាអ្នកកត់ត្រាបញ្ជីហិរញ្ញវត្ថុសម្រាប់មូលនិធិសាធារណៈទាំងអស់របស់រដ្ឋ។
- គ្រប់គ្រងប្រព័ន្ធប្រាក់បៀវត្សរបស់រដ្ឋ និងច្បាប់អចលនទ្រព្យដែលមិនមានម្ចាស់កម្មសិទ្ធិ ព្រមទាំងធ្វើសវនកម្ម និងពិនិត្យមើលប្រតិបត្តិការរបស់រដ្ឋ។
- បម្រើនៅក្នុងក្រុមប្រឹក្សាភិបាលសមភាព ក្រុមប្រឹក្សាភិបាលគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល និងគណៈកម្មការផ្សេងៗទៀត។

---



### Meghann Adams | សន្តិភាព និងសេរីភាព

នៅក្នុងសេដ្ឋកិច្ច $4 ទ្រីលានរបស់California ហេតុអ្វីបានជាយើងរាប់លាននាក់បានទទួលប្រាក់កម្រៃត្រឹមតែមួយរស់ៗ? ក្នុងនាមជាប្រធានសហជីពអ្នកបើកបរឡានក្រុងសាលារៀន SMART 1741 នៅទីក្រុងSan Francisco ខ្ញុំមានបទពិសោធន៍ច្រើនឆ្នាំក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់សហជីព និងមានកំណត់ត្រាក្នុងការតស៊ូដើម្បីសមាជិករបស់ខ្ញុំទប់ទល់នឹងការវាយប្រហាររបស់មហាសេដ្ឋីលើប្រព័ន្ធសាលារៀនរបស់យើង។ ក្នុងនាមជាអ្នកត្រួតពិនិត្យរបស់អ្នក ខ្ញុំនឹងតស៊ូដើម្បីដោះស្រាយវិបត្តិនៃលទ្ធភាពទិញ បិទចន្លោះប្រហោងពន្ធសាជីវកម្ម និងដាក់ចេញផែនការវិនិយោគឡើងវិញរបស់រដ្ឋ California ដើម្បីដកយកប្រាក់សោធននិវត្តន៍សាធារណៈពីសង្គ្រាម និងវិនិយោគឡើងវិញលើលំនៅឋាន និងថាមពលបៃតង។ ដល់ពេលដែលត្រូវដាក់ទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹកសន្ធាប់របស់យើងដើម្បីធ្វើការសម្រាប់កម្មករដែលបង្កើតវា។ បោះឆ្នោតឱ្យគណបក្សសង្គមនិយម - យើងអាចរួមគ្នាកសាងរដ្ឋ California សម្រាប់ប្រជាជន មិនមែនសម្រាប់មហាសេដ្ឋីទេ! *LeftUnitySlate.org Meghann4CA.com*

ទូរស័ព្ទ: (510) 543-1789 | អ៊ីមែល: info@megann4ca.com
Instagram: @meghann4ca | https://www.meghann4ca.com/

---



### Malia M. Cohen | ប្រជាធិបតេយ្យ

ក្នុងនាមជាអ្នកត្រួតពិនិត្យរដ្ឋ California លោកស្រី Malia Cohen បម្រើការជាប្រធានមន្ត្រីហិរញ្ញវត្ថុរបស់រដ្ឋ ដោយការពារហិរញ្ញវត្ថុរបស់ប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេទីបួនរបស់ពិភពលោក។ លោកស្រីកំពុងឈរឈ្មោះសម្រាប់ការបោះឆ្នោតឡើងវិញ ដើម្បីធានាថាប្រាក់របស់អ្នកជាប់ពន្ធត្រូវបានគ្រប់គ្រងដោយមានតម្លាភាព ការទទួលខុសត្រូវ និងភាពយុត្តិធម៌។ ដោយបានកើត និងធំធាត់នៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ម៉ាលីយ៉ា យល់ច្បាស់អំពីការសន្យារបស់រដ្ឋ California និងភាពបន្ទាន់នៃការការពារវាសម្រាប់មនុស្សជំនាន់ក្រោយ។ ក្នុងនាមជាម្តាយដែលធ្វើការ ជាអ្នកប្រជាធិបតេយ្យពេញមួយជីវិត និងជាអ្នកបម្រើសាធារណៈដែលមានការលះបង់ លោកស្រីជឿជាក់ថា ថវិកាគឺជាឯកសារសីលធម៌ដែលគួរឆ្លុះបញ្ចាំងពីតម្លៃរួមរបស់យើង និងវិនិយោគលើមនុស្ស មិនមែនផលប្រយោជន៍ពិសេសនោះទេ។ ក្នុងនាមជាអ្នកត្រួតពិនិត្យ, Malia បានពង្រឹងតម្លាភាពហិរញ្ញវត្ថុដោយពង្រីកការចូលមើលជាសាធារណៈនៃទិន្នន័យហិរញ្ញវត្ថុ និងប្រាក់បៀវត្សរ៍ ដោយផ្តល់ឱ្យប្រជាជន California នូវទិដ្ឋភាពច្បាស់លាស់អំពីរបៀបដែលដុល្លារសាធារណៈត្រូវបានចំណាយ។ លោកស្រីបានចេញផ្សាយរបាយការណ៍សាច់ប្រាក់ប្រចាំខែទាន់ពេលវេលា ដើម្បីជួយរក្សាភាពរឹងមាំផ្នែកហិរញ្ញវត្ថុរបស់រដ្ឋ California កំឡុងពេលមានភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច, បានបង្រួបបង្រួមខោនធីទាំង 58 ជាមួយនឹងទ្រព្យសម្បត្តិរាប់លានដុល្លារដែលមិនទាន់មានអ្នកទាមទារ និងបានផ្តល់កិត្តិយសដល់រដ្ឋាភិបាលក្នុងមូលដ្ឋានចំពោះឧត្តមភាពក្នុងការរាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។ លោកស្រីក៏បានជំរុញការធ្វើទំនើបកម្មប្រព័ន្ធបើកប្រាក់បៀវត្សរ៍របស់រដ្ឋ California ដែលហួសពេលជាយូរមកហើយ ដើម្បីបម្រើដល់បុគ្គលិកសាធារណៈទូទាំងរដ្ឋបានកាន់តែប្រសើរ។ នៅពេលដែលទំនុកចិត្តលើរដ្ឋាភិបាលមានសារៈសំខាន់ជាងពេលណាៗទាំងអស់, Malia Cohen ប្តេជ្ញាការពារអនាគតហិរញ្ញវត្ថុរបស់រដ្ឋ California និងធ្វើឱ្យក្តីស្រមៃរបស់រដ្ឋ California ក្លាយជាការពិតសម្រាប់សហគមន៍ទាំងអស់។ ចូលរួមជាមួយគ្រូបង្រៀន គិលានុបដ្ឋាយិកា បុគ្គលិកថែទាំសុខភាព វិស្វករប្រតិបត្តិការ ជាងទឹក ជាងបំពង់ កម្មករអគ្គិសនី និងកម្មករនៅទូទាំងរដ្ឋ California ក្នុងការគាំទ្រ Malia Cohen សម្រាប់តំណែងអ្នកគ្រប់គ្រង។ ស្វែងយល់បន្ថែមនៅ៖ *MaliaCohenForCA.com*

Instagram: https://www.instagram.com/malia.cohen | Facebook: https://www.facebook.com/MaliaCohen

---

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន

## អ្នកត្រួតពិនិត្យ



**Herb W Morgan** | សាធារណរដ្ឋ

រដ្ឋ California បានត្រៀមខ្លួនរួចជាស្រេចសម្រាប់យុគសម័យថ្មីនៃតម្លាភាពហិរញ្ញវត្ថុ និងការត្រួតពិនិត្យទំនើប។ ក្នុងនាមជាអ្នកត្រួតពិនិត្យរដ្ឋ ខ្ញុំនឹងអនុវត្តតម្លាភាពយ៉ាងខ្លាំងនៅទូទាំងរដ្ឋ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន—ដោយការផ្សព្វផ្សាយការចំណាយកម្រិតប្រតិបត្តិការតាមអ៊ីនធឺណិតជាមួយនឹងការរាយការណ៍ស្ទើរតែភ្លាមៗ ដើម្បីឱ្យប្រជាជន California គ្រប់រូបអាចមើលឃើញយ៉ាងច្បាស់ពីរបៀបដែលមូលនិធិសាធារណៈត្រូវបានប្រើប្រាស់។ នៅពេលដែលការពិតអាចមើលឃើញដោយមនុស្សគ្រប់គ្នា ការជជែកវែកញែកអំពីការចំណាយក៏ស្ងប់ស្ងាត់ ហើយទំនុកចិត្តលើរដ្ឋាភិបាលក៏កើនឡើង។ ការផ្ដោតសំខាន់របស់ខ្ញុំគឺការធ្វើទំនើបកម្ម និងការទទួលខុសត្រូវ។ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប យើងអាចធ្វើឱ្យប្រតិបត្តិការមានភាពរលូន ជំរុញកំណែទម្រង់ដែលមានអត្ថន័យ និងធានាថាធនធានបានទៅដល់ថ្នាក់រៀន សហគមន៍ និងកម្មវិធីដែលសំខាន់បំផុត។ ដោយមានបទពិសោធន៍ជិតបួនទសវត្សរ៍ក្នុងការត្រួតពិនិត្យការវិនិយោគ និងប្រព័ន្ធហិរញ្ញវត្ថុស្មុគស្មាញ ខ្ញុំនឹងនាំមកនូវការគ្រប់គ្រងប្រកបដោយវិន័យ និងភាពជាអ្នកដឹកនាំជាក់ស្ដែងដល់ទីក្រុង Sacramento—នូវការពង្រឹងវប្បធម៌នៃការអាណិតអាសូររបស់រដ្ឋ California ដោយធ្វើឱ្យប្រាក់ដុល្លារសាធារណៈនីមួយៗដំណើរការកាន់តែឆ្លាតវៃ លឿនជាងមុន និងមានប្រសិទ្ធភាពជាងមុនសម្រាប់ប្រជាជនដែលខ្លួនបម្រើ។

អ៊ីមែល: info@herbmorgan.com | X: @herb4controller | Instagram: @herb4controller

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្ដីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្ដល់ជូនសេចក្ដីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្ដីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្ដីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អ្នកចាត់ចែងធនធានហិរញ្ញវត្ថុ

- ក្នុងនាមជាធនាគារិករបស់រដ្ឋ គ្រប់គ្រងការវិនិយោគរបស់រដ្ឋ និងគ្រប់គ្រងការលក់បណ្ណកម្ចីរដ្ឋ និងមូលប័ត្រ។
- បម្រើការក្នុងគណៈកម្មការជាច្រើន ដែលភាគច្រើនទាក់ទងនឹងការធ្វើទីផ្សារមូលប័ត្របំណុល។
- បង់មូលនិធិរបស់រដ្ឋនៅពេលចំណាយដោយអ្នកត្រួតពិនិត្យ និងភ្នាក់ងាររដ្ឋដទៃ។



### Eleni Kounalakis | ប្រជាធិបតេយ្យ

ខ្ញុំជាអ្នកជំនួញស្រី អ្នកជំនាញហិរញ្ញវត្ថុ និងជាកូនស្រីរបស់ជនអន្តោប្រវេសន៍ជនជាតិក្រិច។ ខ្ញុំជឿជាក់លើក្តីស្រមៃ California ហើយក្នុងនាមជាអភិបាលរង ខ្ញុំបានខិតខំប្រឹងប្រែងគាំទ្រដល់អាជីវកម្មខ្នាតតូច ការអប់រំ និងឱកាសសម្រាប់គ្រួសារដែលខិតខំធ្វើការ។ ខ្ញុំកំពុងឈរឈ្មោះជាហេរញ្ញិករដ្ឋ ដើម្បីក្លាយជាអ្នកគ្រប់គ្រង ហិរញ្ញវត្ថុរបស់រដ្ឋកាលីហ្វ័រញ៉ាដែលមានវិន័យ និងទទួលខុសត្រូវ ដោយផ្តោតលើការការពារគ្រួសារកម្មករ ការពង្រឹងសេដ្ឋកិច្ចរបស់យើង និងការធ្វើការវិនិយោគដ៏ឆ្លាតវៃដែលឆ្លុះបញ្ចាំងពីតម្លៃរបស់យើង។ ខ្ញុំកំពុងឈរឈ្មោះជាជាហេរញ្ញិករដ្ឋដើម្បី៖ *សាងសង់លំនៅឋានដែលមានតម្លៃសមរម្យដោយប្រើប្រាស់ ហិរញ្ញវត្ថុសាធារណៈ។ ប្រយុទ្ធប្រឆាំងនឹងការវាយប្រហាររបស់លោក Trump ទៅលើការថែទាំសុខភាព និងជនអន្តោប្រវេសន៍របស់យើង។ ការពារប្រាក់សោធននិវត្តន៍របស់ប្រជាជន California ដែលខិតខំធ្វើការ។ វិនិយោគលើអនាគតហិរញ្ញវត្ថុរបស់កុមារ និងគ្រួសារ។* ខ្ញុំមានការគាំទ្រពីអភិបាល Gavin Newsom, សមាជិកព្រឹទ្ធសភា Alex Padilla, សមាជិកព្រឹទ្ធសភា Adam Schiff និងអ្នកនាំពាក្យ Nancy Pelosi។ ខ្ញុំក៏ទទួលបានការគាំទ្រ និងការយល់ព្រមពីគ្រូបង្រៀនរដ្ឋ California ជាង 450,000 នាក់ផងដែរ។ អ្នកពន្លត់អគ្គីភ័យ អ្នកសង្គ្រោះបឋម និងបុគ្គលិកថែទាំសុខភាពរបស់រដ្ឋ California ក៏គាំទ្របេក្ខភាពរបស់ខ្ញុំដែរ ហើយខ្ញុំសង្ឃឹមថានឹងមានការគាំទ្ររបស់អ្នកដែរ។ ក្នុងនាមជាអ្នកជំនួញស្រីម្នាក់ ខ្ញុំបានចំណាយពេលរាប់ទសវត្សរ៍ក្នុងការសាងសង់សហគមន៍លំនៅឋាន ប្រើប្រាស់ហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់លទ្ធផល។ ក្នុងនាមជាអភិបាលរងទី 50 របស់រដ្ឋ California និងជាអ្នកការទូតរបស់អតីតប្រធានាធិបតី Obama ខ្ញុំបាននាំយកជំនាញហិរញ្ញវត្ថុក្នុងពិភពលោកពិតមកដោះស្រាយបញ្ហាប្រឈមដ៏លំបាកបំផុតមួយចំនួនរបស់រដ្ឋ។ ខ្ញុំបានបង្កើតការងារថាមពលស្អាត គ្រប់គ្រងដីសាធារណៈ និងបានបោះឆ្នោតអនុម័តគ្រែថ្មីជាង 60,000 គ្រែនៅក្នុងបរិវេណមហាវិទ្យាល័យ ដើម្បីជួយកាត់បន្ថយការចំណាយសម្រាប់និស្សិត និងគ្រួសារ។ ខ្ញុំជាអ្នកតស៊ូដ៏ខ្លាំងក្លាម្នាក់ដើម្បីលទ្ធិប្រជាធិបតេយ្យ។ ខ្ញុំនៅជួរមុខប្រឆាំងនឹងការវាយប្រហាររបស់លោក Donald Trump ទៅលើសហគមន៍ជនអន្តោប្រវេសន៍ និងសេរីភាពបន្តពូជរបស់ស្ត្រី—ទាំងអស់នេះ ខណៈពេលដែលកំពុងការពារបរិស្ថានរបស់យើង និងតម្លៃស្នូលរបស់រដ្ឋ California។ *EleniForCA.com*

2443 Fillmore Street #300, San Francisco, CA 94115 | អ៊ីមែល: info@eleniforca.com
Instagram: @eleniforca | X: @eleniforca



### Glenn Turner | បៃតង

ដកខ្លួនចេញពីអំពើប្រល័យពូជសាសន៍! មូលនិធិសោធននិវត្តន៍រដ្ឋ (CalSTRS និង CalPERS) បានវិនិយោគជាង $3 ពាន់លានលើក្រុមហ៊ុនដែលធ្វើអាជីវកម្មជាមួយអ៊ីស្រាអែល។ ហេរញ្ញិករដ្ឋ California ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ពួកគេ។ យើងត្រូវតែដកខ្លួនចេញពីអ៊ីស្រាអែល ក្រុមហ៊ុនផលិតអាវុធ និងឥន្ធនៈហ្វូស៊ីល។ យើងត្រូវការពន្ធលើមហាសេដ្ឋី ការលុបបំណុលសិស្សខ្នាតធំ ប្រាក់ឈ្នួលខ្ពស់ជាងមុន ការថែទាំសុខភាពសម្រាប់ទាំងអស់គ្នា ធនាគារសាធារណៈដើម្បីជួយផ្តល់មូលនិធិដល់លំនៅឋាន និងសំណាញ់សុវត្ថិភាពសម្រាប់ 99%។ ក្នុងនាមជាម្ចាស់អាជីវកម្មខ្នាតតូចដែលចូលនិវត្តន៍ (ជាង 30 ឆ្នាំ) ខ្ញុំរៀបចំផែនការ 5–10 ឆ្នាំមុន ដោយតាមដានប្រាក់កាក់យ៉ាងប្រុងប្រយ័ត្ន។ ចូរយើងរៀបចំផែនការសម្រាប់អនាគតរបស់យើង មិនមែនសម្រាប់ភាពតឹងរ៉ឹងនោះទេ។ បោះឆ្នោត *LeftUnitySlate.org* សម្រាប់ព័ត៌មានបន្ថែម៖ *GlennTurner26.org*

P.O. Box 7005, Berkeley, CA 94707 | ទូរស័ព្ទ: (510) 527-2855
អ៊ីមែល: glennturnerforstatetreasurer@gmail.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អ្នកចាត់ចែងធនធានហិរញ្ញវត្ថុ



### David Serpa | សាធារណរដ្ឋ

*ស្វាមី។ ឪពុក។ អតីតយុទ្ធជន។ អ្នកជំនួញ។ ពលរដ្ឋដែលជាប់ពន្ធលើសកម្រិត។ www.serpaforCA.com*

ទូរស័ព្ទ: (951) 691-7798 | អ៊ីមែល: davidserpahomes@gmail.com
Facebook: https://www.facebook.com/DavidSerpaforThePeople?mibextid=wwXIfr
TikTok: tiktok.com/@davidserpaforcalifornia



### Jennifer Hawks | សាធារណរដ្ឋ

ខ្ញុំមិនមែនជាអ្នកនយោបាយអាជីពទេ ហើយទស្សនៈនោះហើយជាមូលហេតុដែលខ្ញុំឈរឈ្មោះជាបេក្ខភាពហិរញ្ញិករដ្ឋ California។ ក្នុងនាមជាអ្នករស់នៅ Silicon Valley តាំងពីឆ្នាំ 1983 ខ្ញុំបានឃើញរដ្ឋ California រីកចម្រើន បង្កើតថ្មី និងប្រឈមមុខនឹងបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុកាន់តែស្មុគស្មាញ។ ខ្ញុំបានចិញ្ចឹមគ្រួសាររបស់ខ្ញុំនៅទីនេះ ធ្វើការនៅក្នុងអង្គការធំៗ និងបម្រើការនៅក្នុងក្រុមប្រឹក្សាភិបាលសហគមន៍ និងសាធារណៈ ដែលជាកន្លែងថវិកាត្រូវតែមានតុល្យភាព ហើយការសម្រេចចិត្តមានផលវិបាកពិតប្រាកដ។ បទពិសោធន៍ទាំងនោះបានបង្រៀនខ្ញុំថា គោលបំណងល្អគឺមិនគ្រប់គ្រាន់ទេ។ ការគ្រប់គ្រងហិរញ្ញវត្ថុដ៏រឹងមាំតម្រូវឱ្យមានវិន័យ ការតាមដាន និងការទទួលខុសត្រូវ។ បញ្ហាប្រឈមផ្នែកសារពើពន្ធរបស់រដ្ឋ California មិនបានកើតឡើងក្នុងមួយយប់នោះទេ។ ពួកវាគឺជាលទ្ធផលនៃការសម្រេចចិត្តអស់រយៈពេលជាច្រើនឆ្នាំដោយគ្មានការត្រួតពិនិត្យគ្រប់គ្រាន់ ឬវិន័យរយៈពេលវែង។ ខ្ញុំជាមនុស្សដែលយកចិត្តទុកដាក់លើព័ត៌មានលម្អិត និងជាប់លាប់ ហើយខ្ញុំជឿថា ហេរញ្ញិកមានកាតព្វកិច្ចសួរសំណួរពិបាកៗ តាមដានប្រាក់ និងផ្តល់ចម្លើយច្បាស់លាស់ដល់សាធារណជន នៅពេលដែលមានអ្វីមួយមិនសមហេតុផល។ ភាពស្មោះត្រង់ ភាពសុចរិត និងតម្លាភាព មិនមែនជាពាក្យស្លោកទេ ពួកវាគឺជាកាតព្វកិច្ចសំខាន់ៗរបស់ការិយាល័យនេះ។ ការិយាល័យហេរញ្ញិកគួរតែដំណើរការដោយមានការត្រួតពិនិត្យយ៉ាងម៉ត់ចត់ ស្តង់ដាការអនុវត្តដែលអាចវាស់វែងបាន និងតម្លាភាពពេញលេញសម្រាប់អ្នកជាប់ពន្ធ រដ្ឋាភិបាលមូលដ្ឋាន និងវិនិយោគិន។ ក្នុងនាមជាហេរញ្ញិក ខ្ញុំនឹងផ្តល់អាទិភាពដល់ការធ្វើសវនកម្មយ៉ាងហ្មត់ចត់ របាយការណ៍ច្បាស់លាស់ និងវិន័យហិរញ្ញវត្ថុជាក់ស្តែង ដើម្បីពង្រឹងមូលដ្ឋានសារពើពន្ធរបស់រដ្ឋ California។ ការិយាល័យនេះមានដើម្បីការពារថវិកាសាធារណៈ ដោយមិនគិតពីរបៀបវារៈនយោបាយ។ ការផ្តោតសំខាន់របស់ខ្ញុំនឹងផ្តោតលើអ្វីដែលល្អបំផុតសម្រាប់ប្រជាជននៃរដ្ឋ California។ ភាពជាអ្នកបម្រើប្រកបដោយការទទួលខុសត្រូវ គណនេយ្យភាព និងស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែង។ បោះឆ្នោតឱ្យ Jennifer Hawks *www.hawksforus.com*

P.O. Box 60415, Palo Alto, CA 94306 | ទូរស័ព្ទ: (650) 305-5003
អ៊ីមែល: jennifergogop@yahoo.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អ្នកចាត់ចែងធនធានហិរញ្ញវត្ថុ



### Tony Vazquez | ប្រជាធិបតេយ្យ

ខណៈពេលដែលរដ្ឋ California កំពុងប្រឈមមុខនឹងបញ្ហាប្រឈមដ៏លំបាកបំផុតមួយចំនួនរបស់ខ្លួន សន្តិសុខហិរញ្ញវត្ថុគឺជាអាទិភាពចម្បងមួយ។ ការត្រួតពិនិត្យសេដ្ឋកិច្ចធំជាងគេទីបួននៅលើពិភពលោក ទាមទារឱ្យមានគណនេយ្យភាពសារពើពន្ធដ៏រឹងមាំ នីតិវិធី និងពិធីសារយ៉ាងហ្មត់ចត់ និងការប្តេជ្ញាចិត្តដើម្បីមានភាពយុត្តិធម៌នៅក្នុងការពិនិត្យហិរញ្ញវត្ថុទាំងអស់។ អស់រយៈពេល 40 ឆ្នាំចុងក្រោយនេះ ខ្ញុំបានបូជាជីវិតរបស់ខ្ញុំដើម្បីភាពប្រសើរឡើងនៃរដ្ឋ California។ ខ្ញុំធ្លាប់បានសកម្មក្នុងមូលនិធិអប់រំ និងសហគមន៍ អភិបាលកិច្ចមូលដ្ឋាន និងក្រុង ក្នុងនាមជាសមាជិកក្រុមប្រឹក្សាក្រុង និងជាអភិបាលក្រុង Santa Monica ព្រមទាំងតំណាងទូទាំងរដ្ឋក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ California។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ខ្ញុំបានបម្រើការជាប្រធាន BOE និងបម្រើការនៅក្នុង Franchise Tax Board. ដែលតំណាងឱ្យអ្នកជាប់ពន្ធទូទាំងរដ្ឋ និងនៃស្រុកទី 3 ដែលជាខោនធីមានប្រជាជនច្រើនជាងគេបំផុតនៅក្នុងរដ្ឋ។ ខ្ញុំជឿថា អាទិភាពចម្បងដែលរដ្ឋ California កំពុងប្រឈមមុខនៅពេលនេះ គឺលំនៅឋានដែលមានតម្លៃសមរម្យ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ នៅ BOE ខ្ញុំបានផ្តួចផ្តើមគម្រោង ការធ្វើអោយប្រសើរឡើង និងប្រសិទ្ធិភាព សម្រាប់ដំណើរការលើកលែងពន្ធ ការអនុវត្ត និងនីតិវិធីរបស់យើង ហើយបានផ្តួចផ្តើមយុទ្ធនាការអប់រំដើម្បីជូនដំណឹងដល់អ្នកដាក់ពាក្យសុំលំនៅឋានដែលមានចំណូលទាបអំពីរបៀបទាមទារការលើកលែងពន្ធលើអចលនទ្រព្យ។ ខ្ញុំនាំមកកាន់បេក្ខភាពរបស់ខ្ញុំនូវទស្សនៈពិសេសមួយអំពីអ្វីដែលល្អបំផុតសម្រាប់រដ្ឋ California។ ខ្ញុំស្រឡាញ់រដ្ឋ California។ ភាពចម្រុះនៃចំនួនប្រជាជនទូទាំងពិភពលោកតែមួយគត់ និងសម្រស់ធម្មជាតិរបស់វាបានក្លាយជាមេដែកទាក់ទាញសម្រាប់អ្នកដែលមកទស្សនាទាំងអស់។ ប្រសិនបើត្រូវបានជ្រើសរើសជាហេរញ្ញិករដ្ឋ California ខ្ញុំនឹងលះបង់ការយកចិត្តទុកដាក់ទាំងស្រុងរបស់ខ្ញុំទៅលើការត្រួតពិនិត្យសារពើពន្ធយ៉ាងច្បាស់លាស់ វិធីសាស្រ្តច្នៃប្រឌិតចំពោះបញ្ហាប្រឈមធំៗ និងការអភិវឌ្ឍក្រុមអ្នកជំនាញដ៏ល្បីល្បាញ ដើម្បីជួយរដ្ឋ California ឱ្យឆ្លើយតប និងយកឈ្នះលើបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុទាំងអស់របស់ខ្លួន។

12501 Imperial Hwy., Ste. 200, Norwalk, CA 90650 | ទូរស័ព្ទ: (310) 664-8949
អ៊ីមែល: vazquez4treasurer@tonyvazquez.org | Facebook៖ tonyvazquezca | X: @tonyvazquezca

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## អគ្គមេធាវី

- ក្នុងនាមជាប្រធានមន្ត្រីច្បាប់របស់រដ្ឋ ធានាថាច្បាប់រដ្ឋត្រូវបានអនុវត្ត និងស៊ើបអង្កេតសកម្មភាពក្លែងបន្លំ ឬខុសច្បាប់។
- ប្រធានក្រសួងយុត្តិធម៌ ដែលផ្តល់សេវាផ្លូវច្បាប់របស់រដ្ឋាភិបាលរដ្ឋ និងតំណាងឱ្យរដ្ឋក្នុងសំណុំរឿងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។
- មើលខុសត្រូវទីភ្នាក់ងារអនុវត្តច្បាប់ រួមមានមេធាវី និងអធិការមណ្ឌលខោនធី។



### Marjorie Mikels | បៃតង

ខ្ញុំជាមេធាវី មានសញ្ញាបត្របណ្ឌិតផ្នែកច្បាប់ពី UCLA, មានអាជ្ញាប័ណ្ណអនុវត្តនៅរដ្ឋ California, តុលាការ Ninth Circuit និងតុលាការកំពូលសហរដ្ឋអាមេរិក ដែលគាំទ្រដោយគណបក្ស Left Unity Slate និងគណបក្សបៃតង។ ការគាំទ្រយុត្តិធម៌ និងការទទួលខុសត្រូវ អាទិភាពរបស់ខ្ញុំ៖ លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងកាត់ទោសការរំលោភសិទ្ធិមនុស្ស; ការពារសេរីភាពនៃការនិយាយ/បញ្ឈប់ការចាប់ពិរុទ្ធនៅក្នុងថ្នាក់រៀន/គ្រប់ទីកន្លែង; រឹតបន្តឹងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និងជីវិតរបស់យើងដោយក្រុមហ៊ុនបច្ចេកវិទ្យាធំៗ; អនុវត្តការផ្លាស់ប្តូរយ៉ាងឆាប់រហ័សពីឥន្ធនៈហ្វូស៊ីល/នុយក្លេអ៊ែរ ទៅជាថាមពលកកើតឡើងវិញស្អាត; សន្តិសុខពិតប្រាកដបន្ថែមទៀតសម្រាប់មនុស្សទាំងអស់ សិទ្ធិទាំងអស់; លើកកម្ពស់ការថែទាំសុខភាពជាសកល ពន្ធលើមហាសេដ្ឋី និងកាត់បន្ថយការចំណាយយោធាដើម្បី បញ្ចប់ភាពក្រីក្រ; បញ្ឈប់ ICE និងចក្រពត្តិនិយម; ប្រយុទ្ធប្រឆាំងនឹងហ្វាស៊ីសនិយម! ការបំផុសគំនិតបន្ថែម៖ <*marjoriemikels4justice.com*>

3542 Fruitvale Ave., #129, Oakland, CA 94602
អ៊ីមែល: m4justice2026@gmail.com



### Michael E. Gates | សាធារណរដ្ឋ

គ្រួសារនៅរដ្ឋ California សមនឹងទទួលបានសុវត្ថិភាពម្តងទៀត។ ឧក្រិដ្ឋកម្មកំពុងកើនឡើង ភាពគ្មានផ្ទះសម្បែងមិនអាចគ្រប់គ្រងបាន ការក្លែងបន្លំប្រាក់របស់អ្នកជាប់ពន្ធកំពុងរីករាលដាល ហើយកុមាររបស់យើង ជាពិសេសកុមារីតូចៗ មិនកំពុងត្រូវបានការពារឡើយ។ ការិយាល័យអគ្គមេធាវីគួរតែផ្តោតលើការអនុវត្តច្បាប់ និងរក្សាសុវត្ថិភាពគ្រួសារ មិនមែនលេងនយោបាយទេ។ ខ្ញុំជាស្វាមី និងជាឪពុករបស់កូនប្រាំនាក់ ហើយដូចឪពុកម្តាយគ្រប់រូបដែរ ខ្ញុំចង់ឱ្យកូនៗរបស់យើងធំឡើងនៅក្នុងសហគមន៍ដែលមានសុវត្ថិភាព។ នោះហើយជាមូលហេតុដែលសុវត្ថិភាពសាធារណៈតែងតែជាអាទិភាពចម្បងរបស់ខ្ញុំ។ ក្នុងនាមជាមេធាវីក្រុង Huntington Beach ខ្ញុំបានតស៊ូមតិដើម្បីប្រជាជន។ ខ្ញុំបានបង្កើតកម្មវិធីចោទប្រកាន់ព្រហ្មទណ្ឌក្រុង ដែលចោទប្រកាន់បទឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងគុណភាពនៃជីវិត និងបានកាត់បន្ថយចំនួនបទឧក្រិដ្ឋកម្មដល់ពីរខ្ទង់។ យើងបានបង្ហាញថា នៅពេលដែលច្បាប់ត្រូវបានអនុវត្ត សហគមន៍នឹងរីកចម្រើន។ ក្នុងនាមជាអគ្គមេធាវី ខ្ញុំនឹងធ្វើឱ្យបទឧក្រិដ្ឋខុសច្បាប់ម្តងទៀតដោយការចោទប្រកាន់បទឧក្រិដ្ឋទាំងអស់ រួមទាំងការអនុវត្តសំណើលេខ 36 ហើយប្រើប្រាស់ច្បាប់ដើម្បីដោះស្រាយភាពគ្មានផ្ទះសម្បែងដោយធ្វើឱ្យឧក្រិដ្ឋជនទទួលខុសត្រូវ ខណៈពេលដែលនាំមនុស្សចេញពីផ្លូវរបស់យើង និងទទួលការព្យាបាល។ ខ្ញុំនឹងក្រោកឈរឡើងដើម្បីប៉ូលីស គាំទ្រការអនុវត្តច្បាប់ និងការពារពួកគេនៅពេលដែលពួកគេត្រូវបានវាយប្រហារដោយអយុត្តិធម៌។ ខ្ញុំក៏នឹងនាំយកកម្មវិធីដែលមានប្រសិទ្ធភាពដែលបានកាត់បន្ថយឧក្រិដ្ឋកម្ម និងភាពគ្មានផ្ទះសម្បែងនៅ Huntington Beach ទៅកាន់ទីក្រុងនានាទូទាំងរដ្ឋ California ផងដែរ។ ខ្ញុំនឹងកាត់ទោសយ៉ាងហ្មត់ចត់ចំពោះការក្លែងបន្លំ និងអំពើពុករលួយនៅ Sacramento ការពារសិទ្ធិឪពុកម្តាយ អនុវត្តច្បាប់ដែលរារាំងក្មេងប្រុសមិនឱ្យចូលរួមក្នុងកីឡារបស់ក្មេងស្រី និងគាំទ្រអត្តសញ្ញាណប័ណ្ណអ្នកបោះឆ្នោត។ នេះគឺជាការិយាល័យដ៏មឹងម៉ាត់។ ខ្ញុំនឹងតស៊ូដើម្បីប្រជាជន California ប្រចាំថ្ងៃ ហើយនាំមកនូវការទទួលខុសត្រូវ និងសុវត្ថិភាពត្រឡប់មករដ្ឋ California វិញ។ ស្វែងយល់បន្ថែមនៅ *www.Gates4AG.com*។

អ៊ីមែល: info@gates4ag.com | X: https://x.com/MichaelGatesESQ | Instagram: https://www.instagram.com/michael.e.gates/

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## ស្នងការធានារ៉ាប់រង

- ដឹកនាំនាយកដ្ឋានធានារ៉ាប់រង ដែលអនុវត្តច្បាប់ធានារ៉ាប់រងរដ្ឋ California និងប្រកាន់ខ្ជាប់នូវបទបញ្ញត្តិដើម្បីអនុវត្តច្បាប់។
- ផ្តល់អាជ្ញាបណ្ណ ដាក់កម្រិត និងពិនិត្យក្រុមហ៊ុនធានារ៉ាប់រង។
- ឆ្លើយសំណួរសាធារណៈ និងពាក្យបណ្តឹងអំពីវិស័យធានារ៉ាប់រង។



### Patrick Wolff | ប្រជាធិបតេយ្យ

រដ្ឋ California កំពុងស្ថិតក្នុងវិបត្តិធានារ៉ាប់រង។ យើងត្រូវការស្នងការធានារ៉ាប់រងម្នាក់ដែលមានជំនាញស៊ីជម្រៅផ្នែកធានារ៉ាប់រង និងហិរញ្ញវត្ថុដើម្បីដោះស្រាយវា ពោលគឺមិនមែនអ្នកដែលពាក់ព័ន្ធនឹងនយោបាយដែលបង្កើតបញ្ហានោះឡើយ។ ខ្ញុំមិនមែនជាអ្នកនយោបាយទេ ហើយប្រសិនបើជាប់ឆ្នោត នេះគឺជាតំណែងជាប់ឆ្នោតតែមួយគត់ដែលខ្ញុំនឹងឈរឈ្មោះឱ្យ។ ចាប់ពីឆ្នាំ 2001–2005 ខ្ញុំបានធ្វើការនៅធនាគារធំមួយ ដែលនៅទីនោះខ្ញុំបានបង្កើតអាជីវកម្មប្រឹក្សាធានារ៉ាប់រងផ្ទះ និងរថយន្ត។ ចាប់តាំងពីឆ្នាំ 2005 មក ខ្ញុំបានធ្វើការជាអ្នកវិភាគហិរញ្ញវត្ថុ ដែលក្នុងចំណោមវិស័យផ្សេងៗទៀត ខ្ញុំបានវិភាគលើទីផ្សារ និងក្រុមហ៊ុនធានារ៉ាប់រង។ ខ្ញុំយល់ដឹងច្បាស់ពីរបៀបដែលការធានារ៉ាប់រងដំណើរការ ហើយខ្ញុំកំពុងឈរឈ្មោះដើម្បីធ្វើឱ្យប្រព័ន្ធធានារ៉ាប់រងរបស់យើងមានយុត្តិធម៌ ប្រសិទ្ធភាព និងតម្លាភាព។ ស្នងការធានារ៉ាប់រងត្រូវតែជាអ្នកការពារអតិថិជន និងធានាថា នាយកដ្ឋានធានារ៉ាប់រង *មិនស្ថិតនៅក្រោមឥទ្ធិពលរបស់ក្រុមហ៊ុន*ធានារ៉ាប់រងឡើយ។ យុទ្ធនាការរបស់ខ្ញុំមិនទទួលយកប្រាក់ណាមួយពីក្រុមហ៊ុនធានារ៉ាប់រង ឬក្រុមហ៊ុនឥន្ធនៈផូស៊ីលឡើយ ហើយខ្ញុំនឹងមិនទទួលយកកាដូពីសាជីវកម្ម ឬក្រុមផលប្រយោជន៍ពិសេសណាមួយឡើយ។ មុនពេលខ្ញុំបញ្ចប់ការសិក្សានៅមហាវិទ្យាល័យក្នុងឆ្នាំ 1997 ខ្ញុំគឺជាជើងឯកលេងអុកម្នាក់: ខ្ញុំបានក្លាយជាមហាជើងឯកលេខអុក និងជាម្ចាស់ជើងឯកអុកសហរដ្ឋអាមេរិកចំនួនពីរលើក។ ខ្ញុំចេះពីរបៀបតស៊ូ និងឈ្នះនៅក្នុងស្ថានភាពលំបាក និងស្មុគស្មាញ ហើយខ្ញុំនឹងនាំយកជំនាញទាំងនោះមកប្រើប្រាស់ក្នុងតួនាទីជាស្នងការធានារ៉ាប់រង។ អ្នកអាចអានផែនការលម្អិតរបស់ខ្ញុំដើម្បីដោះស្រាយវិបត្តិការធានារ៉ាប់រងតាមរយៈ *https://patrickwolff.com/my-plan*។ ខ្ញុំនឹងមានកិត្តិយសណាស់ក្នុងការទទួលបានសំឡេងឆ្នោតពីអ្នក ហើយក្នុងនាមជាស្នងការធានារ៉ាប់រងរបស់អ្នក ខ្ញុំនឹងក្លាយជា Wolff ដែលនៅខាង*អ្នក*។ *https://patrickwolff.com/*

3450 Sacramento St. #430, San Francisco, CA 94118 | ទូរស័ព្ទ: (415) 323-6537 | អ៊ីមែល: patrick@patrickwolff.com
Instagram: https://www.instagram.com/wolffonyourside/ | X: https://x.com/WolffOnYourSide

*គ្មានរូបថតបានដាក់ជូនមកទេ*

### Stacy A. Korsgaden | សាធារណរដ្ឋ

លោកស្រី Stacy Korsgaden គឺជាអ្នកជំនាញធានារ៉ាប់រងមានអាជ្ញាបណ្ណ (អាជ្ញាបណ្ណលេខ #0750748) ជាម្ចាស់អាជីវកម្មខ្នាតតូច និងជាពលរដ្ឋ California ពេញមួយជីវិត កំពុងប្រជែងតំណែងជាស្នងការធានារ៉ាប់រង ដើម្បីបើកឱ្យមានទីផ្សារធានារ៉ាប់រងដែលមានការប្រកួតប្រជែង ដែលបម្រើដល់អ្នកប្រើប្រាស់ មិនមែនបម្រើដល់ពួកមន្ត្រីការិយាល័យឡើយ។ អស់រយៈពេលជិត 40 ឆ្នាំមកនេះ លោកស្រីបានធ្វើការដោយផ្ទាល់ជាមួយក្រុមគ្រួសារ មនុស្សចាស់ កសិករ និងអាជីវកម្មខ្នាតតូច ដើម្បីជួយពួកគេការពារផ្ទះសម្បែង ជីវភាព និងអនាគតរបស់ពួកគេ។ លោកស្រីបានឃើញផ្ទាល់ភ្នែកនូវរបៀបដែលការគ្រប់គ្រងហួសហេតុ ការបំភ័ន្តទីផ្សារ និងភាពបរាជ័យនៃការត្រួតពិនិត្យ បានធ្វើឱ្យអ្នកប្រើប្រាស់មានជម្រើសតិចតួច និងមានតម្លៃខ្ពស់ជាងមុន។ លោកស្រី Korsgaden នាំយកបទពិសោធជាក់ស្តែង មិនមែនមនោគមវិជ្ជានោះទេ មកក្នុងការងារនេះ។ ក្នុងនាមជាស្នងការធានារ៉ាប់រង Stacy នឹងតស៊ូដើម្បីទីផ្សារសេរី និងយុត្តិធម៌ ដែលនឹងស្តារការប្រកួតប្រជែងឡើងវិញ។ គោលដៅរបស់លោកស្រីគឺសាមញ្ញ កាត់បន្ថយថ្លៃចំណាយ បង្កើនជម្រើស និងទីផ្សារធានារ៉ាប់រងដ៏រឹងមាំដែលពិតជាដំណើរការសម្រាប់អ្នកប្រើប្រាស់។ លោកស្រី Stacy Korsgaden ស្នើសុំសន្លឹកឆ្នោតពីអ្នកដោយក្តីគោរព ដើម្បីនាំយកការប្រកួតប្រជែង ការទទួលខុសត្រូវ និងវិចារណញ្ញាណ ត្រឡប់មកកាន់វិស័យធានារ៉ាប់រងរដ្ឋ California វិញ។

P.O. Box 972, Grover Beach, CA 93483 | ទូរស័ព្ទ: (805) 710-0732
អ៊ីមែល: stacy@stacykorsgaden.com | X: @SKorsgaden | Facebook: Stacy Korsgaden for California Insurance Commissioner

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន

## ស្នងការធានារ៉ាប់រង



### Jane Kim | ប្រជាធិបតេយ្យ

ស្នងការធានារ៉ាប់រងគួរតែធ្វើការបម្រើអ្នកដើម្បីបញ្ចុះតម្លៃ មិនមែនធ្វើការបម្រើឧស្សាហកម្មដើម្បីបង្កើនប្រាក់ចំណេញនោះឡើយ។ ហេតុដូច្នេះហើយ ខ្ញុំនឹងមិនទទួលយកប្រាក់សូម្បីមួយសេនពីវិស័យធានារ៉ាប់រងឡើយ។ ឥឡូវនេះ ប្រព័ន្ធធានារ៉ាប់រងយើងខូចហើយ។ ក្រុមហ៊ុនធានារ៉ាប់រងដំឡើងថ្លៃសេវារបស់យើង លុបចោលការធានា និងបដិសេធសំណងរបស់យើង ខណៈពេលដែលពួកគេប្រមូលប្រាក់ចំណេញបានយ៉ាងច្រើនបំផុត។ ក្នុងនាមជាស្នងការធានារ៉ាប់រង ខ្ញុំនឹង*កំណត់កម្រិតប្រាក់ចំណេញហួសហេតុ* និង*បង្កកកម្រិតថ្លៃសេវារបស់អ្នក* នៅពេលអ្នកដាក់ពាក្យទាមទារសំណង។ ខ្ញុំនឹងបង្កើតកម្មវិធី*ធានារ៉ាប់រងគ្រោះមហន្តរាយសាធារណៈសម្រាប់ទាំងអស់គ្នា* ដើម្បីឱ្យយើងមានការការពារនៅពេលមានគ្រោះអគ្គិភ័យ ទឹកជំនន់ ឬការរញ្ជួយដីកើតឡើង។ ខ្ញុំនឹងបង្ក្រាប*ការកំណត់តម្លៃខុសច្បាប់* បញ្ឈប់ក្រុមហ៊ុនធានារ៉ាប់រងមិនឱ្យប្រើប្រាស់ពិន្ទុក្រេឌីតដើម្បីបដិសេធការធានារ៉ាប់រង និងតស៊ូដើម្បី*ការថែទាំសុខភាពដែលធានាជូនកុមារគ្រប់រូប*នៅក្នុងរដ្ឋ California។ ខ្ញុំគឺជាមេធាវីសិទ្ធិស៊ីវិល អ្នករៀបចំកម្មវិធី និងជាអ្នកតស៊ូមតិដើម្បីអ្នកប្រើប្រាស់ ហើយខ្ញុំចេះពីរបៀបដោះស្រាយបញ្ហាប្រឈមធំៗ និងឈ្នះដើម្បីគ្រួសារអ្នកធ្វើការ។ ក្នុងនាមជាអ្នកត្រួតពិនិត្យជាប់ឆ្នោតនៅទីក្រុង San Francisco ខ្ញុំបានឈ្នះ*ការផ្តល់ជូនមហាវិទ្យាល័យសហគមន៍ឥតគិតថ្លៃជាសកល ប្រាក់ឈ្នួលអប្បបរមា $15* ដំបូងគេរបស់រដ្ឋ California និង*លំនៅឋានតម្លៃសមរម្យកម្រិតខ្ពស់បំផុត*។ ខ្ញុំទទួលបានការគាំទ្រពីថ្នាក់ដឹកនាំរដ្ឋ និងថ្នាក់ជាតិ ដូចជាសមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក Bernie Sanders, អ្នកត្រួតពិនិត្យថវិកា Malia Cohen, គ្រូបង្រៀន និងបុគ្គលិកថែទាំសុខភាព ពីព្រោះពួកគេដឹងថាខ្ញុំនឹងតស៊ូដើម្បី *អ្នក*។ ដល់ពេលហើយសម្រាប់ប្រព័ន្ធធានារ៉ាប់រងមួយដែលបម្រើដល់គ្រួសារអ្នកធ្វើការ *ទាំងអស់* ហើយខ្ញុំនឹងមានកិត្តិយសណាស់ក្នុងការទទួលបានសំឡេងឆ្នោតពីអ្នក។ ចូលទៅកាន់ *JaneKim.org*ដើម្បីស្វែងយល់បន្ថែម។

371 Lakeport Blvd. #391, Lakeport, CA 95453
អ៊ីមែក: info@janekim.org | Instagram: @janekim | Facebook: https://www.facebook.com/JaneKimCA



### Sean Lee | សាធារណរដ្ឋ

លោក Sean Lee គឺជានាយកប្រតិបត្តិសេវាកម្មហិរញ្ញវត្ថុម្នាក់ដែលប្ដេជ្ញាការពារអ្នកប្រើប្រាស់ ក្រុមគ្រួសារ ម្ចាស់ផ្ទះ មនុស្សចាស់ និងអាជីវកម្មខ្នាតតូចនៅក្នុងរដ្ឋ California។ អស់រយៈពេលជាងពីរទសវត្សរ៍មកនេះ លោក Lee បានជួយបុគ្គលម្នាក់ៗ និងម្ចាស់អាជីវកម្មឱ្យយល់ដឹងពីការធានារ៉ាប់រង គ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងធ្វើការសម្រេចចិត្តដោយមានព័ត៌មានច្បាស់លាស់។ លោកបានធ្វើការជាមួយក្រុមគ្រួសារដែលប្រឈមនឹងការឡើងថ្លៃធានារ៉ាប់រង ម្ចាស់ផ្ទះដែលស្វែងរកការការពារដែលអាចទុកចិត្តបាន និងមនុស្សចាស់ដែលព្រួយបារម្ភអំពីសន្តិសុខហិរញ្ញវត្ថុ។ នៅដើមអាជីពរបស់លោក លោក Lee បានធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រនៅ JPL / NASA តាមរយៈ Caltech ដោយបានបង្កើតវិធីសាស្ត្រដែលមានវិន័យ និងផ្អែកលើទិន្នន័យដើម្បីវិភាគបញ្ហាស្មុគស្មាញ។ បន្ទាប់មក លោកបានយកជំនាញវិភាគទាំងនោះមកប្រើប្រាស់ក្នុងវិស័យធានារ៉ាប់រង និងសេវាកម្មហិរញ្ញវត្ថុ។ លោក Lee ជឿជាក់ថាស្នងការធានារ៉ាប់រងត្រូវតែជានិយតករឯករាជ្យដែលផ្តោតលើអត្រាធានារ៉ាប់រងដែលយុត្តិធម៌ ភាសានៃគោលនយោបាយច្បាស់លាស់ និងការការពារអ្នកប្រើប្រាស់ឱ្យបានរឹងមាំ។ លោកគាំទ្រតម្លាភាព ការទទួលខុសត្រូវ និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើការអនុវត្តធានារ៉ាប់រង។ លោក Lee ក៏គាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាដែលកំពុងលេចឡើងដោយមានការទទួលខុសត្រូវផងដែរ រួមទាំងបញ្ញាសិប្បនិម្មិត និង InsurTech ដើម្បីបង្កើនប្រសិទ្ធភាព និងប្រឆាំងនឹងការបន្លំ។ *ប្រសិនបើជាប់ឆ្នោត លោក Sean Lee នឹងធ្វើការដោយមិនគិតពីការនឿយហត់ ដើម្បីការពារអ្នកប្រើប្រាស់ និងពង្រឹងទីផ្សារធានារ៉ាប់រងរបស់រដ្ឋ California*។

300 Spectrum Center Drive, #400, Irvine, CA 92618 | ទូរស័ព្ទ: (213) 568-5515 | អ៊ីមែល: SeanLI@antai.us
Linkedin: www.linkedin.com/in/sean-lee-phd-0556624b/ | Facebook: www.facebook.com/ad.lee.39

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## ស្នងការធានារ៉ាប់រង



**Ben Allen** | ប្រជាធិបតេយ្យ

នៅថ្ងៃទី 7 ខែមករា ឆ្នាំ 2025 គ្រោះអគ្គិភ័យ Palisades បានផ្ទុះឡើងត្រឹមតែប៉ុន្មានម៉ាយល៍ពីផ្ទះរបស់ខ្ញុំ ដោយបានបំផ្លិចបំផ្លាញសហគមន៍ដែលខ្ញុំបានតំណាងនៅក្នុងព្រឹទ្ធសភារដ្ឋអស់រយៈពេលជាងមួយទសវត្សរ៍។ ការជួយដល់ម្ចាស់ឆ្នោតរាប់រយនាក់ដែលបានបាត់បង់អ្វីៗគ្រប់យ៉ាងឱ្យដោះស្រាយបណ្តឹងទាមទារសំណងធានារ៉ាប់រងបានជោគជ័យ បានផ្តល់ឱ្យខ្ញុំនូវបទពិសោធផ្ទាល់ចំពោះប្រព័ន្ធធានារ៉ាប់រងដែលមិនដំណើការរបស់យើង។ នៅពេលឈរនៅកណ្តាលផ្សែង ផេះ និងភាពមិនច្បាស់លាស់ ខ្ញុំបានឃើញថាភាពបរាជ័យមានលក្ខណៈដូចម្តេច។ រដ្ឋ California ត្រូវតែធ្វើឱ្យប្រសើរជាងនេះ។ ហេតុដូច្នេះហើយ ខ្ញុំកំពុងប្រជែងតំណែងជាស្នងការធានារ៉ាប់រង: ដើម្បីការពារអ្នកប្រើប្រាស់ ការពារបរិស្ថាន និងធ្វើឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះប្រជាជនដែលខ្លួនបម្រើ។ រដ្ឋ California ត្រូវការអ្នកដឹកនាំដែលមានការប្តេជ្ញាចិត្ត និងមានប្រវត្តិការងារច្បាស់លាស់ដើម្បីសម្រេចបាននូវលទ្ធផល។ ខ្ញុំមានប្រវត្តិការងារជោគជ័យជាយូរមកហើយក្នុងការបម្រើផលប្រយោជន៍សាធារណៈ: នៅក្នុងព្រឹទ្ធសភារដ្ឋ ខ្ញុំបានតតាំងជាមួយក្រុមអ្នកបញ្ចុះបញ្ចូលនៃវិស័យធានារ៉ាប់រង, បានអនុម័តច្បាប់ការពារអ្នកប្រើប្រាស់ដែលរឹងមាំបំផុតមួយចំនួននៅក្នុងប្រទេស និងបានដឹកនាំកិច្ចខិតខំប្រឹងប្រែងដើម្បីវិនិយោគថវិកាចំនួន $10 ពាន់លាន ក្នុងការបង្ការភ្លើងឆេះព្រៃ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹក និងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ ក្នុងនាមជាស្នងការធានារ៉ាប់រង អាទិភាពលេខ 1 របស់ខ្ញុំគឺការទុកអ្នកប្រើប្រាស់ជាចម្បង។ នោះមានន័យថា: *ការទាមទារឱ្យអ្នកបំពុលបរិស្ថានទទួលខុសត្រូវ: ខ្ញុំនឹងធ្វើឱ្យសាជីវកម្មដែលបំពុលបរិស្ថានទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះការខូចខាតអាកាសធាតុដែលរុញច្រានថ្លៃចំណាយលើការធានារ៉ាប់រងឱ្យឡើងថ្លៃ។ ការយកចិត្តទុកដាក់ដោយយុត្តិធម៌បន្ទាប់គ្រោះមហន្តរាយ: ខ្ញុំនឹងការពារអ្នកប្រើប្រាស់ និងតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងសម្របសម្រួលការកសាងឡើងវិញឱ្យបានឆាប់រហ័ស និងរឹងមាំ។ ការបង្ការគ្រោះមហន្តរាយនាពេលអនាគត: ខ្ញុំនឹងពន្លឿនកម្មវិធីគ្រប់គ្រងរុក្ខជាតិ និងព្រៃឈើដែលកាត់បន្ថយហានិភ័យនៃអគ្គិភ័យ និងកាត់បន្ថយថ្លៃធានារ៉ាប់រងរបស់អ្នក។ គ្មានឥទ្ធិពលពីឧស្សាហកម្ម: ខ្ញុំកំពុងបដិសេធការចូលរួមវិភាគទានពីយុទ្ធនាការឧស្សាហកម្មធានារ៉ាប់រង។* ខ្ញុំមានកិត្តិយសដែលទទួលបានការគាំទ្រពីថ្នាក់ដឹកនាំដូចជា សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក Adam Schiff, អ្នកបោះឆ្នោតបរិស្ថានរដ្ឋ California, អ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California, និងសហព័ន្ធគ្រូបង្រៀនរដ្ឋកាលីហ្វ័រញ៉ា។។ ខ្ញុំក៏សង្ឃឹមថានឹងទទួលបានការគាំទ្រពីអ្នកផងដែរ។ *benallenca.com*

1700 Tribute Rd., Suite 201, Sacramento, CA 95815 | ទូរស័ព្ទ: (805) 334-0154
អ៊ីមែល: info@benallenca.com | Instagram: @benallenca | X: @BenAllenCA



**Robert P Howell** | សាធារណរដ្ឋ

ច្រើនឆ្នាំមុនពេលមានគ្រោះអគ្គិភ័យនៅទីក្រុង Los Angeles ខ្ញុំបានព្រមានថា ប្រព័ន្ធធានារ៉ាប់រងរបស់រដ្ឋ California កំពុងបរាជ័យចំពោះមនុស្សដែលខ្លួនគួរតែការពារ។ បច្ចុប្បន្ននេះ ការបរាជ័យនោះ គឺជាសោកនាដកម្ម និងមិនអាចប្រកែកបាន។ ប្រព័ន្ធធានារ៉ាប់រងរបស់រដ្ឋ California មិនដំណើការ ហើយវាមិនមែនទើបតែបរាជ័យក្នុងរយៈពេលមួយយប់នោះទេ។ ក្រុមហ៊ុនធានារ៉ាប់រងបានប្រតិបត្តិការដោយមានការត្រួតពិនិត្យតិចតួចបំផុតអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ គោលនយោបាយត្រូវបានលុបចោល ការធានាត្រូវបានកាត់បន្ថយ និងថ្លៃធានារ៉ាប់រងត្រូវបានដំឡើង ខណៈពេលដែលអ្នកកំណត់ច្បាប់អង្គុយមើលនៅខាងក្រៅ។ ប្រជាជនរដ្ឋ California ធ្វើអ្វីគ្រប់យ៉ាងដ៏ត្រឹមត្រូវ។ ពួកគេបង់ថ្លៃធានារ៉ាប់រង និងគោរពតាមច្បាប់។ ប៉ុន្តែនៅពេលដែលពួកគេត្រូវការការធានារ៉ាប់រងបន្ទាន់ ប្រព័ន្ធនេះបែរជាបរាជ័យចំពោះពួកគេទៅវិញ។ អ្នកនយោបាយអាជីពដែលជំពាក់គុណអ្នកមានអំណាចផ្ទៃក្នុងធានារ៉ាប់រងបានបង្កើតបញ្ហាទាំងនេះ។ ខ្ញុំសន្យាថា *នឹងមិន* ទទួលយកការបរិច្ចាគផ្នែកនយោបាយពីក្រុមហ៊ុនធានារ៉ាប់រងឡើយ។ ខ្ញុំគឺជាស្វាមី ឪពុក និងជាជីតាម្នាក់។ ខ្ញុំគឺជាម្ចាស់អាជីវកម្មម្នាក់ដែលយល់ដឹងពីលទ្ធភាពចំណាយនៅក្នុងពិភពលោកពិត។ ក្នុងនាមជានាយកប្រតិបត្តិនៃក្រុមហ៊ុនផលិតសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតនៅ Silicon Valley យើងជួលកម្មករអាមេរិក និងគ្រប់គ្រងថវិកាចំណាយយ៉ាងម៉ឺងម៉ាត់។ ការបោះឆ្នោតជូនលោក Robert Howell ធ្វើជាស្នងការធានារ៉ាប់រង នឹងធានាបាននូវអ្នកត្រួតពិនិត្យឯករាជ្យសម្រាប់អ្នកប្រើប្រាស់។ ខ្ញុំនឹងទាមទារឱ្យក្រុមហ៊ុនធានារ៉ាប់រងទទួលខុសត្រូវចំពោះច្បាប់ និងតតាំងការអនុវត្តដែលរំលោភបំពាន។ ខ្ញុំនឹងអនុវត្ត “សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិរបស់អ្នកបង់ថ្លៃធានារ៉ាប់រង” ដើម្បីការពារម្ចាស់គោលការណ៍ធានារ៉ាប់រងពីការលុបចោលដោយអយុត្តិធម៌ និងការដំឡើងថ្លៃដែលមិនសមហេតុផល។ យើងសមនឹងទទួលបានស្នងការធានារ៉ាប់រងម្នាក់ដែលអនុវត្តច្បាប់ និងឆ្លើយតបចំពោះប្រជាជន។ ប្រជាជននៅរដ្ឋ California ទូទៅត្រូវតែជាអាទិភាពចម្បង។ ខ្ញុំទទួលយកការទទួលខុសត្រូវនោះយ៉ាងម៉ឺងម៉ាត់បំផុត។ *សូមបោះឆ្នោតជូន Robert Howell ធ្វើជាស្នងការធានារ៉ាប់រងនៃរដ្ឋ California។* ម្យ៉ាងវិញទៀត . . . ប្រជាជននៅរដ្ឋ California ច្រើនជាង 5.4 លាននាក់ បានបោះឆ្នោតជូន Robert Howell ធ្វើជាស្នងការធានារ៉ាប់រងកាលពីឆ្នាំ 2022។ លើកនេះ ពួកយើងមកឈ្នះទាំងអស់គ្នា! *ElectRobertHowell.com CRAgop.org*

1145 Ardsley Ct., San Jose, CA 95120 | ទូរស័ព្ទ: (408) 629-7600
អ៊ីមែល: robert.howell@reagan.com | electroberthowell.org

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន

## ស្នងការធានារ៉ាប់រង

### Eduardo “Lalo” Vargas | សន្តិភាពនិងសេរីភាព



ជារៀងរាល់ឆ្នាំ ប្រជាជននៅរដ្ឋ California បង់ថ្លៃធានារ៉ាប់រងកាន់តែខ្ពស់ សម្រាប់តែការធានារ៉ាប់រងតិចតួចប៉ុណ្ណោះ។ ខ្ញុំសន្យាថានឹងបង្កកការដំឡើងអត្រាថ្លៃធានារ៉ាប់រង និងកាត់បន្ថយថ្លៃបង់ធានារ៉ាប់រង ដើម្បីស៊ើបអង្កេត និងទាមទារឱ្យនាយកប្រតិបត្តិធានារ៉ាប់រងទទួលខុសត្រូវចំពោះនីតិវិធីទាមទារសំណងដែលកេងប្រវ័ញ្ច និងដើម្បីតស៊ូសម្រាប់ប្រព័ន្ធធានារ៉ាប់រងសាធារណៈមួយដែលធានានូវការធានារ៉ាប់រងពេញលេញ និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា។ ក្នុងនាមជាអ្នកសង្គមនិយម គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ អ្នករៀបចំសហជីព អតីតអ្នកពន្លត់អគ្គិភ័យ និង EMT—ខ្ញុំមានបទពិសោធយ៉ាងទូលំទូលាយក្នុងការបម្រើប្រជាជនទូទៅ និងការយកផលប្រយោជន៍របស់ពួកគេជាចម្បង។ បោះឆ្នោតជូនអ្នកសង្គមនិយម ឆ្នាំ 2026! បោះឆ្នោតជូន *LeftUnitySlate.org*។

ទូរស័ព្ទ: (213) 770-8485 | អ៊ីមែល: info@lalovargas4ca.com
lalovargas4ca.com | @lalovargas4ca

### Merritt Farren | សាធារណរដ្ឋ



ខ្ញុំគឺ Merritt Farren ជាអ្នករស់រានមានជីវិតពីគ្រោះអគ្គិភ័យព្រៃឈើនៅរដ្ឋ California, អតីតមេធាវីក្រុមហ៊ុន Amazon, និងជាអតីតប្រធានផ្នែកច្បាប់ បណ្ដឹងទាមទារសំណងរបស់ភ្ញៀវ និងប្រតិបត្តិការសន្តិសុខសម្រាប់ Disneyland Resort។ ខ្ញុំបានបាត់បង់ផ្ទះរបស់ខ្ញុំនៅក្នុងគ្រោះអគ្គិភ័យ Pacific Palisades ហើយបានឃើញដោយផ្ទាល់ភ្នែកនូវភាពមិនដំណើការនៃប្រព័ន្ធធានារ៉ាប់រងរបស់យើង។ បន្ទាប់ពីមានអគ្គិភ័យកើតឡើង ខ្ញុំបានចូលរួមក្នុងដំណើរការដំឡើងអត្រាការប្រាក់របស់ State Farm ដើម្បីតំណាងឱ្យផលប្រយោជន៍អ្នកប្រើប្រាស់។ រដ្ឋ California កំពុងស្ថិតចំណុចកណ្ដាលនៃវិបត្តិធានារ៉ាប់រង។ មនុស្សរាប់លាននាក់—ទាំងបុគ្គល ក្រុមគ្រួសារ និងអាជីវកម្ម—មិនអាចទទួលបានការធានារ៉ាប់រងដែលយើងត្រូវការនោះទេ។ អ្នកដែលអាចទទួលបាន កំពុងប្រឈមមុខនឹងការឡើងថ្លៃយ៉ាងគំហុក ហើយការប្រព្រឹត្តទៅលើអ្នកប្រើប្រាស់បន្តកាន់តែអាក្រក់ទៅៗ។ តើរឿងនេះអាចកើតឡើងដោយរបៀបណា? រដ្ឋ California គឺជាមជ្ឈមណ្ឌលដ៏អស្ចារ្យបំផុតរបស់ពិភពលោកក្នុងការដោះស្រាយបញ្ហាប្រកបដោយការផ្លាស់ប្ដូរថ្មី។ វិស័យឯកជនរបស់យើងគឺល្អលើសគេ។ ប៉ុន្តែនៅពេលនិយាយដល់ការកែទម្រង់ការធានារ៉ាប់រង រដ្ឋាភិបាលរបស់យើងបានបរាជ័យចំពោះយើង។ ខ្ញុំមានបទពិសោធន៍នៅក្រុមហ៊ុនចំនួនពីរដែលមានការផ្លាស់ប្ដូរថ្មីៗ និងផ្ដោតលើអតិថិជនបំផុតក្នុងពិភពលោក គឺ Amazon និង Disney។ ក្រុមហ៊ុនទាំងពីរយល់ឃើញថា ការយកអតិថិជនជាចម្បងមិនមែនជាការដាក់កម្រិតលើភាពជោគជ័យនោះទេ វាគឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីជំរុញវា។ ខ្ញុំចង់នាំមកនូវការផ្លាស់ប្ដូរថ្មីដែលផ្ដោតលើអតិថិជនដែលខ្ញុំបានរៀនសូត្រ មកកាន់ការត្រួតពិនិត្យការធានារ៉ាប់រងនៅរដ្ឋ California។ មិនមែនជាការផ្លាស់ប្ដូរបន្តិចបន្តួចនៅផ្នែកខាងក្រៅនោះទេ។ ប៉ុន្តែគឺជាការកែទម្រង់ពិតប្រាកដ។ ការកែទម្រង់ដែលពង្រីកជម្រើសធានារ៉ាប់រងរបស់អ្នក កាត់បន្ថយថ្លៃចំណាយរបស់អ្នក និងរក្សាសុវត្ថិភាពគ្រួសាររបស់អ្នក។ បោះឆ្នោតជូនខ្ញុំធ្វើជាស្នងការធានារ៉ាប់រង ហើយអ្នកនឹងឃើញការគិតយ៉ាងម៉ឺងម៉ាត់ និងសកម្មភាពដែលមិនរារែកដែលយើងត្រូវការ—ទាំងក្នុងការធានារ៉ាប់រងផ្ទះ សុខភាព អាជីវកម្ម និងយានយន្ត។ អូ ម្យ៉ាងទៀត ខ្ញុំកំណត់ខ្លួនឯងថា ជាបេក្ខជនតម្លៃនៅរដ្ឋ California។ ខ្ញុំឱ្យតម្លៃបំផុតលើអ្វីដែលពលរដ្ឋ California ឱ្យតម្លៃបំផុត: នោះគឺសុទិដ្ឋិនិយម ភាពច្នៃប្រឌិត ការទទួលខុសត្រូវផ្ទាល់ខ្លួន សុវត្ថិភាពសម្រាប់សហគមន៍របស់យើង សេរីភាពបុគ្គល និងសេចក្ដីមេត្តាចំពោះអ្នកដទៃ។ សូមអរគុណពីខ្ញុំ Merritt

26565 West Agoura Road, Suite 200, Calabasas, CA 91302 | អ៊ីមែល: Merritt@MerrittFarrenca.com
@MerrittFarrenCA | Facebook: www.facebook.com/MerrittFarrenCA

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្ដីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្ដល់ជូនសេចក្ដីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្ដីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្ដីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## ស្នងការធានារ៉ាប់រង



### Steven Craig Bradford | ប្រជាធិបតេយ្យ

Steve Bradford កំពុងប្រជែងតំណែងជាស្នងការធានារ៉ាប់រងនៃរដ្ឋ California ដើម្បីស្តារស្ថិរភាព ភាពយុត្តិធម៌ និងលទ្ធភាពចំណាយទៅកាន់ទីផ្សារធានារ៉ាប់រងរបស់រដ្ឋ California ឡើងវិញ។ ក្នុងនាមជាអតីតព្រឹទ្ធសភារដ្ឋ និងជាមន្ត្រីសាធារណៈម្នាក់ លោក Bradford នាំយកបទពិសោធរាប់ទសវត្សរ៍ក្នុងរដ្ឋាភិបាល និងការរៀបចំគោលនយោបាយមកកាន់តួនាទីដ៏សំខាន់នេះ រួមទាំងការបម្រើការងារនៅក្នុងគណៈកម្មាធិការធានារ៉ាប់រងនៃនីតិបញ្ញត្តិរដ្ឋ ដែលលោកបានជួយបង្កើតការឯកភាពគ្នាលើបញ្ហាប្រឈមនៃបទប្បញ្ញត្តិដ៏ស្មុគស្មាញ។ លោក Bradford ជឿជាក់ថា មិនគួរមានប្រជាជននៅរដ្ឋ Californiaណាម្នាក់ប្រឈមមុខនឹងការបំផ្លិចបំផ្លាញផ្នែកហិរញ្ញវត្ថុ បន្ទាប់ពីមានគ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស ឬធម្មជាតិនោះទេ ហើយលោកនឹងធ្វើការសហការជាមួយក្រុមហ៊ុនធានារ៉ាប់រង និយតកររដ្ឋាភិបាលក្នុងតំបន់ និងអ្នកប្រើប្រាស់ ដើម្បីធ្វើឱ្យទីផ្សារមានស្ថិរភាព បញ្ចុះតម្លៃធានារ៉ាប់រងឱ្យកាន់តែសមរម្យ និងបញ្ឈប់ក្រុមហ៊ុនធានារ៉ាប់រងមិនឱ្យលុបចោលការធានារ៉ាប់រងរបស់ពលរដ្ឋ California។ ផែនការរបស់ Steve រួមមានការនាំយកតម្លាភាពមកកាន់ការកំណត់ថ្លៃធានារ៉ាប់រង ការផ្តល់រង្វាន់ដល់អ្នកដែលការពារផ្ទះសម្បែងរបស់ខ្លួន ការកសាងទីផ្សារធានារ៉ាប់រងឡើងវិញនៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់ និងការធ្វើឱ្យអត្រាថ្លៃសេវាមានភាពសមហេតុផល។ លោក Bradford នឹងគាំទ្រដល់ការផ្លាស់ប្តូរដែលមានសុវត្ថិភាពជាងមុនសម្រាប់អ្នកដែលប្រឈមនឹងហានិភ័យបំផុត ធ្វើទំនើបកម្មនាយកដ្ឋានធានារ៉ាប់រង និងដាក់សមធម៌ជាអាទិភាពចម្បង។ ពេញមួយអាជីពរបស់គាត់ លោក Bradford បានតស៊ូដើម្បីក្រុមគ្រួសារអ្នកធ្វើការ ការទទួលបានការថែទាំសុខភាពដោយសមធម៌ ឱកាសសេដ្ឋកិច្ច និងការការពារអ្នកប្រើប្រាស់។ លោកបានតាក់តែងច្បាប់ដើម្បីពង្រីកការទទួលបានការថែទាំសុខភាព លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការពារសហគមន៍ទូទាំងរដ្ឋ ហើយមានប្រវត្តិច្បាស់លាស់ក្នុងការលើកកម្ពស់ប្រជាជន California ដែលខ្វះខាតសេវា។ ហេតុដូច្នេះហើយ ទើបលោក Bradford ទទួលបានការគាំទ្រពីសមាជិកបក្សប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន ក្រុម Teamsters កម្មករសំណង់ និងថ្នាក់ដឹកនាំដូចជារដ្ឋលេខាធិការ Shirley Weber, ហេរញ្ញិកដ្ឋ Fiona Ma, សមាជិកសភា Adam Gray, អតីតប្រធានព្រឹទ្ធសភារដ្ឋ Toni Atkins—ពីព្រោះពួកគេទទួលស្គាល់នូវភាពជាអ្នកដឹកនាំ ភាពសុចរិត និងការតស៊ូមតិមិនឈប់ឈររបស់លោកសម្រាប់ការទទួលខុសត្រូវ និងទីផ្សារធានារ៉ាប់រងមួយដែលដំណើរការបានល្អ។ ត្រឹមថ្ងៃទី 2 ខែមិថុនា សូមបោះឆ្នោតជូន Steve Bradford ធ្វើជាស្នងការធានារ៉ាប់រង។ *ស្វែងយល់បន្ថែមតាមរយៈ www.bradfordforcalifornia.com*

អ៊ីមែល: info@bradfordforcalifornia.com
X: https://x.com/stevebradford | Facebook: https://www.facebook.com/BradfordForCalifornia/

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# ក្រុមប្រឹក្សាភិបាលមណ្ឌលសមភាពរដ្ឋ CALIFORNIA

## ខោនធីនៅក្នុងក្រុមប្រឹក្សាភិបាលមណ្ឌលសមភាពនីមួយៗ

**មណ្ឌល 1**

Alpine, Amador, Butte, Calaveras, Colusa, El Dorado, Fresno, Glenn, Inyo, Kern, Kings, Lassen, Madera, Mariposa, Merced, Modoc, Mono, Nevada, Placer, Plumas, Sacramento, San Bernardino, San Joaquin, Shasta, Sierra, Siskiyou, Solano, Stanislaus, Sutter, Tehama, Tulare, Tuolumne, Yolo, Yuba

**មណ្ឌល 2**

Alameda, Contra Costa, Del Norte, Humboldt, Lake, Marin, Mendocino, Monterey, Napa, San Benito, San Francisco, San Luis Obispo, San Mateo, Santa Barbara, Santa Clara, Santa Cruz, Sonoma, Trinity, Ventura

**មណ្ឌល 3**

Los Angeles

**មណ្ឌល 4**

Imperial, Orange, Riverside, San Bernardino, San Diego



# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## ក្រុមប្រឹក្សាភិបាលសមភាព

បម្រើការឱ្យក្រុមប្រឹក្សាភិបាលសមភាព គណៈកម្មការពន្ធដារជាប់ឆ្នោតរបស់រដ្ឋ ដែល:
- វាយតម្លៃទ្រព្យសម្បត្តិរបស់ផ្លូវរថភ្លើងដែលមានការគ្រប់គ្រង និងសេវាទឹកភ្លើងសាធារណៈជាក់លាក់ និងវាយតម្លៃ និងប្រមូលពន្ធលើទូររថភ្លើងឯកជន។
- មើលការខុសត្រូវការអនុវត្តការវាយតម្លៃរបស់អ្នកវាយតម្លៃប្រចាំខោនធីទាំង 58 របស់រដ្ឋ។
- វាយតម្លៃ និងប្រមូលពន្ធលើភេសជ្ជៈមានជាតិស្រា និងរួមគ្នាគ្រប់គ្រងពន្ធលើក្រុមហ៊ុនធានារ៉ាប់រង។

## មណ្ឌល 1



### Donald E. Williamson | ប្រជាធិបតេយ្យ

បទពិសោធន៍ ជាង 35 ឆ្នាំ ។ លោក Donald Williamson ទទួលបានវិញ្ញាបនបត្រចំនួន 4 -ពីក្រុមប្រឹក្សាសមភាពរដ្ឋ (B.O.E.)។ • វិញ្ញាបនបត្រអ្នកវាយតម្លៃអចលនទ្រព្យ • វិញ្ញាបនបត្រផ្នែកវាយតម្លៃអចលនទ្រព្យអចិន្ត្រៃយ៍ • វិញ្ញាបនបត្រអ្នកវាយតម្លៃអចលនទ្រព្យកម្រិតខ្ពស់ B.O.E. • អ្នកបង្រៀន B.O.E.—បង្រៀនថ្នាក់ផ្តល់វិញ្ញាបនបត្រដល់អ្នកវាយតម្លៃអចលនទ្រព្យ • ទីប្រឹក្សា B.O.E. អនុប្រធានអ្នកវាយតម្លៃអចលនទ្រព្យ—B.O.E. សញ្ញាបត្រជាន់ខ្ពស់ ។ ជាប់ឆ្នោតជាប្រធានអ្នកវាយតម្លៃអចលនទ្រព្យប្រចាំខោនធី San Bernardino ចំនួន 3 អាណត្តិ។ អាទិភាពទី 1 គឺ "សេវាសាធារណៈល្អ"—បានជួយដល់ជនរងគ្រោះដោយអគ្គិភ័យជាង 30,000 នាក់។ ប្រធានអ្នកវាយតម្លៃអចលនទ្រព្យ លោក Williamson ព្រមទាំងបុគ្គលិកដ៏ឆ្នើមរបស់គាត់មានវត្តមាននៅមជ្ឈមណ្ឌលការជម្លៀស និងចុះមូលដ្ឋានផ្ទាល់ជារៀងរាល់ថ្ងៃ។ ទទួលបានការសម្របសម្រួលការស្នាក់នៅជាផ្លូវការ។ • តវ៉ាប្រឆាំងនឹង B.O.E.: ទទួលបានជ័យជម្នះ—ជួយការពារទីក្រុង អាជីវកម្ម និងម្ចាស់ផ្ទះចល័ត/ម្ចាស់លំនៅឋាន • រក្សាការងារបានជាង 900 កន្លែងនៅ Victorville និង Ontario • ប្រធានអ្នកវាយតម្លៃអចលនទ្រព្យ លោក Donald Williamson បានជួយដល់មនុស្សចាស់ ព្រះវិហារសាសនា អតីតយុទ្ធជនពិការ និង (VFW)—American Legion ឱ្យទទួលបានការលើកលែងពន្ធពេញលេញរបស់ពួកគេ។ • ប្រធានអ្នកវាយតម្លៃអចលនទ្រព្យ លោក Williamson បានគាំទ្រការបង្កើនជំនួយសម្រាប់ម្ចាស់ផ្ទះ/អ្នកជួលផ្ទះដែលជាមនុស្សចាស់ និងជនពិការ។ បានជួយដល់មនុស្សចាស់ចំនួន 10,000,000 នាក់នៅទូទាំងរដ្ឋ។ • បានកាត់បន្ថយរាល់ការវាយតម្លៃពន្ធលើសលប់ទាំងអស់ ស្របតាមសំណើច្បាប់ 8 និង R&T ក្រមចំណូល និងពន្ធដារ ហើយនឹងបន្តធ្វើដូច្នេះម្តងទៀត។ បានបង្កើតគណៈកម្មាធិការត្រួតពិនិត្យថវិកា—ចំណាយតិចជាងថវិកាគ្រោងទុកពេញមួយរយៈពេល 12 ឆ្នាំ។ ប្រធានពីអតីតៈ: សមាគមប្រធានអ្នកវាយតម្លៃអចលនទ្រព្យរដ្ឋ ភាគកណ្តាលនៃរដ្ឋ California ខាងត្បូង អតីតយុទ្ធជន: កងទ័ពជើងទឹកសហរដ្ឋអាមេរិក USMC—SEMPER FI, Kiwanis: អតីត ភិបាលរង, ធ្វើជាប្រធាន 7 ដង, នាយក: កម្មវិធីស្បៀងអាហារសម្រាប់គ្រួសារខ្វះខាត, ជួយដល់មូលនិធិ Ronald McDonald House មន្ទីរពេទ្យសម្រាកព្យាបាល និងសិស្សានុសិស្ស។ Elks: សមាជិកស្ថាបនិក, សមាជិក American Legion។ រៀបការបាន 49 ឆ្នាំ: ភរិយាឈ្មោះ Martha។ កូនប្រុស: Dale, James និង Donald II។ ទទួលបានការគាំទ្រជាផ្លូវការពី: Mark Westwood—ប្រធានសមាគមអ្នករស់នៅផ្ទះចល័ត Yucaipa។ ទទួលបានការគាំទ្រជាផ្លូវការពី Tim Prince សមាជិកសភាប្រចាំគណៈកម្មាធិការកណ្តាលគណបក្សប្រជាធិបតេយ្យ។ ទទួលបានការគាំទ្រពីសមាជិកសហជីព Teamsters AFL-CIO—ដូចជា ក្រុមអ្នកពន្លត់អគ្គិភ័យ កម្មករសំណង់ ជាងឈើ វិស្វករ អ្នកជំនាញវិជ្ជាជីវៈ និងគិលានុបដ្ឋាយិកា។ ទទួលបានការគាំទ្រពី: គ្រូបង្រៀន អតីតយុទ្ធជន មនុស្សចាស់ ម្ចាស់ផ្ទះ និងអ្នកជួលផ្ទះ។ "ខ្ញុំនឹងធ្វើជាសំឡេងតំណាងឱ្យអ្នកនៅទូទាំងរដ្ឋ" សូមបោះឆ្នោតជូនលោក Donald Williamson សម្រាប់ក្រុមប្រឹក្សាសមភាពរដ្ឋ **មណ្ឌល** 1

29102 Rosewood Lane, Highland, CA 92346 | ទូរស័ព្ទ: (909) 709-9448 | អ៊ីមែល: dwmson44@msn.com



### Nader F Shahatit | សាធារណរដ្ឋ

ខ្ញុំបាទ Nader Shahatit គឺជាទីប្រឹក្សាពន្ធដារ និងជាអ្នកតស៊ូមតិយ៉ាងសកម្មដើម្បីសិទ្ធិអ្នកបង់ពន្ធ ដែលប្តេជ្ញាចិត្តក្នុងការកសាងប្រព័ន្ធពន្ធដារមួយប្រកបដោយភាពយុត្តិធម៌ និងសមភាពសម្រាប់ពលរដ្ឋ California ទាំងអស់។ ខ្ញុំនឹងការពារសំណើច្បាប់ 13 ហើយនាំយកនូវការផ្លាស់ប្តូរថ្មីដែលជំរុញដោយបញ្ញាសិប្បនិម្មិតទំនើប មកអនុវត្តក្នុងរដ្ឋបាលពន្ធដាររបស់យើងដើម្បីធ្វើឱ្យសេវាកម្មកាន់តែសាមញ្ញ រហ័ស និងងាយស្រួលប្រើប្រាស់សម្រាប់ពលរដ្ឋជាង 10 លាននាក់ នៅក្នុង**មណ្ឌល**មួយ ក៏ដូចជានៅទូទាំងរដ្ឋ California។ សន្លឹកឆ្នោតរបស់អ្នកគឺជាសំឡេងរបស់អ្នក។ ខ្ញុំស្នើសុំដោយក្តីគោរពនូវឱកាសនេះដើម្បីទទួលបានការគាំទ្រពីអ្នករាល់គ្នា ដោយមិនគិតពីនិន្នាការនយោបាយឡើយ។

28793 Beattie St., Highland, CA 92346 | ទូរស័ព្ទ: (909) 936-0515
អ៊ីមែល: shahatitnader@yahoo.com | shahatit4boe2026.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## ក្រុមប្រឹក្សាភិបាលសមភាព

### មណ្ឌល 1



**Nelson Esparza** | ប្រជាធិបតេយ្យ

លោក Nelson Esparza គឺជាមន្ត្រីបម្រើការងារសាធារណៈដ៏មានការលះបង់ម្នាក់ និងជាអ្នកតស៊ូមតិដ៏ល្បីល្បាញសម្រាប់ក្រុមគ្រួសារវណ្ណៈពលករនៅរដ្ឋ California។ ដោយធំដឹងក្តីនៅ ជ្រលងភ្នំកណ្តាល រដ្ឋ California ជីវិតនិងអាជីពរបស់ Nelson ត្រូវបានកសាងឡើងដោយការប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅចំពោះឱកាស ភាពយុត្តិធម៌ និងភាពរុងរឿងផ្នែកសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា។ ក្នុងនាមជាអ្នកអប់រំ និងជាសាស្ត្រាចារ្យផ្នែកសេដ្ឋកិច្ចដ៏យូរឆ្នាំ លោក Nelson នឹងនាំយកនូវចំណេះដឹងផ្នែកសេដ្ឋកិច្ចពិតប្រាកដ មកកាន់ក្រុមប្រឹក្សាពន្ធដាររដ្ឋ California។ នៅក្នុងក្រុមប្រឹក្សាក្រុង Fresno គាត់បម្រើការជាប្រធានគណៈកម្មាធិការហិរញ្ញវត្ថុ និងសវនកម្ម—ដែលជាកន្លែងគាត់ដោះស្រាយបញ្ហាហិរញ្ញវត្ថុស្មុគស្មាញជារៀងរាល់ថ្ងៃ។ លើសពីនេះទៅទៀត គាត់បានទាក់ទាញការវិនិយោគរាប់រយលានដុល្លារសម្រាប់សហគមន៍របស់យើង។ លោក Nelson កំពុងប្រជែងតំណែងជាក្រុមប្រឹក្សាភិបាលសមភាពរដ្ឋដើម្បីធានាថាប្រព័ន្ធពន្ធរបស់រដ្ឋ California មានភាពយុត្តិធម៌ ហើយថាក្រុមហ៊ុនសាជីវកម្មនានា និងអ្នកមានស្តុកស្តម្ភនឹងបង់ចំណែកពន្ធដែលត្រឹមត្រូវរបស់ពួកគេ។ លោក Nelson នឹងតស៊ូដើម្បីលុបបំបាត់ចន្លោះប្រហោងនៃច្បាប់ពន្ធ និងបង្ក្រាបអ្នកគេចពន្ធ ដើម្បីធានាថារដ្ឋាភិបាលក្នុងតំបន់របស់យើងអាចបន្តវិនិយោគលើវិស័យអប់រំ ការថែទាំសុខភាព សុវត្ថិភាពសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍសេដ្ឋកិច្ច។ ក្នុងពេលជាមួយគ្នានេះ គាត់នឹងប្រឆាំងចំពោះការយកពន្ធថ្មីៗទៅលើក្រុមគ្រួសារវណ្ណៈកណ្តាល និងវណ្ណៈពលករដែលកំពុងជួបប្រទះនឹងការលំបាកក្នុងការផ្គត់ផ្គង់ជីវភាពរួចទៅហើយនោះ។ គាត់នឹងតស៊ូដើម្បីឱ្យកាន់តែមានតម្លាភាពនៅក្នុងប្រព័ន្ធពន្ធរបស់យើង និងសម្រាប់ការវាយតម្លៃពន្ធអចលនទ្រព្យប្រកបដោយភាពយុត្តិធម៌ និងមិនលម្អៀង។ លោក Nelson ទទួលបានការគាំទ្រពីគ្រូបង្រៀន គិលានុបដ្ឋាយិកា មន្ត្រីអនុវត្តច្បាប់ និងថ្នាក់ដឹកនាំជាច្រើននៅកម្រិតមូលដ្ឋាន កម្រិតរដ្ឋ និងសហព័ន្ធទូទាំងមណ្ឌលរបស់យើង—ដោយសារតែពួកគេដឹងថាគាត់មានបទពិសោធន៍ និងការតាំងចិត្តខ្ពស់ក្នុងការការពារប្រាក់ពន្ធ និងសេវាសាធារណៈរបស់យើង។ ត្រឹមថ្ងៃទី 2 ខែមិថុនា សូមបោះឆ្នោតជូនលោក Nelson Esparza សម្រាប់ក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ—និងស្វែងយល់បន្ថែមនៅគេហទំព័រ *nelsonesparza.com*។

អ៊ីមែល: nelson@nelsonesparza.com
Facebook: facebook.com/esparzanelson | Instagram: @esparzaforBOE



**Shannon Grove** | សាធារណរដ្ឋ

តើនេះមិនទាន់ដល់ពេលទៀតឬដែលមនុស្សធម្មតាគួរមានសំឡេង នៅពេលដែលពួកគេត្រូវការជំនួយពីរដ្ឋាភិបាលរដ្ឋរបស់យើងនៅ Sacramento នេះ? នោះហើយជាមូលហេតុដែលខ្ញុំកំពុងប្រជែងតំណែងជាក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ។ វាគឺជាការិយាល័យមួយដែលអ្នកប្រហែលជាមិនធ្លាប់បានឮនោះទេ ថាវាមានភារកិច្ចជួយប្រជាពលរដ្ឋ នៅពេលដែលពួកគេគិតថារដ្ឋាភិបាលបានយកពន្ធពីពួកគេដោយអយុត្តិធម៌។ ជាដំបូង សូមរៀបរាប់បន្តិចអំពីខ្លួនខ្ញុំ។ ខ្ញុំធំដឹងក្តីនៅខោធី Kern។ បន្ទាប់ពីបញ្ចប់វិទ្យាល័យ ខ្ញុំបានចូលបម្រើក្នុងកងទ័ពសហរដ្ឋអាមេរិក ហើយបន្ទាប់ពីបញ្ចប់ការបម្រើការងារនោះ ខ្ញុំបានចាប់ផ្តើមអាជីវកម្មខ្នាតតូចមួយ ដែលជួយមនុស្សក្នុងមូលដ្ឋានឱ្យស្វែងរកការងារដែលមានប្រាក់បៀវត្សល្អ។ ក្នុងនាមជាម្ចាស់អាជីវកម្ម ខ្ញុំធ្លាប់ឆ្លងកាត់បទពិសោធនៃការខិតខំប្រឹងប្រែងដោះស្រាយជាមួយបទប្បញ្ញត្តិរដ្ឋាភិបាល និងបែបបទរដ្ឋបាលដ៏ស្មុគស្មាញមិនចេះចប់មិនចេះហើយ។ ក្រោយមក ខ្ញុំបានឈរឈ្មោះ ហើយឈ្នះអាសនៈក្នុងសភា និងបន្ទាប់មកគឺព្រឹទ្ធសភារដ្ឋ។ នៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ខ្ញុំត្រូវបានគេស្គាល់ថាជាអ្នកមានសំឡេងដ៏រឹងមាំរបស់គណបក្សទាំងពីរសម្រាប់សុវត្ថិភាពសាធារណៈ។ ជាពិសេស ខ្ញុំបានដឹកនាំយុទ្ធនាការដើម្បីធ្វើឱ្យការជួញដូរផ្លូវភេទលើកុមារក្លាយជាបទឧក្រិដ្ឋធ្ងន់ធ្ងរ។ នេះត្រូវបានចុះហត្ថលេខាជាច្បាប់ ហើយឥឡូវនេះកំពុងជួយការពារពលរដ្ឋ California ដែលងាយរងគ្រោះបំផុតរបស់យើង។ ខ្ញុំក៏ធ្លាប់ជាសំឡេងតំណាងឱ្យម្ចាស់អាជីវកម្មខ្នាតតូច កសិករ និងម្ចាស់កសិដ្ឋានចិញ្ចឹមសត្វផងដែរ។ ជាញឹកញាប់អាជីវកម្មទាំងនេះដំណើរការដោយក្រុមគ្រួសារ ដែលជាផ្នែកដ៏សំខាន់សម្រាប់រដ្ឋរបស់យើង។ ខ្ញុំបានខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយច្បាប់ ពន្ធ និងថ្លៃសេវាដែលមិនយុត្តិធម៌ ហើយធ្វើឱ្យអាជីវកម្មកាន់តែងាយស្រួលក្នុងការចាប់ផ្តើម រីកចម្រើន និងដើម្បីជួលបុគ្គលិកបន្ថែមទៀត។ ក្នុងនាមជាតំណាងរបស់អ្នកនៅក្នុងក្រុមប្រឹក្សាសមភាព គោលដៅរបស់ខ្ញុំគឺច្បាស់លាស់: ដើម្បីធានាថាអ្នកមានកន្លែងណាមួយសម្រាប់ពឹងពាក់ នៅពេលដែលអ្នកជឿថាអ្នកត្រូវបានគេយកពន្ធដោយអយុត្តិធម៌ និងត្រូវការជំនួយមួយចំនួន។ នោះគឺជាការសន្យារបស់ខ្ញុំចំពោះអ្នក។

អ៊ីមែល: press@shannongroveca.com
Facebook: https://www.facebook.com/ShannonGroveForCA/ | Instagram: https://www.instagram.com/shannongrove4ca

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## ក្រុមប្រឹក្សាភិបាលសមភាព

### មណ្ឌល 2



**John Pimentel** | ប្រជាធិបតេយ្យ

ក្រុមគ្រួសារនៅរដ្ឋ California កំពុងប្រឈមមុខនឹងការកើនឡើងថ្លៃចំណាយ និងប្រព័ន្ធពន្ធអយុត្តិធម៌។ យើងត្រូវការភាពជាអ្នកដឹកនាំជាក់ស្តែង និងមានតុល្យភាព ដែលផ្តោតលើភាពយុត្តិធម៌ តម្លៃសមរម្យ និងការទទួលខុសត្រូវ។ ខ្ញុំគឺជាសមាជិកគណបក្សប្រជាធិបតេយ្យដែលមាន*សុភវិនិច្ឆ័យ* ដែលនឹង: *បញ្ឈប់ការយកពន្ធលើការលក់អាហារ។* វាជាការដើរថយក្រោយនិងដាក់បន្ទុកលើគ្រួសារពលករមនុស្សចាស់ និងយុវជន។ *បិទចន្លោះប្រហោងពន្ធ* ដូច្នេះសាជីវកម្មធំៗ និងអ្នកមានបង់ចំណែកពន្ធរបស់ពួកគេដោយយុត្តិធម៌។ *ពង្រឹងតម្លាភាពនិងទំនួលខុសត្រូវ* ដើម្បីធានាថារដ្ឋាភិបាលរបស់យើងសក្តិសមនឹងទទួលបានការជឿទុកចិត្តពីសាធារណជន។ ខ្ញុំបានសម្រេចលទ្ធផលពេញមួយអាជីពរបស់ខ្ញុំ។ ខ្ញុំបានអភិវឌ្ឍគម្រោងថាមពលកកើតឡើងវិញលើសពី $1.5 ពាន់លាន ក្នុងវិស័យបង្កើតថាមពលពីខ្យល់ ពន្លឺព្រះអាទិត្យ ជីវឥន្ធនៈ និងការកែច្នៃទឹកឡើងវិញ—ដោយបង្កើតការងារសហជីពរាប់ពាន់កន្លែង ព្រមទាំងកាត់បន្ថយថ្លៃចំណាយលើថាមពល។ ក្នុងនាមជាអនុរដ្ឋលេខាធិការផ្នែកដឹកជញ្ជូននៃរដ្ឋ California ខ្ញុំបានអនុវត្តកិច្ចសន្យាផ្អែកលើការលើកទឹកចិត្តការផ្លាស់ប្តូរថ្មី ដែលបានសាងសង់ឡើងវិញផ្លូវហាយវេដែលខូចខាតដោយសាររញ្ជួយដីបានយ៉ាងឆាប់រហ័ស បានបង្រួបបង្រួមស្ថាប័ននានាដើម្បីលុបបំបាត់ការងារស្ទួនគ្នា និងបានពង្រីកការល្បាតតាមផ្លូវហាយវេនៅ California (CHP) ដើម្បីកែលម្អសុវត្ថិភាពសាធារណៈ។ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលមហាវិទ្យាល័យសហគមន៍ ខ្ញុំបានដឹកនាំកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតមហាវិទ្យាល័យឥតគិតថ្លៃ។ ការចុះឈ្មោះបានកើនឡើង 24% ហើយមានមនុស្សចំនួន 35,000 នាក់បានប្រើប្រាស់កម្មវិធីនេះដើម្បីកាត់បន្ថយថ្លៃចំណាយលើការសិក្សាមហាវិទ្យាល័យ ឬបង្កើនជំនាញ និងប្រាក់ចំណូលរបស់ពួកគេ។ រឿងរ៉ាវរបស់ខ្ញុំឆ្លុះបញ្ចាំងពី California’s Promise។ លោកតារបស់ខ្ញុំជាកសិករ។ ឪពុករបស់ខ្ញុំបានចូលរៀននៅសាលាមត្តេយ្យដោយមិនចេះនិយាយភាសាអង់គ្លេស។ ជំនាន់របស់ខ្ញុំជាជំនាន់ដំបូងដែលបញ្ចប់ការសិក្សាថ្នាក់មហាវិទ្យាល័យ។ ខ្ញុំបានចូលរៀននៅមហាវិទ្យាល័យសហគមន៍នៅ Stockton ហើយបានផ្ទេរទៅ UC Berkeley និងបានបញ្ចប់ថ្នាក់ឧត្តមសិក្សានៅ Harvard។ ការអប់រំសាធារណៈបានផ្លាស់ប្តូរមាគ៌ាជីវិតរបស់ខ្ញុំ។ ខ្ញុំចង់តបស្នងសងវិញ។ ខ្ញុំគ្រោងនឹងកែសម្រួលគោលនយោបាយស្តីពីពន្ធដារ និងការចំណាយដែលមិនដំណើរការរបស់រដ្ឋ California បន្ទាបថ្លៃចំណាយសម្រាប់ជីវភាពគ្រួសារពលករ និងធានាថាប្រព័ន្ធពន្ធដាររបស់យើងមានភាពយុត្តិធម៌។ *ខ្ញុំសូមគោរពស្នើសុំការបោះឆ្នោតពីអ្នក។*

20 Park Road, Suite E, Burlingame, CA 94010 | ទូរស័ព្ទ: (650) 210-6916 | អ៊ីមែល: JPimentel2020@gmail.com
Facebook: https://facebook.com/JohnPimentelCA | Instagram: https://instagram.com/johnsmcccd/



**Sally J. Lieber** | ប្រជាធិបតេយ្យ

ខ្ញុំមានកិត្តិយសក្នុងការបម្រើការជាអ្នកតំណាងរបស់អ្នកនៅក្នុងក្រុមប្រឹក្សាសមភាពរដ្ឋ California ដែលជាកន្លែងដែលខ្ញុំធ្វើការដើម្បីធ្វើឱ្យប្រព័ន្ធពន្ធរបស់យើងកាន់តែមានគណនេយ្យភាព និងតម្លាភាពសម្រាប់ពលរដ្ឋ California។ នៅក្នុងក្រុមប្រឹក្សាភិបាល ខ្ញុំបានធ្វើការដើម្បីពង្រីកការផ្សព្វផ្សាយអំពីការបន្ធូរបន្ថយពន្ធអចលនទ្រព្យ ពង្រឹងលទ្ធភាពទទួលបានការក្រេឌីតពន្ធសម្រាប់អតីតយុទ្ធជន និងគ្រួសារដែលមានប្រាក់ចំណូលទាប បង្កើនព័ត៌មានសាធារណៈអំពីច្បាប់ស្តីពីសំណើប្រជាមតិ 19 និងពង្រឹងការការពារអ្នកប្រើប្រាស់សម្រាប់ការធានារ៉ាប់រងរបស់ម្ចាស់ផ្ទះ។ ខ្ញុំបានគាំទ្រលំនៅឋានដែលមានតម្លៃសមរម្យ ការការពារការលួចអត្តសញ្ញាណសម្រាប់ម្ចាស់អចលនទ្រព្យ និងបានធានាថា ក្រុមប្រឹក្សាភិបាលបានឆ្លើយតបប្រកបដោយការទទួលខុសត្រូវ និងប្រសិទ្ធិភាពចំពោះការផ្លាស់ប្តូរច្បាប់ពន្ធដាររបស់រដ្ឋ។ ខ្ញុំមិនទទួលយកការវិភាគទានពី PAC របស់សាជីវកម្មឡើយ ហើយនឹងតែងតែទទូចឱ្យអ្នកមានទ្រព្យសម្បត្តិបង់នូវអ្វីដែលពួកគេជំពាក់។ ក្នុងរយៈពេលបួនឆ្នាំបន្ទាប់ ខ្ញុំនឹងបន្តធ្វើការដើម្បីការវាយតម្លៃលើពន្ធអចលនទ្រព្យដែលត្រឹមត្រូវ និងប្រកបដោយសមភាព ជំនួយដល់អ្នកបង់ពន្ធដែលបានពង្រីក និងគោលនយោបាយដែលគាំទ្រលំនៅឋានតម្លៃសមរម្យ ការស្តារឡើងវិញពីគ្រោះមហន្តរាយ និងស្ថិរភាពសេដ្ឋកិច្ចសម្រាប់គ្រួសារពលករ។ ក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាភិបាល ខ្ញុំបានការស្បថចូលកាន់តំណែងតាមរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក និងរដ្ឋ California រួមទាំងច្បាប់សំណើប្រជាមតិ 13 ផងដែរ។ មុនពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល ខ្ញុំបានបម្រើការនៅក្នុងស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន តំបន់ និងរដ្ឋ។ នៅក្នុងសភាតំណាងរាស្ត្ររដ្ឋ California ខ្ញុំបានតាក់តែងច្បាប់ដើម្បីដំឡើងប្រាក់ឈ្នួលអប្បបរមាទូទាំងរដ្ឋ, ការពារឆ្នេរសមុទ្ររបស់យើង និងឆ្នេរ San Francisco, ពង្រីកថាមពលកកើតឡើងវិញ, បង្កើនអាហារូបករណ៍ Cal Grant, និងបានធ្វើការដើម្បីរក្សាលទ្ធភាពចូលរៀនមហាវិទ្យាល័យសហគមន៍ដោយឥតគិតថ្លៃនៅទូទាំងរដ្ឋ។ ខ្ញុំមានមោទនភាពដែលទទួលបានការគាំទ្រពីគ្រូបង្រៀន និងអ្នកពន្លត់អគ្គីភ័យទូទាំងរដ្ឋ និងទទួលបានចំណាត់ថ្នាក់ 100% ពេញមួយជីវិតពី Planned Parenthood, Sierra Club, Congress of California Seniors និង Equality California។ អ្វីដែលសំខាន់បំផុតនោះ គឺខ្ញុំមានមោទនភាពក្នុងការបម្រើអ្នក។ ខ្ញុំសូមគោរពស្នើសុំការបោះឆ្នោតពីអ្នក។ *www.sallylieber.org*

333 W. San Carlos St., Suite 600, San Jose, CA 95110 | ទូរស័ព្ទ: (650) 597-2587
អ៊ីមែល: vote@sallylieber.org | Facebook: www.facebook.com/CAvoteSally

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## ក្រុមប្រឹក្សាភិបាលសមភាព

## មណ្ឌល 2



### Bill Shireman | សាធារណរដ្ឋ

ពន្ធរបស់រដ្ឋ California អាចមានភាពយុត្តិធម៌ អាចព្យាករណ៍បាន និងបន្ទាបឱ្យទាបតាមដែលអាចធ្វើទៅបាន—ខណៈពេលដែលផ្តល់នូវតម្លៃពិតប្រាកដសម្រាប់គ្រួសារ សហគមន៍ និងសេដ្ឋកិច្ច និងបរិស្ថាន។ ប៉ុន្តែជារឿយៗពេក អ្នកមានអំណាចមានឥទ្ធិពល និងក្រុមផលប្រយោជន៍ពិសេស បានក្តោបក្តាប់និងខ្ជះខ្ជាយថវិការបស់យើង។ ខ្ញុំបានចំណាយជីវិតការងាររបស់ខ្ញុំដើម្បីបញ្ឈប់រឿងនោះ។ ក្នុងនាមជាមន្ត្រីសាធារណៈនៃបក្សទាំងពីរនិងជាអ្នកដឹកនាំអាជីវកម្ម ខ្ញុំបានជួយកសាងប្រព័ន្ធកែច្នៃឡើងវិញដ៏ទំនើបរបស់ California—ដោយបានកាត់បន្ថយពន្ធ បង្កើតការងារ និងការពារឆ្នេរសមុទ្រ និងសត្វព្រៃរបស់យើង។ ប្រព័ន្ធនោះបង្កើតចំណូលដោយខ្លួនឯង និងបានកែច្នៃឡើងវិញ ជាងកន្លះពាន់ពាន់លាននូវកំប៉ុង ផ្លាស្ទិក កុំព្យូទ័រនិងអ្វីៗជាច្រើនទៀត ដោយមិនពឹងផ្អែកទាល់តែសោះលើប្រាក់ពន្ធ។ សព្វថ្ងៃនេះរដ្ឋ California កំពុងប្រឈមមុខនឹងវិបត្តិលទ្ធភាពទិញក្នុងកាន់តែជ្រៅ។ លំនៅឋាន ថ្លៃឈ្នួលផ្ទះ ពន្ធ និងធានារ៉ាប់រងកំពុងជំរុញឱ្យគ្រួសារនានាចាកចេញ បង្កើនភាពមិនស្មើគ្នា និងធ្វើឱ្យប៉ះពាល់ដល់សាលារៀនសាធារណៈ។ ក្រុមប្រឹក្សាភិបាលសមភាពបំពេញតួនាទីយ៉ាងសំខាន់ ប៉ុន្តែត្រូវបានគេមើលរំលង—គឺការពារម្ចាស់ផ្ទះ អនុវត្តច្បាប់ សំណើប្រជាមតិ 13 និងធានាថាពន្ធអចលនទ្រព្យមានភាពយុត្តិធម៌ និងស្របច្បាប់។ ត្រូវតែមានការការពារច្បាប់សំណើប្រជាមតិ 13—និងធ្វើទំនើបកម្ម—ដើម្បីឱ្យរដ្ឋ California ដំណើការម្តងទៀតសម្រាប់គ្រួសារពលករ និងអាជីវកម្មខ្នាតតូចជាថ្មីម្តងទៀត មិនមែនសម្រាប់តែអ្នកមានអំណាចផ្ទៃក្នុង និងមហាសេដ្ឋីនោះទេ។ នៅក្នុងក្រុមប្រឹក្សាភិបាលសមភាព ខ្ញុំនឹងក្លាយជាអ្នកអភិរក្សហិរញ្ញវត្ថុដែលមានមនសិការ: • ការពារអ្នកបង់ពន្ធពីការវាយតម្លៃដែលអយុត្តិធម៌ • លើកកម្ពស់លទ្ធភាពទទួលបានលំនៅឋានតម្លៃសមរម្យ និងឱកាស • ធានាថាពន្ធត្រូវបានគ្រប់គ្រងប្រកបដោយសមត្ថភាព និងតម្លាភាព • កែសម្រួលប្រព័ន្ធដើម្បីឱ្យយើងអាចកាត់បន្ថយ និងបង្វែរពន្ធ ដើម្បីសម្រេចបានលទ្ធផលកាន់តែច្រើនដោយចំណាយតិចជាងមុន។ កំណត់ត្រារបស់ខ្ញុំបង្ហាញថាយើងអាចកាត់បន្ថយពន្ធ និងផ្តល់តម្លៃគុណនឹងពីរទៅបួនដងសម្រាប់រាល់ប្រាក់ដុល្លារដែលបានចំណាយ។ តោះយើងធ្វើឱ្យរដ្ឋ California ដំណើរការឡើងវិញ។

អ៊ីមែល: Bill@SolutionCitizen.org | LinkedIn: linkedin.com/in/bill-shireman

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## ក្រុមប្រឹក្សាភិបាលសមភាព

### មណ្ឌល 3



**Yvonne Yiu** | ប្រជាធិបតេយ្យ

ក្នុងនាមជាអ្នកតំណាងរបស់អ្នកនៅក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ *ខ្ញុំនឹងប្រើប្រាស់បទពិសោធ 25 ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីបម្រើការជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ California ការពារថវិកាពន្ធរបស់អ្នក តាមរយៈការធ្វើសវនកម្មដើម្បីលុបបំបាត់ការខ្ជះខ្ជាយរបស់រដ្ឋាភិបាល និងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើនតម្លាភាព។ បច្ចុប្បន្ននេះ ខ្ញុំកំពុងបម្រើការនៅក្នុងគណៈកម្មាការប្រឹក្សាយោបល់ការវិនិយោគក្នុងស្រុកនៃហិរញ្ញិករដ្ឋ ដែលនៅទីនោះខ្ញុំបានជួយសហគមន៍ក្នុងការគ្រប់គ្រងការវិនិយោគ ការចំណាយលើសេវាសាធារណៈ ដូចជាប៉ូលិស និងពន្លត់អគ្គិភ័យ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបស់ពួកគេ។* ខ្ញុំបានធ្វើអន្តោប្រវេសន៍មកសហរដ្ឋអាមេរិកពីទីក្រុង Hong Kong នៅពេលដែលខ្ញុំមានអាយុ 16 ឆ្នាំបន្ទាប់ពីការស្លាប់របស់ឪពុករបស់ខ្ញុំ។ តាមរយៈការខិតខំប្រឹងប្រែង ខ្ញុំទទួលបាន *សញ្ញាបត្របរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពី UCLA , អនុបណ្ឌិត MBA ពីសាកលវិទ្យាល័យ Loyola Marymount* និងការជ្រើសតាំងជាអ្នកជំនាញផ្នែកបទប្បញ្ញត្តិ និងអនុលោមភាពដែលមានវិញ្ញាបនបត្រពី *Wharton Business School*។ *ខ្ញុំកាន់អាជ្ញាប័ណ្ណមូលបត្រចំនួន 10 ពីអាជ្ញាធរបទប្បញ្ញត្តិឧស្សាហកម្មសហព័ន្ធ (FINRA)*។ បន្ទាប់ពីបានបម្រើការងារនៅក្រុមហ៊ុនហិរញ្ញវត្ថុឈានមុខគេជាច្រើន ខ្ញុំបានបង្កើតក្រុមហ៊ុនវិនិយោគផ្ទាល់ខ្លួន ដែលមានទ្រព្យសម្បត្តិសកម្មសរុបជាង $1 ពាន់លាន។ ក្នុងនាមជាចៅហ្វាយក្រុងនៃ Monterey Park បទពិសោធផ្នែកហិរញ្ញវត្ថុ និងដំបូន្មានរបស់ខ្ញុំបានសន្សំសំចៃជាង $55 លាន ហើយបានជួយឱ្យថវិការបស់យើងមានតុល្យភាព និងបង់ថ្លៃសេវាទីក្រុង។ នៅលើក្រុមប្រឹក្សាភិបាលសមភាព ខ្ញុំនឹង *1) ការពារហិរញ្ញវត្ថុរបស់រដ្ឋ California ដោយធានាបាននូវការទទួលខុសត្រូវ និងតម្លាភាព 2) ប្រើប្រាស់សវនកម្មដើម្បីបង្ហាញ និងលុបបំបាត់ការខ្ជះខ្ជាយរបស់រដ្ឋាភិបាល និង 3) បង្កើតកម្មវិធីដើម្បីជួយប្រជាជនឱ្យសម្រេចបាននូវសន្តិសុខសេដ្ឋកិច្ច និងធ្វើឱ្យរដ្ឋ California មានតម្លៃជីវភាពរស់នៅសមរម្យ។* ក្នុងនាមជាម្តាយនៃកូនប្រុស 3 នាក់ ខ្ញុំតែងតែតស៊ូដើម្បីគ្រួសាររបស់យើងទាំងអស់គ្នា។ ខ្ញុំមិនមែនជាអ្នកនយោបាយទេ។ *ខ្ញុំគឺជាអ្នកកែទម្រង់ និងជាបេក្ខជនតែម្នាក់គត់ ដែលមានការអប់រំ បទពិសោធ និងប្រវត្តិការងារទាំងក្នុងវិស័យសាធារណៈ និងឯកជន ដើម្បីកែលម្អហិរញ្ញវត្ថុរបស់រដ្ឋ California ធានានូវការវិនិយោគឱ្យបានត្រឹមត្រូវ និងសន្សំសំចៃថវិការបស់អ្នកបង់ពន្ធ។*

988 Kingsford Street, Monterey Park, CA 91754 | ទូរស័ព្ទ: (951) 833-8185
អ៊ីមែល: yvonneyiu@yahoo.com | www.yvonneyiu.com



**Mike Gipson** | ប្រជាធិបតេយ្យ

សមាជិកសភា លោក Mike Gipson គឺជាអ្នកដឹកនាំដែលមានបទពិសោធរាប់ទសវត្សរ៍ក្នុងការតស៊ូមតិសម្រាប់គ្រួសារពលករ។ គាត់កំពុងប្រជែងតំណែងជាក្រុមប្រឹក្សាភិបាលសមភាពដើម្បីតស៊ូសម្រាប់ភាពយុត្តិធម៌ តម្លាភាព និងការទទួលខុសត្រូវ ។ លោក Mike នឹងតស៊ូដើម្បីបិទចន្លោះប្រហោងពន្ធដែលមហាសេដ្ឋី និងសាជីវកម្មកេងប្រវ័ញ្ច ដើម្បីជៀសវាងការបង់ចំណែកពន្ធសមរម្យរបស់ពួកគេ។ ដោយបានកើត និងធំធាត់ឡើងក្នុងទីក្រុង Los Angeles លោក Mike បានប្រើប្រាស់ជីវិត និងការងាររបស់លោកដើម្បីបម្រើសាធារណៈ។ លោកធ្លាប់បានធ្វើការឱ្យសហជីពនិយោជិតផ្នែកសេវាកម្ម និងសហជីពអ្នកអប់រំសាធារណៈ ជាសមាជិកក្រុមប្រឹក្សាក្រុងមូលដ្ឋាន ជាអតីតមន្ត្រីប៉ូលីសមូលដ្ឋាន ហើយបច្ចុប្បន្ន លោកគឺជាសមាជិកសភារដ្ឋ California។ លោកគឺជាប្រធានក្រុមតំណាងរាស្ត្របក្សប្រជាធិបតេយ្យដែលកាន់តំណែងយូរបំផុតក្នុងប្រវត្តិសាស្ត្ររបស់រដ្ឋ។ ក្នុងនាមជាសមាជិកសភា លោក Mike បានបង្កើតច្បាប់ដំបូងបង្អស់ដែលការពារកុមារ និងគ្រួសារក្នុងរដ្ឋ California ពី ICE, ច្បាប់ដើម្បីលុបបំបាត់ “កាំភ្លើងខ្មោច” ផលិតតាមបច្ចេកវិទ្យា 3-D ពីលើដងផ្លូវ និងកុំឱ្យធ្លាក់ក្នុងដៃជនល្មើស, ការផ្តល់ថវិកាសម្រាប់ការពង្រីកលទ្ធភាពទទួលបានសេវាថែទាំសុខភាព ការអប់រំ និងការថែទាំកុមារ ព្រមទាំងការវិនិយោគលើសេវាកម្មសុខភាពផ្លូវចិត្ត។ នោះហើយជាមូលហេតុដែលអភិបាល Gavin Newsom បាននិយាយថា “លោក Mike ជាអ្នកដឹកនាំដ៏អង់អាចក្លាហានសម្រាប់ប្រជាជននៃរដ្ឋរបស់យើង។” ពីមុនលោក Mike បម្រើការជាប្រធានបុគ្គលិកសម្រាប់អតីតប្រធានក្រុមប្រឹក្សាភិបាលសមភាព។ បច្ចុប្បន្ន លោក Mike បម្រើការជាប្រធានគណៈកម្មាធិការចំណូល និងពន្ធដារនៃរដ្ឋសភា ដែលត្រួតពិនិត្យក្រុមប្រឹក្សាភិបាលសមភាព។ នៅលើ BOE លោក Gipson នឹងនាំយកថវិកាចាំបាច់ដើម្បីគាំទ្រដល់ការថែទាំសុខភាពប្រកបដោយគុណភាព សាលារៀនរឹងមាំ និងសេវាសង្គមសំខាន់ៗដែលទ្រទ្រង់គ្រួសារ និងសហគមន៍នៅទូទាំងរដ្ឋរបស់យើង។ ត្រឹមថ្ងៃទី 2 ខែមិថុនា សូមបោះឆ្នោតឱ្យ Mike Gipson ជាក្រុមប្រឹក្សាភិបាលសមភាព! បានទទួលការគាំទ្រពីគិលានុបដ្ឋាយិកា កម្មករសំណង់ និងគ្រូបង្រៀន។ សូមចូលទៅកាន់គេហទំព័រ *mikegipson.net*

X: https://x.com/mgipson2014 | Facebook: https://www.facebook.com/MikeGipson4BOE

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## ក្រុមប្រឹក្សាភិបាលសមភាព

### មណ្ឌល 4



**Cody Petterson** | ប្រជាធិបតេយ្យ

ក្នុងនាមជាអនុប្រធានក្រុមប្រឹក្សាភិបាលសមភាព**មណ្ឌល**បួន លោក Cody Petterson គឺជាបេក្ខជនដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់បំផុតនៅលើសន្លឹកឆ្នោត។ គាត់បានជួយត្រួតពិនិត្យការវាយតម្លៃទ្រព្យសម្បត្តិសាជីវកម្មប្រចាំឆ្នាំដែលមានតម្លៃ $167 ពាន់លាន និងការវាយតម្លៃពន្ធលើអចលនទ្រព្យនៅក្នុងខោនធីចំនួន 58 នៃរដ្ឋ California។ “ខ្ញុំកំពុងឈរឈ្មោះដើម្បីស្តារឡើងវិញនូវវណ្ណៈកណ្តាលរបស់រដ្ឋ California ដែលកំពុងជួបការលំបាក កសាងហេដ្ឋារចនាសម្ព័ន្ធរបស់យើងឡើងវិញ វិនិយោគឡើងវិញទៅលើសាលារៀនរបស់យើង និងជំរុញការសាងសង់ និងការអភិរក្សលំនៅឋានសម្រាប់ប្រជាពលករ  California ។ ជាមួយនឹងបទពិសោធពាក់កណ្តាលទសវត្សរ៍នៅ BOE ខ្ញុំមានលក្ខណសម្បត្តិពិសេសក្នុងការប្រើប្រាស់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាភិបាលដើម្បីធានាថា ក្រុមហ៊ុនសេវាកម្មសាធារណៈបង់ចំណែកស្មើភាពគ្នារបស់ពួកគេសម្រាប់ការអប់រំសាធារណៈ និងសេវាកម្មផ្សេងទៀត និងដើម្បីធ្វើឱ្យប្រព័ន្ធពន្ធរបស់យើងដំណើរការសម្រាប់គ្រួសារពលករ។” ក្នុងនាមជាអតីតប្រធានក្រុមប្រឹក្សាភិបាលសិក្សារបស់មណ្ឌលរួបរួម San Diego ដែលទើបតែផុតអាណត្តិ លោក Cody Petterson បានរក្សាតុល្យភាពថវិកាដ៏លំបាកៗ និងបានផ្តល់អាទិភាពដល់សុខុមាលភាពព្រមទាំងការរីកចម្រើនផ្នែកសិក្សារបស់កូនៗយើង។ លោក Cody បានជួយដឹកនាំការអនុម័តលើការសាងសង់លំនៅឋានដែលមានតម្លៃសមរម្យជាង 2,800 ខ្នង សម្រាប់គ្រូបង្រៀន និងបុគ្គលិក—ច្រើនជាងចំនួនសរុបទូទាំងរដ្ឋ 3 ដង—ហើយបម្រើជាប្រធានស្ថាបនិកនៃអាជ្ញាធរហិរញ្ញវត្ថុលំនៅឋានតំបន់ San Diego។ នៅក្នុងក្រុមប្រឹក្សាភិបាលសមភាព លោកនឹងមានលក្ខណសម្បត្តិពិសេស ដើម្បីបន្តការងារនេះ។ លោក Mike Schaefer ដែលជាសមាជិកក្រុមប្រឹក្សាភិបាលកំពុងផុតអាណត្តិ ដែលអាសនៈរបស់លោកដែល Dr. Petterson កំពុងប្រជែងតំណែងបន្តនោះបាននិយាយថា: “ខ្ញុំសូមគាំទ្រលោក Cody យ៉ាងពេញទំហឹង។” គាត់ស្គាល់ការងារនេះច្បាស់លាស់បំផុត ហើយគាត់អាចចាប់ផ្តើមអនុវត្តការងារបានភ្លាមៗ។ គាត់បានធ្វើការងារដ៏ឆ្នើមសម្រាប់ខ្ញុំ ហើយនឹងធ្វើការងារដ៏ឆ្នើមបែបនេះទៀតសម្រាប់អ្នកបង់ពន្ធរបស់រដ្ឋ California។”

ទូរស័ព្ទ: (858) 314-8229 | អ៊ីមែល: codypettersonsd@gmail.com
www.codyforequalization.com | Instagram: codyforequalization



**Gardner C. Osborne** | សេរីនិយម

ជាមួយបទពិសោធ 25 ឆ្នាំក្នុងការអនុវត្តពន្ធដារក្នុងនាមជាភ្នាក់ងារដែលបានចុះបញ្ជី តំណាងឱ្យបុគ្គល និងអាជីវកម្មខ្នាតតូច ព្រមទាំងក្នុងនាមជាអ្នករស់នៅទីនេះ 45 ឆ្នាំ កង្វល់របស់ខ្ញុំគឺការចំណាយលើសកម្រិតរបស់រដ្ឋ និងការការពារច្បាប់ សំណើប្រជាមតិ 13។ ក្នុងនាមជាអ្នកកាន់តំណែងសាធារណៈដែលជាពលរដ្ឋម្នាក់ នឹងតស៊ូប្រឆាំងនឹងការរំលោភអំណាចរបស់ស្ថាប័ននីតិប្បញ្ញត្តិ ដូចជាការបង្កើត CDTFA ដែលបានដកហូតការទទួលខុសត្រូវផ្នែកពន្ធដារពីតំណែងជាប់ឆ្នោតនេះនៅឆ្នាំ 2017 ហើយជំនួសមកវិញដោយប្រព័ន្ធរដ្ឋបាលដែលត្រូវបានការពារពីឥទ្ធិពលនយោបាយ។ *ការផ្លាស់ប្តូរ* នឹងមិន*កើតឡើង* ឡើយប្រសិនបើគ្មាន *សន្លឹកឆ្នោតរបស់អ្នក* សម្រាប់ *Osborne4Equalization.com*

1545 Grand Ave., San Diego, CA 92109 | ទូរស័ព្ទ: (858) 733-5095
អ៊ីមែល: gardner@osborne4equalization.com | osborne4equalization.com | Facebook: osborne4equalization

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្ដីថ្លែងការណ៍របស់បេក្ខជន
## ក្រុមប្រឹក្សាភិបាលសមភាព

### មណ្ឌល 4



### Martín Arias | ប្រជាធិបតេយ្យ

សូមចូលរួមជាមួយក្រុមអ្នកពន្លត់អគ្គីភ័យរដ្ឋ California ក្នុងការបោះឆ្នោតជូនលោក Martín Arias សម្រាប់ក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ California! "អ្នកគាំពារអ្នកបង់ពន្ធ Martín Arias គឺជាបេក្ខជនដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តែម្នាក់គត់ និងជាអ្នកជំនាញដែលមានការទទួលស្គាល់ដោយ ក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ ដែលអ្នកពន្លត់អគ្គិភ័យទុកចិត្ត។ យើងបានឃើញកំណត់ត្រាដ៏រឹងមាំរបស់ Martín ក្នុងការការពារអ្នករស់រានមានជីវិតពីភ្លើងឆេះព្រៃពីពន្ធលើអចលនទ្រព្យ និងការផាកពិន័យដោយអយុត្តិធម៌ នៅពេលសាងសង់ផ្ទះរបស់ពួកគេឡើងវិញ។"—អគ្គិភ័យនៅ CAL តំបន់ 2881។ *ក្នុងនាមជាអ្នកគាំពារអ្នកបង់ពន្ធរបស់អ្នក លោកMartínArias បាន "ជួយសង្គ្រោះអ្នកជាប់ពន្ធរាប់លាននាក់" ហើយគាត់នឹងសម្រេចបានការបន្ធូរបន្ថយពន្ធដល់អ្នកផងដែរ!* ដោយប្រើប្រាស់កម្មវិធីសន្សំពន្ធរបស់ក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ California លោក Martín បានជួយសន្សំសំចៃដល់ម្ចាស់ផ្ទះ $31.8 លាន សន្សំសំចៃដល់មនុស្សចាស់ $5.7 លាន សន្សំសំចៃដល់អតីតយុទ្ធជនពិការ $36.8 លាន សន្សំសំចៃដល់វិហារសាសនា អង្គការមិនស្វែងរកប្រាក់ចំណេញ លំនៅឋានដែលមានតម្លៃសមរម្យ អាជីវកម្មខ្នាតតូច និងអ្នកជួលផ្ទះចំនួន $228 លាន ក្នុងការបន្ធូរបន្ថយពន្ធ។ Martín ធានានូវតម្លាភាព និងភាពយុត្តិធម៌—ការពារអ្នកជួល និងម្ចាស់ផ្ទះជាមួយនឹងការសន្សំសំចៃពន្ធតាមសំណើប្រជាមតិ 13។ ក្នុងនាមជាកូនប្រុសដ៏មានមោទនភាពរបស់ជនអន្តោប្រវេសន៍វណ្ណៈពលករ លោក Martín យល់ពីការលំបាកដែលប្រឈមមុខនឹងប្រជាជនរដ្ឋ California ជាច្រើនដែលធ្វើការធ្ងន់ និងបង់ពន្ធ ប៉ុន្តែនៅតែពិបាកក្នុងការមានលទ្ធភាពទិញផ្ទះ។ ហើយជាមូលហេតុដែលលោក Martín ប្រយុទ្ធដើម្បីធ្វើឱ្យរដ្ឋ California មានតម្លៃសមរម្យជាងមុន ការពារអ្នក និងក្រុមគ្រួសាររបស់អ្នកពីការបង់ពន្ធលើសកម្រិត! លោក Martín គឺជាអ្នកបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ San Diego State ជាឪពុករបស់កូនពីរនាក់ និងជាស្វាមីរបស់ភរិយាដ៏អស្ចារ្យម្នាក់ដែលជាអ្នកធ្វើការផងដែរ។ លោក Martín បម្រើការនៅក្នុង USS MIDWAY និងថ្នាក់ដឹកនាំ YMCA។ ត្រូវបានគាំទ្រដោយអ្នកពន្លត់អគ្គីភ័យ គ្រូបង្រៀន អ្នកជិតខាង ម្ចាស់អាជីវកម្មខ្នាតតូច *សមាជិក ក្រុមប្រឹក្សាភិបាលសមភាពរដ្ឋ California Tony Vazquez* និងថ្នាក់ដឹកនាំសហគមន៍មកពីខោនធី San Diego ខោនធី Orange ខោនធី Riverside ខោនធី Imperial និងខោនធី San Bernardino ព្រមទាំងសមាជិកព្រឹទ្ធសភា និងសមាជិកសភានៃក្រុមប្រជុំសភាឡាតាំងរដ្ឋ California។ "ខ្ញុំនឹងមានកិត្តិយសណាស់ក្នុងការទទួលបានសំឡេងឆ្នោតរបស់អ្នក ហើយនិងបន្តតស៊ូមតិដើម្បីអ្នក ។"—Martín Arias ទូរសព្ទដៃ: (619) 483-1122 ស្វែងយល់បន្ថែមតាមរយៈគេហទំព័រ *www.VoteMartinArias.com*

3288 Adams Ave #16713, San Diego, CA 92176 | ទូរស័ព្ទ: (619) 483-1122
អ៊ីមែល: martin@votemartinarias.com | Facebook: martinarias.ca | Instagram: @martinarias.ca



### Tom Umberg | ប្រជាធិបតេយ្យ

ខ្ញុំកំពុងប្រជែងតំណែងជាក្រុមប្រឹក្សាសមភាពដើម្បីធ្វើជាអ្នកឃ្លាំមើលរបស់អ្នក—ប្រយុទ្ធដើម្បីធ្វើឱ្យប្រព័ន្ធពន្ធរបស់យើងមានយុត្តិធម៌ និងសមភាពសម្រាប់ពលរដ្ឋ California ទូទៅ ខណៈពេលដែលធានាថាក្រុមហ៊ុនសាជីវកម្មដែលមានប្រាក់ច្រើនធំៗបង់ចំណែកពន្ធដោយយុត្តិធម៌របស់ពួកគេ។ ក្រុមប្រឹក្សាភិបាលសមភាពផ្តល់នូវការទទួលខុសត្រូវសម្រាប់ប្រាក់រាប់ពាន់លានដុល្លារពីពន្ធអចលនទ្រព្យ ការផ្តល់មូលនិធិដល់សេវាកម្មក្នុងស្រុកសំខាន់ៗ រួមមានសាលារៀន មន្ទីរពេទ្យ បណ្ណាល័យ សួនច្បារ និងការឆ្លើយតបបន្ទាន់។ ខ្ញុំនឹងក្លាយជាសំឡេងរបស់អ្នកសម្រាប់ភាពយុត្តិធម៌នៃពន្ធ ការពារម្ចាស់ផ្ទះ អ្នកជួល និងអាជីវកម្មខ្នាតតូច ខណៈពេលដែលប្រឆាំងនឹងផលប្រយោជន៍អ្នកមានដែលគេចវេសពីច្បាប់។ កំណត់ត្រារបស់ខ្ញុំបង្ហាញថាខ្ញុំយកចិត្តទុកដាក់ចំពោះគ្រួសារពលករ និងដឹងពីរបៀបធានាការទទួលខុសត្រូវនៅក្រុមប្រឹក្សា។ ក្នុងព្រឹទ្ធសភារដ្ឋ ខ្ញុំបានសរសេរច្បាប់ "No Kings" ដើម្បីរារាំងលោក Donald Trump ពីការបង្ហាញខ្លួននៅលើសន្លឹកឆ្នោតរដ្ឋ California ម្តងទៀត និងបានគាំទ្រច្បាប់ដែលទាមទារការទទួលខុសត្រូវពី ICE ខណៈពេលដែលការពារសិទ្ធិស៊ីវិលសម្រាប់ពលរដ្ឋ California ទាំងអស់។ ក្នុងនាមជាព្រះរាជអាជ្ញាសហព័ន្ធ និងជា JAG យោធា ខ្ញុំបានកាត់ទោសអ្នកនយោបាយ និងបុគ្គលិករដ្ឋាភិបាលពីបទឆបោក ការរំលោភបំពាន និងអំពើពុករលួយ ធ្វើឱ្យរដ្ឋាភិបាលបរទេសពុករលួយទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្ស និងស៊ើបអង្កេតការបំភិតបំភ័យរបស់គណបក្សសាធារណៈរដ្ឋចំពោះអ្នកបោះឆ្នោតឡាទីនដោយការដាក់ឆ្មាំយាមការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត។ ថ្មីៗនេះ ខ្ញុំបានសរសេរវិធានការមួយដើម្បីបង្ក្រាបឥទ្ធិពលនៃក្រុមផលប្រយោជន៍ពិសេសនៅក្នុងការបោះឆ្នោតរបស់យើង។ ក្នុងនាមជាអ្នកជំនួញខ្នាតតូច ខ្ញុំយល់ពីបញ្ហាប្រឈមដែលអាជីវកម្ម និងពលកររបស់យើងប្រឈមមុខ។ ខ្ញុំមានមោទនភាពដែលត្រូវបានគាំទ្រដោយអភិបាលរដ្ឋ Gavin Newsom, សមាជិកព្រឹទ្ធសភាអាមេរិក Adam Schiff, សមាជិកព្រឹទ្ធសភារដ្ឋ California Steve Padilla, អ្នកជំនាញពន្លត់អគ្គិភ័យនៅ California, និងសហជីពពលកម្ម ដែលតំណាងឱ្យបុគ្គលិកថែទាំសុខភាព អ្នកអប់រំ និងគិលានុបដ្ឋាយិកា។ ខ្ញុំមានកិត្តិយសណាស់ ប្រសិនបើទទួលបានសន្លឹកឆ្នោតរបស់អ្នក។

P.O. Box 1630, Sunset Beach, CA 90742 | ទូរស័ព្ទ: (949) 679-0052
អ៊ីមែល: Info@TomUmberg.com | www.TomUmberg.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន
## ក្រុមប្រឹក្សាភិបាលសមភាព

### មណ្ឌល 4



**Denis Bilodeau** | សាធារណរដ្ឋ

អ្នកជាប់ពន្ធនៅភាគខាងត្បូងរដ្ឋ California សមនឹងទទួលបានរដ្ឋាភិបាលដែលការពារគ្រួសារពីការចំណាយខ្ពស់ និងការពារអាជីវកម្មខ្នាតតូចពីបទប្បញ្ញត្តិដែលបំផ្លាញការងារ។ ខ្ញុំកំពុងឈរឈ្មោះដើម្បីនាំមកនូវការការពារអ្នកជាប់ពន្ធដ៏រឹងមាំ និងការត្រួតពិនិត្យឯករាជ្យចំពោះប្រព័ន្ធពន្ធលើអចលនទ្រព្យចំនួន $8.7 ទ្រីលានរបស់រដ្ឋ California។ ខ្ញុំបានចុះហត្ថលេខាលើការសន្យារបស់*សមាគមក្រុមអ្នកបង់ពន្ធ Howard Jarvis* ដើម្បីការពារសំណើប្រជាមតិ 13 និងប្រឆាំងនឹងការដំឡើងពន្ធ។ ខ្ញុំត្រូវបានគាំទ្រដោយ *Reform California* ហើយនឹងប្រយុទ្ធប្រឆាំងនឹងពន្ធលើរង្វាស់ម៉ែលរថយន្តដែលបានស្នើឡើង។ ក្នុងនាមជាប្រធាននៃ *សមាគមអ្នកជាប់ពន្ធនៅខោនធី Orange* ខ្ញុំប្រយុទ្ធនឹងការខ្ជះខ្ជាយរបស់រដ្ឋាភិបាល និងទាមទារតម្លាភាព។ ខ្ញុំនាំមកនូវបទពិសោធបម្រើសេវាសាធារណៈរយៈពេល 25 ឆ្នាំ រួមទាំងការដឹកនាំមណ្ឌលកែច្នៃទឹកខោនធី Orange County Water District ដែលជាកន្លែងខ្ញុំធ្វើឱ្យថវិកាមានតុល្យភាព ផ្តល់ទឹកបរិភោគដែលមានគុណភាពខ្ពស់បំផុតនៅក្នុងរដ្ឋ California និងការពារបរិស្ថាន។ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាក្រុង ខ្ញុំបានផ្តោតលើការរក្សាសុវត្ថិភាពសហគមន៍របស់យើង និងការលុបបំបាត់ភាពគ្មានផ្ទះសម្បែង។ នៅក្នុងក្រុមប្រឹក្សាភិបាលសមភាព ខ្ញុំនឹងធ្វើការដើម្បីកាត់បន្ថយការចំណាយសម្រាប់អ្វីគ្រប់យ៉ាង ចាប់ពីវិក្កយបត្រអគ្គិសនី និងឧស្ម័ន រហូតដល់គ្រឿងទេស និងឱសថវេជ្ជបញ្ជា។ ខ្ញុំគាំទ្រដល់ការរីកចម្រើនដែលមានលក្ខណៈសមហេតុផលដែលការពារសហគមន៍ និងផ្តល់ឱកាសយុត្តិធម៌ដល់មនុស្សជំនាន់ក្រោយក្នុងការមានកម្មសិទ្ធិផ្ទះ។ ខ្ញុំនឹងការពារម្ចាស់ផ្ទះពីពន្ធអចលនទ្រព្យខ្ពស់ដែលនាំឱ្យថ្លៃជួលផ្ទះឡើងខ្ពស់។ ខ្ញុំនឹងក្លាយជាសំឡេងឯករាជ្យសម្រាប់អ្នកជាប់ពន្ធ។ សូមបោះឆ្នោតឱ្យ *Denis Bilodeau ជាក្រុមប្រឹក្សាភិបាលសមភាព*។

P.O. Box 1871, Orange, CA 92862 | ទូរស័ព្ទ: (858) 633-3352
អ៊ីមែល: info@BilodeauForBOE.com | BilodeauForBOE.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អគ្គនាយកផ្នែកអប់រំសាធារណៈ (ការិយាល័យគ្មានបក្ស)

- ក្នុងនាមជាប្រធានសាលាសាធារណៈរបស់រដ្ឋ ផ្តល់ទិសដៅគោលនយោបាយអប់រំដល់មណ្ឌលសាលារៀនក្នុងមូលដ្ឋាន និងធ្វើការជាមួយសហគមន៍អប់រំដើម្បីកែលម្អលទ្ធផលការសិក្សា។
- ដឹកនាំនាយកដ្ឋានអប់រំ និងអនុវត្តគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាលអប់រំរបស់រដ្ឋ។
- បម្រើជាអតីតសមាជិកការិយាល័យរបស់ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធឧត្តមសិក្សារបស់រដ្ឋ។



### Josh Newman

រដ្ឋ California គឺជាកន្លែងដែលមានសេដ្ឋកិច្ចធំជាងគេទីបួននៅលើពិភពលោក ដែលជាអ្នកឈានមុខគេលើពិភពលោកក្នុងការច្នៃប្រឌិត និងឱកាស។ ប្រព័ន្ធអប់រំសាធារណៈរបស់យើងគួរតែឆ្លុះបញ្ចាំងពីឋានៈនោះ ប៉ុន្តែសិស្សភាគច្រើននៃរដ្ឋ California មិនបានបំពេញតាមស្តង់ដារកម្រិតថ្នាក់សិក្សានៅក្នុងការអាន គណិតវិទ្យា ឬវិទ្យាសាស្ត្រទេ។ នេះជាសញ្ញាយ៉ាងច្បាស់ថា ប្រព័ន្ធរបស់យើងមិនត្រូវបានតម្រង់ដើម្បីភាពជោគជ័យនោះទេ។ ក្នុងនាមជាអតីតទាហាន អ្នកជំនួញ អ្នកអប់រំក្នុងថ្នាក់រៀន និងជាអតីតសមាជិកព្រឹទ្ធសភារដ្ឋដែលបានធ្វើជាប្រធានគណៈកម្មាធិការអប់រំព្រឹទ្ធសភា ខ្ញុំបានមើលឃើញទាំងសក្តានុពលដ៏អស្ចារ្យរបស់សិស្សនៅរដ្ឋ California និងឧបសគ្គរចនាសម្ព័ន្ធដែលរារាំងពួកគេ។ ប្រព័ន្ធសាលារៀនបែបរិមជ្ឈការដ៏ធំរបស់រដ្ឋ California ដែលមានសិស្សរាប់លាននាក់ និងពន្ធរាប់ពាន់លានដុល្លារ កង្វះនៃការសម្របសម្រួល និងភាពជាអ្នកដឹកនាំដែលត្រូវការ ដើម្បីធានាថាសិស្សគ្រប់រូប មិនថាភូមិសាស្ត្រ ឬសាវតាណាក៏ដោយ ទទួលបានការអប់រំសាធារណៈដែលមានគុណភាពខ្ពស់ដែលពួកគេសមនឹងទទួលបាន។ ខ្ញុំកំពុងប្រជែងតំណែងជាអគ្គនាយករដ្ឋ ព្រោះរដ្ឋ California អាចធ្វើបានល្អជាងនេះ ហើយត្រូវតែធ្វើឱ្យបានល្អជាងនេះ។ នៅក្នុង ព្រឹទ្ធសភា ខ្ញុំបានតាក់តែងច្បាប់សំខាន់ៗដែលធ្វើទំនើបកម្មសាលារៀន ពង្រឹងការគាំទ្រសិស្ស ពង្រីកផ្លូវអាជីព-បច្ចេកទេស និងការកែលម្អការរៀបចំគ្រូបង្រៀន។ ខ្ញុំបានបង្កើតសម្ព័ន្ធភាព ដោះស្រាយបញ្ហាស្មុគស្មាញ និងសម្រេចបានលទ្ធផល ហើយខ្ញុំមានមោទនភាពដែលបានទទួលការគាំទ្រយ៉ាងទូលំទូលាយពីអ្នកអប់រំ ឪពុកម្តាយ អាជ្ញាធរអនុវត្តច្បាប់ ស្ថាប័នអាជីវកម្ម និងសហជីពពាណិជ្ជកម្មនៅទូទាំងរដ្ឋ California។ ក្នុងនាមជាអគ្គនាយក ខ្ញុំនឹងនាំយកការសម្របសម្រួលនិងការសហការដែលប្រព័ន្ធអប់រំរបស់យើងត្រូវការជាបន្ទាន់ ដោយផ្តោតលើការពង្រីកជំនួយសុខភាពផ្លូវចិត្ត ការពង្រឹងភាពជាដៃគូជាមួយផ្នែកពលកម្មនិងឧស្សាហកម្ម ការសម្របសម្រួលថ្ងៃសិក្សាជាមួយនឹងថ្ងៃធ្វើការ និងធានាថាសាលារបស់យើងរៀបចំសិស្សប្រកបដោយប្រសិទ្ធិភាពសម្រាប់សេដ្ឋកិច្ចដែលផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងការចូលរួមពេញលេញនៅក្នុងលទ្ធិប្រជាធិបតេយ្យរបស់យើង។ អនាគតរបស់រដ្ឋ California ពឹងផ្អែកលើភាពរឹងមាំនៃសាលារដ្ឋរបស់យើង។ សិស្សរបស់យើងទាំងអស់សមនឹងទទួលបានល្អជាងនេះ។ *www.newmanforspi.com*

1400 N. Harbor Blvd., Suite 505, Fullerton, CA 92835 | ទូរស័ព្ទ: (310) 463-5257
អ៊ីមែល: josh@newmanforca.com | Facebook: joshnewmanca | Instagram: newmanforca



### Ainye Long

អ្នកនាង Long គឺជាសិស្សសាលារដ្ឋ California ជំនាន់ទីបី និងជាគ្រូបង្រៀនសាលារដ្ឋជំនាន់ទីប្រាំដែលបានប្តេជ្ញាចិត្តក្នុងការពង្រឹងរដ្ឋ California តាមរយៈយុវជន និងការអប់រំ។ អស់រយៈពេល 19 ឆ្នាំមកហើយ គាត់បានធ្វើជាអ្នកដឹកនាំបង្រៀនគណិតវិទ្យានៅ Oakland, Richmond, Los Angeles និង San Francisco ដោយបម្រើសហគមន៍ចម្រុះនៅទូទាំងរដ្ឋ។ គាត់ក៏បានដឹកនាំក្នុងនាមជានាយកផ្នែកទំនាក់ទំនងគ្រួសារនិងសហគមន៍ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រចាំតំបន់ ដោយបង្កើតភាពជាដៃគូរឹងមាំរវាងសាលារៀន និងគ្រួសារ។ បច្ចុប្បន្ន គាត់ជាគ្រូបង្រៀនគណិតវិទ្យាថ្នាក់ទី 8 និងជាប្រធាននាយកដ្ឋាននៅសាលា Willie L. Brown Middle School ក្នុងមណ្ឌលសិក្សាធិការរួបរួម San Francisco គាត់ណែនាំអ្នកអប់រំ និងជ្រោមជ្រែងឧត្តមភាពនៃការបង្រៀន។ បន្ទាប់ពីក្លាយជាគ្រូបង្រៀនសាលារដ្ឋតែមួយគត់នៅក្នុងការប្រណាំងប្រជែងឆ្នាំ 2022 គាត់បន្តដឹកនាំជាមួយនឹងបទពិសោធថ្នាក់រៀនពិតប្រាកដ។

ទូរស័ព្ទ: (445) 204-7284 | អ៊ីមែល: Info@AinyeLong4CA.com | Instagram: @AinyeLong4CA | AinyeLong4CA.com

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អគ្គនាយកផ្នែកអប់រំសាធារណៈ (ការិយាល័យគ្មានបក្ស)



### Frank Lara

ក្នុងនាមជាអ្នកដឹកនាំសហជីពនិងជាគ្រូសាលារដ្ឋអស់រយៈពេលជាងដប់ឆ្នាំ ខ្ញុំបានឃើញភាពពិតនៃសាលារបស់យើងផ្ទាល់តែម្តង។ រដ្ឋ California គឺជាកន្លែងដែលមានសេដ្ឋកិច្ចធំជាងគេទីបួននៅលើពិភពលោក ប៉ុន្តែថ្នាក់រៀនមានសិស្សច្រើន អគារសិក្សាបែកប្រេះ ហើយសិស្សមិនបានទទួលសេវាកម្មគ្រប់គ្រាន់ទេ។ ក្នុងនាមជាអនុប្រធាននៃ អ្នកអប់រំរួបរួម នៃ San Francisco ខ្ញុំបានឃើញពីថាមពលរបស់ពលករដែលតស៊ូជាមួយគ្នាដើម្បីប្រព័ន្ធប្រសើរជាងនេះ។ ខ្ញុំនឹងជំរុញទៅសាជីវកម្មពន្ធដារនិងមហាសេដ្ឋីដើម្បីឱ្យផ្តល់បុគ្គលិកពេញលេញដល់សាលារៀន និងធ្វើទំនើបកម្មបរិក្ខារ។ ខ្ញុំនឹងតស៊ូដើម្បីទំហំថ្នាក់តូចជាងមុន ការអប់រំពិសេសប្រកបដោយគុណភាព, សាលាដែលគ្មាន ICE, ការសិក្សាអំពីជនជាតិភាគតិច, និងការថែទាំកុមារនិងមហាវិទ្យាល័យឥតគិតថ្លៃសម្រាប់ទាំងអស់គ្នា។ បោះឆ្នោតជូនសង្គមនិយម។ បោះឆ្នោតជូន *LeftUnitySlate.org*

4121 Montgomery St., Oakland, CA 94611 | ទូរស័ព្ទ: (510) 626-0126
អ៊ីមែល: info@frank4caschools.com | Instagram: frank4caschools | TikTok: frank4caschools



### Sonja Shaw

សាលារដ្ឋរបស់ California កំពុងបរាជ័យកូនៗរបស់យើង។ តិចជាងពាក់កណ្តាលនៃពួកគេអាចអាន ឬសរសេរនៅកម្រិតថ្នាក់សិក្សា។ កីឡាសម្រាប់កុមារីកំពុងរងការវាយប្រហារ ដោយអត្តពលិកនារីបានបាត់បង់មេដាយ និងអាហារូបករណ៍។ អត្តពលិកនារីជាច្រើនទៀតថែមទាំងផ្លាស់ប្តូរសម្លៀកបំពាក់នៅក្នុងរថយន្តរបស់ពួកគេមុនពេលហ្វឹកហាត់ ព្រោះពួកគេមានអារម្មណ៍ថាមិនមានសុវត្ថិភាពក្នុងបន្ទប់ទុកឥវ៉ាន់។ នេះជារឿងមិនអាចទទួលយកបានទេ។ ក្នុងនាមជាម្តាយដែលមានកូនស្រីពីរនាក់ ខ្ញុំបានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាភិបាលសិក្សាធិការរួបរួម Chino Valley ដោយសារតែឪពុកម្តាយទាមទារឱ្យមានការផ្លាស់ប្តូរ។ យើងបានសម្រេចលទ្ធផល។ នៅពេលខ្ញុំចូលកាន់តំណែងនៅឆ្នាំ 2022 មណ្ឌលរបស់យើងបានប្រឈមមុខនឹងបញ្ហាដូចគ្នាដែលឃើញនៅទូទាំងរដ្ឋ California: ចំណាត់ថ្នាក់មិនល្អ ពិន្ទុប្រឡងធ្លាក់ចុះ ការរំខានផ្នែកនយោបាយនៅក្នុងថ្នាក់រៀន និងក្មេងស្រីបាត់បង់ភាពយុត្តិធម៌ និងឯកជនភាព។ យើងបានជ្រើសរើសគន្លងផ្សេង។ យើងបានផ្តោតឡើងវិញលើការអាន ការសរសេរ និងគណិតវិទ្យា។ បានការពារកន្លែងលេងកីឡា និងកន្លែងឯកជនរបស់ក្មេងស្រី។ បានកាត់ការិយាធិបតេយ្យ។ បានបញ្ជូនធនធានត្រឡប់ទៅថ្នាក់រៀនវិញ ដែលជាកន្លែងដែលត្រូវទទួលបាន។ លទ្ធផលគឺមិនអាចប្រកែកបានទេ។ លទ្ធផលរបស់សិស្សមានភាពប្រសើរឡើង ហើយការស្រាវជ្រាវឯករាជ្យបានទទួលស្គាល់មណ្ឌលរបស់យើងថាជាគំរូសម្រាប់ការស្តារការសិក្សាក្រោយកូវីដ។ ភាពជោគជ័យនោះមិនបានមកពីអាណត្តិ Sacramento ទេ។ វាបានមកពីឪពុកម្តាយដែលកាន់ដៃគ្នា ហើយក្រោកឈរឡើងដើម្បីសុភវិនិច្ឆ័យ។ ក្នុងនាមជាអគ្គនាយCOVID ខ្ញុំនឹងនាំយកភាពជាអ្នកដឹកនាំដូចគ្នានេះមកទូទាំងរដ្ឋ។ ខ្ញុំនឹងធ្វើជាអ្នកតស៊ូមតិឯករាជ្យសម្រាប់សិស្ស និងក្រុមគ្រួសារ មិនមែនជាអ្នកផ្ទៃក្នុងនយោបាយទេ។ ផែនការរបស់ខ្ញុំគឺធម្មតាទេ: ស្តារស្តង់ដារសិក្សាខ្ពស់ក្នុងការអាន ការសរសេរ និងគណិតវិទ្យា, ការពារ Title IX, ធានានូវយុត្តិធម៌ និងសុវត្ថិភាពសម្រាប់ក្មេងស្រី, ផ្តល់ឱ្យឪពុកម្តាយនូវសិទ្ធិចូលរួមពិតក្នុងការប្រជុំ, គាំទ្រគ្រូឆ្នើម, និងកាត់បន្ថយការិយាធិបតេយ្យដែលខ្ជះខ្ជាយ។ ផែនការមាននៅថ្នាក់មូលដ្ឋាន។ យើងបានបញ្ជាក់រួចហើយថាវាដំណើរការ។ តោះសម្រេចឱ្យបានលទ្ធផលសម្រាប់សិស្សនៅរដ្ឋ California គ្រប់គ្នា។ ស្វែងយល់បន្ថែមតាមរយៈ *ShawForCA.com*។

6939 Schaefer Avenue, Suite D #119, Chino, CA 91710 | ទូរស័ព្ទ: (949) 495-1310
អ៊ីមែល: info@shawforca.com | X: @realSonjaShaw | Instagram: @SonjaShaw2026

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អគ្គនាយកផ្នែកអប់រំសាធារណៈ (ការិយាល័យគ្មានបក្ស)



### Gus Mattammal

ខ្ញុំធំឡើងនៅក្នុងតំបន់ដែលមានសាលារដ្ឋដែលបរាជ័យ ហើយខ្ញុំបានមើលឃើញជំនាន់ទាំងមូលនៃអ្នកមានចំណូលទាប ដែលភាគច្រើនក្មេងស្បែកខ្មៅនិងត្នោតជាកត្តាមួយក្នុងបញ្ហានេះ។ ឪពុកម្តាយរបស់ខ្ញុំបានលះបង់យ៉ាងធំធេងដើម្បីផ្តល់ឱកាសល្អជាងដល់ខ្ញុំ ហើយការអប់រំបានក្លាយជាជំនួយយូរអង្វែងរបស់ខ្ញុំ ដែលជាផ្លូវទៅកាន់ជីវិតល្អប្រសើរជាង។ នៅរដ្ឋ California សិស្សដែលមានប្រាក់ចំណូលទាបរបស់យើង ដែលភាគច្រើនជាសិស្សដែលមានពណ៌សម្បុរ កំពុងតែបរាជ័យក្នុងការទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។ ពួកគេមិនទទួលបានការជ្រោមជ្រែងទេ។ រដ្ឋ California ជាប់ចំណាត់ថ្នាក់នៅជិតបាតនៅសហរដ្ឋអាមេរិកទាក់ទងនឹងលទ្ធផល បើទោះបីជាជាប់ចំណាត់ថ្នាក់ក្នុងកំពូល 20 ទាក់ទងនឹងការចំណាយក៏ដោយ។ ពីមួយឆ្នាំទៅមួយឆ្នាំភាពអយុត្តិធម៌នេះនៅតែបន្ត ហើយកូនៗរបស់យើងត្រូវទទួលរងនូវបញ្ហានេះ។ ក្នុងនាមជាអគ្គនាយក ខ្ញុំនឹងផ្លាស់ប្តូររឿងរ៉ាវ។ ខ្ញុំជាអ្នកអប់រំពេញម៉ោងអស់រយៈពេល 23 ឆ្នាំហើយ ដោយធ្វើការជាមួយសិស្សជាង 1,000 នាក់នៃគ្រប់សាវតា។ ខ្ញុំបានចំណាយពេល 19 ឆ្នាំក្នុងនាមជានាយកប្រតិបត្តិជាន់ខ្ពស់នៃក្រុមហ៊ុនអប់រំដែលមានការទទួលស្គាល់ថ្នាក់ជាតិ។ ខ្ញុំជាអ្នកតំណាងជាប់ឆ្នោត និងជាអ្នកនិពន្ធសៀវភៅដែលដាក់ចេញនូវរបៀបវារៈកំណែទម្រង់ដ៏មោះមុតមួយសម្រាប់សាលារៀនរបស់រដ្ឋ California និងចក្ខុវិស័យសម្រាប់តួនាទីជាអគ្គនាយក។ ខ្ញុំជាបេក្ខជនតែម្នាក់គត់ដែលអាចផ្តល់ឱ្យអ្នកនូវបទពិសោធដ៏ទូលំទូលាយ និងស៊ីជម្រៅក្នុងការអប់រំ និងនៅក្នុងការិយាល័យជាប់ឆ្នោត ដើម្បីធានាថាសិស្សគ្រប់រូប មិនថាមានប្រវត្តិបែបណានោះទេ អាចអានសៀវភៅ ធ្វើគណិតវិទ្យា និងទទួលបានការងារធ្វើ។ ការអប់រំមិនបាច់ប្រកាន់បក្សទេ។ វាអាចនាំមនុស្សមករួមគ្នា ពីព្រោះយើងទាំងអស់គ្នាចង់ឱ្យកូនៗរបស់យើងទទួលបានការអប់រំដ៏ល្អអស្ចារ្យមួយ។ ចូលរួមជាមួយសមាជិករដ្ឋសភា គ្រូបង្រៀន អគ្គនាយក ឪពុកម្តាយ និងសិស្សពីគ្រប់មជ្ឈដ្ឋាននយោបាយក្នុងការគាំទ្រខ្ញុំ។ វាងាយស្រួលក្នុងការចងចាំ: *បោះឆ្នោតឲ្យ Gus សម្រាប់ពួកយើង!*

1900 S. Norfolk St., Suite 350, San Mateo, CA 94403 | ទូរស័ព្ទ: (650) 451-5335
អ៊ីមែល: gus@gusforca.com | Instagram: @theonetruegus | X: @theonetruegus



### Al Muratsuchi

ខ្ញុំជាអ្នកអប់រំ អតីតប្រធានក្រុមប្រឹក្សាភិបាលសាលាក្នុងមូលដ្ឋាន ឪពុកម្តាយនៃសិស្សសាលារដ្ឋ និងជាប្រធានគណៈកម្មាធិការអប់រំសភារដ្ឋ California ជាមួយនឹងកំណត់ត្រាដែលបង្ហាញឱ្យឃើញពីការតស៊ូដើម្បីសាលារៀនរបស់រដ្ឋ California អស់ជាច្រើនទសវត្សរ៍។ ខ្ញុំកំពុងប្រជែងតំណែងជាអគ្គនាយកផ្នែកអប់រំសាធារណៈ ពីព្រោះខ្ញុំចង់ឱ្យសាលារដ្ឋ California ក្លាយជាសាលាល្អបំផុតនៅក្នុងប្រទេស។ ក្នុងនាមជាកូនប្រុសរបស់ជនអន្តោប្រវេសន៍ ជាផលិតផលនៃសាលារដ្ឋ និងជានិស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យជំនាន់ទីមួយពី Berkeley និង UCLA ខ្ញុំមានចំណង់ខ្លាំងក្នុងការប្រយុទ្ធដើម្បីឱកាសអប់រំស្មើគ្នាសម្រាប់ទាំងអស់គ្នា។ ក្នុងនាមជាប្រធានផ្នែកអប់រំនៅក្នុងសភានីតិបញ្ញត្តិរដ្ឋ California ខ្ញុំបានដឹកនាំការតស៊ូ ដើម្បីផ្តល់មូលនិធិយ៉ាងពេញលេញដល់សាលារបស់យើង កាត់បន្ថយចំនួនសិស្សក្នុងមួយថ្នាក់ ផ្តល់សិល្បៈនិងតន្ត្រីបន្ថែមទៀត ព្រមទាំងការអប់រំបច្ចេកទេសអាជីព ពង្រីកកម្មវិធីមត្តេយ្យសិក្សានិងក្រោយម៉ោងសិក្សាប្រកបដោយគុណភាព ផ្តល់អាហារនៅសាលាសម្រាប់ទាំងអស់គ្នា ព្រមទាំងគាំទ្រសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់សិស្ស។ ដើម្បីធ្វើឱ្យពិន្ទុតេស្តការអានប្រសើរឡើង ខ្ញុំបានសហការតាក់តែងច្បាប់មួយ និងផ្តល់មូលនិធិសម្រាប់ការបង្រៀនការអានតាមសូរសព្ទបន្ថែមទៀតដោយផ្អែកលើវិទ្យាសាស្ត្រនៃការអាន។ នៅពេលដែលការវាយឆ្មក់អន្តោប្រវេសន៍បានគំរាមកំហែងដល់សិស្សរបស់យើង ខ្ញុំបានសរសេរច្បាប់ស្តីពី សាលាជ្រកកោនសុវត្ថិភាពរដ្ឋ California ដើម្បីទប់ស្កាត់ ICE ចេញពីសាលារៀនរបស់យើង។ ហើយដើម្បីជួសជុលអគារសិក្សាដែលចាស់និងមិនមានសុវត្ថិភាពរបស់យើងទូទាំងរដ្ឋ ខ្ញុំបានសរសេរសំណើប្រជាមតិ 2 ដែលជាមូលបត្រកម្ចីរបស់សាលារដ្ឋតម្លៃ $10 ពាន់លានដុល្លារដែលអ្នកបោះឆ្នោតនៅរដ្ឋ California បានអនុម័តក្នុងឆ្នាំ 2024។ ខ្ញុំមានមោទនភាពដែលត្រូវបានគាំទ្រដោយគ្រូបង្រៀន និងបុគ្គលិកសាលាជាង 370,000 នាក់ ដែលតំណាងដោយសហព័ន្ធគ្រូបង្រៀនរដ្ឋ California និងសមាគមបុគ្គលិកសាលារដ្ឋ California។ នៅថ្ងៃទី 2 ខែមិថុនា សូមបោះឆ្នោតជូន Al Muratsuchi សម្រាប់អគ្គនាយកនៃការអប់រំសាធារណៈ។ សូមចូលទៅកាន់ *www.AlforCaliforniaSchools.com*

P.O. Box 4375, Torrance, CA 90510 | អ៊ីមែល: info@alforcaliforniaschools.com
X: www.x.com/AMuratsuchi | Instagram: www.instagram.com/almuratsuchi

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

# សេចក្តីថ្លែងការណ៍របស់បេក្ខជន

## អគ្គនាយកផ្នែកអប់រំសាធារណៈ (ការិយាល័យគ្មានបក្ស)



### Richard Barrera

ខ្ញុំមានកិត្តិយសក្នុងការបម្រើការជាអគ្គនាយករដ្ឋនៃការអប់រំសាធារណៈរបស់ទីប្រឹក្សាជាន់ខ្ពស់ Tony Thurmond និងត្រូវបានគាំទ្រដោយសមាគមគ្រូបង្រៀនរដ្ឋ California (CTA) តំណាងឱ្យគ្រូបង្រៀនក្នុងថ្នាក់រៀន គិលានុបដ្ឋាយិកា ទីប្រឹក្សា និងអ្នកអប់រំជាង 300,000 នាក់។ គ្រូបង្រៀនប្រចាំឆ្នាំរបស់រដ្ឋ California, Tammy Reina និង Zenaida Rosario: "យើងជឿជាក់លើ Richard ក្នុងការតស៊ូដើម្បីសិស្ស និងអ្នកអប់រំរបស់យើង។ គាត់បានសម្រេចលទ្ធផលអស់រយៈពេល 18 ឆ្នាំមកហើយ!" ក្នុងនាមជាប្រធានមណ្ឌលសិក្សាធិការរួបរួម San Diego ដែលធំជាងគេទី 2 របស់រដ្ឋ ខ្ញុំបានផ្លាស់ប្តូរមណ្ឌលដែលមានវិបត្តិទៅជាគំរូនៃភាពជោគជ័យថ្នាក់ជាតិ។ ក្នុងចំណោមមណ្ឌលក្រុងធំៗទាំងអស់ ឥឡូវនេះ យើងជាប់ចំណាត់ថ្នាក់លេខ 1 ក្នុងការអាន និងគណិតវិទ្យាលើ "កាតរបាយការណ៍របស់ជាតិ"។ នៅរដ្ឋ California យើងជាប់ចំណាត់ថ្នាក់លេខមួយក្នុងការអាន គណិតវិទ្យា វិទ្យាសាស្ត្រ អត្រាបញ្ចប់ការសិក្សា និងការត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ/អាជីព។ យើងបានទទួលភាពជោគជ័យដោយការកាត់ភាពខ្ជះខ្ជាយ និងការិយាធិបតេយ្យ ព្រមទាំងការវិនិយោគដោយផ្ទាល់ទៅកាន់សិស្ស គ្រួសារ និងអ្នកអប់រំរបស់យើង។ ខ្ញុំបានស្នើសុំអ្នកបោះឆ្នោតចំនួន 4 ដងដោយជោគជ័យ ដើម្បីប្តូរអគារដែលមានអាយុ 60 ឆ្នាំទៅជាសាលាទំនើបទាន់សម័យ និងប្រកបដោយនិរន្តរភាពបរិស្ថាន។ យើងបានបង្កើនប្រាក់បៀវត្សរ៍គ្រូបង្រៀន 40%, បានផ្តល់ការថែទាំសុខភាពគ្រួសារពេញលេញ និងបានបង្កើតផ្ទះរាប់ពាន់ខ្នងដែលមានតម្លៃសមរម្យសម្រាប់គ្រួសារ និងអ្នកអប់រំរបស់យើង។ ខ្ញុំបានប្រយុទ្ធដើម្បីការពារសិស្សពីរដ្ឋបាល Trump ដែលគ្មានបេះដូង: រក្សា ICE ឱ្យចេញពីសាលារៀនរបស់យើង, គាំទ្រសិស្ស LGBTQ, ព្រមទាំងផ្តល់សក្ខីកម្មនៅចំពោះមុខសហសភាប្រឆាំងនឹងការកាត់បន្ថយថវិកាការអប់រំដ៏កំហុករបស់ Trump។ ខ្ញុំត្រូវបានគាំទ្រដោយអ្នកទាំងឡាយដែលមានទំនួលខុសត្រូវបំផុតចំពោះជោគជ័យរបស់សិស្ស—តាំងពីគ្រូក្នុងថ្នាក់រៀននៃ CTA រហូតដល់នាយកសាលានៃ និង Cindy Marten ដែលជាអនុលេខាធិការផ្នែកអប់រំរបស់ប្រធានាធិបតី Biden។ Tony Thurmond ដែលជាអគ្គនាយកការអប់រំសាធារណៈបច្ចុប្បន្ន: "កំណត់ត្រាជោគជ័យរបស់សិស្សរបស់ Richard Barrera គឺគ្មានគូប្រៀប។ នោះហើយជាមូលហេតុដែលខ្ញុំបានសុំឱ្យគាត់ចូលរួមជាមួយយើងនៅនាយកដ្ឋានអប់រំរដ្ឋ California។ ហេតុនេះហើយបានជាខ្ញុំគាំទ្រគាត់ក្នុងការបោះឆ្នោតនេះ។" *BarreraforEdu.com*

1732 Granada Avenue, San Diego, CA 92102 | ទូរស័ព្ទ: (619) 937-8619
អ៊ីមែល: rbcoi@yahoo.com | Facebook: Richard Barrera | Instagram: richardbarrera2026



### Anthony Rendon

ប្រព័ន្ធអប់រំសាធារណៈរបស់រដ្ឋ California បានផ្លាស់ប្តូរជីវិតរបស់ខ្ញុំ។ ខ្ញុំមិនមែនជាសិស្សពូកែនៅវិទ្យាល័យទេ។ ខ្ញុំស្ទើតែរៀនមិនចប់ ហើយបានទៅធ្វើការក្នុងឃ្លាំង និងសំណង់។ ប៉ុន្តែខ្ញុំបានរកឃើញចំណង់ចំណូលចិត្តរបស់ខ្ញុំក្នុងការរៀននៅមហាវិទ្យាល័យសហគមន៍ ហើយបានបញ្ចប់ការសិក្សាពី Cal State Fullerton និងទទួលបាន Ph.D. នៅ UC Riverside។ នៅទីបំផុត ខ្ញុំបានក្លាយជាអ្នកនាំពាក្យរដ្ឋសភា—ដែលជាមួយក្នុងចំណោមមន្ត្រីសាធារណៈកំពូលនៅរដ្ឋ California—ជាស្នាដៃដ៏មានអត្ថន័យសម្រាប់ចៅប្រុសរបស់ជនអន្តោប្រវេសន៍ម៉ិកស៊ិកម្នាក់។ ខ្ញុំកំពុងប្រជែងតំណែងជាអគ្គនាយកការអប់រំសាធារណៈ ដើម្បីបន្តបេសកកម្មពេញមួយជីវិតរបស់ខ្ញុំ ក្នុងការផ្តល់ជូនកុមារគ្រប់រូប ដោយមិនគិតពីប្រវត្តិ ឱ្យទទួលបានការអប់រំសាធារណៈប្រកបដោយគុណភាពខ្ពស់។ នៅពេលខ្ញុំដំណើរការកម្មវិធីអប់រំកុមារតូចសម្រាប់ក្មេងក្រីក្រ ខ្ញុំបានឃើញផលប៉ះពាល់ដ៏ហិនហោចនៃការកាត់ថវិការដ្ឋ។ ដូច្នេះ ក្នុងនាមជាអ្នកនាំពាក្យសភា ខ្ញុំបានបង្កើនមូលនិធិអប់រំ 50 ភាគរយ បន្ទាប់មកបានអនុម័តច្បាប់ត្រួតពិនិត្យការអប់រំខ្លាំងបំផុតនៅក្នុងប្រទេស ហើយបានក្រោកឈរដោយជោគជ័យប្រឆាំងរដ្ឋបាល Trump ដើម្បីការពារសាលារៀន និងសិទ្ធិស៊ីវិលរបស់យើង។ សព្វថ្ងៃនេះ សាលារៀនមិនត្រឹមតែត្រូវការការវិនិយោគបន្ថែមប៉ុណ្ណោះទេ ប៉ុន្តែសាលារៀនក៏ត្រូវការការកែទម្រង់ពិតប្រាកដដែរ។ សាលារបស់យើងគួរតែផ្តោតលើជំនាញស្នូលដែលក្មេងៗត្រូវការដើម្បីជោគជ័យ។ យើងគួរតែប្រយ័ត្នចំពោះបន្ទុកលើសនៃបច្ចេកវិទ្យា ដែលបំផ្លាញសមត្ថភាពសិក្សា និងការរីកចម្រើនរបស់សិស្ស។ ភាពជាអ្នកដឹកនាំដែលសហការគ្នារវាងមាតាបិតា អ្នកអប់រំ និងសាលារៀនមានសារៈសំខាន់ណាស់ក្នុងការបង្កើតរបាការពារត្រឹមត្រូវជុំវិញបច្ចេកវិទ្យាក្នុងថ្នាក់រៀន។ សិស្សគួរតែមានការរំខានតិចជាងនេះនៅក្នុងថ្នាក់។ គ្រូបង្រៀនមិនគួរប្រកួតប្រជែងជាមួយក្បួនដោះស្រាយបច្ចេកវិទ្យារាប់ពាន់លានដុល្លារ ដើម្បីបង្រៀនមូលដ្ឋានគ្រឹះនៃការអាន ការសរសេរ គណិតវិទ្យា វិទ្យាសាស្ត្រ និងពលរដ្ឋវិជ្ជានោះទេ។ បទពិសោធជីវិតរបស់ខ្ញុំផ្តល់ឱ្យខ្ញុំនូវឧបករណ៍ដើម្បីផ្តល់នូវការផ្លាស់ប្តូរដ៏មានអត្ថន័យ។ កូនៗរបស់យើងមិនសមនឹងទទួលបានតិចជាងនេះទេ។ *www.anthonyrendon.org/*

249 E. Ocean Blvd., Ste. 814, Long Beach, CA 90802 | ទូរស័ព្ទ: (916) 251-9380 | អ៊ីមែល: info@anthonyrendon.org
Facebook: facebook.com/AnthonyRendonCA | Instagram: instagram.com/anthonyrendonca

ទស្សនៈ និងមតិយោបល់ដែលបេក្ខជនបង្ហាញគឺជាមតិយោបល់ផ្ទាល់ខ្លួន ហើយមិនតំណាងឱ្យទស្សនៈនិងមតិយោបល់របស់ការិយាល័យរដ្ឋលេខាធិការឡើយ។ លំដាប់នៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឆ្នោតដោយចៃដន្យ។ បេក្ខជនជាអ្នកផ្តល់ជូនសេចក្តីថ្លែងការណ៍នៅលើទំព័រនេះ ហើយស្ថាប័នផ្លូវការមិនបានត្រួតពិនិត្យភាពត្រឹមត្រូវណាមួយឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានស្ម័គ្រចិត្តបញ្ជូន និងបង់ថ្លៃដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់សេចក្តីថ្លែងការណ៍អាចនៅតែមានលក្ខណៈសម្បត្តិដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

**California Motor Voter**

កម្មវិធី California Motor Voter កំពុងធ្វើឱ្យការចុះឈ្មោះបោះឆ្នោតនៅនាយកដ្ឋានយានយន្ត (DMV) រដ្ឋ California កាន់តែងាយស្រួល និងមានសុវត្ថិភាព។ បុគ្គលដែលមានសិទ្ធិទាំងអស់ដែលបំពេញប្រតិបត្តិការប័ណ្ណបើកបរ អត្តសញ្ញាណប័ណ្ណ ឬការផ្លាស់ប្តូរអាស័យដ្ឋានតាមអ៊ីនធឺណិត តាមប្រៃសណីយ៍ ឬដោយផ្ទាល់នៅ DMV នឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិដើម្បីបោះឆ្នោត លុះត្រាតែពួកគេជ្រើសរើស "មិនចូលរួម" ការចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ។

កម្មវិធី California Motor Voter អនុវត្តចំពោះពលរដ្ឋ California ដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ហើយបំពេញតាមលក្ខណៈវិនិច្ឆ័យខាងក្រោមទាំងអស់:

- ពលរដ្ឋសហរដ្ឋអាមេរិក។
- អ្នករស់នៅរដ្ឋ California។
- បច្ចុប្បន្នមិនជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋ។
- បច្ចុប្បន្នមិនត្រូវបានរកឃើញដោយតុលាការថាអសមត្ថភាពផ្លូវចិត្តក្នុងការបោះឆ្នោត។

ការចុះឈ្មោះបោះឆ្នោតជាមុនអាចរកបានសម្រាប់អ្នកដែលមានអាយុ 16 និង 17 ឆ្នាំ។ ការចុះឈ្មោះបោះឆ្នោតរបស់ពួកគេនឹងក្លាយជាសកម្មដោយស្វ័យប្រវត្តិនៅពេលពួកគេមានអាយុ 18 ឆ្នាំ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ *motorvoter.sos.ca.gov*។

ដើម្បីចុះឈ្មោះបោះឆ្នោតនៅលើអ៊ីនធឺណិតតាមរយៈ *RegisterToVote.ca.gov*។

---

# ព័ត៌មានស្តីពីឯកជនភាពការចុះឈ្មោះអ្នកបោះឆ្នោត

**ការចុះឈ្មោះអ្នកបោះឆ្នោតសម្ងាត់របស់កម្មវិធី Safe at Home:** អ្នកបោះឆ្នោតមួយចំនួនដែលប្រឈមមុខនឹងស្ថានភាពគំរាមកំហែងដល់ជីវិតអាចមានសិទ្ធិទទួលបានស្ថានភាពជាអ្នកបោះឆ្នោតសម្ងាត់ ប្រសិនបើពួកគេជាសមាជិកសកម្មនៃកម្មវិធី Safe at Home។ នេះរាប់បញ្ចូលទាំងជនរងគ្រោះ និងអ្នករស់រានមានជីវិតពីអំពើហិង្សាក្នុងគ្រួសារ ការតាមដាន ការបំពានផ្លូវភេទ ការជួញដូរមនុស្ស ការចាប់ពង្រត់កុមារ និងការធ្វើបាបមនុស្សពេញវ័យ/មនុស្សចាស់ក្នុងបន្ទុក ព្រមទាំងបុគ្គលិក/អ្នកម៉ៅការនៅស្ថាប័នសាធារណៈដែលភ័យខ្លាចចំពោះសុវត្ថិភាពរបស់ពួកគេដោយសារតែការងាររបស់ពួកគេសម្រាប់ស្ថាប័នសាធារណៈ និងអ្នកផ្តល់សេវាថែទាំសុខភាពបន្តពូជ និយោជិត អ្នកស្ម័គ្រចិត្ត និងអ្នកជំងឺដែលភ័យខ្លាចចំពោះសុវត្ថិភាពរបស់ពួកគេ ដោយសារតែការជាប់ទាក់ទងរបស់ពួកគេជាមួយនឹងកន្លែងថែទាំសុខភាពបន្តពូជ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកម្មវិធី Safe at Home របស់រដ្ឋលេខាធិការ ដោយមិនគិតថ្លៃតាមរយៈលេខ (877) 322-5227 ឬចូលទៅកាន់ *sos.ca.gov/safeathome*។

**ឯកជនភាពព័ត៌មានអ្នកបោះឆ្នោត:** ព័ត៌មានស្តីពីលិខិតបញ្ជាក់ការចុះឈ្មោះបោះឆ្នោតរបស់អ្នកនឹងត្រូវបានប្រើដោយមន្ត្រីរៀបចំការបោះឆ្នោត ដើម្បីផ្ញើព័ត៌មានផ្លូវការដល់អ្នកអំពីដំណើរការបោះឆ្នោត ដូចជាទីតាំងនៃកន្លែងបោះឆ្នោតរបស់អ្នក និងវិធានការ និងបេក្ខជនដែលនឹងបង្ហាញនៅលើសន្លឹកឆ្នោត។ ការប្រើប្រាស់ព័ត៌មានការចុះឈ្មោះអ្នកបោះឆ្នោតសម្រាប់ពាណិជ្ជកម្ម គឺត្រូវបានហាមឃាត់ដោយច្បាប់ និងមានទោសកម្រិតមជ្ឈិម។ ព័ត៌មានអ្នកបោះឆ្នោតប្រហែលជាត្រូវបានផ្តល់ទៅបេក្ខជនសម្រាប់មុខតំណែង គណៈកម្មាធិការវិធានការសន្លឹកឆ្នោត ឬជនដទៃទៀតសម្រាប់ការបោះឆ្នោត សម្រាប់គោលបំណងលក្ខណៈសិក្សាស្រាវជ្រាវ សារព័ត៌មាន នយោបាយ ឬរដ្ឋាភិបាល ដូចដែលត្រូវបានសម្រេចដោយរដ្ឋលេខាធិការ។ ប័ណ្ណបើកបរ លេខសន្តិសុខសង្គម ឬ ហត្ថលេខារបស់អ្នក ដូចដែលបានបង្ហាញលើប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក មិនត្រូវអាចបញ្ចេញសម្រាប់គោលបំណងទាំងនេះទេ។ ប្រសិនបើអ្នកមានសំនួរទាក់ទងនឹងការប្រើប្រាស់ព័ត៌មានអ្នកបោះឆ្នោត ឬមានបំណងចង់រាយការណ៍អំពីការប្រើប្រាស់ខុសលើព័ត៌មានទាំងនេះ ដែលគួរអោយសង្ស័យ សូមទូរសព្ទទៅបណ្តាញទាន់ហេតុការណ៍អ្នកបោះឆ្នោតឥតគិតថ្លៃរបស់រដ្ឋលេខាធិការតាមលេខ (888) 345-4917។

# ការដាស់តឿន៖ ការទាក់ទាញយកសំឡេងឆ្នោត ត្រូវបានហាមឃាត់!

ការបំពានអាចនាំឱ្យមានការផាកពិន័យ និង/ឬ ដាក់ពន្ធនាគារ។

## ទីកន្លែង៖

- នៅក្នុងបរិវេណជុំវិញបុគ្គលម្នាក់ដែលឈរតម្រង់ជួរដើម្បីបោះឆ្នោតសន្លឹកឆ្នោតរបស់ពួកគេ ឬក្នុងចម្ងាយ 100 ហ្វីតពីច្រកចូលកន្លែងបោះឆ្នោត ការបោះឆ្នោតនៅចិញ្ចើមផ្លូវ ឬប្រអប់ទម្លាក់សន្លឹកឆ្នោត សកម្មភាពខាងក្រោមត្រូវបានហាមឃាត់។



## សកម្មភាពអ្វីខ្លះត្រូវបានហាមឃាត់៖

- **មិនត្រូវ** ស្នើសុំឱ្យបុគ្គលណាម្នាក់បោះឆ្នោតឱ្យ ឬប្រឆាំងនឹងបេក្ខជនណាមួយ ឬវិធានការសន្លឹកឆ្នោត។
- **មិនត្រូវ** បង្ហាញឈ្មោះ រូបថត ឬនិមិត្តសញ្ញារបស់បេក្ខជន។
- **មិនត្រូវ** បិទផ្លូវចូល ឬឈរត្រែតត្រតនៅក្បែរប្រអប់ទម្លាក់សន្លឹកឆ្នោត។
- **មិនត្រូវ** ផ្តល់ឯកសារ ឬព័ត៌មានដែលអាចស្តាប់បានសម្រាប់ ឬប្រឆាំងនឹងបេក្ខជនណាមួយ ឬវិធានការបោះឆ្នោតនៅជិតកន្លែងបោះឆ្នោត មណ្ឌលបោះឆ្នោត ឬប្រអប់ទម្លាក់សន្លឹកឆ្នោត។
- **មិនត្រូវ** ផ្សព្វផ្សាយញត្តិ រួមទាំងសម្រាប់ការផ្តួចផ្តើមគំនិត ការធ្វើប្រជាមតិ ការរំលឹកឡើងវិញ ឬការតែងតាំងបេក្ខជនណាមួយ។
- **មិនត្រូវ** ចែកចាយ បង្ហាញ ឬស្លៀកសម្លៀកបំពាក់ណាមួយ (មួក អាវ សញ្ញា ប៊ូតុង ស្ទីគ័រ) ដែលរួមបញ្ចូលឈ្មោះបេក្ខជន រូបភាព និមិត្តសញ្ញា និង/ឬគាំទ្រ ឬប្រឆាំងបេក្ខជន ឬវិធានការលើសន្លឹកឆ្នោតណាមួយ។
- **មិនត្រូវ** បង្ហាញព័ត៌មាន ឬនិយាយទៅកាន់អ្នកបោះឆ្នោតអំពីសិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោត។

ការហាមឃាត់ការទាក់ទាញសំឡេងឆ្នោតដែលបានសង្ខេបខាងលើមានចែងនៅក្នុងមាត្រា 7 នៃជំពូកទី 4 នៃផ្នែកទី 18 នៃក្រមបោះឆ្នោតរដ្ឋ California ។

# ការដាស់តឿន៖ ភាពពុករលួយក្នុងដំណើរការបោះឆ្នោត ត្រូវបានហាមឃាត់!

ការបំពានអាចនាំឱ្យមានការផាកពិន័យ និង/ឬដាក់ពន្ធនាគារ។

## សកម្មភាពអ្វីខ្លះត្រូវបានហាមឃាត់៖

- **មិនត្រូវ** ប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តការក្លែងបន្លំការបោះឆ្នោត។
- **មិនត្រូវ** ផ្តល់សំណង ឬការសូកប៉ាន់ ដល់បុគ្គលណាម្នាក់ ក្នុងទម្រង់ណាមួយ ឬដោយមធ្យោបាយណាមួយ ដែលជំរុញ ឬព្យាយាម ជំរុញឱ្យមនុស្សបោះឆ្នោត ឬបដិសេធមិនទៅបោះឆ្នោត។
- **មិនត្រូវ** បោះឆ្នោតដោយខុសច្បាប់។
- **មិនត្រូវ** ព្យាយាមបោះឆ្នោត ឬជួយដល់អ្នកដទៃដើម្បីបោះឆ្នោតនៅពេលដែលមិនមានសិទ្ធិក្នុងការបោះឆ្នោត។
- **មិនត្រូវ** ចូលរួមក្នុងការទាក់ទាញសំឡេងឆ្នោត ថតរូប ឬចុះបញ្ជីអ្នកបោះឆ្នោតដែលចូល ឬចេញពីកន្លែងបោះឆ្នោត ឬរារាំងផ្លូវចូល ច្រកចេញ ឬចំណតចតរថយន្ត។
- **មិនត្រូវ** ជំទាស់សិទ្ធិបោះឆ្នោតរបស់បុគ្គលណាម្នាក់ ឬរារាំងអ្នកបោះឆ្នោតមិនឱ្យបោះឆ្នោត ពន្យារពេលដំណើរការបោះឆ្នោត ឬណែនាំជនណាម្នាក់ក្នុងលក្ខណៈក្លែងបន្លំថាពួកគេមិនមានសិទ្ធិបោះឆ្នោត ឬមិនបានចុះឈ្មោះបោះឆ្នោត។
- **មិនត្រូវ** ព្យាយាមបញ្ជាក់ពីវិធីសាស្រ្តដែលអ្នកបោះឆ្នោតបានបំពេញលើសន្លឹកឆ្នោតរបស់ពួកគេ។
- **មិនត្រូវ** កាន់ ឬរៀបចំឱ្យនរណាម្នាក់កាន់អាវុធនៅជិតបរិវេណកន្លែងបោះឆ្នោតឡើយ ដោយមានករណីលើកលែងមួយចំនួន។
- **មិនត្រូវ** បង្ហាញខ្លួន ឬរៀបចំឱ្យនរណាម្នាក់បង្ហាញខ្លួននៅក្នុងឯកសណ្ឋានមន្ត្រីរក្សាសន្តិភាព អ្នកយាម ឬបុគ្គលិកសន្តិសុខ នៅជិតបរិវេណកន្លែងបោះឆ្នោត ដោយមានករណីលើកលែងមួយចំនួន។
- **មិនត្រូវ** រំខាន ឬជ្រៀតជ្រែកជាមួយផ្នែកណាមួយនៃប្រព័ន្ធបោះឆ្នោត។
- **មិនត្រូវ** បន្លំ ក្លែងបន្លំ ឬរំខានដល់របាយការណ៍សន្លឹកឆ្នោត។
- **មិនត្រូវ** កែប្រែរបាយការណ៍សន្លឹកឆ្នោត។
- **មិនត្រូវ** ប៉ុនប៉ង បំផ្លាញ ឬផ្លាស់ប្តូរបញ្ជីបោះឆ្នោត សន្លឹកឆ្នោតផ្លូវការ ឬធុងសន្លឹកឆ្នោត។
- **មិនត្រូវ** បង្ហាញធុងប្រមូលសន្លឹកឆ្នោតក្រៅផ្លូវការណាមួយដែលអាចបញ្ឆោតអ្នកបោះឆ្នោតឱ្យជឿថាវាជាប្រអប់ប្រមូលសន្លឹកឆ្នោតផ្លូវការ។
- **មិនត្រូវ** លួចបន្លំ ឬជ្រៀតជ្រែកច្បាប់ចម្លងលទ្ធផលនៃការបោះឆ្នោត។
- **មិនត្រូវ** បង្ខិតបង្ខំ ឬបញ្ឆោតបុគ្គលដែលមិនចេះអានអក្សរ ឬមនុស្សចាស់ជរាឱ្យបោះឆ្នោតឱ្យ ឬប្រឆាំងនឹងបេក្ខជន ឬវិធានការផ្ទុយពីចេតនារបស់ពួកគេ។
- **មិនត្រូវ** ដើរតួជាមន្ត្រីបោះឆ្នោតខណៈពេលដែលអ្នកមិនមែនជាបុគ្គលិក។

**និយោជក**មិនអាចទាមទារ ឬសុំឱ្យនិយោជិតរបស់ពួកគេនាំយកសន្លឹកឆ្នោតតាមប្រៃសណីយ៍មកកន្លែងធ្វើការ ឬសុំឱ្យនិយោជិតរបស់ពួកគេបោះឆ្នោតសន្លឹកឆ្នោតរបស់ពួកគេនៅកន្លែងធ្វើការទេ។ នៅពេលបើកប្រាក់បៀវត្សរ៍ ឬប្រាក់ឈ្នួល និយោជកមិនអាចភ្ជាប់មកជាមួយនូវឯកសារដែលមានឥទ្ធិពលលើគំនិតនយោបាយ ឬសកម្មភាពរបស់និយោជិតរបស់ពួកគេឡើយ។

**សមាជិកក្រុមប្រឹក្សាប្រចាំមណ្ឌល** មិនអាចព្យាយាមកំណត់ពីវិធីដែលអ្នកបោះឆ្នោតបានបោះឆ្នោតជ្រើសរើសសន្លឹកឆ្នោតរបស់ពួកគេ ឬប្រសិនបើព័ត៌មាននោះត្រូវបានរកឃើញ មិនអាចបង្ហាញពីវិធីដែលអ្នកបោះឆ្នោតបានបោះឆ្នោតសន្លឹកឆ្នោតរបស់ពួកគេឡើយ។

ការហាមឃាត់លើសកម្មភាពដែលពាក់ព័ន្ធនឹងអំពើពុករលួយនៃដំណើរការបោះឆ្នោតដូចដែលបានសង្ខេបខាងលើមានចែងនៅក្នុងជំពូកទី 6 នៃផ្នែកទី 18 នៃក្រមច្បាប់ការបោះឆ្នោតរដ្ឋ California។

# លក្ខខណ្ឌតម្រូវនៃអត្តសញ្ញាណអ្នកបោះឆ្នោត និងការចុះឈ្មោះនៅរដ្ឋ California

### ☑ តើអ្នកណាអាចចុះឈ្មោះបោះឆ្នោតនៅរដ្ឋ California?

**ដើម្បីចុះឈ្មោះបោះឆ្នោត អ្នកត្រូវតែ៖**

- ជាពលរដ្ឋអាមេរិក និងជាអ្នករស់នៅរដ្ឋ California
- 18 ឆ្នាំឡើងទៅនៅថ្ងៃបោះឆ្នោត (ឬ 16 ឬ 17 ឆ្នាំ ដើម្បីចុះឈ្មោះជាមុន)
- បច្ចុប្បន្នមិនជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់បទឧក្រិដ្ឋ
- បច្ចុប្បន្នមិនត្រូវបានតុលាការរកឃើញថាអសមត្ថភាពខាងផ្លូវចិត្តក្នុងការបោះឆ្នោត

### ☑ តើខ្ញុំត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណឬទេដើម្បីបោះឆ្នោត?

ក្នុងករណីភាគច្រើន អត់ទេ។ រដ្ឋ California ជាទូទៅមិនតម្រូវឱ្យអ្នកបោះឆ្នោតបង្ហាញអត្តសញ្ញាណប័ណ្ណនៅពេលបោះឆ្នោតនោះទេ។

### ☑ តើនៅពេលណាដែលអ្នកអាចត្រូវបានស្នើសុំមើលអត្តសញ្ញាណប័ណ្ណ?

អ្នកប្រហែលជាត្រូវការបង្ហាញអត្តសញ្ញាណប័ណ្ណ លុះត្រាតែលក្ខខណ្ឌ ទាំងអស់ ខាងក្រោមអនុវត្ត៖

- អ្នកកំពុងបោះឆ្នោតជាលើកដំបូងនៅក្នុងការបោះឆ្នោតសហព័ន្ធ
- អ្នកបានចុះឈ្មោះតាមប្រៃសណីយ៍ ឬតាមអ៊ីនធឺណិតហើយ
- អ្នកមិនបានផ្តល់អត្តសញ្ញាណប័ណ្ណ CA ឬ SSN របស់អ្នកនៅពេលចុះឈ្មោះ

អ្នកនឹងត្រូវបានជូនដំណឹងជាមុន ប្រសិនបើករណីនេះអនុវត្តចំពោះអ្នក។

**បុគ្គលិកបោះឆ្នោតអាចស្នើសុំអត្តសញ្ញាណប័ណ្ណបាន ប្រសិនបើបញ្ជីឈ្មោះអ្នកបោះឆ្នោតបង្ហាញយ៉ាងច្បាស់ថា វាត្រូវបានទាមទារ។**

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ *vote.ca.gov* ឬទូរស័ព្ទទៅលេខទាន់ហេតុការណ៍អ្នកបោះឆ្នោតរបស់យើងតាមរយៈ: (888) 345-4917។**

### ☑ តើទម្រង់អត្តសញ្ញាណបែបណាដែលអាចទទួលយកបាន (ប្រសិនបើត្រូវបានតម្រូវ)?

**អ្នកអាចបង្ហាញអត្តសញ្ញាណប័ណ្ណដែលមានរូបថត ឬគ្មានរូបថត ដែលរួមមាន៖**

- ប័ណ្ណបើកបររដ្ឋ California ឬអត្តសញ្ញាណប័ណ្ណរដ្ឋ
- លិខិតឆ្លងដែនអាមេរិក
- អត្តសញ្ញាណប័ណ្ណសិស្ស ឬយោធា
- សំបុត្រផ្លូវការពីទីភ្នាក់ងាររដ្ឋាភិបាល
- សែកប្រាក់ឈ្នួល ឬសែកប្រាក់ពីរដ្ឋាភិបាល
- វិក្កយបត្រទឹកភ្លើង ឬរបាយការណ៍ធនាគារ

សម្រាប់បញ្ជីពេញលេញ សូមមើល៖ *www.sos.ca.gov/elections/hava-id-standards*

អត្តសញ្ញាណប័ណ្ណដោយមានរូបថតមិនចាំបាច់ទេ វាគ្រាន់តែជាជម្រើសមួយក្នុងចំណោមជម្រើសជាច្រើនដែលមានសុពលភាព។ អត្តសញ្ញាណប័ណ្ណមិនចាំបាច់បង្ហាញអាសយដ្ឋានរបស់អ្នក ឬត្រូវបានចេញដោយរដ្ឋាភិបាលនោះទេ។

### ☑ អត់មានអត្តសញ្ញាណប័ណ្ណពេលបោះឆ្នោតមែនទេ?

អ្នកនៅតែអាចបោះឆ្នោតបណ្តោះអាសន្នបាន។ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរាប់ក្រោយពីមន្ត្រីបោះឆ្នោតបានបញ្ជាក់ ថាអ្នកបានចុះឈ្មោះដើម្បីបោះឆ្នោតនៅក្នុងខោនធីនោះ ហើយអ្នកមិនបានបោះឆ្នោតក្នុងការបោះឆ្នោតនោះនៅឡើយ។

### ☑ ពិនិត្យមើលស្ថានភាពអ្នកបោះឆ្នោតរបស់អ្នកតាមអនឡាញ

ចូលមើលទំព័រស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំ (My Voter Status) របស់រដ្ឋលេខាធិការនៅលើគេហទំព័រ *voterstatus.sos.ca.gov* ដើម្បីពិនិត្យស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក ស្វែងរកកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតរបស់អ្នក និងមានច្រើនទៀត។

ដើម្បីពិនិត្យមើលស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក អ្នកត្រូវបញ្ចូលនាមខ្លួន នាមត្រកូល ថ្ងៃខែឆ្នាំកំណើត និងលេខប័ណ្ណបើកបររដ្ឋ California ឬលេខអត្តសញ្ញាណប័ណ្ណរដ្ឋ California របស់អ្នកឬលេខបួនខ្ទង់ចុងក្រោយនៃលេខសន្តិសុខសង្គមរបស់អ្នក។

សូមចូលទៅកាន់ *voterstatus.sos.ca.gov* សម្រាប់ព័ត៌មានលម្អិតអំពីអ្នកបោះឆ្នោតសំខាន់ៗ។

# សំនួរដែលគេសួរញឹកញាប់ទាក់ទងនឹងប្រព័ន្ធ ការបោះឆ្នោតតាមប្រៃសណីយ៍ដែលអាចចូលប្រើបានពីចម្ងាយ

ប្រព័ន្ធបោះឆ្នោតតាមសំបុត្រ (RAVBM) ដែលអាចចូលប្រើបានពីចម្ងាយ គឺជាឧបករណ៍អនឡាញដែលអាចឱ្យអ្នកបោះឆ្នោតទាំងអស់ រួមទាំងជនពិការអាចចូលប្រើ អាន និងកំណត់ការជ្រើសរើសលើសន្លឹកឆ្នោតរបស់ពួកគេដោយប្រើឧបករណ៍ណាមួយក៏បាន។ ជាលទ្ធផល អ្នកបោះឆ្នោតដែលមានពិការភាពត្រូវបានផ្តល់ឱកាសដើម្បីអាន និងកំណត់ការជ្រើសរើសលើសន្លឹកឆ្នោតរបស់ពួកគេជាលក្ខណៈឯកជន និងដោយឯករាជ្យដោយប្រើបច្ចេកវិទ្យាជំនួយផ្ទាល់ខ្លួនរបស់ពួកគេ។

វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា RAVBM មិនមែនជាទម្រង់នៃការបោះឆ្នោតតាមអ៊ីនធឺណិតទេ។

ទោះបីជាការជ្រើសរើសលើសន្លឹកឆ្នោតអាចត្រូវបានកំណត់តាមអ៊ីនធឺណិតដោយប្រើប្រព័ន្ធ RAVBM ក៏ដោយ អ្នកបោះឆ្នោតត្រូវតែបោះពុម្ព និងបញ្ជូនការជ្រើសរើសលើសន្លឹកឆ្នោតរបស់ពួកគេទៅឱ្យមន្ត្រីបោះឆ្នោតខោនធីរបស់ពួកគេ។

## តើ RAVBM ដំណើរការយ៉ាងដូចម្ដេច?

អ្នកបោះឆ្នោតអាចចូលទៅបោះឆ្នោត និងកំណត់ការជ្រើសរើសលើ សន្លឹកឆ្នោតរបស់ពួកគេដោយប្រើកុំព្យូទ័រណាមួយដែលមានអ៊ីនធឺណិត។ ប្រព័ន្ធនេះអាចប្រើបានជាមួយឧបករណ៍អានលើអេក្រង់ ។ អ្នកបោះឆ្នោតត្រូវបោះពុម្ពសន្លឹកឆ្នោតដែលបានគូសចម្លើយរួច ហើយប្រគល់វាវិញនៅត្រឹមការបិទការបោះឆ្នោតនៅម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត។ ការជ្រើសរើសលើសន្លឹកឆ្នោត RAVBM មិនអាចត្រូវបានផ្ញើតាមអ៊ីម៉ែលបានទេ។ មានតែអ្នកបោះឆ្នោតមួយចំនួនដែលជាពលរដ្ឋឯកសណ្ឋាន និងនៅក្រៅប្រទេសដែលបោះឆ្នោតដោយអវត្តមាន (UOCAVA) ប៉ុណ្ណោះដែលអាចបញ្ជូនវាតាមទូរសារ (fax)។

ដើម្បីធានាបាននូវភាពឯកជននៃការជ្រើសរើសរបស់អ្នកបោះឆ្នោតនីមួយៗ ប្រព័ន្ធ RAVBM មិនរក្សាទុកជម្រើសរបស់អ្នកបោះឆ្នោត ឬបញ្ជូនពួកគេតាមអ៊ីនធឺណិតទេ។ ខោនធីនីមួយៗគ្រប់គ្រង RAVBM ដោយមានភាពខុសគ្នាបន្តិចបន្តួច។ ទោះជាយ៉ាងណាក៏ដោយ ជំហានទាំងប្រាំខាងក្រោមជាធម្មតាពិពណ៌នាអំពីរបៀបដែល RAVBM ដំណើរការនៅទូទាំងរដ្ឋ California៖

## តើខ្ញុំអាចបោះឆ្នោតដោយប្រើប្រព័ន្ធ RAVBM យ៉ាងដូចម្ដេច?

1. **ស្វែងរក ឬស្នើសុំតំណគេហទំព័រចូលប្រើ RAVBM ពីខោនធីរបស់អ្នក។** សូមទាក់ទងការិយាល័យបោះឆ្នោតនៃខោនធីរបស់អ្នកតាមទូរស័ព្ទ អ៊ីមែល ឬតាមរយៈគេហទំព័របោះឆ្នោតខោនធីរបស់អ្នក ដើម្បីស្នើសុំតំណចូលប្រើ RAVBM។

2. **ធ្វើតាមតំណដើម្បីចូលមើលការណែនាំ និងគូសលើការជ្រើសរើសសន្លឹកឆ្នោតរបស់អ្នក។** តំណចូលប្រើគួរតែនាំអ្នកទៅកាន់ទំព័របញ្ជាក់។ បន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នក អ្នកអាចពិនិត្យមើលការណែនាំ RAVBM របស់អ្នក។ បន្ទាប់មកអ្នកនឹងបន្តទៅកំណត់ការជ្រើសរើសលើសន្លឹកឆ្នោតរបស់អ្នកនៅលើឧបករណ៍ផ្ទាល់ខ្លួនរបស់អ្នក ដោយប្រើបច្ចេកវិទ្យាជំនួយផ្ទាល់ខ្លួនរបស់អ្នកតាមការចាំបាច់។ Disability Rights California បានបោះពុម្ពផ្សាយវីដេអូបង្ហាញពីប្រព័ន្ធ RAVBM។

3. **ពិនិត្យ និងបោះពុម្ពការជ្រើសរើសលើសន្លឹកឆ្នោត RAVBM របស់អ្នក។** ពិនិត្យមើលការជ្រើសរើសលើសន្លឹកឆ្នោតរបស់អ្នក និងធ្វើការកែតម្រូវតាមការចាំបាច់។ ក្រោយពេលបញ្ចប់ សូមធ្វើតាមការណែនាំសម្រាប់ការបោះពុម្ពការជ្រើសរើសលើសន្លឹកឆ្នោតរបស់អ្នក។

4. **ដាក់សន្លឹកឆ្នោត RAVBM ដែលបានគូសចម្លើយរួចរបស់អ្នកនៅក្នុងស្រោមសំបុត្រមួយ។** ចុះហត្ថលេខា និងបិទស្រោមសំបុត្រ។ ប្រសិនបើអ្នកបានទទួលសន្លឹកឆ្នោតតាមប្រៃសណីយ៍ វានឹងរួមបញ្ចូលស្រោមសំបុត្រផ្ញើត្រឡប់សន្លឹកឆ្នោតជាផ្លូវការ។ ប្រើស្រោមសំបុត្រនេះដើម្បីផ្ញើត្រឡប់មកវិញនូវសន្លឹកឆ្នោត RAVBM បំពេញរួចដែលបានបោះពុម្ពរបស់អ្នក។ ចងចាំថាត្រូវចុះហត្ថលេខានៅខាងក្រោយស្រោមសំបុត្រ បិទស្រោមសំបុត្រ និងចុះហត្ថលេខានៅចន្លោះរវាងរន្ធដែលបានចោះពីរ។

   **ចំណាំ៖** ប្រសិនបើអ្នកមិនមានស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតមកវិញជាផ្លូវការទេ សូមទាក់ទងការិយាល័យបោះឆ្នោតខោនធីរបស់អ្នកដើម្បីស្នើសុំជំនួស។ ប្រសិនបើមិនមានពេលគ្រប់គ្រាន់មុនថ្ងៃបោះឆ្នោត ដើម្បីទទួលស្រោមសំបុត្រជំនួសទេ សូមមើលការណែនាំអំពីការប្រគល់មកវិញទាក់ទងនឹងការប្រើប្រាស់ស្រោមសំបុត្រស្តង់ដារដែលមិនមែនផ្លូវការ។ អ្នកប្រហែលជាត្រូវបោះពុម្ពផ្នែកមួយនៃស្រោមសំបុត្រ ឬ "សេចក្តីប្រកាស" ពីឯកសារដែលត្រូវបានផ្តល់ឱ្យនៅពេលអ្នកចូលប្រើប្រព័ន្ធ RAVBM។

5. **ប្រគល់សន្លឹកឆ្នោត RAVBM របស់អ្នកមកវិញនៅក្នុងស្រោមសំបុត្រដែលបានចុះហត្ថលេខា និងបិទជិត។** ផ្ញើសន្លឹកឆ្នោត RAVBM របស់អ្នកមកវិញតាមប្រៃសណីយ៍ ឬនៅប្រអប់ទម្លាក់សន្លឹកឆ្នោតណាមួយនៅក្នុងខោនធីរបស់អ្នក កន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធីរបស់អ្នក ឬការិយាល័យបោះឆ្នោតនៃខោនធីរបស់អ្នក។ ប្រសិនបើនរណាម្នាក់ផ្សេងទៀតកំពុងបញ្ជូនសន្លឹកឆ្នោតរបស់អ្នកជំនួសអ្នក សូមប្រាកដថាឈ្មោះ ទំនាក់ទំនង (ត្រូវជាអ្វីនឹងអ្នក) និងហត្ថលេខារបស់ពួកគេត្រូវបានរួមបញ្ចូលនៅលើស្រោមសំបុត្រ។ សម្រាប់ការណែនាំបន្ថែមអំពីរបៀបប្រគល់សន្លឹកឆ្នោត RAVBM របស់អ្នកមកវិញ សូមពិនិត្យមើលការណែនាំការផ្ញើ ឬទូរសព្ទទៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក។

# ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានភាពពិការ

រដ្ឋ California ប្តេជ្ញាចិត្តដើម្បីធានាថា អ្នកបោះឆ្នោតគ្រប់រូបអាចបោះឆ្នោតបាន ប្រកបដោយឯកជនភាពនិងឯករាជ្យភាព។

សម្រាប់ព័ត៌មានលម្អិតអំពីជំនួយអ្វីខ្លះដែលខោនធីរបស់អ្នកផ្តល់ជូនដល់អ្នកបោះឆ្នោតមានពិការភាព សូមពិនិត្យមគ្គុទេសក៍ព័ត៌មានអ្នកបោះឆ្នោតខោនធីរបស់អ្នក ឬទាក់ទងមន្ត្រីបោះឆ្នោតខោនធីរបស់អ្នក។ ព័ត៌មានទំនាក់ទំនងខោនធីអាចរកបាននៅ *sos.ca.gov/elections/voting-resources/county-elections-offices*។

## ការបោះឆ្នោតនៅកន្លែងបោះឆ្នោត ឬមជ្ឈមណ្ឌលបោះឆ្នោត

ប្រសិនបើអ្នកត្រូវការជំនួយគូសសន្លឹកឆ្នោតរបស់អ្នក អ្នកអាចជ្រើសរើសមនុស្សបានរហូតដល់ពីរនាក់ដើម្បីជួយអ្នក។ បុគ្គលនេះមិនអាចជា៖

- និយោជករបស់អ្នក ឬនរណាម្នាក់ ដែលធ្វើការឱ្យនិយោជករបស់អ្នកឡើយ
- មេដឹកនាំសហជីពកម្មកររបស់អ្នក ឬនរណាម្នាក់ ដែលធ្វើការឱ្យសហជីពការងាររបស់អ្នក

*ការបោះឆ្នោតក្បែរចិញ្ចើមផ្លូវ* អនុញ្ញាតឱ្យអ្នកចតនៅជិតកន្លែងបោះឆ្នោតតាមដែលអាចធ្វើទៅបាន។ មន្ត្រីបោះឆ្នោតនឹងយកបញ្ជីឈ្មោះឲ្យអ្នកចុះហត្ថលេខា សន្លឹកឆ្នោតមួយ និងសម្ភារៈបោះឆ្នោតឯទៀត ដែលអ្នកត្រូវការ មិនថាអ្នកនៅក្បែរចិញ្ចើមផ្លូវ ឬ នៅក្នុងឡាន។

គ្រប់កន្លែងបោះឆ្នោត និងមណ្ឌលបោះឆ្នោតទាំងអស់ តម្រូវឲ្យមានការបង្កលក្ខណៈងាយស្រួលសម្រាប់ ជនពិការអាចចូលទៅបោះឆ្នោតបាន ហើយនឹងមានម៉ាស៊ីនបោះឆ្នោតដែលអាចចូលប្រើបាន។

## ការបោះឆ្នោតនៅផ្ទះ

ប្រព័ន្ធបោះឆ្នោតតាមសំបុត្រពីចម្ងាយ (RAVBM) ផ្តល់នូវជម្រើសអាចធ្វើបានសម្រាប់អ្នកបោះឆ្នោតជាជនពិការ ដើម្បីទទួលសន្លឹកឆ្នោតរបស់ខ្លួននៅឯលំនៅឋាន ហើយគូសវាដោយឯករាជ្យ និង ដោយឯកជន មុននឹងផ្ញើវាទៅមន្ត្រីផ្នែកបោះឆ្នោត។ សូមទាក់ទងមន្ត្រីរៀបចំការបោះឆ្នោតខោនធីរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

## មគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតជាសំឡេង និងអក្សរធំៗ

មគ្គុទ្ទេសក៍នេះមានជាសំឡេង និងបោះពុម្ពជាអក្សរធំៗ ដែលផ្តល់ជូនជាភាសាអង់គ្លេស ចិន ហិណ្ឌូ ជប៉ុន ខ្មែរ កូរ៉េ អេស្ប៉ាញ តាកាឡុក ថៃ និងវៀតណាមដោយមិនគិតថ្លៃ ។

ដើម្បីស្នើសុំ៖

សូមចូលទៅកាន់គេហទំព័រ *vote.ca.gov*

សូមទូរស័ព្ទទៅបណ្តាញទាន់ហេតុការណ៍ឥតគិតថ្លៃសម្រាប់អ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការតាមរយៈ (888) 345-4917

ទាញយកទម្រង់ជាសំឡេង MP3 នៅគេហទំព័រ *https://voterguide.sos.ca.gov/km/audio*

# កាលបរិច្ឆេទដែលត្រូវចងចាំ!

★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★ ★



## កុំបង្អង់យូរ សូមបោះឆ្នោតថ្ងៃនេះ!

**សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកមកវិញភ្លាមៗនៅពេលដែលអ្នកទទួលបានវា។**
**រយៈពេលបោះឆ្នោតបានមុនដោយបោះឆ្នោតតាមសំបុត្រនឹងបើកនៅថ្ងៃទី 4 ខែឧសភា ឆ្នាំ 2026។**
**ការិយាល័យបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹកដល់ម៉ោង 8:00 យប់នៅថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026 ដែលជាថ្ងៃបោះឆ្នោត!**

### ខែឧសភា

| អា | ច | អ | ពុ | ព្រ | សុ | សៅ |
|---|---|---|---|---|---|---|
| | | | | | 1 | 2 |
| 3 | 4 | 5 | 6 | 7 | 8 | 9 |
| 10 | 11 | 12 | 13 | 14 | 15 | 16 |
| 17 | 18 | 19 | 20 | 21 | 22 | 23 |
| 24 | 25 | 26 | 27 | 28 | 29 | 30 |
| 31 | | | | | | |

**ថ្ងៃទី 4 ខែឧសភា**
មន្ត្រីបោះឆ្នោតខោនធីនឹងចាប់ផ្តើមផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រនៅចំ ឬមុនកាលបរិច្ឆេទនេះ។

**ថ្ងៃទី 4 ខែឧសភា ដល់ ថ្ងៃទី 2 ខែមិថុនា**
រយៈពេលបោះឆ្នោតដើម្បីបញ្ជូនសន្លឹកឆ្នោតមកវិញ។

**ថ្ងៃទី 5 ខែឧសភា**
ប្រអប់ទម្លាក់សន្លឹកឆ្នោតដែលមានសុវត្ថិភាពត្រូវបានបើក។

**ថ្ងៃទី 18 ខែឧសភា**
ថ្ងៃចុងក្រោយដើម្បីចុះឈ្មោះបោះឆ្នោត។ ការចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយមាននៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬទីតាំងបោះឆ្នោតបន្ទាប់ពីថ្ងៃផុតកំណត់នៃការចុះឈ្មោះបោះឆ្នោត រហូតដល់ និងរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោត។

**ថ្ងៃទី 23 ខែឧសភា**
មណ្ឌលបោះឆ្នោតថ្ងៃដំបូងបើកនៅក្នុងខោនធីដែលមានច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតដោយផ្ទាល់បានមុន។

**ថ្ងៃទី 30 ខែឧសភា**
ទីតាំងបោះឆ្នោតជាមុននៅទូទាំងរដ្ឋ California នឹងបើកនៅថ្ងៃសៅរ៍ ទី 30 ខែឧសភា។ សូមចូលទៅកាន់ *caearlyvoting.sos.ca.gov* ដើម្បីស្វែងរកទីតាំងនិងម៉ោងបោះឆ្នោត។

### ខែមិថុនា

| អា | ច | អ | ពុ | ព្រ | សុ | សៅរ៍ |
|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 |
| 7 | 8 | 9 | 10 | 11 | 12 | 13 |
| 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 |
| 28 | 29 | 30 | | | | |

**ថ្ងៃអង្គារ ទី 2 ខែមិថុនា ឆ្នាំ 2026**
ថ្ងៃចុងក្រោយដើម្បីបោះឆ្នោតដោយផ្ទាល់ ឬបញ្ជូនសន្លឹកឆ្នោតមកវិញត្រឹមម៉ោង 8:00 យប់

កន្លែងបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹកដល់ម៉ោង 8:00 យប់

សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកមកវិញភ្លាមៗនៅពេលដែលអ្នកទទួលបានវា។ សន្លឹកឆ្នោតបោះឆ្នោតតាមសំបុត្រត្រូវតែបានបោះត្រាដោយប្រៃសណីយ៍មិនឱ្យលើសពីថ្ងៃទី 2 ខែមិថុនា។

**ថ្ងៃទី 9 ខែមិថុនា**
ថ្ងៃចុងក្រោយដែលខោនធីអាចទទួលយកសន្លឹកឆ្នោតបោះឆ្នោតតាមសំបុត្រដែលបានបោះត្រាដោយប្រៃសណីយ៍ត្រឹមថ្ងៃបោះឆ្នោត។

**ថ្ងៃទី 24 ខែមិថុនា**
ថ្ងៃចុងក្រោយដើម្បីកែបញ្ហាហត្ថលេខាលើសន្លឹកឆ្នោតត្រឹមម៉ោង 5:00 ល្ងាច

**California Secretary of State**
**Elections Division**
1500 11th Street
Sacramento, CA 95814

NONPROFIT
U.S. POSTAGE
PAID
CALIFORNIA
SECRETARY
OF STATE

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service ®

ថ្ងៃទី 2 ខែមិថុនា ឆ្នាំ 2026

# ការបោះឆ្នោតបឋម

## កាលបរិច្ឆេទដែលត្រូវចងចាំ

**ថ្ងៃទី 4 ខែឧសភា**
មន្ត្រីបោះឆ្នោតខោនធីនឹងចាប់ផ្តើមផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រនៅចំ ឬមុនកាលបរិច្ឆេទនេះ។ សូមប្រគល់សន្លឹកឆ្នោតរបស់អ្នកមកវិញភ្លាមៗនៅពេលដែលអ្នកទទួលបានវា។

**ថ្ងៃទី 4 ខែឧសភា - ថ្ងៃទី 2 ខែមិថុនា**
រយៈពេលបោះឆ្នោតជាមុនដោយបោះឆ្នោតតាមសំបុត្រ។

**ថ្ងៃទី 5 ខែឧសភា**
ប្រអប់ទម្លាក់សន្លឹកឆ្នោតដែលមានសុវត្ថិភាពត្រូវបានបើក។

**ថ្ងៃទី 18 ខែឧសភា**
ថ្ងៃចុងក្រោយដើម្បីចុះឈ្មោះបោះឆ្នោត។ ការចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយមាននៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬទីតាំងបោះឆ្នោតបន្ទាប់ពីថ្ងៃផុតកំណត់នៃការចុះឈ្មោះបោះឆ្នោត រហូតដល់ និងរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោត។

**ថ្ងៃទី 23 ខែឧសភា**
មណ្ឌលបោះឆ្នោតថ្ងៃដំបូងបើកនៅក្នុងខោនធីដែលមានច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតដោយផ្ទាល់ជាមុន។

**ថ្ងៃទី 30 ខែឧសភា**
ទីតាំងបោះឆ្នោតជាមុននៅទូទាំងរដ្ឋ California នឹងបើកនៅថ្ងៃសៅរ៍ ទី 30 ខែឧសភា។ សូមចូលទៅកាន់ *caearlyvoting.sos.ca.gov* ដើម្បីស្វែងរកទីតាំង និងម៉ោងបោះឆ្នោត។

**ថ្ងៃអង្គារ ទី 2 ខែមិថុនា ឆ្នាំ 2026**
ថ្ងៃចុងក្រោយដើម្បីបោះឆ្នោតដោយផ្ទាល់ ឬបញ្ជូនសន្លឹកឆ្នោតមកវិញត្រឹមម៉ោង 8:00 យប់ ការិយាល័យបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 យប់។ សន្លឹកឆ្នោតបោះឆ្នោតតាមសំបុត្រត្រូវតែបានសម្គាល់ថាបានបោះត្រាដោយប្រៃសណីយ៍មិនឱ្យលើសពីថ្ងៃទី 2 ខែមិថុនា។

## សម្រាប់ច្បាប់ចម្លងបន្ថែមនៃមគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតជាភាសាណាមួយខាងក្រោម សូមទូរស័ព្ទទៅ៖

**English:** (800) 345-VOTE (8683)

**Español/Spanish:** (800) 232-VOTA (8682)

**中文/Chinese:** (800) 339-2857

**हिन्दी/Hindi:** (888) 345-2692

**日本語/Japanese:** (800) 339-2865

**ខ្មែរ/Khmer:** (888) 345-4917

**한국어/Korean:** (866) 575-1558

**Tagalog:** (800) 339-2957

**ภาษาไทย/Thai:** (855) 345-3933

**Việt ngữ/Vietnamese:** (800) 339-8163

**TTY/TDD:** 711

**ងាយស្រួល ប្រើលើ ទូរស័ព្ទ ស្មែនខ្ញុំ**

**តើអ្នកត្រូវបានចុះឈ្មោះបោះឆ្នោតដែរឬទេ? មើលនៅទីនេះ៖ *voterstatus.sos.ca.gov***

ក្នុងកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយថ្លៃចំណាយការបោះឆ្នោត អង្គនីតិបញ្ញត្តិរដ្ឋបានផ្តល់សិទ្ធិដល់រដ្ឋ និងបណ្តាខោនធីដើម្បីធ្វើតាមសំបុត្រនូវឯកសារមគ្គុទ្ទេសក៍តែមួយច្បាប់ប៉ុណ្ណោះទៅដល់គ្រួសារបោះឆ្នោតនីមួយៗ។ អ្នកអាចស្នើសុំច្បាប់ចម្លងបន្ថែមដោយទាក់ទងមន្ត្រីបោះឆ្នោតខោនធីរបស់អ្នក ឬដោយទូរស័ព្ទទៅលេខ (888) 345-4917។

OSP 26 161309 UNION LABEL